# THÉÂTRE DU SOLEIL

# ប្រវត្តិគួរឲ្យស្រើប តែពុំទាន់ចប់
# នៃនរោត្តមសីហនុ
# ព្រះមហាក្សត្រនៃកម្ពុជា

**© Théâtre du Soleil**
**ISBN: 2.9050012.02.1**

**THÉÂTRE DU SOLEIL***

# ប្រវត្តិគួរឲ្យស្ញើប តែពុំទាន់ចប់
# នៃនរោត្តមសីហនុ
# ព្រះមហាក្សត្រនៃកម្ពុជា

ដោយ

Hélène Cixous

ផ្សព្វផ្សាយជាថ្មីដោយបង្រួញសង្ខេបពីច្បាប់ដែលចេញផ្សាយឆ្នាំ១៩៨៥ និង ១៩៨៧

ប្រែសម្រួលដោយ

អាំង ជូលាន

* ក្រុម Théâtre du Soleil សូមឧទ្ទិសសៀវភៅនេះទៅវិញ្ញាណក្ខន្ធមិត្ត Benoît Barthélémy

# បុព្វបទ

ល្ខោននេះបង្ហាញពីការចាក់ស្រេះដំពាក់ដំពិន ក្នុងទំនាក់ទំនងរវាងមនុស្សនិងមនុស្ស, រវាងប្រទេសនិងប្រទេស, រវាងមហាអំណាចនិងប្រទេសតូចមួយ “មិនចូលបក្សពួក” ដែលវិវឌ្ឍន៍រហូតដល់ការប្រល័យពូជមនុស្សជាតិ។ ស្នាដៃអក្សរសាស្ត្រដ៏ខ្ពង់ខ្ពស់នេះ យកឧទាហរណ៍ប្រទេសតូចស្ថិតនៅក្នុងស្ថានភាពប្រវត្តិសាស្ត្រនិងនយោបាយពិសេសមួយ មកពិនិត្យផ្គុំផ្គួនឹងវាសនាជូរចត់របស់មនុស្ស។ ប្រទេសជាឧទាហរណ៍នៃចាកលោកនោះគឺកម្ពុជា រីឯវាសនារសាត់អណ្តែតនៃមនុស្សគឺបង្ហាញតាមរយៈក្សត្រមួយអង្គដែលគេទ្បាមពាត់មិនឲ្យស្ងប់ព្រះទ័យ ហើយដែលខំរើបម្រះ ស្រែកកោកកាកមិនព្រមចុះចាញ់។

រឿងនេះ អ្នកស្រី Hélène Cixous សរសេររៀបចំឡើងនៅដើមទសវត្ស ១៩៨០ សម្រាប់ក្រុមល្ខោនដ៏មានឈ្មោះល្បីហៅថា Théâtre du Soleil ដែលដឹកនាំដោយអ្នកស្រី Ariane Mnouchkine។ បើគិតពីពេលករកើតនៅឆ្នាំ១៩៦៤មកនោះ Théâtre du Soleil សម្តែងរឿងនានា រាប់តាំងពីរឿងចាស់ៗល្បីនៅអឺរ៉ុប រហូតដល់រឿងជាស្នាដៃរួមគ្នាដែលគាត់តែងឡើងនៅសម័យថ្មីនេះ តែដែលទាំងអស់នោះសុទ្ធសឹងជា “ប្រវត្តិសាស្ត្រជំនាន់យើង” ដូចគ្នា។ ឥទ្ធិពលពីសិល្បៈនិងប្រពៃណីល្ខោននៃអាស៊ីមានច្រើន ចំណែកឯក្រុមអ្នកសម្តែងក៏ចេញមកពីជាតិសាសន៍ផ្សេងៗគ្នា ដែលសឲ្យឃើញពីចក្ខុវិស័យចម្រុះជាតិគ្នា ស្របទៅតាមបំណងនៃក្រុមល្ខោននេះ។

អ្នកស្រី Cixous ធំដឹងក្តីនៅប្រទេសអាល់ហ្សេរី ដែលកាលនោះជាអាណានិគមន៍បារាំង។ ដោយសារពូជគាត់ជា Juif គេដកសញ្ជាតិបារាំងរបស់គាត់ចេញ កាលពីសង្គ្រាមលោកលើកទីពីរ។ ដូច្នេះគ្មានអ្វីប្លែកទេ ដែលក្រោយមក ពេលមករស់នៅប្រទេសបារាំងដើម្បីបន្តការសិក្សានោះ អ្នកស្រីតែងធ្វើការរិះគន់យ៉ាងខ្លាំងលើគំនិតក្នុងទស្សនវិជ្ជាក្តី ក្នុងនយោបាយក្តី ដែលគេមានទម្លាប់ធ្វើនិងផ្សព្វផ្សាយនៅអឺរ៉ុប។ គេស្គាល់ជាទូទៅក្នុងប្រទេសនានា ថាអ្នកស្រី Cixous ជាអ្នកនិពន្ធស្នាដៃអក្សរសាស្ត្រយ៉ាងច្រើនដែលតែងតែថ្កើះថ្កៀល, រំលឹក, វែកញែក និងបញ្ចោញទ្រឹស្តីអំពីស្ត្រី។ សំណេរស្រាវជ្រាវទាំងអម្បាលមាណរបស់គាត់សុទ្ធសឹងជាស្នាដៃអក្សរសាស្ត្រនិងទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់។ ប្រវត្តិគួរឲ្យស្ញើប តែមិនទាន់ចប់ ប្រៀបដូចជាស្ពានមួយភ្ជាប់ជម្រៅរឿងល្ខោនលោក Shakespeare មករៀបនិទានមួយបែបផ្សេងថ្មី អំពីមូលហេតុនៃបញ្ហានានាលើលោក ដែលចាក់ស្រេះប្រទាក់ក្រឡាគ្នា លំបាកនឹងរកចុងរកដើម។ ដើម្បីសរសេរ ប្រវត្តិគួរឲ្យស្ញើបនេះ អ្នកស្រី Cixous ធ្វើការស្រាវជ្រាវវែងឆ្ងាយណាស់អំពីប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងបរិបទអន្តរជាតិដែលគ្របដណ្តប់លើនយោបាយប្រទេសនិងតំបន់។ នេះជា

ស្នាដៃមួយដ៏កម្រក្នុងការលាតត្រដាងឡើងវិញនូវហេតុផល ដែលចេញមកពីនាយ ឬធ្លាក់ពីលើមកសង្គ្រប់សម្រេចវាសនាឲ្យស្ថានការណ៍នានាក្នុងលោក កាលពីមុននេះបន្តិច។

ការពុះពារដើម្បីនាំរឿងល្ខោន ដែលដើមឡើយរៀបរៀងនិងសម្ដែងសម្រាប់មជ្ឈដ្ឋានអឺរ៉ុបឲ្យ “ត្រឡប់មក” ប្រទេសកម្ពុជាវិញ, ការខិតខំឲ្យក្រុមល្ខោនខ្មែរ ហ្សា–ពន្លឺសិល្បៈ យករឿងនេះមកសម្ដែងបត់បែនតាមទេពកោសល្យខ្លួន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់នៃ Théâtre du Soleil, ការរៀបចំគម្រោងធ្វើយ៉ាងណាឲ្យរឿងល្ខោនអឺរ៉ុបនិយាយពីស្រុកខ្មែរ ហើយដែលក្លាយទៅជាខ្មែរនេះ បានសម្ដែងឲ្យទស្សនិកជននៅក្នុងស្រុកនិងក្រៅស្រុកបានមើល..., ទាំងអស់នេះកើតឡើងដោយសារយើងខ្ញុំមានបំណងធ្វើឲ្យចាប់ផ្ដើមមានទំនាក់ទំនងដូរពិសោធន៍ទៅវិញទៅមកក្នុងវិស័យល្ខោន ជាការជម្រុញឲ្យមានទស្សនៈវិស័យទូលំទូលាយក្នុងសិល្បៈនេះ ទាំងនៅប្រទេសកម្ពុជាផង ទាំងក្រៅប្រទេសផង។

ច្បាប់ជាភាសាខ្មែរនេះ ជាការប្រែសម្រួលនិងបង្រួញផ្នែកខ្លះៗ នៃច្បាប់ដើមជាភាសាបារាំង។ ឈុតខ្លះដែលមានក្នុងសំណេរក៏មិនយកមកសម្ដែង ឬក៏មានការប្រែប្រួលខ្លះៗក្នុងការសម្ដែងដែរ។

អាស្វី ថមសុន

កក្កដា ២០១១

# រាយនាមតួអង្គ

កម្ពុជា៖

**ព្រះញាតិវង្ស**

នរោត្តម សីហនុ, *ព្រះមហាក្សត្រ បន្ទាប់មកជាសម្ដេច (ព្រះឧបយុវរាជ)*

នរោត្តមសុរាម្រឹត, *ព្រះមហាក្សត្រសោយទីវង្គត, ព្រះបិតានៃព្រះនរោត្តមសីហនុ*

ព្រះមហាក្សត្រីយានី កុសមៈ, *ព្រះមាតានៃព្រះនរោត្តមសីហនុ*

អ្នកម្នាង, *ព្រះជាយានៃព្រះនរោត្តមសីហនុ*

អ្នកមុំ សាវៃ, *ជំនិតនឹងព្រះមហាក្សត្រីយានី*

**អ្នកជំនិតនឹងមិត្តព្រះមហាក្សត្រ**

សម្ដេច ប៉ែន នុត

អនុសេនីយ៍ឯកអុង មាង, *អង្គរក្សសម្ដេច*

ជា សាន, *ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងមូស្គូ*

**សត្រូវព្រះមហាក្សត្រ**

អ្នកអង្គម្ចាស់ស៊ីសុវត្ថិសិរិមតៈ

ឧត្តមសេនីយ៍ លន់ នល់

ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងប៉ារីស៍

**អ្នករាំង**

រាមា ម៉ុក, *អ្នកភ្លេង*

ឱត ប៊ុនសួ, *អ្នកបម្រើសម្ដេច*

ឱត សុផុន, *អ្នកបំម្រើព្រះមហាក្សត្រីយានីកុសុមៈ*

អនុសេនីយ៍ឯក និស្ស័យ

**ភ្នំពេញ**

អ្នកស្រីខៀវ សំណុល, *អ្នកលក់បន្លែ, ម្ដាយលោកខៀវសំផន*

អ្នកស្រី ឡាំណោ, *យួនអ្នកលក់ត្រី*

យុគន្ធរ, *កូនចិញ្ចឹមស្រីទាំងពីរនាក់ខាងលើ*

**អ្នកជំនិតលោកលន់ នល់**

អនុសេនីយ៍ឯក ស៊ឹម ណារ៉ាង

អនុសេនីយ៍ឯក អ៊ិន សូផាត

**សាធារណៈរដ្ឋលោក លន់ នល់**

ប្រីសិទ្ធនៃវីរសេនីយ៍ អ៊ុំ សាវុធ

ចេង ហេង, *ប្រធានរដ្ឋសភា*

ឡុង បូរេត, *នាយករដ្ឋមន្ត្រី*

សូ ខាំខូយ, *ប្រធានាធិបតី*

**ខ្មែរក្រហម**

សាឡុត សរ

ខៀវ សំផន

ហ៊ូ យន់

អៀង សារី

អ្នកស្រី អៀង ធីរិទ្ធ

**តួអង្គផ្សេងទៀត**

អ្នកស្រែ

ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា

ក្រុមចម្រៀងជាពួក

កម្មាភិបាល, *កម្មាភិបាលខ្មែរក្រហមម្នាក់*

ឈន ហៃ, *កម្មាភិបាលខ្មែរក្រហម*

**សហរដ្ឋអាមេរិក**

ហង់រី គីស៊ីងហ្គ័រ, *ទីប្រឹក្សាប្រធានាធិបតីនិចសុន*

មែលវីន លែត, *រដ្ឋលេខាធិការការពារជាតិ*

ឧត្តមសេនីយ៍អាប្រាមស៍, *ឧត្តមសេនីយ៍មេបញ្ជាការទ័ពអាមេរិកប្រចាំវៀតណាមខាងត្បូង*

រ៉ូប៊ែរ ម៉ាក់គ្លិនតុក, *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា*

ឧត្តសេនីយ៍ តាប៊ែរ

ហាគិនស៊ី, *ភ្នាក់ងារសេអ៊ីអា*

វីលាម វ៉ាតស៊ី, *លេខាក្រុមប្រឹក្សាសន្តិសុខជាតិ*

ចន ហ្គុនធឺរ ឌីន, *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា*

ឃីលី, *លេខារបស់លោកឌីន*

គីត ម៉ាក់ក្លុស្គី, *តំណាងរាស្ត្រ គណបក្សសាធារណរដ្ឋ*

**សហភាពសូវៀត**

អាឡិចស៊ី កូស៊ីហ្គីន, *នាយករដ្ឋមន្ត្រី*

អ្នកបកប្រែ

**ប្រទេសចិន**

ជូ អេនឡាយ, *នាយករដ្ឋមន្ត្រី*

លីវ កៀង, *ប្រីសិទ្ធិពិសេសនៃជូ អេនឡាយ*

ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងប៉េកាំង

អេជែន ម៉ាណាក់, *ឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងប៉េកាំង*

**ប្រទេសវៀតណាម**

ផាំ វ៉ាន់ដុង, *នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋវៀតណាមខាងជើង*

ឧត្តមសេនីយ៍ យ៉ាប, *រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការ កងទ័ពសាធារណរដ្ឋវៀតណាមខាងជើង*

ឧត្តមសេនីយ៍ វ៉ាន់ ទៀនឌុង, *ស្តីទីរដ្ឋមន្ត្រីខាងលើ*

# សម័យកាលទី៣

# ឈុតទី១

## ឆាកទី១

*(ភ្នំពេញ, ព្រះបរមរាជវាំង។ ព្រះមហាក្សត្រសីហនុ, សម្ដេចប៉ែន នុត, អ្នកអង្គម្ចាស់សិរិមតៈ, លោកម៉ាក់គ្លិនតុក, ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក, ឯកអគ្គរដ្ឋទូតផ្សេងទៀត, អ្នកបម្រើ។ល។ យាងនឹងដើរចូលមក)*

**ព្រះសីហនុ**

យីថ្ងៃនេះមនុស្សអើងកងល្អមែន!
របៀបនេះហើយដែលខ្ញុំចូលចិត្ត។
សម្ដេចប៉ែន នុត, អញ្ជើញមកខាងស្ដាំជិតខ្ញុំ,
ក្នុងពិធីបរមបុរាណ, តែរៀបចំថ្មីបែបនេះ, កាលណាបានសម្ដេចនៅជិតខ្ញុំ, ខ្ញុំធូរខ្លួនស្រួលចិត្ត, ព្រោះសម្ដេចស្មោះនឹងខ្ញុំ។
ឯកឧត្ដមទូតសហរដ្ឋអាមេរិក,
ឯកឧត្ដមនឹងឃើញថាខ្ញុំកាត់សេចក្ដីយ៉ាងដូចម្ដេចនៅក្រោមដើមក្បោករបស់ខ្ញុំនេះ។
មក! មក! នរណាប្ដឹងប្ដល់, នរណាទទួលជំងឺចិត្ត គឺពេលនេះហើយ!
មក! កូនចៅ! តវ៉ាអ្វីស្រេចតែចិត្តចុះ!

**អ្នកស្រែទីមួយ**

នេះជាលើកទី៣ហើយដែលទូលព្រះបង្គំមកប្ដឹង ហើយសម្ដេចឱ្យទូលបង្គំត្រូវ២លើករួចមកហើយ!

**ព្រះសីហនុ**

មើល! កូន, មិនសប្បាយចិត្តរឿងអ្វី?

**អ្នកស្រែទីមួយ**

*កាលពីលើកទីមួយ ទូលព្រះបង្គំមិនសុខចិត្តពីលោកចៅហ្វាយខេត្តបង្ខំកូនចៅឲ្យបង់ពន្ធច្រើនពេកលើផលស្រូវដំណាំដែលខំប្រមូលបាន, ហើយមិនតែប៉ុណ្ណោះចាប់យកជ្រូកជាត់ៗរបស់យើងទៀត។ កាលនោះព្រះអង្គឲ្យយើងឈ្នះ។ ទឹកព្រះទ័យនេះ ទេព្តានឹងថ្វាយព្រះពរ!*

**ព្រះសីហនុ**

*ចុះលើកទីពីរវិញ?*

**អ្នកស្រែទីមួយ**

*លើកទីពីរវិញ រឿងតែដដែលនេះឯង!*

**ព្រះសីហនុ**

*ម៉េចអញ្ចឹងទៀត, បើឱ្យឲ្យឈ្នះហើយ?*

**អ្នកស្រែទីមួយ**

*ក្រាបទូល, ឱ្យឲ្យទូលបង្គំត្រូវមែន តែលោកចៅហ្វាយខេត្តធ្វើមិនដឹងមិនឮ។*

**ព្រះសីហនុ**

*បើអញ្ចឹងថ្ងៃនេះ រឿងដដែលនោះឯង, មែនទេ?*

**អ្នកស្រែទីមួយ**

*មិនមែនទេ, ក្រាបទូល, លើកនេះរឿងធ្ងន់ធ្ងរជាងមុនទៀត! គឺរឿងរាំងស្ងួត!*

**ព្រះសីហនុ**

*ហ្អ! តទៅទៀត*

**អ្នកស្រែទីមួយ**

*គឺរឿងហួតហែងអត់ភ្លៀង, ក្រាបទូល! ២ឆ្នាំមកហើយ មេឃរាំងស្ងួតយកកម្មកូនចៅខ្លាំងណាស់! តើព្រះអង្គមេត្តាប្រោសយាងទៅភូមិកូនចៅដើម្បីបួងសួងបានឬទេ?*

### ព្រះសីហនុ

កូនឯងមកពីណា បានជាមកឲ្យឪបញ្ហាមេឃឲ្យភ្លៀងដូច្នេះ?

### អ្នកស្រែទីមួយ

សូមក្រាបទូលសម្ដេចឪ, មកពីរតនគីរី។

### ព្រះសីហនុ

នៅឯនោះហើយ នៅតែអត់ភ្លៀងទៀត?
ចុះក្រែងនៅឯភ្នំឯនោះ កូនចៅមានស្ដេចខាងទឹកភ្លៀងមែនទេ?
ក្រែងលោកូនចៅធ្វើឲ្យព្រះនោះខ្វាល់ទេដឹង?

### អ្នកស្រែទីមួយ

ពិតហើយក្រាបទូល។ កាលពី២ឆ្នាំមុន កូនចៅមិនបានកាប់ក្របីថ្វាយ។ តាំងពីនោះមក ព្រះលែងស្ដីរក កូនចៅរហូត។

### ព្រះសីហនុ

នែកូន! កុំឲ្យឪទៅអន្តរាគមនឹងទេពដូច្នោះ។ យើងត្រូវគោរពវន្ទាលុតក្រាបព្រះរាជាយើងទាំងប៉ុន្មាន ដូចជាយើងគោរពលុតក្រាបទេពនានាដែរ។ ប៉ុន្តែ កូនឯងគ្រាន់បើ, ហ៊ានទទួលស្គាល់កំហុសខ្លួន, ដូច្នោះត្រឡប់ទៅវិញមិនដៃទទេឡើយ, ឪឲ្យក្របីដើម្បីយកទៅបូជាថ្វាយស្ដេចទឹកភ្លៀង។
ទៅចុះ, ហើយនាំសេចក្ដីគោរពរបស់ឪទៅដល់ស្ដេចទឹកភ្លៀងផង។

### ខៀវសំផន

*(និយាយតែឯង)*

គិតទៅងាយណាស់, ដើម្បីឲ្យកសិករស្រឡាញ់, ឲ្យតែធ្វើអ្វីបន្តិចបន្តួចក៏គេធូរចិត្តដែរ។

### ព្រះសីហនុ

តរឿងយើងទៀត! ដល់វេនទរណា?

**អ្នកស្រែទីពីរ**

ក្រាបទូលសម្ដេចឪ, ទូលព្រះបង្គំមកទូលនេះក្នុងនាមអ្នកភូមិបាំងរលឹម នៅខាងពាយព្យបាត់ដំបង។ គេដេញយើងខ្ញុំត្រណាត់ត្រណែងពីដីដែលធ្លាប់រស់នៅ ដើម្បីយកដីនោះមកតាំងទីរោងចក្រស្ករ។

**ព្រះសីហនុ**

នរណាដែលដេញកូនចៅនោះ?

**អ្នកស្រែទីពីរ**

ក្រុមហ៊ុនមួយមកពីទីក្រុង, "ក្រុមហ៊ុនអាមីរ៉ាក់... អាមេរិកាំង-ខ្មែរ...ដើម្បីអភិវ..."។ គេថាដីនោះមិនមែនជារបស់កូនចៅទេ តែជារបស់លោកចៅហ្វាយខេត្ត។ ព្រះករុណាថ្លៃវិសេស កូនចៅទាំងអស់គ្នាតពូជពង្សពីណាពីណីមកនៅលើដីនេះឯង។

**សម្ដេចប៉ែន នុត**

ព្រះករុណាថ្លៃវិសេស រឿងនេះក៏បង្ករឡើងដោយលោក សង់គ្រុន ទៀតដែរ, គឺលោកសង់គ្រុនដែលត្រូវជាប្អូនថ្លៃរបស់ទ្រង់សិរិមតៈ។ គាត់ជាប្រធានក្រុមហ៊ុននោះ។

**ព្រះសីហនុ**

ស្រែកូនឯងគឺជារបស់កូនឯង។ គ្មានឲ្យរោងចក្រណាមកសង់កន្លែងនោះទេ, ស្រេចតែឪ! សម្ដេចប៉ែននុត, ខ្ញុំសូមប្រគល់បន្ទុកនេះឲ្យចាត់ការ ហើយសូមប្រាប់ទៅលោកសង់គ្រុនផងថា ខ្ញុំស្អប់ណាស់ល្បិចកលព្រមទាំងចរិតលីលារបៀបសក្ដិភូមិនេះ។

**ម៉ាក់ឃ្លិនតុក**

ព្រះករុណាថ្លៃវិសេស, អ្នកផ្ដល់ថវិកាសង់រោងចក្រនៅលើដីបងជីដូនមួយព្រះអង្គនោះ ជាជនជាតិអាមេរិកាំង យើងខ្ញុំម្នាក់។

**ព្រះសីហនុ**

*សង់គ្រុនពុំមែនបងប្អូនជីដូនមួយខ្ញុំទេ! ហើយដីនោះក៏មិនមែនរបស់គាត់ទៀត, ដូច្នេះគឺមិនមែនរបស់លោកដែរ, ឯកឧត្ដមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក!*

**ម៉ាក់គ្លិនតុក**

រឿងនេះច្បាស់ជាមានការយល់ច្រឡំអ្វីមួយហើយ....

**ព្រះសីហនុ**

ប្រាកដហើយ, ឯកឧត្តម។ ហេតុនេះ ខ្ញុំសូមឯកឧត្តមមេត្តាប្រាប់ទៅក្រុមហ៊ុនចម្រុះអាមេរិកាំងខ្មែរនោះ ថាយើងពុំត្រូវការគេទេ។ ហើយសូមឲ្យនាយកក្រុមហ៊ុននោះ ទាក់ទងទៅសម្ដេចប៉ែន នុត ដើម្បីដោះស្រាយរឿងនេះឲ្យជ្រះស្រឡះ។

**ម៉ាក់គ្លិនតុក**

ក្រាបទូល, ទូលបង្គំនឹងប្រាប់ទៅគេ, ប៉ុន្តែមានកិច្ចសន្យាមួយទៅហើយ។

**ព្រះសីហនុ**

សូមមេត្តាដោះស្រាយជាមួយសម្ដេចប៉ែន នុតចុះ។

**ម៉ាក់គ្លិនតុក**

ក្រាបទូល, ទ្រង់សិរិមតៈ ជ្រាបរឿងនេះច្បាស់លាស់...ហើយស្គាល់តំបន់នោះផង...

**ព្រះសីហនុ**

ខ្ញុំបានជម្រាបហើយ, សូមមើលរឿងនេះជាមួយសម្ដេចប៉ែន នុត, ហើយឈប់ជជែកត្រឹមនេះ! Stop!

**ខៀវសំណុល**

*(និយាយទៅទស្សនិកជន)*

នេះទើបហៅថាស្ដេច! គឺចេះធ្វើឲ្យគេទន់ចិត្តទន់ថ្លើម!ព្រះអង្គមានអនុភាពខែងរែងលើសគេថាទៅទៀត។

**ទ្រង់សិរិមតៈ**

ហ្លួងអូន!

### ព្រះសីហនុ

មានការអីទៅ អ្នកអង្គម្ចាស់សិរិមតៈ?

### ទ្រង់សិរិមតៈ

ហ្លួងអូន ធ្វើដូច្នេះគឺរាំងរាធ្វើឲ្យខាតបង់ឧស្សាហកម្មសម្បើមណាស់ ដែលទើបតែនៅក្មេងខ្ចីផង។ អ្នកវិនិយោគគេរត់អស់ហើយ បើយ៉ាងនេះ!

ឯរឿងរោងចក្រចម្រាញ់ស្ករនេះ ប្អូនថ្លៃបងមានច្បាប់អនុញ្ញាតត្រឹមត្រូវពីក្រសួង ក្រោយពីបង់ប្រាក់សិទ្ធិកាន់កាប់យ៉ាងថ្លៃ ហើយជាដុល្លារផង។ ហ្លួងអូនបានសន្យាដល់សង់គ្រុនថា នឹងជួយសម្រួលសំណុំរឿងនោះទៀតផង។

### ព្រះសីហនុ

ប៉ុន្តែក្រោយមក ខ្ញុំបានសន្យាពាក្យផ្សេងចំពោះមុខប្រជាជន។

### ទ្រង់សិរិមតៈ

បើជាអ្នកខ្លះទៀតវិញ គេអាចបំភ្លេចពាក្យសន្យាខ្លួនឯង ហើយរកលេសគេចវេះបាន។

### ព្រះសីហនុ

ខ្ញុំបានរៀបជើងព្រួលអស់ហើយ។ ខ្ញុំស្គាល់ពិភពរបស់ម្ចាស់បងច្បាស់។ ទ្រព្យធនសន្ធឹកសន្ធាប់ធ្វើឲ្យម្ចាស់បងវង្វេង។ខំបម្រះឡើងម្ចាស់បង! អ្នកស្រែនេះមិនអាចចាកចេញពីឫសគល់ខ្លួនបានទេ ព្រោះដើមឈើនេះចាស់រាប់ពាន់ឆ្នាំហើយ។ ចំណែកឯប្អូនថ្លៃម្ចាស់បង មានទៅពិបាកអី? បើកតែឡានម៉ែកសេឌីស (Mercedes) គាត់ ឲ្យផុតពីកន្លែងនេះទៅច្បាស់ជារកដីសង់រោងចក្រនោះបានហើយ។ ហ្អ! រកមើលម្តុំពោធិសាត់មើល!

### សម្តេចប៉ែននុត

ក្រាបទូល, ទូលព្រះបង្គំដូចជាមិនស្របតាមទេ, ព្រោះបើដូច្នោះឆ្នាំក្រោយមុខជាអ្នកស្រែមកតវ៉ាតាំងពីពោធិសាត់ទៀតពុំខាន!

### ព្រះសីហនុ

ឬក៏ទៅរកឆ្ងាយហួសពីនោះទៀត។ ប្រទេសកម្ពុជាយើងសម្បូណ៌ដីណាស់ មិនខ្វះទេ។ ហ្អ! មានបណ្តឹងអីទៀត? កូនចៅនិយាយមក, ឪស្តាប់។

## ខៀវសំផន

ព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំមានសំណូមពរមួយ។

## ព្រះសីហនុ

កូនឯងមកពីណា? ហើយចង់បានអ្វី?

## ខៀវសំណុល

ព្រះករុណាថ្លៃវិសេស, នេះគឺកូនខ្ញុំម្ចាស់។ ឱព្រះជាម្ចាស់! វានឹងនិយាយទាមទារអ្វី?

## ខៀវសំផន

ទូលព្រះបង្គំមានសញ្ញាប័ត្រមកពីសាកលវិទ្យាល័យក្រុងប៉ារីស៍។ ទូលព្រះបង្គំជាបណ្ឌិតខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ទូលព្រះបង្គំត្រឡប់មកស្រុកវិញកាលពី៣ ឆ្នាំមុន ហើយបានដាក់ពាក្យសូមកន្លែងធ្វើការនៅសាកលវិទ្យាល័យនិងវិទ្យាល័យ។ ពាក្យសុំនោះ គេបញ្ជូនមកទូលព្រះបង្គំវិញ៦ដង ដោយទារឲ្យសរសេរបំពេញបន្ថែម។ គេថាខ្វះលិខិតគាំទ្រ។

## ព្រះសីហនុ

ហើយទៅ យ៉ាងម៉េចទៀត ?

## ខៀវសំផន

គេសួរទូលបង្គំថា មានស្គាល់អ្នកណាជាអ្នកវាំងទេ។

## ព្រះសីហនុ

យ៉ាងម៉េច? ចង់បានលិខិតគាំទ្រ?

## ខៀវសំផន

ទូលបង្គំចង់បានសេចក្ដីបំភ្លឺ, ក្រាបទូល។ ទូលព្រះបង្គំចង់ដឹងថា នៅសាកលវិទ្យាល័យ គេឲ្យកន្លែងមនុស្សធ្វើការតាមសមត្ថភាពឬតាមការលុតក្រាប។

**ព្រះសីហនុ**

*មើល! កូន, កូនឯងឈ្មោះអ្វី?*

**ខៀវ សំផន**

*ខៀវ សំផន, ក្រាបទូល។*

**ព្រះសីហនុ**

*ឱ! ឯងនេះហើយដែលបានផ្ញើសំបុត្រមកឱ្យ ដែលចុះហត្ថលេខាថា "ខៀវ សំផន និងហ៊ូ យន់, បណ្ឌិតមកពីសាកលវិទ្យាល័យស៊ែកបោន* (Sorbonne) *នៅប៉ារីស៍" ហើយដែលក្នុងនោះ មានទាមទារឱ្យដកសាកលវិទ្យាធិការចេញ ពីតំណែង!*

**ខៀវ សំផន**

*ក្រាបទូល, ក្នុងរឿងនេះមិនមែនមានតែទូលព្រះបង្គំម្នាក់ឯងទេ, យើងខ្ញុំមានគ្នា៤នាក់។ មិត្តទូលបង្គំទាំងនោះមានបំណងបញ្ចេញ...*

**ព្រះបាទសីហនុ**

*យ៉ាងម៉េច? យ៉ាងម៉េច? ៤នាក់ ដែលមានសញ្ញាប័ត្រ? ហើយចង់បានអី? ចង់បានសេចក្ដីពន្យល់៤? ចង់បានអ្វីលើសពីនោះទៀតទេ? យី! ទៅប៉ារីស៍ដោយសារថវិកាយើង! ដោយសារអាហារូបករណ៍យើង! ហើយចូលក្នុងសម្ព័ន្ធនិស្សិតកម្មុយនិស្ត, បន្ទាប់មកយកលុយយើងទៅទិញសៀវភៅមួយចប់របស់ម៉ាក្សនិងម៉ៅសេទុង។ គេមិនអស់ចិត្តទេ, គេយកសៀវភៅទាំងនោះទៅគរលើគ្នា កើតជាភ្នំលិទ្ធិម៉ាក្ស, ហើយពីលើភ្នំនោះ គេឈរយ៉ាងសម្ញែងមើលមករាស្ត្រខ្មែរដែលរស់នៅសុខសាន្តមិនដឹងអី! ប៉ុណ្ណោះហើយ មិនសុខចិត្តទៀត, គឺមកសូមការគាំទ្រពីស្ដេច! អ្នកឯងទាំងប៉ុន្មាននេះ ធ្វើឱ្យខ្ញុំខាតពេលសម្រាប់រាស្ត្រ, រីឯ ខ្លួនឯងវិញមិនមែនជារាស្ត្រសោះ! នែ កុំចាចៅយើង ហើយចង់យកចំណេញពីយើង។ ទីនេះជាសាលាកាត់ក្ដីសម្រាប់អ្នកដែលពុំចេះសរសេរបារាំង។ ត្រឡប់ទៅណាទៅណាវិញទៅ! ទៅកាកដេឡាតាំង(* Quartier Latin*)* , *ទៅហាណូយ ឬក៏ទៅប៉េកាំងទៅ!*

*(លោកខៀវសំផនដើរចេញ)*

*សរសេរអត្ថបទទៅ, ខ្ញុំច្បាស់ជាអាន, ព្រោះអ្វីដែលគេសរសេរ ខ្ញុំអានទាំងអស់។*

ណ្ហើយ! ឥឡូវនេះ ស្ដាប់ភ្លេងបន្តិចសិនឲ្យថ្លាចិត្ត។ ហើយរកភេសជ្ជៈឲ្យកូនចៅខ្ញុំទទួលទានឲ្យបានគ្រប់ៗគ្នា។ ១ ម៉ោងទៀត ចាំយើងតរឿងសប្បាយទៀត។

*(ព្រះរាជាយាងចេញដោយមានអ្នកហែរហមតាម។ លោកខៀវសំផន និងលោក សាឡុត សរ ចូលមក)*

### សាឡុត សរ

អន្តរាគមន៍ប្អូនឯងធ្វើឲ្យបងភ្ញាក់ផ្អើលខ្លាំងណាស់។ បើនិយាយមែនទែន គឺបងបារម្ភ ហើយពិបាកចិត្តខ្លាំងទៀត។

### ខៀវសំផន

ពិបាកចិត្ត? ម៉េចអញ្ចឹង?

### ខៀវសំណុល

ម៉ែបានប្រាប់ហើយថាឲ្យនៅឲ្យស្ងៀម! ឥឡូវព្រះករុណាខ្វាល់នឹងយើងទាំងអស់គ្នា, ឃើញទេ? លោក សាឡុត សរ ចេះថ្លឹងថ្លែងជាងឯង។

### ខៀវសំផន

ម៉ែ, ប៉ុណ្ណឹងបានហើយ!

### សាឡុត សរ

អ្នកមីង, ខ្ញុំសូម...

### ខៀវសំណុល

សូមកុំប្រកែកប្រកាន់, លោកម្ចាស់! ខ្ញុំបិទមាត់ហើយ។ យាយចាស់បិទមាត់ហើយ។ ខ្ញុំទៅវិញហើយ។ យាយចាស់ទៅវិញហើយ។

*(គាត់ដើរចេញ)*

### សាឡុត សរ

បងប្រាប់ម្ដងទៀត, បងមិនចូលចិត្តអន្តរាគមន៍ប្អូនអម្បាញ់មិញសោះ។ ឃើញទេ, គ្មាននរណាម្នាក់ក្នុងចំណោមគ្នាយើង ដែលបាននិយាយឡើយ, មានតែប្អូនឯងម្នាក់គត់ ដែលធ្វើខែងរែង។

### ខៀវ សំផន

ខ្ញុំទ្រាំមិនបាននឹងល្បិចល្បានព្រះអង្គ។ អម្បាញ់មិញខ្ញុំចង់...

### សាឡុត សរ

យល់ហើយ, បងយល់ប្អូនឯងច្បាស់, តែជាការជាក់ស្តែង អូនឯងទៅជាចេញមុខធ្លោមុនប្រជាជនទៅវិញ។ សត្រូវយើងក៏យល់ថាដូច្នោះដែរ។ នេះហើយលទ្ធផល។

### ខៀវ សំផន

ខ្ញុំស្តាយណាស់បង។

### សាឡុត សរ

ប្អូនឯងមិនបានគិតដល់ទេ, តែធ្វើនេះ នាំឲ្យប្រជារាស្ត្រមិនចូលចិត្តយើង។ តាមពិតយើងគួរធ្វើយ៉ាងណាឲ្យគេស្រឡាញ់យើង។ យើងមិនត្រូវធ្វើអ្វីដែលប្លែក លើកខ្លួនហួសពីប្រជាជនឡើយ។

### ខៀវ សំផន

យី! ខ្ញុំខ្មាសខ្លួនឯងណាស់។ ខ្ញុំធ្វើមកនេះគ្មានគិតពិចារណាអ្វីសោះ។ ខ្ញុំសូមទោសទៅចុះ!

### សាឡុត សរ

ខ្លឹមសារនៃបដិវត្តន៍មិនមែននៅចំមាត់ទ្វារជាប់នឹងជណ្ដើរនោះទេ។
ទាល់តែលំបាកលំបិនខ្លាំងណាស់ទើបយកបាន។ ណ្ហើយលោកប្អូន! បងលាសិនហើយ។

### ខៀវ សំផន

ម៉េចអញ្ចឹង, ក្រែង...

## សាឡុត សរ

ទេ, ទេ! ថ្ងៃនេះប្អូនឯងវិលវល់គំនិត, កុំមកជួបគ្នាក្នុងកិច្ចជំនុំយើងអី។ បងសូមទូន្មានចុះថា ទុកពេល ២-៣ថ្ងៃគិតពិចារណាសិនទៅ។ ដំបូន្មានព្រះសង្ឃមានប្រយោជន៍ខ្លះដែរ ព្រោះលោកធ្លាប់ប្រដៅបងឲ្យទុកពេលខ្លះសម្រាប់ពិចារណាលើខ្លួនឯង។ ក្រោយពីត្រិះរិះ២-៣ថ្ងៃហើយ ប្រហែលជាប្អូនយល់ថា ប្អូនមិនមែនកើតមកដើម្បីបម្រើឧត្តមគតិក្រុមយើងទេក៏មិនដឹង!

## ខៀវ សំផន

បង! ខ្ញុំរស់មក ក៏ដើម្បីតែឧត្តមគតិនេះឯង។

## សាឡុត សរ

នរណាក៏អាចច្រឡំភាន់ដែរ។

ត្រូវគិតទៅប្រជាជនមុនគេបង្អស់! កុំយកគំនិតសុទ្ធមកប្រើ, យកបេះដូងមកប្រើផង។ ឥឡូវនេះ ប្អូនទៅផ្ទះសិនចុះ។

## ខៀវ សំផន

បាទ។ សូមបងជម្រាបបងអៀង សារី និងបងហ៊ូ យន់ផងថា ខ្ញុំស្ដាយយ៉ាងខ្លាំងដែលបានធ្វើថ្លង់នេះ។

*(លោកខៀវសំផនដើរចេញ)*

## សាឡុត សរ

អ្នកអស់នោះ ខ្ញុំស្អប់ទាំងអស់។ ខ្ញុំស្អប់អ្នកដែលកំសាកមិនហ៊ានស្អប់, អ្នកដែលស្អប់តែលើបបូរមាត់ តែតាមពិតខ្លាចគេញ៉ម។

កំហឹងអើយ, ឯងពិតជាសុចរិតមែន!

កំហឹងអើយ, ឯងជាកម្លាំង, ឯងជាប្រាជ្ញា, ឯងជាប្រទីបបំភ្លឺវាសនាខ្ញុំ។

ខ្ញុំហ៊ានប្រកាសយ៉ាងពេញមុខ,

ដូច្នេះចូរឯងកំចាត់ឲ្យផុតពីប្រទេសខ្ញុំនូវអាគមគាថានៃព្រះពុទ្ធចោលម្សៀតនេះ។

ឱ, រាជាធិបតេយ្យដ៏គម្រក់អើយ! អញខ្ពើមរបៀបមាយាជកខ្ទីរបស់ឯង, របៀបកាច់រាង, ឫកខ្ពស់របស់ឯង។ អញនឹងបកអាក្រាតសំពត់សូត្រសាវស្បៃឯង ដែលគ្រាន់តែជាគ្រឿងគ្របដណ្ដប់កាយស្រីសំដីងប៉ុណ្ណោះ។ ពេលនោះពិភពលោកនឹងភ្ញាក់ផ្អើលបើកភ្នែកមើលកម្ពុជាដែលបរិសុទ្ធ, ដែលម៉ឺងម៉ាត់, ដែលគ្មានអ្វីធ្វើឲ្យ ទន់ស្រួយរលួយបាន។

ថ្ងៃណាមួយឆាប់ៗនេះ ប្រវត្តិសាស្ត្រនឹងដូរផ្លូវ,
ពួកអាក្អេងក្អាងនៅជាប់យើងនេះ, ពួកអាលេបទឹកដីគេ, ពួកអាយួនអត់ពូជ,
និងពួកអាមហាចោរប្លន់, អាយក្សក្អែកខ្វាក់, គឺអាមេរិកាំង, ពួកវាអស់ទាំងនេះនឹងឃើញថា នៅមុខវា
មានប្រទេសមួយងើបឈរ, គឺកម្ពុជាដែលគ្មាននរណាកំចាត់បាន។
កម្ពុជានោះចុះមកពីលើភ្នំ ហើយដេញពួកអាអស់នោះឲ្យផុតពីដែនខ្មែរ ដោយប្រយុទ្ធហូរឈាមដាប
ពោះដំរី។
នែ,មៀវយួនមេកោង! ច្រើនសតវត្សមកហើយដែលឯងយកដីយើងទៅប្រើហាក់ដូចជាកន្លែង
ចាក់សម្រាម។
អញនឹងដុតរំលាយឯងឲ្យដូចជេះ។
អញជាស្នូនថ្នាំង។ អញបំបែកឯងឲ្យខ្ទេចទៅជាអំបែង, កិនបុកឲ្យឯងក្លាយជាដីហ្មត់ឡើងដូចដើមវិញ,
ទើបអញសូនដីផុងនោះ ឲ្យទៅជាប្រជាជនខ្មែរថ្មី។
អញដឹងថា ដែលអញនឹងធ្វើនេះ ពុំទាន់ដែលនរណាបានធ្វើឡើយ។
សាកលលោកទាំងមូលច្បាស់ជានឹងភ្ញាក់ផ្អើល។

*(គាត់ដើរចេញ)*

## ឆាកទី២

*(នៅក្នុងហោព្រះធាតុ។ ប្រតិមាព្រះបាទសុរាម្រឹត។ ព្រះសីហនុយាងចូលមក)*

### ព្រះសីហនុ

បីឆ្នាំហើយដែលកូនវែងនឹកគិតមក,
ឱលោកឪពុកជាទីគោរព, ជាទីរលឹក, ជាទីស្នេហាបំផុត។
ឱលោកឪពុកដ៏ឧត្តុង្គឧត្តមជាទីសក្ការៈ,
លោកមិនចង់និយាយមកកូនទេឬអ្វី?
ដែលកូនប្រើពេលយ៉ាងយូរសាងរូបនេះពុំឲ្យមានខ្ចោះ គឺមិនមែនមកពីខ្ជិលច្រអូសឬពុំរវល់គិតគូរឡើយ,
នេះគឺមកពីកូនចង់ឲ្យរូបលោកឪពុកស្រស់សង្ហាបំផុត
កូនចង់ឲ្យដូនតាលោកឪពុកឃើញថា
លោកមានកូនមួយដែលគោរពបូជាឪពុក។
ឥឡូវនេះ លោកតាំងទីនៅជាមួយបុព្វការីជនរបស់លោកហើយ។
លោកមានវិញ្ញាណក្ខ័ន្ធរីករាយជាមួយទេពដែលស្ថិតនៅជុំវិញនេះ។
កូនចង់ពិគ្រោះជាមួយលោកឪពុកបន្តិច!
សូមកុំស្ងៀមឈឹងដូច្នេះ, និយាយរកកូនផង, ព្រោះការនេះសំខាន់ណាស់។

*(ប្រតិមាក៏កម្រើកមានជីវិត)*

### ព្រះសុរាម្រឹត

និយាយមក, មានរឿងអ្វីខ្លះ?

### ព្រះសីហនុ

អ្វីៗមិនសូវស្រួលសោះ ចំពោះកូនក៏ដូចជាចំពោះប្រទេសយើង។
កូនមិនដែលប្រទះពេលតឹងតែង, រញ៉េរញ៉ៃបែបនេះសោះ។
សត្រូវដែលដណ្ដើមចង់យកនគរយើងកាន់តែច្រើនទៅៗ, ហើយកាន់តែឃោរឃៅទៅៗ។

### ព្រះសុរាម្រិត

យើងនៅតែឯករាជ្យដដែលឬអ្វី?

### ព្រះសីហនុ

*យើងនៅតែឯករាជ្យ, ប៉ុន្តែ...*

### ព្រះសុរាម្រិត

*យើងពុំមែនជាស្តេចទៀតទេ!*

### ព្រះសីហនុ

*យើងនៅជាស្តេចនៅឡើយ!*

### ព្រះសុរាម្រិត

*និយាយមកមើល, កូន! យ៉ាងម៉េចហើយ ពួក "អ្នកគ្រាក់ៗ" នោះ?*
*កូនឯងជាមួយអាមេរិកាំងយ៉ាងម៉េចទៅហើយ?*

### ព្រះសីហនុ

*វាធ្វើពុំឲ្យកូនបានល្ហែសោះ*

### ព្រះសុរាម្រិត

*ម៉េចក៏កូនឯងមិនដេញវាចេញឲ្យផុតទៅ?*

### ព្រះសីហនុ

*កូនខំដេញពុំឈប់ពុំឈរទេ! ដេញចេញតាមបង្អួចមួយផុតភ្លាម ក្រុមញាតិលោកឪពុកនាំចូលមកតាមបង្អួចមួយផ្សេងទៀត។*
*ដួនកាលកូនជិះឡានតាមវិថីឯករាជ្យ, កូនគិតថាខ្លួនឯងដូចកូនកណ្តុរមិកកេ (Mickey) កំពុងទទួលភ្ញៀវរាប់រយដែលសុទ្ធតែជាឆ្មា!*
*គិតសព្វៗទៅ, រឿងអ្វីក៏ចេញមកពីយួនទាំងអស់។*
*បងប្អូនរួមជាតិយើងតែងតែយល់ខុសថា អាមេរិកាំងយកចិត្តទុកដាក់នឹងខ្លួន, នឹងវប្បធម៌, នឹងវាសនាខ្មែរ។ តាមពិតគេផ្តោតអារម្មណ៍តែទៅលើយួនប៉ុណ្ណោះ។ គេយកចិត្តទុកដាក់តែនឹងយួន, គេខ្លាចតែយួន,*

គេស្រមើលស្រម័យតែអំពីយួន។ យើងឯនេះវិញ គ្រាន់តែជាឈ្នាន់ក្រាលព្រំ សម្រាប់គេជាន់ឡើងទៅ
អើតមើលអ្នកជិតខាងយើងប៉ុណ្ណោះ។

## ព្រះសុរាម្រឹត

យួននោះបង្ករឿងមកយើង ៣សតវត្សមកហើយ។ ម៉្សិលមិញ ពុកបាននិយាយរឿងនេះជាមួយបុព្វបុរស
យើង។ ម៉េចក៏កូនឯងបណ្តោយឲ្យវាចូលមកស្រុកយើង ពួកអាលេបដីគេនោះ? គេមិនដែលទុកឲ្យកណ្តុរ
ចូលក្នុងជង្រុកទេ។ គ្នាវាច្រើនឬអី?

## ព្រះសីហនុ

តាមពិត មានចំនួន៥សែននាក់ដូចជំនាន់លោកឪពុកដែរ។ តែពួកនេះគ្មានអ្វីឲ្យយើងបារម្ភទេ ព្រោះគេ
រស់នៅរកស៊ីធម្មតាជាមួយយើង។ ដែលប្តូរផ្លាស់នោះគឺចំនួនពួកវាតាមទល់ដែន។ វាចេញចូលមកពេល
យប់ ដូចសត្វទីទុយ សត្វមៀមដែរ ដែលយើងមិនអាចឃើញចលនាច្បាស់ដោយសារងងឹត។ ពួកនោះជា
ក្រុមកុម្មុយនិស្ត។

## ព្រះសុរាម្រិត

ពួកនោះ កូនឯងត្រូវតែដេញវាចេញ ព្រោះវាមិនមែនមកនៅធម្មតាជាមួយអ្នកឯងទៀតទេ, គឺវាមកបំបែក,
បញ្ចុះបញ្ចូល។

## ព្រះសីហនុ

ពុកដូចជាអន្ទះអន្ទែងបន្តិច តាំងពីចាកចោលលោកនេះទៅ! បើកូនហ៊ានតែប៉ះពាល់ពួកដែលលួច
ចូលមក, ភ្លាមនោះអ្នកដែលចាំតែរករឿងយើងនឹងស្រែកធ្វើជាចោទឡោ យកលេសមកញាំញីយើងជា
ពុំខាន។

## ព្រះសុរាម្រិត

អីយ៉ា! កូនឯងឥឡូវនឹងធឹងជាងមុនច្រើន! មានរឿងឬដំណឹងអ្វីផ្សេងទៀតទេ?

## ព្រះសីហនុ

គ្មានទេ... អូ! មាន! នឹងមានការបោះឆ្នោត

### ព្រះសុរាម្រឹត

*បោះឆ្នោត?*

### ព្រះសីហនុ

ពុកចាំទេថា យើងបានយល់ព្រមលើគោលការណ៍ថានឹងបោះឆ្នោតដោយសេរី? កាលនោះ គឺមុនពេលដែលពុកសុគត...

### ព្រះសុរាម្រិត

*...! ...! ...!*

### ព្រះសីហនុ

នៅខែប្រាំងខាងមុខនេះនឹងមានការបោះឆ្នោតជាសាកល។ សព្វថ្ងៃនេះ មានគណបក្សចំនួន៦ហើយ ដែលកើតឡើងដើម្បីប្រចាំងនឹងរាជ្យអំណាច។

### ព្រះសុរាម្រិត

*គណបក្ស? ហិនហោចហើយបើយ៉ាងនេះ! សុទ្ធតែជាការលោភ, នាំឲ្យបែកបាក់។*

### ព្រះសីហនុ

មិនយូរទេ ពួកនោះនឹងមកដល់ខ្លោងទ្វាររាំងស្រែកទាមទារកាត់យករាជបល្ល័ង្កមួយកំណាត់។ បើកូននៅជាស្តេច កូននឹងបាត់បង់អ្វីៗរលីង គ្មានអ្វីសល់ឡើយ។ គឺសោយរាជ្យលើបល្ល័ង្កខ្លួនឯងតែប៉ុណ្ណោះ, បើនៅជាស្តេច។

### ព្រះសុរាម្រិត

*បិទកុំឲ្យមានបោះឆ្នោតទៅ! រកអ្វីមកជំនួសវិញ!*

### ព្រះសីហនុ

កូនបានគិតហើយ, កូនមានគម្រោងល្បិតល្អន់ជាសម្ងាត់មួយ។
លោកឪពុកព្រួទេ?

### ព្រះសុរាម្រិត

ពុកបានតែស្តាប់ប៉ុណ្ណោះ!

### ព្រះសីហនុ

សូមលោកឪពុកអនុញ្ញាតឲ្យកូនដាក់រាជ្យចុះ។ ឈប់សិនពុក! ចាំស្តាប់កូនពន្យល់សិន! កូននឹងប្រគល់ព្រះរាជ្យបល្ល័ង្កទៅហ្លួងម៉ែ។ ពេលនោះកូនទៅជាព្រះអង្គម្ចាស់ ហើយនឹងទៅដាក់បេក្ខភាពឈរឈ្មោះបោះឆ្នោតដែរ។ ដោយសារបេក្ខជននោះជាកូន, គឺកូនពិតជានឹងឈ្នះ។ ពេលនោះកូនទៅជាស្តេចមួយបែបទៀត ដែលមានសេរីភាព ហើយខ្លាំងក្លាជាងមុន។ លោកឪពុកយល់យ៉ាងណាដែរ?

### ព្រះសុរាម្រិត

ចោលរាជ្យបល្ល័ង្ក! គួរឲ្យស្តាយមែន...

### ព្រះសីហនុ

ទុកចិត្តកូនចុះ, កូនគិតនេះមិនខុសទេ។
សម័យនេះមិនអាចទរណាជាព្រះផងជាស្តេចផងតែឯងទៀតឡើយ។
កូននៅតែជាព្រះដដែល តែលើសពីនេះទៅទៀតកូនជាមេគណបក្ស។
កូននឹងទៅជាឧទាហរណ៍មួយដែលពុំធ្លាប់មាន៖ គឺអ្នកដែលយករាជ្យបល្ល័ង្កទៅដូរនឹងអសនៈនៅសភា។ ពេលនោះហើយដែលកូនកាន់តែល្បីហើយមានអំណាចលើសស្តេចធម្មតា។ កូនជាតំណាងព្រះនៅស្ថានលើផង, តំណាងពលរដ្ឋនៅឯនេះផង , ហើយកម្លាំងបូកគ្នានេះនឹងនាំឲ្យកូនតស៊ូប្រយុទ្ធដើម្បីឯករាជ្យជាទីសក្ការៈ។

### ព្រះសុរាម្រិត

បើដូច្នោះ កូនដាក់រាជ្យទៅ! តែកុំភ្លេចថា គេនឹងស្អប់កូនដូចអ្នកនយោបាយទូទៅដែរ។ កូនមានអ្នកជិតស្និតគាំទ្រទេ?

### ព្រះសីហនុ

មាន! គឺប្រជារាស្ត្រ។ នៅក្នុងកំពែងវាំង គឺជារោងសៀកដែលមានសុទ្ធតែខ្លាសាហាវ, ប៉ុន្តែចេញផុតទៅក្រៅទៅ គឺមានតែស្នេហា។

### ព្រះសុភាម្រិត

ពិតមែនហើយថា រាស្ត្រស្រឡាញ់កូន, ប៉ុន្តែមិនដឹងយកទៅធ្វើអីទេ។ ដើម្បីរំាសនាខ្ពស់ត្រដែត យើងត្រូវការមាស, ត្រូវការរោងចក្រ, ត្រូវការអាវុធ។
កុំរំពឹងលើអ្នកស្រែដែលមានតែដៃកកាយព្រះធរណី ហើយជំពាក់គេវ៉ាន់កនោះ។

### ព្រះសីហនុ

មិនប្រាកដថាជាអញ្ចឹងទេ...

### ព្រះសុភាម្រិត

យ៉ាងណាក៏ត្រូវគិតឲ្យវែងឆ្ងាយសិន។

### ព្រះសីហនុ

លោកឪពុក, កូនត្រូវលាពុកត្រឹមណេះសិនហើយ។

### ព្រះសុភាម្រិត

ពុកមិនបានជួយកូនប៉ុន្មានសោះ!

### ព្រះសីហនុ

បានទូលលោកឪពុកប៉ុណ្ណេះ, ធ្វើឲ្យកូនធូរទ្រូងច្រើន។
ឲ្យតែបានទូលយោបល់អ្វីទៅពុក, កូនហាក់ដូចជាយល់ខ្លួនឯងកាន់តែច្បាស់។

*(ទាំងពីរអង្គយាងចេញទៅ)*

## ឆាកទី៣

*(ព្រះបរមរាជវាំង។ លោក ម៉ាក់គ្លិនតុក ជាទូតអាមេរិកដើរចូលមក)*

**ម៉ាក់គ្លិនតុក**

គិតថាខ្លួនឯងជាអ្វីហ្នឹង? កោះហៅគេឯងទាំងយប់! ពេលថ្មីនេះហើយ ស្រាប់តែនឹកឃើញឲ្យគេជួបជុំ យ៉ាងឱឡារិក, ទាំងព្រះញាតិ, ទាំងមន្ត្រីអ្នកមុខអ្នកការ, ទាំងទូតគ្រប់គ្នា!

*(ទ្រង់សិរិមត: ចូលមក)*

**ទ្រង់សិរិមត:**

គួរឲ្យសរសើរឯកឧត្តមមែន, ដែលផ្តល់កិត្តិយសឲ្យយើងខ្ញុំដោយខំអញ្ជើញមកស្តាប់ហ្លួងអូនខ្ញុំ បើកបង្ហាញព្រះតម្រិះដ៏ថ្លៃថ្លារបស់ព្រះអង្គ។

**ម៉ាក់គ្លិនតុក**

តាមពិត ព្រះរាជានេះធ្វើអ្វីតាមតែព្រះទ័យ, អាងតែអំណាច។

អំណាចនោះគ្រាន់តែជាវត្ថុសាមញ្ញមួយដែលគេជឿថាសក្តិសិទ្ធិ, ហៅថាម្កុដ, ហើយដែលមនុស្សសាមញ្ញ ម្នាក់យកមកពាក់ប៉ុណ្ណោះ។

**ទ្រង់សិរិមត:**

កុំឲ្យច្រឡំថាព្រះរាជានោះជាស្តេចរបស់ខ្ញុំ, ហើយដែលនៅសោយរាជ្យនៅឡើយនេះ ក៏ដោយសារលោក ខ្លះដែរ។

ខ្ញុំស្អប់គាត់នោះមែនទែន, ស្អប់ណាស់!

មានហេតុផល ៣មុខ ដែលធ្វើឲ្យខ្ញុំស្អប់។

ជាដំបូង គឺគាត់លួចរាជ្យបល្ល័ង្កខ្ញុំ យកទៅធ្វើឲ្យអាប់ឱនសាបរលាបអស់។

បន្ទាប់មក ខ្ញុំស្អប់ដោយសារគាត់នោះ មានគេចូលចិត្តច្រើន។ ចូលចិត្តនោះ តាមពិតរបៀបថោក, ធ្វើអ្វីឲ្យ តែត្រូវចំណូលចិត្តអ្នកតូចតាចគ្មានចំណេះអ្វី។ គុណសម្បត្តិដែលគេថានោះ តាមពិតគឺ ឫកព្រហើន, កោង, វៀចវេ, បញ្ចើចបញ្ចើរាស្ត្រ។

មួយទៀត ខ្ញុំស្អប់ពីព្រោះគាត់នោះប្រឆាំងអាមេរិកាំង។ គាត់ជាជនផ្តាច់ការរបៀបចាស់គម្រិល, មិនជ្រួត ជ្រាបនូវអ្វីដែលជាការជឿនលឿន, ខ្វាយខ្វល់តែពីខ្លួនឯង ព្រមទាំងការកំសាន្តប៉ាឡែ, ឯផ្នែកឧស្សាហ-កម្ម និងសព្វាវុធ ពុំសូវគិតទេ។ មនុស្សផិតក្បត់នេះ ក្បត់ទាំងខ្លួនឯង, ក្បត់ព្រះរបស់ឯង ព្រម ទាំងគ្រួសារ

ដោយចូលដៃនិងពួកកុម្មុយនិស្ត! មិនត្រឹមតែចូលដៃជាមួយរុស្ស៊ីនិងចិនទេ គឺជាមួយពួកកុម្មុយនិស្តយួន ដែលជាចចកដើរឃ្លាំរាគត្បាតនៅតាមទល់ដែនជាច្រើនសតវត្សមកហើយ, នេះពុំនិយាយពីពួកឯទៀតផង។

ហេតុផលចុងក្រោយដែលធ្វើឲ្យខ្ញុំស្អប់ជារឿងអាស្រូវក្នុងអាទិត្យនេះ, គឺការប្រកាសអព្យាក្រិតបោកប្រាស់ដោយគ្មានសួរយោបល់នរណាដឹតិចតួចសោះ!

## ម៉ាក់គ្លិនតុក

ហេតុផលបាន ៦ហើយតែទ្រង់ថាមាន៧។

## ទ្រង់សិរិមត:

អព្យាក្រិត! ពាក្យនេះគ្មានបានការអ្វីទេ!

## ម៉ាក់គ្លិនតុក

តែព្រះអង្គបានបញ្ជាក់ដែរថា “អព្យាក្រិតយ៉ាងសន្ទោសន្ទៅ”, មែនទេ?

## ទ្រង់សិរិមត:

អព្យាក្រិតសន្ទោសន្ទៅនៃកម្ពុជា! នេះប្រែថា នៅច្វេងផងស្តាំផងក្នុងពេលតែមួយ, គឺថាទៅរកសង្គមនិយមផង ទៅរកមូលធននិយមផង, ពុទ្ធសាសនាផង ឥតជឿសាសនាផង។

ឯកឧត្តម, នេះគឺព្រះអង្គបំភាន់គេឯងគ្រប់គ្នាហើយ។

ម្យ៉ាងទៀត ព្រះអង្គលក់ខ្លួនឲ្យយួនហើយ។ អញ្ជើញទៅទល់ដែនចុះ ច្បាស់ជាពុំដឹងឯណាទេជាទល់ដែន។ នៅខាងលើនោះ គឺជាប្រទេសវៀតណាមស្រេចទៅហើយ។ យើងខ្ញុំជាអ្នកដែលគេលេបទាំងរស់។ នេះហើយដែលព្រះអង្គហៅថា “អព្យាក្រិត”។

គឺយើងឯនេះទេ ដែលគេធ្វើឲ្យទន់ជ្រាយ, យើងដែលតពូជពង្សពីក្សត្រដែលបានសាងបុរីដ៏មហិមានៅលើដីនេះ ហើយដែលពេលនោះ វៀតណាមគ្រាន់តែជាក្រុមមនុស្សអន់ថយគ្មានអារ្យធម៌អ្វីឡើយ។ អស់លោកក៏ដូច្នោះដែរ, ព្រះរាជាអាចបោកប្រាស់បានយ៉ាងងាយ។

## ម៉ាក់គ្លិនតុក

អ្នកអង្គម្ចាស់កុំបារម្ភហួសពេក។ យើងខ្ញុំបានរៀបចំ ជាសម្ងាត់នូវល្បិចកលយ៉ាងសាហាវ។

**ទ្រង់សិរិមត:**

នេះជាលើកទី៤ហើយដែលខ្ញុំដឹងថានឹងបរាជ័យទៀត។ បើខ្ញុំធ្វើកលវិលវិញ ច្បាស់ជាបានជោគជ័យ។

**ម៉ាក់គ្លិនតុក**

ដូច្នេះ ម៉េចទ្រង់មិនធ្វើទៅ?

**ទ្រង់សិរិមត:**

ពូជស៊ីសុវត្ថិមិនដែលធ្វើកលឡើយ។ ម្នាក់ៗមាននាទីផ្ទាល់របស់ខ្លួន។

*(ព្រះសីហនុយាងមកជាមួយសម្ដេចប៉ែន នុត)*

**ព្រះសីហនុ**

មើល! ម្ចាស់បង, ពេញចិត្តឬអត់ដែលប្អូនដាក់រាជ្យនេះ?

**ទ្រង់សិរិមត:**

មិនពេញចិត្តទេ?

**ព្រះសីហនុ**

ចុះអព្យាក្រិតរបស់ខ្ញុំវិញ?

**ទ្រង់សិរិមត:**

ក៏មិនពេញចិត្តដែរ!

**ព្រះសីហនុ**

មិនពេញចិត្តដែរ? ឃើញទេ, លោកឯកអគ្គរដ្ឋទូត, ទោះជាខ្ញុំធ្វើអ្វីក៏បងខ្ញុំមិនគាំទ្រដែរ! បើខ្ញុំពាក់មួដ, មុខលោកឡើងស្វាយ, បើខ្ញុំដោះមួដចេញ, មុខលោកឡើងស្លេក។ នេះគឺមកពីលោកស្អប់ខ្ញុំ!

*(ឯកអគ្គរាជទូតជប៉ុនចូលមក ដោយគក់ក្រហល់)*

## ព្រះសីហនុ

មានការអ្វីពិសេសឬឯកឧត្តម?

## ទូតជប៉ុន

ក្រាបទូល, ក្នុងរឿងទាំងអស់នេះ ទូលព្រះបង្គំត្រូវទូលទៅព្រះចៅអធិរាជថា ព្រះអង្គដាក់រាជ្យ ឬក៏ព្រះអង្គមិនដាក់រាជ្យទេ?

## ព្រះសីហនុ

ឯកឧត្តម, មុននេះ ព្រះបាទនរោត្តមសីហនុយាងចេញពីព្រះទីនាំងទេវាវិនិច្ឆ័យតាមនេះ។ ឥឡូវសូមឯកឧត្តមមើលទៅបង្អួចដែលនៅខាងនោះ។ គឺតាមនោះហើយដែលសីហនុនឹងចូលទៅវិញ។ សម្តេចប៉ែន នុត, ក្រៅពីសម្តេចមានតែខ្ញុំទេ, មើលទៅ, ដែលត្រេកអរនឹងការសម្រេចចិត្តនេះ។ មើល! គួរអស់លោកជូរទឹកមុខឡើង, កុំក្រៀមក្រំពេក។ យប់នេះ នៅមាត់ទន្លេ យើងនឹងឃើញមនុស្សម្នាមានទឹកមុខរីករាយជាពុំខាន។

*(ព្រះសីហនុយាងចេញដោយសម្តេចប៉ែន នុត, លោកទូតជប៉ុននិងលោកម៉ាក់គ្លិនតុកចេញតាម)*

## ទ្រង់សិរិមត:

*ឱម្ចាស់ថ្លៃ! គ្មានអ្នកក្រោមកពីណាទេ, គឺរូងថ្លើមខ្លួនតែខ្លួនឯង!*
*រាជាធិប្បតេយ្យកំពុងបាត់បង់ ហើយស្រុតចុះទៅ ដូចថ្ងៃកំពុងលិច។*
*១០ឆ្នាំទៀត, ៥ប៉ុណ្ណោះផងក៏មិនដឹង, យើងជាញាតិវង្សនិងគ្រាន់តែជារឿងពីអតីតប៉ុណ្ណោះ។*
*ព្រះជាម្ចាស់! ប្រទានពរឲ្យទូលបង្គំផង!*
*យ៉ាងហោចណាស់ជួយឲ្យទូលព្រះបង្គំទៅជាព្រះរាជាចុងក្រោយនៃកម្ពុជាចុះ!*
*សូមព្រះអង្គប្រគល់រាជ្យបល្ល័ង្កមកទូលព្រះបង្គំវិញ។ បានតែ១ឆ្នាំក៏សុខចិត្ត, ឬតែ១ខែក៏យកដែរ!*
*ព្រះអង្គអាចប្រស់ព្រំ ឬផ្តន្ទាស្តេចនានា, របបនានា, សូមព្រះអង្គប្រទានតែ១ថ្ងៃក៏បាន,*
*មិនបាច់មានអំណាច១ថ្ងៃនោះក៏ហីចុះ, មានតែនាមហៅថាស្តេចក៏អស់ចិត្តដែរ។*

*(ទ្រង់ចេញទៅវិញ)*

## ឆាកទី៤

*(ហោព្រះធាតុ។ ព្រះវិញ្ញាណក្ខន្ធព្រះបាទសុរាម្រឹត។ ព្រះសីហនុយាងចូលមក)*

ព្រះសុរាម្រិត

ម៉េចទៅ, ព្រឹត្តិការណ៍នោះយ៉ាងណាដែរ?

ព្រះសីហនុ

ជោគជ័យយ៉ាងត្រចះត្រចង់!

ព្រះសុរាម្រិត

ទេព្តាទាំងពួងតែងជួយកូនដូចតែសព្វដង។

ព្រះសីហនុ

ឥឡូវនេះ កូនជាប្រមុខរដ្ឋាភិបាល។ ថ្វីត្បិតតែលែងជាស្តេច, កូននៅតែជាទីសក្ការៈ ដែលពុំអាចនរណាធ្វើឲ្យរង្គើបាន។

ព្រះសុរាម្រិត

ពុកសម្លឹងឃើញថា នរណាត្រូវធ្វើរដ្ឋមន្ត្រីទី១...

ព្រះសីហនុ

កូនបានរើសរួចហើយ, គឺសម្តេចប៉ែន នុត

ព្រះសុរាម្រិត

ត្រូវហើយ, ពុកគិតដូចគ្នានោះឯង។ អើ! ធូទ្រូង! មើល, និយាយពីអ្នកមិនសប្បាយចិត្តម្តង។

ព្រះសីហនុ

មានតែក្រុមបងប្អូនជីដូនមួយ, នាម៉ឺនមុខមន្ត្រី និងអ្នករញ៉ីរញ៉ៃដដែលៗនោះឯង។ កូនធ្លាប់ទូលពុកហើយរឿង នេះ។

### ព្រះសុរាម្រិត

តែយ៉ាងណាក៏ពួកកុម្មុយនិស្តមិនអបអរដែរ, មែនទេ?

### ព្រះសីហនុ

គេសប្បាយ! សប្បាយដោយបានអសនៈបន្តិចបន្តួចនោះ!

### ព្រះសុរាម្រិត

មានអសនៈកុម្មុយនីស្តដោយពេញមុខ? ដូចជាខកចិត្តបន្តិចទៅវិញហើយ!

### ព្រះសីហនុ

កូនត្រូវការពួកកុម្មុយនីស្ត។ មានពាទាក់ដែលកូនឲ្យដំណែងជារដ្ឋមន្ត្រី។ ម្នាក់នោះ ច្បាស់ជាលោកឪពុកចូលចិត្តហើយ, ឈ្មោះខៀវ សំផន, កូនឲ្យកាន់កាប់ក្រសួងសេដ្ឋកិច្ច។ គាត់នោះគ្មានរវល់រឿងអ្វីក្រៅពីធ្វើការទេ, ទៅណាមកណាជិះតែកង់, រកតែប្រពន្ធមួយក៏គ្មានផង!

### ព្រះសុរាម្រឹត

អត់ប្រពន្ធ? ម៉េចក៏យល់ថាពុកនឹងពេញចិត្ត?

### ព្រះសីហនុ

គាត់នោះមិនចូលចិត្តចេញមុខចេញមាត់ ហើយមិនយកបុណ្យសក្តិជាធំឡើយ, ធ្វើអ្វីៗមធ្យ័តខ្លាំងណាស់។ ប្រសិនបើកូនឲ្យធ្វើត្រឹមតែជាអនុរដ្ឋលេខាធិការ ក៏គង់គាត់នឹងបំពេញការងារហ្មត់ចត់ដូចគ្នាដែរ។

### ព្រះសុរាម្រឹត

ចម្លែកមែនហ្ន! ប៉ុន្តែយ៉ាងណាក៏ត្រូវប្រយ័ត្នដែរ មនុស្សដែលគ្មានប្រពន្ធហើយគ្មានប្រាថ្នាយសសក្តិដូច្នោះ...
និយាយអញ្ចឹង, មុំសាវើ...

### ព្រះសីហនុ

អូ! សូមទោសលោកពុក, កូនភ្លេច។ អ្នកមុំសាវើ សុខសប្បាយជាទេ, ហើយនៅតែស្អាតស្រស់ប៉ប្រិមដូចមុនដដែល, ថ្វីត្បិតតែរងទុក្ខសោកខ្លាំង ដោយសារមរណភាពរបស់លោកពុក។ គាត់លែងបង្ហាត់ល្ខោនទៀតហើយ។ សព្វថ្ងៃគាត់នៅតែវាំងដដែល ហើយនៅក្បែរហ្លួងម៉ែ។ តាំងពីលោកឪពុកចែកស្ថានទៅ,

ហ្លួងម៉ែរាប់រក ហើយស្រឡាញ់គាត់, មិនដូចមុនទេ។ ទាំងហ្លួងម៉ែ ទាំងគាត់ជួយសម្រាលទុក្ខគ្នាទៅវិញទៅមក... ហើយពុំដែលភ្លេចពុកទេ។

**ព្រះសុរាម្រឹត**

នេះបានហៅថាស្រី!

**ព្រះសីហនុ**

ពុក! កូនគិតលាលោកឪពុកហើយ

**ព្រះសុរាម្រឹត**

កុំភ្លេចមកទៀតណា!

*(ទាំងពីរអង្គយាងចេញទៅ)*

## ចាកទី៥

*(មុខផ្ទះអ្នកស្រីខៀវសំណុល។ គាត់ដើរចូលមក)*

### ខៀវសំណុល

*ឈប់ទទួលពួកប្រេតទាំងនេះឲ្យចូលផ្ទះទៀតហើយ។ ព្រះអើយ! ពួកអស់នេះ, ដូចជាគ្មានឃើញកន្លែងណាមួយដែលហៅថាល្អបានសោះ! ដឹងតែពីស្រែកប្រចាំង! ជាពិសេស តាំងតែពីឮថាកូនខ្ញុំបានទទួលមហាកិត្តិយសមក!*

*ឱព្រះជាម្ចាស់! ស្មានមិនដល់ថា ថ្ងៃមុននេះសោះដែលស្គមក្រពេះ ហើយជាកូនខៀវ សំណុល, អ្នកលក់បន្លែ, ស្រាប់តែម្សិលមិញព្រះករុណាហៅទៅបាយ! គឺសម្ដេចដែលយើងស្រឡាញ់គ្រប់គ្នានោះឯង, តែ សម្ដេចឬហ្លួងដូចតែគ្នាទេ។ គ្រាន់តែដឹងថាសម្ដេចហៅមែន ខ្ញុំយល់ក្លាមថាទំនាយពីមុនមកនោះ ឥឡូវមកដល់ហើយ ព្រោះហោរធ្លាប់ទាយថា៖ “បើកូនអ្នកមិនធ្លាក់ក្នុងក្រញ៉ាំសត្វសាហាវទេ គឺ ច្បាស់ជាបានស្គាល់វាសនាត្រដែតហើយ”។ កាលនោះវាមិនសប្បាយចិត្តសោះ។*

*តាំងតែពីពេលវាទៅស្រុកបារាំង ហើយទៅសេពគប់ពួកមនុស្សកុម្មុយនីស្ដពាលមក, វាដូរយ៉ាងខ្លាំង។ ជួនកាលខ្ញុំចេះតែគិតថា មនុស្សដែលចេញទៅ៥ឆ្នាំមុននេះ តើវានេះឯងហើយឬមិនមែនវា? បើនិយាយពីកិត្តិយសដែលសម្ដេចប្រទាននោះ, គឺក្រោយពីបាយហើយ លោកតែងតាំងវាជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចសម្រាប់ប្រទេសទាំងមូល។ ឯខ្ញុំវិញ, ២ម៉ោង, ខ្ញុំចាំវា២ម៉ោងនៅមុខចម្រឹងទ្វារវាំងកណ្ដាលថ្ងៃថែស។ ដល់រួចទៅ វាចេញមកវិញ ដូចជារហន់ទៅកន្លែងណាមួយ។ ខ្ញុំសួរវាថា “ម្ហូបមានអ្វីខ្លះ? ឆ្ងាញ់ទេ?” ព្រះអើយ! វាគិតតែពីដើរញាប់ជើងមុខខ្ញុំ ព្រោះវារហន់ទៅជំនុំនឹងក្រុមពាលវានោះ, វាមិនគិតសោះថាមានសំណាងទើបនឹងបានអង្គុយនៅតុជាមួយសម្ដេចឪយើងនៅវាំង។ មួយសន្ទុះធំទើបវានឹកថាខ្ញុំអាចផ្ទុះកំហឹងដាក់វា ហើយ ទើបវាបន្ថយល្បឿនដើរ។ ខ្ញុំសួរទៀតថា៖ “ម៉េចទៅម្ហូបអម្បាញ់មិញមានអីខ្លះ?” វាឆ្លើយយ៉ាងកំបុតថា “សាច់មាន់!”។ ខ្ញុំថាទៅវិញ “មាន់!”។ សាច់មាន់នៅព្រះបរមរាជវាំង? វាថា “ប្រហែលជាត្រីទេក៏មិនដឹង, ខ្ញុំមិនបានប៉ះពាល់ទេ ព្រោះខ្ញុំរវល់គិតទៅរឿងផ្សេង”។*

*ពួកក្រុមវានេះតែអញ្ចឹង។ កាលមុន ខ្ញុំខំធ្វើម្ហូបក្លាមយ៉ាងឆ្ងាញ់ឲ្យវាស៊ី, តែគ្មាននរណាមួយខ្វល់ខ្វាយប៉ះសោះ។ ពួកវានេះចម្លែកខ្លាំងណាស់, នេះបានហៅថាកុម្មុយនីស្ដ! លែងចេះរស់, លែងចេះសើច, លែងចេះស៊ី។ នោះ! ក្រុមវាមកហើយ។*

*(លោកសាឡុត សរនិងលោកខៀវ សំផន ចូលមក)*

**សាឡុត សរ**

*ដល់ពេលវេលាត្រូវចូលព្រៃហើយ, អូនឯងមើលមិនឃើញទៀត? រឿងរ៉ាវក្នុងអាទិត្យនេះ ដល់កម្រិតប៉ុណ្ណោះហើយ នៅតែរារែកទៀត?*

**ខៀវ សំផន**

*បង! លើកនេះខ្ញុំយល់ខុសពីបង។ ខ្ញុំយល់ថាយើងត្រូវនៅក្នុងប្រទេសឲ្យគេឃើញ, ជាពិសេសដោយសារហេតុការណ៍ក្នុងអាទិត្យនេះឯង។*

**សាឡុត សរ**

*លោកប្អូន! អាណិតបងទៅមើល! គិតបន្តិចទៀតបានទេ?*

**ខៀវ សំផន**

*គិតនោះឯងហើយ! យើងបានធ្វើ...*

**សាឡុត សរ**

*ស្ងាត់! ទុកឲ្យបងពិចារណាដោយស្ងប់។ គំនិតខ្វែងគ្នានេះនឹងបំបាត់ចោលបាន។*

**ខៀវ សំផន**

*បាទ!*

*(ទាំងពីរនាក់ពិចារណាយ៉ាងស្ងៀម។ លោកហ៊ូ យន់ចូលមក)*

**ហ៊ូ យន់**

*មានរឿងអីហ្នឹង?*

**ខៀវ សំណុល**

*ស្ងាត់! គេសញ្ជាប់សញ្ជឹង! មើល, លោកក្មួយហ៊ូ យន់, មានរឿងអ្វីកើតឡើងក្នុងអាទិត្យនេះ?*

ហ៊ួ យន់

អាទិត្យនេះ? មានតែបោះឆ្នោតថ្ងៃមុននោះឯង!

ខៀវ សំណុល

អញ្ចឹងបោះឆ្នោតនោះជាគ្រោះអន្តរាយ?

ហ៊ួ យន់

អត់ទេ។ អ្នកសង្គមនិយមជាច្រើនជាប់ឆ្នោតនៅគ្រប់កន្លែងក្នុងប្រទេស។ ទាំងកូនអ្នកមីងទាំងខ្ញុំក៏ជាប់ដែរ។

ខៀវ សំណុល

មែន, មានបោះឆ្នោតមែនក្នុងអាទិត្យនេះ។ យីខ្ញុំ, កើតមកជាស្រីសោះ, ក៏បោះនឹងគេដែរកាលពីថ្ងៃអាទិត្យ! បើខ្មោចប្ដីមីងឃើញប្រហែលយ៉ាងម៉េចទៅហ្ន!

សាឡុត សរ

មើល! គិតស្រេចបាច់ហើយនៅ?

ខៀវ សំផន

បាទ!គិតហើយ។

សាឡុត សរ

អើ! មកប្អូនហ៊ួ យន់។ ប្អូនសំផននឹងខ្ញុំកំពុងខ្វែងគំនិតគ្នា។ នែ! បងក៏គិតហើយរួចរាល់ដែរ គឺថានិយាយដោយត្រង់ទៅចុះ បងពុំអាចដូរគំនិតឡើងវិញទេ។ ៣៤អសនៈ សម្រាប់ខាងយើងអ្នកជឿនលឿន គឺច្រើនហួស។ ច្រើនហួស!

ហ៊ួ យន់

ម៉េចក៏ទៅជាច្រើនហួស? ដែលយើងគិតពីមុនមក គឺមិនហួសពី៦ទេ! ឥឡូវ៣៤! នេះមានន័យថាប្រជាជនចាប់ផ្ដើមស្ដាប់យើងហើយ។ ខ្ញុំហួសពីត្រេកអរទៅទៀត។ គឺរន្ធត់ទៀតផងដោយសារកិត្តិយសនេះ។

### សាឡុត សរ

តែខ្ញុំវិញ, ខ្ញុំសូមប្រាប់ថា យើងមកដល់ផ្លូវបំបែកមួយយ៉ាងសំខាន់។ យើងអាចទៅតាមផ្លូវលោភសក្ការៈ, មុខដំណែងនឹងភាពថោកទាបហើយយើងសហការជាមួយអ្នកផ្តាច់ការ។ តែយើងអាចលោតទៅផ្លូវល្អដែលបង្វាងយើងឲ្យផុតពីការអាប់អោន។ បដិវត្តន៍យ៉ាងក្មេងខ្ចីដែលដក់ជាប់ក្នុងថ្លើមប្រម៉ាត់យើង, យើងនាំទៅឲ្យឆ្ងាយផុតពីទីក្រុង។ យកទៅទីដាច់សង្វែង ដែលលំបាកលំបិនមែនតែថ្លៃថ្នូរខ្ពង់ខ្ពស់, ទុកនៅទីនោះរហូតពេលពេញវ័យរឹងមាំ។ ពេលនោះហើយដែលយើងចុះមកវិញយ៉ាងហំហាន ហើយយើងប្រយុទ្ធក្នុងភាពបរិសុទ្ធ, ថ្លៃថ្នូរ, ដើម្បីយកជ័យជំនះ។

*ទៅយើង!*

### ខៀវសំណុល

*ទៅយើង? ចុះហាងមីងទៅជាអ្វីទៅ? នរណាជួយរកលុយឲ្យមីងសងគេ?*

### ខៀវសំផន

បង! *យើងបានសូមសេចក្តីទុកចិត្តពីប្រជាជន។ ឥឡូវគេឲ្យហើយ។ យើងត្រូវតែទទួលយក។*

### ហ៊ូ យន់

ខ្ញុំក៏យល់អញ្ចឹងដែរ។ *(ងាកទៅសាឡុត សរ)*៖ បង ខ្ញុំពិបាកយល់បងណាស់។ បងចង់ចាញ់ឆ្នោតគេវិញឬយ៉ាងម៉េច?

### សាឡុត សរ

*ហ្នឹងហើយ! ជួនកាលចាញ់នោះឯងដែលឈ្នះ!*

### ខៀវសំណុល

*!...!...*

### ហ៊ូ យន់

*ពីមុនមកនោះ យើងប្រទ្បំថាយើងយល់គ្នា, មែនទេ?*

## សាឡុត សរ

ប្រហែលជាបំណងយើងខុសគ្នាទេ, មើលទៅ។ អស់លោកជាអ្នកចូលចិត្តបម្រើ, តែខ្ញុំវិញ ខ្ញុំចូលចិត្តកែប្រែ។

## ខៀវ សំផន

បង! យើងទាំងអស់គ្នាមានគោលដៅតែមួយដូចគ្នាទេ, ដែលជាគោលដៅប្រសើរថ្លៃថ្លាហើយជាទីត្រេកត្រអាល។ ប៉ុន្តែប្រហែលជាផ្លូវដែលដើរទៅគោលដៅតែមួយនោះទេដែលផ្សេងគ្នា។

## សាឡុត សរ

ផ្លូវទៅរកការពិត មានតែមួយគត់។

## ហ៊ូ យន់

គឺថាផ្លូវដែលបងប្រកាន់យកនោះហើយ, មែនទេ?

## សាឡុសរ

ត្រូវហើយ! ណ្ហើយ! អៀង សារីនិងខ្ញុំ, យើងចាកចេញទៅស្អែកនេះ។ ប៉ុន្តែកុំអួតខ្លួនថា ខ្លួននៅទីនេះដោយសារស្រឡាញ់ប្រជាជនឲ្យសោះ។ លាហើយ, អស់លោករដ្ឋមន្ត្រីនៃព្រះករុណា, ខ្ញុំជូនពរឲ្យបានឡានម៉ែកសេឌីស (Mercedes) យ៉ាងខ្ពង់!

## ខៀវ សំណុល

ម៉ែកសេឌីស (Mercedes)? យី ម៉ែកសេឌីស (Mercedes) តែខ្លួនឯងទៅ! ក្រែងប្រណែនគេទេដឹង?

## ខៀវ សំផន

បងឯងមិនស្រួលទេឬយ៉ាងម៉េច? វាយប្រហារមិនមើលថានរណាមិត្ត នរណាសត្រូវយ៉ាងនេះ។

## ហ៊ូ យន់

មិត្ត! ឈប់ឈ្លោះគ្នាទៅ!

**ខៀវ សំណុល**

នែ! បុរសស្លូតបូត, កុំមាត់! អ្នកឯទៀត, ឈ្លោះគ្នាតទៀតទៅ!

**ខៀវ សំផន**

ទាល់តែពេលចូលព្រៃមកដល់ ទើបខ្ញុំចូល! កុំចេះតែគិតថាបញ្ហាខ្ញុំបានតាមចិត្តនោះ!

**សាឡុត សរ**

ខ្ញុំទៅយ៉ាងរីករាយបំផុត ដែលគ្មានអស់ឯងនេះ។ បើឯងនៅជិតខ្ញុំគឺអាចនឹងធ្វើឲ្យខ្ញុំប្រឡាក់ប្រឡូស។

*(លោកសាឡុត សរចេញទៅ)*

**ហ៊ូ យន់**

ឈប់សិន! ក្រែងលោយើងអាចគិតខុស! ស្ដាប់ខ្ញុំបន្តិចសិន, នរណាក៏អាចយល់ច្រឡំដែរ

*(លោកហ៊ូ យន់ដើរតាមលោកសាឡុត សរ)*

**ខៀវ សំណុល**

ទុកឲ្យពិសកំណាចវានោះ ទៅរូងថ្លើមខ្លួនឯងវិញចុះ, នេះប្រសិនបើវាមានថ្លើមប្រម៉ាត់ដូចគេដូចឯង! ឃើញទេ, ម៉ែថាមិនខុសទេ, វានេះជាស្វាក្រេះតែម្ដង!

**ខៀវ សំផន**

បានហើយម៉ែ! ប៉ុណ្ណឹងបានហើយ

តាំងតែពីដើមមក ដែលខ្ញុំចង់បានសង្គមល្អឥតខ្ចោះមួយ។ យើងជម្រះអ្វីៗឲ្យស្អាតសិន។ ឲ្យមនុស្សចេញពីទីក្រុងឲ្យអស់។ ពិភពលោកត្រូវឈានជំហានថ្មីវិញ។ គ្មាននរណាដឹងអំពីអ្វីឡើយ។ ផែនដីនេះនឹងស្អាត ថ្មីស្រឡាង មិនទាន់មានផ្ទះអ្វីមួយនៅឡើយទេ, គ្មានវត្តអារាម, គ្មានស្លាកស្នាមអ្វីទាំងអស់។ ពេលនោះកម្ពុជាបរិសុទ្ធមួយនឹងផុះចេញឡើង។

តែត្រូវចេះអត់ធ្មត់។ រដូវនីមួយៗក្នុងប្រវត្តិសាស្ត្រគឺយូរវែងអន្លាយណាស់។

**ខៀវ សំណុល**
បើធ្វើអ្វីតាមតែចិត្តបាន, ខ្ញុំចង់ឲ្យវាជាអ្នកបើកយន្តហោះវិញ។ នៅលើមេឃ, យ៉ាងណាក៏គេអណ្តែតអណ្តូងក្នុងពពកពិតៗដែរ។

*(ទាំងពីរអ្នកដើរចេញទៅ)*

# ឈុតទី២

## ឆាកទី១

*(ព្រះបរមរាជវាំង។ ព្រះសីហនុយាងចូល, បន្ទាប់មកសម្តេចប៉ែន នុត, លោកលន់ នល់, ទ្រង់សិរិមតៈ, លោកខៀវ សំផន, លោកហ៊ូ យន់, លោកឯកអគ្គរដ្ឋទូត ម៉ាក់គ្លីនតុក, ឧត្តមសេនីយ៍តាប៉ែរ, អ្នកបម្រើ)*

### ព្រះសីហនុ

ឯកឧត្តមឯកអគ្គរដ្ឋទូត, លោកឧត្តមសេនីយ៍, រដ្ឋាភិបាលលោកអះអាងថាគ្មានចេតនាអាក្រក់អ្វីមកលើខ្ញុំទេ។ តើពិតដូច្នោះមែនឬអ្វី?

### ម៉ាក់គ្លីនតុក

*ពិតដូច្នោះមែនហើយ, ក្រាបទូល!*

### ព្រះសីហនុ

ខ្ញុំនៅតែមិនទុកចិត្តទេ។ គេចង់តែកំចាត់ខ្ញុំ, គេចង់កំចាត់ប្រទេសកម្ពុជា។ ខ្ញុំសូមប្រកាសថា ខ្ញុំប្រឆាំងរឿងនេះដាជាច់ខាត។

### លន់ នល់

ព្រះអង្គមានព្រះតម្រិះថាដូចម្តេច?

### ម៉ាក់គ្លីនតុក

ព្រះអង្គចង់មានបន្ទូលពីអ្នកណា?

### ព្រះសីហនុ

*ពីអស់លោកនេះឯងហើយ! អស់លោកអាមេរិកាំង ដែលជាមិត្តយើងខ្ញុំនេះណា! ទេ, លោកឧត្តមសេនីយ៍លន់ នល់, គឺខ្ញុំថាដូច្នេះតែម្តង!*

**ម៉ាក់គ្លីនតុក**

ព្រះអង្គមានបន្ទូលនេះ អយុត្តិធម៌ណាស់!

**ព្រះសីហនុ**

ធម្មតាទេដែលឯកឧត្តមយល់អញ្ចឹង។

**ម៉ាក់គ្លីនតុក**

ព្រះអង្គឃើញហើយថារដ្ឋាភិបាលយើងផ្ដល់ជំនួយមកប្រទេសដ៏តូចរបស់ព្រះអង្គ, ហើយជំនួយនោះរីកកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

**ព្រះសីហនុ**

ហ្ន! ឃើញទេ! អស់លោកឮហើយនៅ? លោកទូតបានប្រើពាក្យថា "តូច"។ នេះបង្ហាញពីការមើលងាយ ហើយជាភស្តុតាងថាមានបំណងអាក្រក់ព្រមទាំងរៀបចំរំលំយើងផង!

**លន់ នល់**

ឱ, ស្រេចហើយ! ច្បាស់ជាមានវិបត្តិហើយពេលនេះ!

**ព្រះសីហនុ**

ខ្ញុំដឹងហើយថាសហរដ្ឋអាមេរិកធំធេងណាស់, តែបើទូតខ្លួនមើលងាយប្រទេសគេថា "តូចញ៉ៅប", រីគីគី "rikiki" នោះ, គឺមិនមែនឲ្យកិត្តិយសទៅប្រទេសដែលខ្លួនជាតំណាងនោះទេ។

**ឧត្ដមសេនីយ៍តាប៉ែរ**

យើងខ្ញុំពុំបាននិយាយដូច្នោះសោះ!

**ព្រះសីហនុ**

ទោះជានៅចំពោះមុខអ្នកបម្រើ, អ្នកកាសែត ហើយនិងអ្នកការទូតផង ក៏លោកម៉ាកគ្លិនតុក មិនប្រណីមាត់។ ម្ដេចក៏មិនទុកយើងឲ្យស្មើនិងប្រទេសដែលតូចជាងយើងទៅទៀត ហើយដែលអស់លោកគោរពនោះផង? តើលោកដែលថា " កូនប្រទេសបែលហ្សិក", "កំទិចប្រទេស អ៊ីស្រាអែល"

*ដែរ? ឲ្យតែនិយាយពីយើងខ្ញុំវិញ គឺលោកមិនដែលភ្លេចទេរឿងបន្ទាបបន្ថោក។ មើលតែកាសែតចុះ! មុនដំបូងគឺកម្ពុជាជាស្រុកតូច, បន្ទាប់មកជាស្រុកតូចណាស់។ ស្អែកឡើងទៀតថា តូចពន់ពេកណាស់។ កម្ពុជាជាអាណាចក្រគេដាក់ក្នុងហោប៉ៅ, គ្មានបានការ, គឺថាជាកំទិចដូរផង់។ នៅឯណាទៅកម្ពុជា? អូ! កម្ពុជានឹងបាត់ឥឡូវហើយ! អូ! បាត់មែន!*

*(លោកលន់ នល់ ដែលនៅពីក្រោយខ្នងព្រះសីហនុ ធ្វើកាយវិការថាសម្ដេចឡប់សតិហើយ, កុំឲ្យភ័យខ្វល់ខ្វាយអ្វី)*

*ប៉ុន្តែសីហនុ មិនទាន់ទៅណាទេ, កម្ពុជាក៏មិនទៅណាដែរ! យើងនៅឯណោះ, គឺនៅចំណុចសំខាន់នៃមហាទ្វីបអាស៊ី! មើលទៅមើល! យើងជាទ័ពស្រួចនៃអញ្ញាក្រិត, ទង់របស់យើងពិណាស, មិនមែន "ខៀវ" មិនមែន"ក្រហម"ឡើយ។ ទីនេះ ជាកំពែងរឹងមាំដែលធម្មជាតិបានសាងឡើង, កំពែងទប់ទល់នឹងជម្ងឺឆ្លងពិភពលោក។ "អង្គរ" គឺយើងខ្ញុំនេះហើយ! និយាយពីកំពែងអញ្ចឹង...*

## ម៉ាក់គ្លីនតុក

*កំពែងនោះគឺយើងខ្ញុំទេ ជាអ្នកការពារ។ ការពារដោយសព្វាវុធយើង ក្រោមការឃ្លាំមើលរបស់នាយទាហ៊ានយើង។*

## ព្រះសីហនុ

*ការពារនោះឯងហើយដែលខ្ញុំចង់និយាយ។ ត្រូវហើយលោកអាមេរិកាំង, ត្រូវហើយ! គឺលោករារាំងការពារយើងមិនឲ្យយើងការពារខ្លួនឯងកើត!*
*មានមួយថ្ងៃ ទ័ពលោកង៉ោឌិនយៀម ចូលមកដីខ្ញុំ ហើយលួចយកដីអស់មួយជុំដែលមានទទឹង៤គីឡូម៉ែត្រ។ ពេលខ្ញុំតបតវិញដោយបញ្ជូនទាហានខ្មែរទៅយកទ្រព្យខ្មែរមកវិញ, វ៉ាស៊ីនតោន ស្រែកថា " ទេ, មិនបានទេ!លោកយៀមជាអ្នកដែលយើងត្រូវតែការពារ, ប៉ះតែសក់គាត់មួយសរសៃក៏មិនបានដែរ!"*

## ម៉ាក់គ្លីនតុក

*ក្រាបទូល, ត្រង់ព្រះអង្គមានបន្ទូលនេះ គឺជាករណីពិសេស។ ក្នុងចំណុចនេះរដ្ឋាភិបាលទូលបង្គំត្រូវតែដាក់កម្រិតការប្រើប្រាស់អាវុធយើងខ្ញុំដូច្នេះហើយ។*

**ព្រះសីហនុ**

*អស់លោកឮទេ? លោកទូតមានប្រសាសន៍ច្បាស់ថា “អាវុធយើង”។ មើល, សូមបញ្ជាក់ឲ្យច្បាស់, អាវុធដ៏សំខាន់នោះ, លោកឲ្យយើងខ្ញុំឬក៏ប្រមូលយកវិញ?*

**ហ៊ូ យន់**

*(និយាយទៅខៀវ សំផន)*

*ត្រូវទទួលស្គាល់ថា ព្រះអង្គពូកែណាស់! សប្បាយស្តាប់មែន!*

**សម្តេចប៉ែន នុត**

*ក្រាបទូល, អាវុធអាមេរិកាំងនោះ ប្រើលែងកើតទៅទៀត! ឡានកាមីញ៉ុង១០០ ដែលឲ្យមកនោះ គឺខូចទាំងអស់។ ដូចជាមានតែម៉ាស៊ីនកំដៅខ្លួនពេលវងាធ្លាក់ទឹកកកទេដែលនៅដើរ។*

**ទ្រង់សិរិមតៈ**

*រឿងហ្នឹងគឺអញ្ចឹងមែន, លោកឧត្តមសេនីយ៍។*

**សម្តេចប៉ែន នុត**

*ចំណែកឯស្បែកជើងកវែង៥០០០គូនោះ, ឯកឧត្តមអើយ, ច្បាស់ជាអ្នកផ្ញើមកច្រឡំពីអ្នកដែលត្រូវទទួលហើយ។ ទាហានខ្មែរយើងខ្ញុំមិនពាក់លេខ៤៨ទេ។*

**ព្រះសីហនុ**

*ហា! និយាយមកមើល, សីហនុត្រូវធ្វើអ្វី?*

**សម្តេចប៉ែន នុត**

*មិត្តរបស់អាមេរិកាំងជាសត្រូវយើង។ ដូច្នេះអាមេរិកាំងជាមិត្តយើងកើតដែរឬអ្វី?*

**ព្រះសីហនុ**

*គិតសព្វៗទៅ ជំនួយអាមេរិកាំងបានប្រយោជន៍អ្វីខ្លះ? ប្រយោជន៍ឲ្យក្រុងភ្នំពេញដ៏ល្អរបស់ខ្ញុំឈ្លក់ញៀននឹងដុល្លារទេដឹង?*

**ហ៊្វ៊ួយន់**

*(និយាយទៅលោកខៀវ សំផន)*

គួរដែរ! មានបន្ទូលនេះ, មែនទេ?

**ព្រះសីហនុ**

មើល! ឥឡូវសូមអស់លោកមានប្រសាសន៍មកចុះ, តើគួរឲ្យខ្ញុំបន្តយកជំនួយអាមេរិកាំងទៀតទេ?

**ខៀវ សំផន**

មិនគួរទាល់តែសោះ, ក្រាបទូល។

**សម្ដេចប៉ែន នុត**

មកទល់ពេលនេះ មានតែការអាប់ឱនកិត្តិយសប៉ុណ្ណោះ។

**លន់ នល់**

ឈប់សិន!ឈប់សិន! រឿងនេះមិនមែនរាក់កំផែលទេ, គិតបន្តិចសិន។

**ទ្រង់សិរិមត:**

កុំយាត់កុំយាំង, ទុកឲ្យព្រះអង្គទៅខាងឆ្វេងអស់មួយខ្យល់ចុះ, គង់តែស្ដាយក្រោយទេ។

**ឧត្តមសេនីយ៍តាប៉ែរ**

*(និយាយទៅលោកម៉ាក់គ្លីនតុក)*

ព្រះអង្គចង់មានបន្ទូលថាម៉េចហ្នឹង?

**ម៉ាក់គ្លីនតុក**

នៅមិនទាន់យល់ទៀត? គឺផ្ដាច់ចំណងនោះឯង! ហើយកុំសង្ឃឹមថាខ្ញុំប្រចាំងរារាំងឲ្យសោះ។ ខ្ញុំជិនឆ្អន់នឹងសត្វសេកនេះណាស់, ធុញថប់នឹងស្រុកខ្មែរដ៏រលួយហើយក្អេងក្អាងបែបនេះទៀតផង។

**ព្រះសីហនុ**

ឯកឧត្តមឯកអគ្គរដ្ឋទូត, អស់លោករដ្ឋមន្ត្រី, អ្នកស្រី, នាងកញ្ញា, អស់លោក, ដោយសាររដ្ឋាភិបាលយើងខ្វល់ខ្វាយយកចិត្តទុកដាក់ខ្លាំងណាស់អំពីកិត្តិយសជាតិ ព្រមទាំងប្រកាន់ជំហរអព្យាក្រិតដាច់អហង្ការ, យើងសម្រេចចិត្តថាចាប់ពីថ្ងៃនេះទៅ យើងលែងទទួលជំនួយសេដ្ឋកិច្ចនិងយោធាពីសហរដ្ឋអាមេរិកហើយ។ យប់នេះព្រះរាជវាំងនឹងចាត់ចែងជប់លៀងយ៉ាងឱឡារិកដល់អ្នករដ្ឋការអាមេរិកាំង ដើម្បីលាគ្នាជារៀងរហូត។

**ហ៊ូ យន់**

*ព្រះអង្គដេញអាមេរិកាំងចេញ!*

**ខៀវ សំផន**

*ស្អែកគង់តែព្រះអង្គហៅមកវិញដដែល!*

**ហ៊ូ យន់**

*បងឯងដូចជាប្លែកណាស់។ បងសាឡុត សរបានប្រគល់មរតកខាងមិនទុកចិត្តឲ្យឬអ្វី? ទៅជាមិនសប្បាយចិត្ត នៅពេលដែលសម្តេចដាក់បែមកយើងទៅវិញ!*

**សម្តេចប៉ែន នុត**

*ធនាគារ, ក្រាបទូល!*

**ព្រះសីហនុ**

*សម្តេចប៉ែន នុតទទួលបន្ទុកធ្វើជាតួបនីយកម្មធនាគារនិងសហគ្រាសបរទេសទាំងអស់។*

**ទ្រង់សិរិមតៈ**

*យី! ជ្រុលពេកហើយ! ជ្រុលពេក!*

**លន់ នល់**

ណេ្ហីយ, បណ្តោយឲ្យទៅច្ចេងសិនទៅ។ *(និយាយទៅក្រុមអាមេរិកាំង)* សូមកុំយកត្រចៀកស្តាប់, អស់លោកគង់តែនឹងត្រឡប់មកវិញទេ។

**ព្រះសីហនុ**

ហើយកុំមានគំនិតថានឹងទៅត្រឡប់មកវិញឲ្យសោះ! ចំណែកឯអស់លោកនៅច្ចេងវិញ ខ្ញុំសូមជម្រាបឲ្យគេឯងដឹងច្បាស់ថា ខ្ញុំគ្មានទំនោរអ្វីទៅរកខ្លាក្រហមឆ្កៅ ដូចជាខ្ញុំគ្មានទំនោរអ្វីទៅរកខ្លាខៀវនោះដែរ។

*(ព្រះអង្គយាងទៅដោយសម្តេចប៉ែន នុតដើរតាមក្រោយ។*
*លោកខៀវ សំផន និងលោកហ៊ូ យន់ដើរចេញ)*

**ម៉ាក់គ្លិនតុក**

កម្ពុជានឹងស្តាយខ្លួនខ្លាំងនៅពេលក្រោយជាពុំខាន។

*(លោកម៉ាក់គ្លិនតុកចេញទៅ ដោយឧត្តមសេនីយ៍ តាប៉ែរទៅតាម)*

**លន់ នល់**

បណ្តេញអាមេរិកាំង! អញ្ចឹងមានតែប្រគល់ខ្លួនយើងឲ្យយួន? ឲ្យចិន? អគ្គមេបញ្ជាការកងទ័ពនឹងឆ្លើយយ៉ាងណាទៅ?

**ទ្រង់សិរិមត:**

ខ្ញុំឆ្ងល់ណាស់ថា ហេតុអ្វីក៏លោកឆ្ងល់? ក្រែងដឹងហើយ, មែនទេ, ថាស្វាដែលយើងបម្រើនោះរបៀបណា ?

**លន់ នល់**

ឱយន្តហោះ ! ប៉ុន្មានថ្ងៃទៀតសោះ ដែលយន្តហោះច្រើនគ្រឿងត្រូវមកដល់! រលាយខ្យុលអស់ហើយ, កម្មសិក្សាអ្នកបើកកប៉ាល់ហោះ !

**ទ្រង់សិរិមត:**

លាហើយ យន្តហោះ, កាំភ្លើងធំ, ឡានក្រោះ

លាហើយ លុយនៅធនាគារ, ឱលោកឧត្តមសេនីយ៍អើយ!
លាហើយក្តីសង្ឃឹម, លាហើយសេរីភាព!
មែនទែនទៅគឺថា លាហើយជីវិត! ប្រសិនបើយើងមិនតបតឲ្យក្លាមៗទៅការវាយប្រហារនៃជនពាល ដែលមិនគិតប្រទេសជាតិនេះ។
ខ្ញុំមានក្រុមខ្ញុំដែរ។ លោកឧត្តមសេនីយ៍លោកចូលមកខាងខ្ញុំឬទេ?

## លន់ នល់

ព្រះហើយព្រះ! ខ្ញុំមិនចង់ឲ្យលោកឧត្តមសេនីយ៍ចេញទៅទាំងសោះកក្រោះដូច្នេះសោះ!
សូមព្រះរាជទានទោស, ក្រាបទូល។

*(លោកលន់ នល់ចេញទៅ ដោយមានទ្រង់សិរិមតៈទៅតាម)*

*(ព្រះមហាក្សត្រីយានី កុសុមៈ យាងចូលមកដោយមានព្រះសីហនុយាងតាម)*

## ព្រះកុសុមៈ

នែកូន! ម៉ែមិនយល់សោះ។
ហាណូយកំពុងឈ្នះសង្គ្រាម។ ស្អែកនេះ ពួកយួនខាងជើងស្គមឃើញតែឆ្អឹងនឹងវាតទីរាលដាលចូលមក ដីស្រែស្ទឹងបឹងបួរយើងពេញជាមិនខាន។ ពេលនោះបាននរណាការពារទឹកដីទៀត?

## ព្រះសីហនុ

យើងការពារដោយខ្លួនឯង, ដោយចិត្តក្លា, ដោយការឈ្លៀសវៃរបស់កូន។ ហ្លួងម៉ែកុំបារម្ភ, កូនដោះស្រាយបាន។ លន់ នល់នៅតែកាន់ខាងការពារជាតិដដែល។

## ព្រះកុសុមៈ

មនុស្សដែលកូនទុកចិត្តបានតែមួយចង្អាមដូចលន់ នល់នេះ, កូនទុកឲ្យនៅដដែល?

## ព្រះសីហនុ

លន់ នល់មិនអាចក្បត់កូនទេ។ កូនដឹងថាចិត្តគាត់ផ្អៀងមកកូនមួយផ្នែកដែរ។ ក្រៅពីនោះ គឺអាស្រ័យទៅលើហោរទាយរបស់គាត់។ យ៉ាងណាក៏ដោយ លន់ នល់ យល់ថាត្រូវបម្រើអ្នកខ្លាំងដែរ, ឯអ្នកខ្លាំងនោះ គឺកូន។

**ព្រះកុសុមៈ**

*វ៉ែក្រងលោបង្រៀនក្រពើឲ្យចេះហែលទឹកទេដឹង ?*

**ព្រះសីហនុ**

*ហ្លួងម៉ែ, សោយរាជ្យ ហើយកុំខ្វល់នឹងអ្វីទៀត, អ្វីៗស្រេចតែកូន។*

*(ព្រះកុសុមៈយាងចេញទៅ)*

*(លោកលន់ នល់និងលោកម៉ាក់គ្លីនតុកចូលមក)*

*លោកម៉ាក់គ្លីនតុក, តើលោកជ្រាបថា កាសែតញូស្វីក (Newsweek) ថាអី លើរូបខ្ញុំទេ ? វាថាគ្រួសារប្រពន្ធខ្ញុំជាម្ចាស់បនស្រីខូចទាំងអស់នៅភ្នំពេញ។ អត្ថបទបំភ្លឹមហាជននេះចេញផ្សាយដោយមានជំនួយពី ឯកអគ្គរាជទូតដែលនៅទីនេះផ្ទាល់។*

**ម៉ាក់គ្លីនតុក**

*ទេ ! បន្ទូលនេះ អាស្រូវខ្លាំងណាស់!*

**ព្រះសីហនុ**

*ត្រូវហើយ, អាស្រូវមែន, គឺមួលបង្កាច់យ៉ាងអាស្រូវ។ នេះ ! មើលទៅមើ ! រក្សាសិទ្ធិ ញូស្វីក (Newsweek) និង ម៉ាក់គ្លីនតុក និងស្ថានទូត, ១៩៦៣, ១៩៦៥។ល។ និង ។ល។ កាសែតនេះ ខ្ញុំយកជើងជាន់ឈ្លីដោយខ្ពើមបំផុត។ ឧត្តមសេនីយ៍ លន់ នល់, លោកធ្វើតាមខ្ញុំទៅ៖ កាលណាយើងចិត្តត្រង់, មានព្រះជួយ, យើងត្រូវជាន់ឈ្លីជង្គង់ឲ្យកប់ទៅក្នុងដី ! លោកម៉ាក់គ្លីនតុក, ប៉ុណ្ណឹងចុះ, សូម អញ្ជើញចេញទៅវិញ។ ខ្ញុំទុកពេលជូនឲ្យល្មមរៀបចំឥវ៉ាន់ទាន់។*

**ម៉ាក់គ្លីនតុក**

*កម្ពុជានឹងស្តាយខ្លួន យំមិនចេញជាពុំខាន !*

*(គាត់ចេញទៅ ដោយលោកលន់ នល់ដើរតាម)*

**ព្រះសីហនុ**

*អើ ! ធូចិត្តណាស់! តែប៉ុណ្ណេះ ខ្ញុំដើរហួចកណ្តាលក្រុងភ្នំពេញយ៉ាងរីករាយលែងខ្វល់ !*

*(ព្រះអង្គយាងចេញទៅដោយច្រៀងផង។ លោកលន់ នល់ចូលមកវិញ)*

**លន់ នល់**

មិនយូរទេ, កម្ពុជានឹងគ្រាន់តែជាកូនត្រីក្រហមមួយហែលនៅក្នុងកែវកញ្ចក់ដាក់ត្រីរបស់ចិនប៉ុណ្ណោះ។ សម្តេចត្រូវត្រឡប់ទៅរកអាមេរិកវិញ។ ប៉ុន្តែធ្វើម៉េចឲ្យព្រះអង្គស្តាប់? ខ្ញុំអស់ផ្លូវនិងបញ្ចុះបញ្ចូលឲ្យព្រះអង្គគោរពសហរដ្ឋអាមេរិកហើយ ព្រោះព្រះទ័យព្រះអង្គពុះកញ្ជ្រោលពេក។ ឥឡូវនេះ មានតែធ្វើបញ្ច្រាស, គឺបញ្ឆេះភ្លើងកំហឹងរវាងព្រះអង្គនិងពួកកុម្មុយនីស្ត កុំឲ្យរលត់បាន។ កំហឹងនោះខ្ញុំមិនចាំបាច់បង្កើតទាំងស្រុងទេ ព្រោះមានរងើកស្រាប់, រងើកដែលរង់ចាំតែគេផ្លុំ ដើម្បីឆេះសន្ធោសន្ធៅជាអណ្តាតភ្លើង។

មែនហើយ! ខ្ញុំនឹងបង្ករឿងនៅខេត្តបាត់ដំបង, ធ្វើយ៉ាងណាឲ្យ... ឱព្រះអង្គអើយ, កុំឲ្យខ្ញុំបាប។

*(គាត់ដើរចេញទៅ)*

## ចាក ទី២

*(សួនច្បារវាំង។ ទន្លេ។ ព្រះសីហនុយាងចូលមកដោយមាន សម្ដេចប៉ែន នុតមកតាម)*

**ព្រះសីហនុ**

ឆ្នាំកន្លងមកនេះដូចជាសុខសប្បាយណាស់, មែនទេសម្ដេច ?

**សម្ដេចប៉ែន នុត**

ក្រាបទូល, ប្រទ្រូសប្រទ្រះបន្តិច, តែបូកសង់ទៅគឺនិយាយថាសុខសប្បាយបាន។

**ព្រះសីហនុ**

អញ្ជើញមកនេះសម្ដេច, អញ្ជើញមកសំដែងការគោរពដល់ផ្កាយដោគជតាខ្ញុំ។

**សម្ដេចប៉ែន នុត**

ជាការពិត, ដែលអ្វីៗទាំងនៅពេលនេះជាទីត្រេកាលរីករាយ។

**ព្រះសីហនុ**

ខ្ញុំសូមជម្រាបការសម្ងាត់មួយ៖ ខ្ញុំបានឲ្យឈ្មោះផ្សេងៗ ទៅផ្កាយណាដែលខ្ញុំស្រឡាញ់។ នៅពេលយប់ខ្លះ, ពេលដែលអ្នកឯទៀតកំពុងលង់លក់យល់សប្តិនៅក្នុងវាំង, ខ្ញុំចេញទៅក្រៅ ហើយនិយាយទៅរកផ្កាយទាំងនោះ។

ដូចជានោះជាដើម, នៅទីនោះ, ឃើញទេ, ផ្កាយមួយដែលភ្លឺជាងគេហាក់ដូចជាទៀនជ្វាលា, សម្ដេចឃើញទេ?

**សម្ដេចប៉ែន នុត**

ក្រាបទូល, ឃើញ។

**ព្រះសីហនុ**

ខ្ញុំហៅថាម៉ូហ្សា (Mozart) ។ គឺលោក Mozart កាលនៅពីតូច។

ឯផ្កាយមួយនោះទៀត ដែលភ្លឺបភ្លែតដូចជាយំនោះ គឺស្ដេចគំលង់ដែលជាបុព្វការីជនខ្ញុំ។ ឃើញទេ កាលនោះនៅតូចប្រឹមប្រិយដូចគ្នា។ បើមួយនៅជិតនោះវិញ, អន់ភ្លឺបន្តិចនោះ, គឺលោកបណ្ឌិតនេរុ។ ឯមួយនោះវិញ ដែលនៅខាងលិចផ្កាយកូនមាន់, សម្ដេចដឹងថាអ្វីទេ? ខ្ញុំសម្គាល់ឃើញតាំងពីឆ្នាំទៅ, នាយប់មួយនៃខែកញ្ញា ១៩៦៦។ សម្ដេចអាចទាយបានទេ?

### សម្ដេចប៉េន នុត

ឧត្តមសេនីយ៍ ដឺហ្គោល ( De Gaulle) ! យីព្រះតម្រិះនេះសមមែន !

### ព្រះសីហនុ

Charles De Gaulle, មហាមិត្តយ៉ាងសំខាន់!

### សម្ដេចប៉េន នុត

យប់នេះហាក់ដូចជាទេព្ដាឲ្យពរមែន, ហាក់ដូចជាទេពនិករទាំងនោះមកប្រទានពរចម្រើនព្រះជន្ម ព្រះអង្គដូច្នោះ។

*(សម្ដេចប៉េន នុតច្រៀងតបនឹងភ្លេង)*

*“ទេព្ដា, ក្លងផ្កា, ស្នេហា, ស្រស់កញ្ញា!*
*ស្រីប្រុសបណ្ដើរគ្នាត្រសង*
*កុំនៅដំអក់, លោកប្រុស, ទៅមុខ, ទៅមុខ*
*ចូលមកក្នុងព្រៃជ្រៅរបស់ខ្ញុំនេះ*
*លឿនឡើង, លោកប្រុស, កុំយឺតយ៉ាវ*
*ប្រពន្ធសម្លាញ់, នាងអូន, បងមកដល់ហើយ, មែនទេ?*
*អូនឃើញដូចជាបងមកដល់ហើយ”*

*(លោកលន់ នល់ចូលមក)*

### លន់ នល់

សូមទេព្ដាថ្វាយព្រះពរព្រះអង្គឲ្យបានព្រះជន្មមួយរយម្ភៃឆ្នាំ, ប្រកបដោយសម្បត្តិស្ដុកស្ដម្ភ, ជនទូទៅ ស្មោះស្ម័គ្រ, បានសុខក្សេមក្សាន្ត។

**ព្រះសីហនុ**

*មើល! លោកជាអ្នកជំនាញខាងទាយមើលមេឃ, មេឃពេលថ្ងៃខួបខ្ញុំនេះយ៉ាងម៉េចដែរ?*

**លន់ នល់**

*មេឃពេលនេះវិសេសវិសាលណាស់, ក្រាបទូល, មិនខុសពីជោគជតាព្រះអង្គទេ។ ទាស់បន្តិច! ទាស់ត្រង់ពពកមកបាំងក្រុមផ្កាយយាមនក្ខ័ល។ ព្រះអង្គទតឃើញទេ?*

**ព្រះសីហនុ**

*មែន! មែន! មុននេះបន្តិចគ្មានពពកសោះ។ ក្រែងលោលោកនាំមកជាមួយទេដឹង? ហា!!! ហា!!!*

**លន់ នល់**

*ក្រាបទូល, ចិត្តទូលបង្គំចង់ធ្វើម្តេចឲ្យតែយប់ដ៏ត្រកាលនេះ មេឃស្រឡះថែសគ្មានអ្វីបាំង។ ប៉ុន្តែ ទំនាយមេឃពុំសូវដែលខុសទេ។*

**សម្តេចប៉ែន នុត**

*លោកឧត្តមសេនីយ៍ចង់ថាម៉េច?*

**លន់ នល់**

*ខាងលើយ៉ាងម៉េច, ខាងក្រោមអញ្ចឹង, ក្រាបទូល។ ពពកនេះ គឺបង្ហាញពីហេតុការណ៍ដែលកើតឡើងនៅបាត់ដំបង។*

**ព្រះសីហនុ**

*បាត់ដំបង? មានរឿងអីកើតឡើង?*

**លន់ នល់**

*អ្នកស្រុក, ក្រាបទូល, ពួកអ្នកស្រុករាប់រយ។*

**ព្រះសីហនុ**

*ត្រូវគេសម្លាប់?*

លន់ នល់

*ទេ, ទេក្រាបទូល! គឺអ្នកស្រុកនោះវិលខ្យល់ដូចច្កួត ហើយបះបោរ។ ទប់មិនឈ្នះទេ, តាំងពីពីរថ្ងៃមកហើយ, ក្រាបទូល។ នេះមកពីយើងពុំចង់ប្រើធម៌ក្តៅបង្ក្រាប។*

ព្រះសីហនុ

*អ្នកស្រែ? បង្ក្រាបអ្នកស្រែ?*

លន់ នល់

*ទាំងហ្វូងៗ, សាហាវណាស់, កាន់ផ្គាក់កាន់ខ្វែវគ្រប់ដៃ, ២ថ្ងៃហើយដែលសម្រុកមកកណ្តាលក្រុងដូចក្របីព្រៃ, បំផ្លិចបំផ្លាញអ្វីៗឲ្យតែទើសមុខ, ហើយស្រែកព្រះនាមព្រះអង្គផង។*

ព្រះសីហនុ

*អ្នកស្រុកហៅខ្ញុំ?! ម្តេចក៏មិនទទួលគេ, បើគេរកខ្ញុំ?*

លន់ នល់

*ពួកនោះមិនខុសអ្វីពីហ្វូងសត្វសាហាវទេ, ក្រាបទូល, គេនាំគ្នាស្រែកថា៖ "សីហនុលក់ខ្លួន! សីហនុជាចោរ! សីហនុជញ្ជក់ញើសឈាមប្រជាជន!"*

ព្រះសីហនុ

*អ្នកស្រែថាអញ្ចឹង? ទេ, មិនមែនទេ, គឺលោកទេដែលមិនយល់។*

លន់ នល់

*ទេ, ក្រាបទូល, នេះគឺពិត។ អ្នកស្រែជាអ្នកធ្វើដូច្នោះ, ទូលព្រះបង្គំឃើញផ្ទាល់ ហើយបម្រុងទៅនិយាយសួរដើមទង ដូចតែទឹកព្រះទ័យព្រះអង្គដែរ។ តែមិនសម្រេច។ ពួកនោះអារក កាប់ខ្លួនក្រុមរក្សាព្រះអង្គជាកំណាត់អស់១០នាក់!*

ព្រះសីហនុ

*កងរក្សាខ្ញុំ? អ្នកស្រុកកូនចៅខ្ញុំ? ទេ, ទៅមិនរួចទេ, គឺមិនពិតឡើយ!*

### សម្ដេចប៉ែន នុត

អ្នកស្រុកប្រឆាំងនឹងសម្ដេច? គួរឲ្យចួលដែរ, នរណាទៅហ្នឹងដែលជម្រុញពីក្រោយខ្នង!

### លន់ នល់

ព្រះអង្គជ្រាបស្រាប់ហើយថា អ្នកស្រុកស្រឡាញ់ព្រះអង្គដល់ណា។ បើទៅជាយ៉ាងនេះ គឺមានអ្វីមួយធ្វើឲ្យភាន់គំនិតវង្វេងឡប់សតិ។

### ព្រះសីហនុ

វង្វេង! មិនមែនវង្វេងទេ, គឺបាក់ចិត្តជឿ ដូចគេត្រូវស្នេហ៍ហើយបែរជាទៅជាច្កួតដូចឆ្កែវិញ! គឺមកពីពួកខ្មែរក្រហម, មែនទេ?

### លន់ នល់

ព្រះអង្គឈ្វេងយល់ច្បាស់មែន, ក្រាបទូល។ គឺពួកខ្មែរក្រហមនោះឯង, ហើយវាមិនទាំងលាក់លៀមអ្វីផង។ ទូលបង្គំមានភស្តុតាង, មានលិខិតញុះញង់ឲ្យធ្វើភាវកម្មដែលវាចែកឲ្យអ្នកស្រុក។ គ្មានអ្វីគួរចួល់ទេ, គ្រាន់តែចេញមកមើលឃើញភ្លាមថាជារបៀបក្បាច់គុណលោកខៀវ សំផន នោះឯង។

### ព្រះសីហនុ

ជារដ្ឋមន្ត្រីផង! ជាឧទ្ទាមផង! របៀបក្បត់និងលាក់ពុតនេះ ដល់កម្រិតហើយ! ពួកខ្មែរក្រហមនេះអាក្រក់ជាងពួកអាគាំងទៅទៀត។
យី, មនុស្សយើងអាចពោះវៀនបត់ជន្ទាសយ៉ាងនេះហ្ន! ក្រហមហើយ អួតខ្លួនជាខ្មែរទៀត! ខ្មែរអីយ៉ាងអញ្ចឹង?
ទេ, ពួកឧទ្ទាមអស់នេះជាចិនមកពីភពផ្សេងទេ! ឃើញទេសម្ដេចប៉ែន នុត, ដូចខ្ញុំបានថាមែន! ច្រើនអាទិត្យហើយដែលខ្ញុំបារម្ភថាមានអាសន្នរោគឆ្លងមកពីស្រុកចិន។
នៅឯណោះមានពូជសាសន៍ថ្មីមួយទៀតទើបនឹងកើត, តាំងពីមានបដិវត្តដែលគេហៅថា "វប្បធម៌" នោះមក។ តែពួកវាសាហាវ, ព្រៃផ្សៃ, សម្លាប់ម៉ែឪឯង, ហើយជម្ងឺនេះ ឆ្លងអាក្រក់ណាស់, ពួកមនុស្សយន្តនោះស្គាល់តែកំហឹង ហើយយកពាក្យស្លោកផ្សេងៗមករុំពាត់ក្បាលកូនចៅខ្មែរឲ្យស្អប់សម្ដេចឪខ្លួន។

### លន់ នល់

ក្រាបទូល, តាំងពីឲ្យអាមេរិកាំងចេញទៅវិញ, ពួកខាងឆ្វេងស្មានថា...

## ព្រះសីហនុ

*ទេ! ទេ! អស់លោកខ្មែរចិន, កុំស្មានថា សីហនុដេញអាមេរិកាំងដោយសារចង់ងាកមករកខ្លួននោះ, នេះគឺជានយោបាយផ្ទាល់ខ្លួនខ្ញុំ ដើម្បីធ្វើឲ្យស្រុកខ្ញុំបរិសុទ្ធ, មានឯករាជ្យបរិហាទឡើងវិញ, ប្រទេសខ្ញុំបន្តកាន់អព្យាក្រិតរហូត, ប្រកាន់ស, ប្រកាន់រាជានិយម។*

*បើពួកក្ដៅខ្មែរក្រហមចង់ខាំខ្ញុំ គឺច្បាស់ជាត្រូវព្រានង់យ៉ាងដំណំហើយ។ លោកលន់ នល់, លោកជាអ្នកស្មោះត្រង់នឹងខ្ញុំ, សូមប្រញាប់ត្រឡប់ទៅបាត់ដំបងវិញ, ហើយធ្វើឲ្យពួកក្បត់អស់នោះដឹងថា កងយោធពលខេមរភូមិន្ទដឹងច្បាស់ណាស់ថា អ្វីទៅហៅថាភក្ដីភាពចំពោះនយោបាយខ្ញុំ។ សូមអញ្ជើញចុះ!*

## លន់ នល់

*កងទ័ពនឹងបង្ហាញថាគេអង់អាច ហើយស្មោះស្ម័គ្រនឹងព្រះអង្គយ៉ាងណា, ក្រាបទូល, ទូលបង្គំសូមសន្យា។*

## សម្ដេចប៉ែន នុត

*លោកឧត្ដមសេនីយ៍, បើពន្លត់ភ្លើងនោះ, សូមប្រយត្ន័កុំបញ្ឆេះភ្លើងផ្សេងទៀត, ព្រោះវានឹងកាន់តែសន្ធោសន្ធៅលើសនោះទៅទៀត។*

## លន់ នល់

*ទូលបង្គំដឹងថាត្រូវធ្វើអ្វីហើយ, ក្រាបទូល។ មិនមែនលើកទី១ ទេដែលទូលបង្គំធ្វើការបង្ក្រាប។*

## ព្រះសីហនុ

*អញ្ជើញចុះ! អញ្ជើញចុះ! ធ្វើយ៉ាងណាឲ្យ ច្បាប់ជាធំឡើងវិញ, ហើយធ្វើម៉េចឲ្យពួកក្រហមជាកូនចៅប្រធានម៉ៅប្រមុខនាវានោះដឹងថា នឹងធ្ងន់ធ្ងរយ៉ាងណាចំពោះវា ដែលមកបើកនាវានៅកន្លែងខ្ញុំនេះ។*

*(លោកលន់ នល់ចេញទៅ)*

## សម្ដេចប៉ែន នុត

*ក្រាបទូល, ព្រះអង្គមិនគួរមានបន្ទូលថា "ត្រូវព្រានង់យ៉ាងដំណំ" ទេ។ បានតែពាក្យនេះទៅ ឧត្ដមសេនីយ៍លន់ នល់នឹងយកទៅអនុវត្តគ្មានប្រណីឡើយ។ បើកើតឡើងដូច្នោះមែន គឺគ្មានអ្វីឲ្យច្រលំសោះ។*

### ព្រះសីហនុ

បើមិនប្រើព្រនង់ធមិក្ដៅ, គិតឲ្យគាត់បង្ក្រាបនឹងអ្វីទៅ? យកស្ករ, ទឹកឃ្មុំផ្អែមល្ហែមទៅបង្ក្រាប?

### សម្ដេចប៉ែន នុត

ច្បាស់ជានឹងមានស្លាប់ហើយ, ក្រាបទូល។

### ព្រះសីហនុ

សម្ដេច, បើមិនទុកចិត្ត សូមបៀមទុកក្នុងខ្លួនសម្ដេចទៅ, ខ្ញុំមិនចង់ឆ្លងជម្ងឺមិនទុកចិត្តនេះទេ។ មេឃពេលនេះ លែងឃើញមានផ្កាយទៀតហើយ។ កំពុងតែសោមនស្សរីករាយ ស្រាប់តែក្រៀមក្រំខ្លោចផ្សាទៅវិញ។ ឱ! ស្ថានផុតទុក្ខ, ខ្ញុំទៅមិនទាន់ដល់ទេ, សូមលាហើយ! ប្រវត្តិសាស្ត្រចាប់ផ្ដើមពីពេលនេះឯង!

*(ទាំងអស់គ្នាចេញទៅ)*

## ឆាកទី៣

*(លោកហ៊ូយន់និងលោកខៀវសំផនចូលមក)*

### ហ៊ូយន់

*សម្ដេចចោទយើងថាជាអ្នកបង្ករការបះបោរ, ហើយថាយើងជាភ្នាក់ងារចិនផង។ បើបានធ្វើអ្វីដូច្នេះមែន តែបន្តិចក៏អស់ចិត្តដែរ!*

### ខៀវសំផន

មិនមែនអញ្ចឹងទេ។ ការបះបោរនេះជាជ័យជំនះយើងមួយហើយ។

### ហ៊ូយន់

*ជ័យជំនះ! លុះត្រាតែយើងនៅជាមួយអ្នកបះបោរក្នុងពេលនោះ! ប៉ុន្តែយើងនៅឯនេះទេ, នៅក្នុងការិយា-ល័យទៀតផង។ ប៉ុណ្ណឹងហើយ គេយកឈាមប្រជាជនមកលាបប្រឡាក់ខ្លួនយើងទៀត!*

### ខៀវសំផន

*ប្រឡាក់! ម៉េចក៏ប្រឡាក់? ផ្ទុយទៅវិញ ឈាមនេះហើយដែលដង្ហោយហៅយើង។ ចំពោះខ្ញុំ, ថ្ងៃនេះគួរឲ្យរីករាយពន់ពេក, ព្រោះគេឃើញថា សីហនុជាឃាតករ។ មិនដែលគិតថាព្រឹត្តការណ៍បែបនេះអាចកើតយ៉ាងរហ័សដូច្នេះផង។*

*គ្មានអ្វីគួរឲ្យសោកស្ដាយទេ។ គ្រាន់តែថា សាឡុត សរ គាត់នឹងបានឱកាសក្អេងក្អាង។ តែនោះជារឿងបន្ទាប់បន្សំតែប៉ុណ្ណោះ។*

### ហ៊ូយន់

*ស្លាប់មនុស្ស៣០០នាក់!*

### ខៀវសំផន

*នឹងមានស្លាប់តទៅទៀត, ហើយទាំងនោះជាជ័យជំនះរបស់យើង, ព្រោះការកាប់សម្លាប់នោះ គឺបម្រើបុព្វហេតុយើងហើយ, មានអ្វីគួរឲ្យស្ដាយ? ប៉ុណ្ណឹងបានហើយ។ យើងចេញទៅយប់នេះតែម្ដង។ អនាគតចាប់ផ្ដើមចេញដំណើរពីព្រៃទៅ។*

**ហ៊ួ យន់**

ខ្ញុំទៅខាងជើង! តាមបណ្ដោយភ្នំនៅរតនគិរី។ នៅឯណោះខ្ញុំមានប្អូនម្នាក់ព្រមទាំងមិត្តឯទៀតដែលប្រជាជនស្រឡាញ់ចូលចិត្តស្រាប់។

**ខៀវ សំផន**

យើងទៅតែឯងវៀងខ្លួនសិន។ ឆ្នាំក្រោយ, គ្រួសារយើងនឹងទៅតាមយើង។

**ហ៊ួ យន់**

ម៉េចក៏ទៅតែឯង?

**ខៀវ សំផន**

ត្រូវទុកឱ្យប្រពន្ធអស់លោកទៅប្ដឹងមិនឈប់មិនឈរនៅសភានិងនៅវាំង។ ទុកឱ្យប្រពន្ធអស់លោកបង្កើតឱ្យមានការខ្សឹបខ្សៀវថា ប៉ូលីសរបស់សីហនុបានធ្វើឃាតយើង។ ឯយើងវិញ, យើងនឹងសរសេរអត្ថបទសម្រាប់ផ្សាយតាមវិទ្យុប៉េកាំងថា យើងត្រូវគេសម្លាប់ហើយ។ យើងក៏គេចមុខចូលព្រៃបាត់ភ្លាម។

**ហ៊ួ យន់**

លើសពីនោះទៅទៀត គឺលន់ នល់ខ្លួនឯងជឿដំណឹងនោះ...វានឹងភ័យខ្លាចមិនទុកចិត្តសីហនុទៅទៀត...

**ខៀវ សំផន**

វានឹងខ្លាចខ្មោចយើងលង!

**ហ៊ួ យន់**

ចុះម្ដាយបងឯងវិញ, គិតជម្រាបគាត់ថាម៉េច?

**ខៀវ សំផន**

ខ្ញុំមិនឱ្យគាត់ដឹងរឿងអ្វីទេ។ ខ្ញុំនឹងបាត់ខ្លួនដោយគ្មានស្រមោល។

**ហ៊ួយន់**

មិនដឹងគាត់យំស្រែកយ៉ាងណាទេ !

**ខៀវសំផន**

ទុក្ខសោកនឹងរលាយបាត់អស់នៅពេលដែលខ្ញុំបង្ហាញខ្លួនឡើងវិញនៅថ្ងៃណាមួយ។

*(ទាំងពីរអ្នកចេញទៅ)*

# ឆាកទី៤

*(ព្រៃនគរ។ លោកគីសីងហ្គ័រ និងឧត្តមសេនីយ៍អាប្រាមស៍ចូលមក)*

*(គេឮសម្លេងយន្តហោះ)*

**គីសីងហ្គ័រ**

ខ្ញុំមិនមែនមកព្រៃនគរនេះដើម្បីស្មានមើលសើៗទេ, គឺដើម្បីពិនិត្យឲ្យដាក់ច្បាស់, ថ្លឹងថ្លែងហើយសម្រេចចិត្ត។ លោកប្រធានាធិបតី និចសុន ចង់ឲ្យបញ្ចប់រឿងវៀតណាមនៅឆ្នាំនេះ។ មើល! លោកចង់ឲ្យខ្ញុំធ្វើ អ្វី? ឧត្តមសេនីយ៍អាប្រាមស៍, តើលោកចង់ឲ្យខ្ញុំធ្វើអ្វី?

**អាប្រាមស៍**

យោបល់ខ្ញុំ? លោកទីប្រឹក្សាសួរយោបល់ខ្ញុំ?
ខ្ញុំយល់ថាបើយាត់ខ្ញុំមិនឲ្យបោសសំអាតឲ្យជ្រះស្រឡះភាគខាងជើងនិងខាងកើតនៃកម្ពុជាទេ ខ្ញុំនឹងបោះបង់វៀតណាមចោល, ហើយខ្ញុំលាលែងពីតំណែង។ សូមលោកប្រឹក្សាជ្រាប, អ្វីៗទាំងអស់កើតឡើងនៅកម្ពុជា នោះឯង។ នៅឯណោះឯងហើយ ដែលយួនឧទ្ទាមជ្រកកោនលាក់ខ្លួន, ហើយដាក់ទីបញ្ជាការធំរបស់វា។ មកទល់ពេលនេះ គឺយើងបាចទឹកឲ្យអស់ពីសមុទ្រមួយ ដោយយកកូនស្លាបព្រាដួស។ ខ្ញុំមិនលេងល្បែងនេះទៀតទេ, ធុញណាស់!
ខ្ញុំចង់ទម្លាក់គ្រាប់បែកនៅត្រង់នេះ, ត្រង់នេះនិង ត្រង់នេះ។ មានអ្វីនឹងពិបាកគិត?

**គីសីងហ្គ័រ**

ចុះអំពីរឿងអព្យាក្រិតវិញ, លោកឧត្តមសេនីយ៍យល់យ៉ាងម៉េចដែរ?

**អាប្រាមស៍**

គ្មានមនុស្សណាសូម្បីតែម្នាក់ដែលជឿរឿងប្រកាសអព្យាក្រិតនោះទេ? ខ្ញុំនិយាយនេះដដែលៗច្រើនឆ្នាំមកហើយ។ សីហនុលក់ខ្លួនឲ្យកងទ័ពក្រហមពេញទី, លោកទីប្រឹក្សា។ កម្ពុជានិងវៀតណាមនោះតែមួយទេ។ ឯវៀតណាមនិងរុស្ស៊ីក៏តែមួយដែរ។ ដូច្នេះហើយលោកចាំអ្វីទៀត? យន្តហោះចម្បាំងខ្ញុំវាឈឺពោះ, មិនខុសពីមេគោដែលឈឺពោះជិតកើតកូនឡើយ។ ឥឡូវចាំអីទៀត?

**គីសីងហ្គ័រ**

ចាំស្តាប់យោបល់រដ្ឋមន្ត្រីការពារជាតិយើងសិន។ គាត់មកពីភ្នំពេញវិញថ្ងៃនេះឯង។

**អាប្រាមស៍**

លោកម៉ែលវីន លែរដ៍ ជាជនស៊ីវិល, សូមលោកទីប្រឹក្សាកុំភ្លេច។

**គីស៊ីងហ្គ័រ**

លោកអាប្រាមស៍, ខ្ញុំក៏ជាស៊ីវិល! ហើយទុកចិត្តខ្ញុំចុះ, ខ្ញុំចេះមើលផែនទីដែរ។ លើផែនទីនោះ យើងយកចិត្តទុកដាក់យ៉ាងខ្លាំងលើកម្ពុជា។ លោកគង់នឹងឃើញទេ។

ទៅអញ្ជើញលោករដ្ឋមន្ត្រីក្រសួងការពារជាតិចូលមក។

*(លោកម៉ែលវីន លែរដ៍ចូលមក)*

**គីស៊ីងហ្គ័រ**

ម៉េចទៅ, លោកលែរដ៍? លោកបានជួបព្រះអង្គម្ចាស់ដែលប្រែប្រួលរកស្ថានមិនត្រូវនោះហើយ, មែន ទេ? លើកនេះ, ចិត្តនោះស្ងប់ឬកញ្ជ្រោល?

**លែរដ៍**

ខ្ញុំឃើញថាព្រះអង្គម្ចាស់នោះជាមនុស្សនឹងន, និយាយស្ដាប់គ្នាបាន។ ព្រះអង្គយល់ថា ពួកកម្មុយនិស្តអាស៊ីមិនទុកឲ្យលោក នៅអព្យាក្រិតបានយូរទៀតទេ ហើយលោកត្រៀមខ្លួនភ្ជាប់ចំណងទាក់ទងជាមួយវ៉ាស៊ីនតោនឡើងវិញ, ក្នុងលក្ខខណ្ឌដែលសហរដ្ឋអាមេរិកទទួលស្គាល់ព្រំដែនកម្ពុជាថាមិនអាចរំលោភបាន។

**គីស៊ីងហ្គ័រ**

លោកយល់ថាគួរយើងធ្វើអ្វី?

**លែរដ៍**

រៀបចំដាក់ទូតឡើងវិញជាមួយប្រទេសតូចនេះ ដែលទោះជាយ៉ាងណាក៏គ្មានបំណងនឹងងាកទៅផ្អែកលើប៉េកាំងឬសហភាពសូវៀតដែរ។ ធ្វើដូច្នោះរួចហើយ អ្វីៗទៀតនឹងងាយយល់។ ជម្ងឺនោះមិនរាតត្បាតវែងឆ្ងាយខ្លាំងទេ, ព្រោះខ្ញុំជឿជាក់ថា ពួកកម្មុយនីស្តខ្មែរមិនលើសពីពាន់ឬ៤ពាន់ឡើយ។

**គីស៊ីងហ្គ័រ**

យ៉ាងម៉េច? ខ្មែរក្រហម? នេះមិនមែនជារឿងរបស់យើងទេ! រឿងដែលយើងខ្វាល់ខ្វាយគឺយួន។ កម្មុយនីស្តយួនមានប៉ុន្មាននៅស្រុកខ្មែរ? រាប់សែន?

### អាប្រាមស៍

យ៉ាងតិច ១សែននាក់។

### ល៉ែវដឺ

មិនមែនទេ, ប្រហែល១ម៉ឺនប៉ុណ្ណោះ។ ជឿខ្ញុំចុះ, គាំទ្រសីហនុទើបមានប្រយោជន៏។ ព្រះអង្គមានគុណវិបត្តិអ្វីគ្រប់បែបយ៉ាង តែព្រះអង្គជាអ្នកកាន់ពុទ្ធសាសនា។ ដូច្នេះព្រះអង្គគ្មានហេតុផលណាមួយនឹងទុកចិត្តយួនឡើយ។ កាលដែលមានបះបោរនៅបាត់ដំបងនោះ ព្រះអង្គបានបង្ហាញជំហររឹងមាំគ្មានរង្កើ។ ម្យ៉ាងទៀត ប្រជារាស្ត្រស្រឡាញ់ព្រះអង្គដោយស្មោះ។ ព្រះអង្គជាកំពែងយ៉ាងរឹងមាំសម្រាប់យើង, មិនឲ្យពួកយួនចូលមកក្នុងស្រុកបាន។

### គីស៊ីងហ្គ័រ

យើងមិនមែនជជែកគ្នារឿងមនោសញ្ចេតនាទេ, គឺនិយាយអំពីយុទ្ធសាស្ត្រ។ ហើយត្រូវធ្វើឲ្យសីហនុបារម្ភខ្លាច មិនមែនធ្វើឲ្យបានចិត្តថាយើងគាំទ្រទេ។ យើងទទួលស្គាល់ព្រំដែននោះ តែយើងនៅតែមិនទុកចិត្តគាត់ដដែល។ បើគាត់ដោះស្រាយជាមួយវៀតណាម រឿងចូលមកទឹកដីគាត់មិនរួចទេ យើងនឹងសម្រុកចូលទៅជួយមួយដៃមួយជើង។ ឲ្យតែគាត់ធ្មេចភ្នែកកុំឃើញអីទៅបានហើយ។
លោកឧត្តមសេនីយ៍, ប្រតិបត្តិការណ៍សំអាតទល់ដែនដែលលោកដឹកនាំនោះ, បរាជ័យមែនទេ

### អាប្រាមស៍

មិនបរាជ័យទាំងស្រុងទេ តែ...

### គីស៊ីងហ្គ័រ

ទេគឺទាំងស្រុង, តែក៏ពុំមែនខុសមកពីលោកដែរ, គឺលោកគ្មានមធ្យោបាយគ្រប់គ្រាន់។
មធ្យោបាយនោះ យើងនឹងជូនលោក !

### ល៉ែវដឺ

មានន័យថាម៉េច ? លោកបម្រុងធ្វើអី ?

**គីសីងហ្គ័រ**

កម្ចាត់មេរោគ, លោកអាប្រាមស៍ នឹងទម្លាក់គ្រាប់បែកនៅតាមទល់ដែនដែលមានមេរោគនោះ។

**លែរដឺ**

ទម្លាក់គ្រាប់បែកនៅកម្ពុជា?

**គីសីងហ្គ័រ**

ទម្លាក់តែត្រង់ណាដែលយួនជ្រកចាក់ឫសនៅប៉ុណ្ណោះ, មែនទេ លោកឧត្តមសេនីយ៍?

**លែរដឺ**

ប៉ុន្តែជម្រកទាំងប៉ុន្មាននោះសុទ្ធតែជាតំបន់មានអ្នកស្រុករស់នៅ!

**អាប្រាមស៍**

លោករដ្ឋមន្ត្រី, យើងនឹងប៉ះពាល់តែកន្លែងណាដែលស្ថិតនៅយ៉ាងតិច ១គ.ម. ពីភូមិអ្នកស្រុក។

**គីសីងហ្គ័រ**

បើត្រូវធ្វើហើយ, ធ្វើទៅ! ខ្ញុំមិនចូលចិត្តសូញសាញទេ។

**លែរដឺ**

ជីវិតជនស៊ីវិល, កុំភ្លេច, លោកទីប្រឹក្សា, ជនស៊ីវិល!
យើងនិយាយមិនចូលគ្នាសោះ, លោកទីប្រឹក្សា។ ខ្ញុំនិយាយពីជីវិតជនស៊ីវិល, ស្លូតត្រង់, ..ពីជីវិតមនុស្ស។

**គីសីងហ្គ័រ**

ត្រូវចេះធ្វើពលិកម្មខ្លះ។ សម័យយើងនេះត្រូវទទួលស្គាល់ថា មានរឿងខ្លះដែលមានវិនាសកម្មជៀសមិនរួច។ សំខាន់គឺជ័យជំនះនៃលោកសេរី។

**លែរដឺ**

ខ្ញុំក៏គិតអញ្ចឹងដែរ, ដូចតែគ្នាទេ។
ចុះបើសម្តេចសីហនុស្រែកប្រឆាំង, គិតយ៉ាងម៉េច?

**គីសីងហ្គ័រ**

យើងនឹងទទួលយកពាក្យប្រចាំងនោះ។

**ឡែរដឺ**

ប៉ុន្តែសភាយើងនឹងស្រែក។

**គីសីងហ្គ័រ**

ស្រែក? ទេ, គ្មានទេ។ យើងចាំបាច់អីផ្សាយដំណឹងទៅសាធារណជនពីប្រតិបត្តិការដ៏លំបាកហើយសំខាន់យ៉ាងនេះ? កាតព្វកិច្ចទៅជាតិយើង គឺជ័យជំនះចុងក្រោយ។

**ឡែរដឺ**

មិនអាចធ្វើអ្វីតាមចិត្តទេ, លោក។ ប្រទេសយើងមានច្បាប់, មានសភា។ នេះជារឿងសីលធម៌ទៀតផង។

**គីសីងហ្គ័រ**

ត្រូវហើយកម្មុយនីស្តក៏មានដែរ ជុំវិញខ្លួនយើងនេះ។ មានអ្វីៗទៀត ដូចជាជម្រុំគុកផ្ដុំមនុស្ស, ដូចជាប្រទេសចិន, ដូចជាមនុស្សចិន។ មានពួករុស្ស៊ី, មានពួកសូវៀត, មានចក្រពត្តិដែលគម្រាមពិភពលោកយ៉ាងសាហាវ!

**ឡែរដឺ**

ខ្ញុំប្រចាំងនឹងការបិទដំណឹងរឿងទម្លាក់គ្រាប់បែកនៅកម្ពុជាមិនឲ្យសភាដឹងនោះ, សូមជ្រាប!

**គីសីងហ្គ័រ**

បាទ! ខ្ញុំឮហើយ!

**ឡែរដឺ**

ខ្ញុំសូមឲ្យកត់ត្រាពាក្យប្រចាំងរបស់ខ្ញុំ ហើយទុកតម្កល់នៅទីណាមួយដែលមិនបាត់, សម្រាប់យកមកផ្សព្វផ្សាយនៅថ្ងៃណាមួយ។

**គីសីងហ្គ័រ**

ទុកពេលឱ្យយើងបាន១ខែ២ដែរឬអត់?

**លែរដឺ**

ខ្ញុំខ្មាសខ្លួនឯងណាស់ដែលកើតមករួមជាតិជាមួយលោកដូច្នេះ។

**គីសីងហ្គ័រ**

បើអញ្ចឹង ទៅនៅប្រទេសផ្សេងទៅ ! ណ្ហើយប៉ុណ្ណេះចុះ, មក, លោកឧត្តមសេនីយ៍។

*(លោកគីសីងហ្គ័រ និងអាប្រាមស៍ចេញទៅ)*

**លែរដឺ**

គិតចុះគិតឡើងទៅ, មិនដឹងថាខ្ញុំគិតត្រូវឬខុស ?
អ្វីដែលខ្ញុំយល់ថាជាលាមក, គេថាជាផ្កា។
ខ្ញុំឬគាត់, តាមពិតទៅ, ដែលបម្រើរដ្ឋយើង ?
ខ្ញុំ ដែលតែងតែថ្លឹងថ្លែងរកខុសត្រូវមិនឈប់ឈរ ? ឬមួយគាត់ដែលបោះជំហានទៅមុខដោយមិនរវែង, រហូតទៅនៅពីលើច្បាប់ទៀតនោះ ?
គួរខ្ញុំលាពីតំណែងឬយ៉ាងណា ?
ឯកោដូចខ្ញុំនេះ ធ្វើឱ្យខ្សោយសន្ទុះចិត្ត, សូម្បីតែការពិចារណារកខុសត្រូវក៏ខ្សោយដែរ !

*(គាត់ដើរចេញទៅ)*

## ឆាកទី៥

*(ព្រះមហាក្សត្រីយានីកុសុមៈយាងមកដោយមានសម្តេចប៉ែន នុត មកតាម)*

**ព្រះកុសុមៈ**

សម្តេច ! លោកបោះបង់យើងចោលឬយ៉ាងណា ?
ម្តេចក៏សម្តេចមានជម្ងឺពេលដែលប្រទេសយើងកំពុងរងទុក្ខគ្រប់បែបយ៉ាងដូច្នេះ ?

**សម្តេចប៉ែន នុត**

ព្រះករុណាថ្លៃវិសេស, មានព្រះពុទ្ធអង្គព្រមទាំងព្រះសពព្រះមហាកញ្ចនកោដ្ឋជាសាក្សី, កាលដែលទូលព្រះបង្គំចាប់ផ្តើមចុះខ្សោយរាងកាយ, ញ័រដៃ, ដាក់បាយខុសមាត់ទៅហើយនោះ ទូលព្រះបង្គំនៅតែប្រឹងប្រែងទ្រដែនដីប្រទេសយើងទាំងញ័រ ! ពេលព្រះរាជបុត្រព្រះអង្គយាងទៅក្រៅស្រុក ទូលព្រះបង្គំនិយាយមិនឈប់មិនឈរទៅជម្ងឺថា "កុំទាន់មកឲ្យឈឺ, ចាំសម្តេចយាងមកវិញសិន"។
សូមព្រះករុណាថ្លៃវិសេសកុំប្រកាន់ទូលព្រះបង្គំដែលខ្សោយរាងកាយយ៉ាងនេះ។ ថ្ងៃនេះ ខ្សោយមែនទែន, ដែលជាសញ្ញាថាសម្តេចយាងមកដល់វិញបន្តិចទៀតនេះឯង។

**ព្រះកុសុមៈ**

ដែលខ្ញុំបារម្ភជ្រុងទៀតនោះ គឺហោរបានទាយប្រាប់ខ្ញុំថា សម្តេចនឹងត្រូវឈឺ, ប៉ុន្តែ មិនមែនភ្លាមពេលនេះទេ, គឺទាល់តែដល់ខែប្រាំងខាងមុខ។ បើហោរនោះទស្សន៍ទាយមិនច្រឡំទេ, មានតែជោគជតារាសីយើងបោះបង់យើងចោល។

*(អ្នកបម្រើម្នាក់ចូលមក)*

**អ្នកបម្រើ**

ព្រះករុណាថ្លៃវិសេស, សម្តេចយាងមកដល់ហើយ។

**ព្រះកុសុមៈ**

សូមសម្តេចជួយទូលយោបល់ល្អៗទៅកូនខ្ញុំផង, បើមិនដូច្នោះទេ គឺងប់ទៅរកយួនហើយ។

**សម្ដេចប៉ែន នុត**

ក្រាបទូល, មិនងប់ទេ, គឺព្រះអង្គស្រឡាញ់គេដោយថ្លឹងថ្លែង, មិនខ្លាំងពេក, មិនតិចពេក។

*(ព្រះសីហនុយាងចូលមក)*

**ព្រះសីហនុ**

*មែន, សម្ដេច! លោកពិតជាឈឺមែន។ ខ្ញុំមិនច្ចល់ទេ! ឆ្នាំ១៩៦៩ នេះនាំមកនូវតែឧបសគ្គ និងព្យុះសង្ឃរា។ ពួកបក្សខាងស្ដាំប្រឹងធ្វើឲ្យសភាវង្គោះរង្គើ, ឯពួកខាងឆ្វេងវិញគិតតែពីវិទ្ធង្សនា។ មុននឹងចូលមកនេះបន្តិច ខ្ញុំនឹកដួចថា "ច្បាស់ជាមាននរណាមានជម្ងឺបៀតបៀនហើយ, ឯអ្នកឈឺនោះមិនអាចជាសិរិមតៈទេ!" ។ ឃើញថា ដូច្នេះមែន! ឥឡូវនេះ ខ្ញុំឃើញប្រផ្នូលច្បាស់នឹងភ្នែកថា ពួកយួនដើរកាត់មុខខ្ញុំ ដោយកណ្ដៀតកម្ពុជារបស់ខ្ញុំនៅក្រោមក្លៀកទៅជាមួយផង។*

**ព្រះកុសុមៈ**

*ឱ! ឥឡូវកូនឯងយល់ខុសត្រូវវិញហើយ, មែនទេ?*

**ព្រះសីហនុ**

*រឿងកើតឡើងថ្មីៗ គឺដូច្នេះ៖ ២អាទិត្យមុននេះ ខ្ញុំទៅត្រួតពិនិត្យតាមទល់ដែនជាមួយកងពលដ៏អង់អាចរបស់យើង។ ខ្ញុំស្លៀកពាក់ឯកសណ្ឋាននិងស្បែកជើង ដែលខ្ញុំឲ្យគេកាត់នៅប៉ារីស៍ សម្រាប់ដើរព្រៃកន្លែងលំបាកលំបិន។ គ្មានអ្វីស្រួលទេ, ទឹកគឺមានតែទឹកត្រពាំង ជីកករយកមកទទួលទាន, ទៅរហូតដល់រតនគីរីស្រាប់តែឃើញថាជាទីរហោស្ថានទៅវិញ។*

**ព្រះកុសុមៈ**

*រហោស្ថាន?*

**សម្ដេចប៉ែន នុត**

*សម្លាប់រង្គៀល?*

**ព្រះសីហនុ**

*ទេ, មិនមែនទេ! គឺមនុស្សរត់ចេញអស់! នេះជាឧក្រិដ្ឋកម្មប្រឆាំងមាតុភូមិ។ ខ្ញុំចូលទៅក្នុងផ្ទះអ្នកស្រុក ដោយនឹកថាគេរៀបចំឲ្យស្អាតបាតដើម្បីទទួលខ្ញុំដូចសព្វដង, ឧទាហរណ៍មានបាច់ផ្កានៅពីក្រោមរូបថត*

ខ្ញុំដែលមានមុខស្រស់ញញឹម។ មិនអញ្ចឹង, ទៅជាឃើញរូបកញ្ចាស់ហូជីមិញសំញ៉ែញមុខ ដាក់ខ្ញុំ, កន្លែងណាក៏មានរូបតាហូដែរ! យូរៗ ទៅ មិនទុកចិត្តខ្លួនឯង, ក្រែងលោនៅក្នុងទឹកដីវៀតណាមទៅទៀត! ពួកអ្នកក្អឹលូង់ខ្វៅទាំង នោះ ជឿគេឃោសនាថាខ្លួនមិនមែនជាកូនចៅសីហនុទេ, តែជាកូនចៅតាពុកមាត់រ៉ុយៗ នោះ។ ខ្ញុំក្តៅចិត្ត ណាស់, ហើយក៏បន្តដំណើរទៅបរកែវ, ទៅដល់នោះក៏ដូចគ្នាដែរ, ខ្ញុំចង់រកមុខអ្នកដើមភ្លើង, គេក៏យកខិត្តប័ណ្ណ ទាំងបាច់ៗ មកបង្ហាញ, គឺខិត្តប័ណ្ណដែលពួកអាខ្មែរកញ្ចះចិនវាទុកនៅកន្លែងនោះ។ ក្នុងនោះវាសំអុយខ្ញុំថាជាឃាតករ, ជាជនក្បត់, ហើយពួកកម្មុយនីស្តនោះ វាអំពាវនាវឲ្យអ្នកស្រុកដើរចោលខ្ញុំ។

## សម្តេចប៉ែន នុត

មេរោគវាជ្រៀតជ្រែកចូលមកក្នុងសរីរាង្គទូលព្រះបង្គំ, ឯចិននិងយួនក៏ជ្រៀតជ្រែកក្បាលចូលសាច់ឈាមប្រទេសយើងដែរ។

## ព្រះសីហនុ

ខ្ញុំមកពីតំបន់នេះវិញ ក្តុកចិត្តស្ទើនឹងស្លាប់, អស់អ្វីៗ រលីងពីខ្លួន, គ្មានសល់អ្វីទៀតទេ, ដង្ហើមស្ទើរផុត, មកដល់នេះ ឃើញថា វាសនាចក់យកសម្តេចពីខ្ញុំទៅទៀត។

## សម្តេចប៉ែន នុត

ក្រាបទូល, ទូលព្រះបង្គំមានទាន់ស្លាប់ឯណា?

## ព្រះសីហនុ

អញ្ចឹងមែន។ សម្តេចនៅរស់, ខ្ញុំក៏នៅរស់, មិនទាន់អស់ផ្លូវនៅឡើយទេ។

## ព្រះកុសុមៈ

កូនគិតតែងតាំងនរណាជំនួសសម្តេចដែលជាអ្នកស្មោះត្រង់នេះ?

## ព្រះសីហនុ

ហ៊ឺ! គិតចុះគិតឡើងទៅ ដូចជាគ្មានឃើញនរណាក្រៅពីលន់ នល់។

**ព្រះកុសុមៈ**

គួរតែងតាំងលន់ នល់ ត្រឹមតែឧបនាយករដ្ឋមន្ត្រីបានហើយទេដឹង?

**ព្រះសីហនុ**

ហ្លួងម៉ែទាស់ចិត្ត លន់ នល់ រឿងអី? គាត់គោរពកោតខ្លាចហ្លួងម៉ែណាស់!

**ព្រះកុសុមៈ**

លន់ នល់ បើគេឲ្យអ្វីគាត់មិនយកទេ, បើគេមិនឲ្យទើបយក។ បើនិយាយអ្វីវិញ ម៉ែមិន ដែលពួមតិ ខ្លួនផ្ទាល់, គឺពូតែការបំពងសម្លេងពាក្យពេចន៏កូនៗ មនុស្សហ្នឹងចេះនិយាយឬអត់, ឬគ្រាន់តែជាខ្មោចចាប់ជាតិទេ ឬអី?

**សម្តេចប៉េន នុត**

ក្រាបទូល, នេះគឺមកពីគាត់ប្រយត្ន័ប្រយែងកុំឲ្យខុស។ គាត់ស្គាល់គេឯងគ្រប់គ្នា ហើយមិនដែលឈ្លោះជាមួយនរណាទាំងអស់។

**ព្រះសីហនុ**

ណ្ហើយ, អញ្ចឹងទៅចុះ, ខ្ញុំនឹងតែងតាំងលន់ នល់ ជារដ្ឋមន្ត្រីទី១។
ចន្លោះពេលនេះ ទៅដល់សម្តេចជាស្រួលបួលឡើងវិញ ខ្ញុំត្រូវអត់ធ្មត់, តែលាក់ល្បិចខ្លះដង។
តើខ្ញុំត្រូវធ្វើអ្វី?

**សម្តេចប៉េន នុត**

ក្រាបទូល, ព្រះអង្គត្រូវការយោបល់ទូលបង្គំមែនឬអី?
យោបល់ទូលបង្គំគឺ៖ ព្រះអង្គកំពុងឃ្វាលបណ្តើរក្របីមួយហ្វូង។ សូមព្រះអង្គកុំហិចហើរខ្ពស់ហួសពីស្នែងពួក វានោះពេក, កុំធ្វើដូច ប្រវឹក។ជំហានព្រះអង្គត្រូវស្មើនឹងជំហានហ្វូងនោះ, បើលឿនពេក ពិតជាព្រះអង្គដាច់គេតែឯង។ តែដាច់ឆ្ងាយពេក, គេតាមមិនទាន់, ច្បាស់ជាចង់ឲ្យព្រះអង្គដួលផ្កាប់មុខហើយ។ សូមព្រះអង្គបន្ថយល្បឿន ហើយម្តងៗ ត្រូវងាកក្រោយផង, ធ្វើយ៉ាងណាឲ្យគេនៅមើលឃើញព្រះអង្គ។ បើមិនដូច្នោះទេ គឺព្រះអង្គយាងចូលដល់អនាគតតែម្នាក់ឯង ពេលដែលហ្វូងនោះដើរហុយដីក្នុងអតីតកាល។ ព្រះអង្គស្តាប់ទូលបង្គំដែរឬអត់? !

**ព្រះសីហនុ**

សម្តេចថា ហ្លួងក្របីនោះដើរឈូសហុយធូលីអតីតកាល, ខ្ញុំជឿថាអញ្ចឹងមែន, ដូច្នេះខ្ញុំនឹងបង្ខំឲ្យដើរឲ្យលឿន។

*(ទ្រង់សិរិមតៈចូលមក)*

ម្ចាស់បងយាងមកស្តាប់ដំណឹង, មែនទេ?

**សិរិមតៈ**

ទេ, បងនាំដំណឹងមកឯណោះ, ហើយជាដំណឹងល្អផង, កញ្ចាស់ហ្វូជីមិញទើបនឹងចែកស្ថានទៅហើយ, គួរឲ្យភ្ញាក់ផ្អើលដែរ។

**ព្រះសីហនុ**

ឱ! តាហ្វូ ដកថយខ្លួនហើយ! ស្តាយមែន! ខ្ញុំធ្លាប់សង្ឃឹមថានឹងបានមកជួបពេលណាមួយ។ ពិតហើយថាគាត់នោះ មិនសូវគោរពព្រះរាជាណាចក្រកម្ពុជាទេ, ប៉ុន្តែយ៉ាងណាក៏គាត់ជាមនុស្សពិសេសខុសគេដែរ សត្រូវមែន, តែជាសត្រូវគួរឲ្យគោរព។ នេះគឺវាសនាចារមកថា ខ្ញុំជួបគាត់នៅពេលដែលគាត់ស្លាប់ជាខ្មោចទៅហើយ។

**ព្រះកុសុមៈ**

យ៉ាងម៉េច, ជួបខ្មោចដែលស្លាប់ទៅហើយ?

**ព្រះសីហនុ**

កូនឡើងយន្តហោះទៅហាណូយស្អែកនេះហើយ! តាមរយៈកូន, ប្រទេសកម្ពុជាទាំងមូលទៅគោរពវិញ្ញាណក្ខន្ធមេកន្ទ្រាញនោះ។

**ទ្រង់សិរិមតៈ**

ក្នុងនាមព្រះញាតិវង្ស, បងប្រឆាំងនឹងការអះអាងនេះ ដែលប្អូននាំប្រទេសកម្ពុជាទៅគោរពសពអ្នកឈ្លានពានយើង។

### ព្រះសីហនុ

គុណបំណាច់របស់ម្ចាស់បងមករាជាធិបតេយ្យមានស្ដួចស្ដើងណាស់ ដូច្នេះយោបល់ម្ចាស់បង ក៏ពុំមានទម្ងន់ប៉ុន្មានដែរ។ គាត់ជាវីរបុរស, ជាជនប្រាជ្ញាចេឹត, ជាមនុស្សពិតប្រាកដ។
ខ្ញុំនឹងទៅហាណូយជាមួយអ្នកម្នាងប្រពន្ធខ្ញុំ។
ទោះជាបងប្អូនដីដូនមួយទាំងប៉ុន្មានធ្វើមុខយ៉ាងម៉េចក៏ដោយ, ព្រះរាជាត្រូវតែបង្ហាញមរណៈទុក្ខនៅវៀតណាម, ព្រោះអ្នកដឹកនាំគេនោះបាននាំមកនូវកិត្តិយសខ្ពង់ខ្ពស់ មកឲ្យអាស៊ីទាំងមូល។ ខ្ញុំជាអ្នកទៅបង្ហាញ មរណៈទុក្ខនោះ។

### សម្ដេចប៉ែន នុត

ព្រះករុណាថ្លៃវិសេស, កុំស្ដេចយាងទៅអី! អាទិត្យនេះមិនមែនជាពេលល្អទេ។

### ព្រះកុសុមៈ

បើចចេស គេឯងនឹងយល់ថា កូនលំអៀង, លែងអព្យាក្រិតហើយ។ ឲ្យនរណាម្នាក់ទៅតំណាងវិញ។

### ព្រះសីហនុ

គ្មាននរណាអាចតំណាងបានទេ! សីហនុជាមនុស្សដែលគេជំនួសមិនបាន។ បើរវល់តែខ្លាចគេគិតថាដូច្នេះថាដូច្នោះ គឺកូនមិនបាច់ដើរពីកៅអីទេ, នៅអង្គុយផ្អែករហូត។ នរណាថាម៉េចក៏ថាចុះ, ខ្ញុំទៅហាណូយ, នេះជាការសម្រេចចិត្តដែលខ្ញុំធ្វើដោយរីករាយ។

### ទ្រង់សិរិមតៈ

*(និយាយទៅទស្សនិកជន)*

ខ្ញុំក៏ដូចគ្នាដែរ។ ខ្ញុំនឹងកាឡាខ្លួនទៅជាយន្តហោះកន្ទុំរុយ ដើម្បីយកឯងយ៉ាងលឿនឲ្យឆ្ងាយពីនេះទៅរកអន្តរាយ។ សិរិមតៈ! ធ្វើយ៉ាងណាកុំឲ្យភ្លាត់។

*(បែរទៅព្រះសីហនុ)*

បងសូមប្រកាសក្ដែងៗថា បងជំទាស់នឹងដំណើរនេះ ដោយបងចាត់ទុកថាជាការក្បត់ជាតិ។

**ព្រះសីហនុ**

មានបន្ទូលយ៉ាងនេះ គឺរឹតតែជម្រុញខ្ញុំថែមទៀត។ អ្វីដែលទ្រង់សិរិមតៈមិនចូលចិត្ត គឺត្រូវចិត្តសីហនុពេញទី!

**សម្ដេចប៉ែន នុត**

ប៉ុន្តែ ប៉ែន នុតជាទីទុកចិត្តរបស់ព្រះអង្គ ហើយដែលកុំពុងទ្រុឌទ្រោមនេះក៏មិនចូលចិត្តដែរ, ក្រាបទូល។

**ព្រះសីហនុ**

ខ្ញុំត្រូវទៅហាណូយ។ សម្ដេចត្រូវទៅពេទ្យ។ រឿងរបៀបនេះមិនត្រូវគិតវែងឆ្ងាយពេកទេ។

*(ព្រះសីហនុយាងចេញ)*

*(ព្រះមហាក្សត្រីយានីយាងចេញដោយមានសម្ដេចប៉ែន នុត ទៅតាម)*

**ទ្រង់សិរិមតៈ**

ល្អហើយ, ព្រះអង្គម្ចាស់ស្វា, ពេលឯងធ្វើដំណើរទៅឆ្ងាយពីម្កុដហើយ, ម្កុដនេះ នឹងហោះ មកទុំនៅលើព្រះកេសអ្នកដែលជាស្ដេចពិតប្រាកដ ។

*(ទ្រង់ដើរចេញ)*

# ឈុតទី៣

## ឆាកទី១

*(ក្រុងប៉ារីស៍។ ស្ថានទូតខ្មែរ។ ព្រះសីហនុយាងចូលមក)*

**ព្រះសីហនុ**

- ដោយយល់ឃើញថា សភាអ្នកតំណាងរាស្ត្រខាងស្តាំជុតលេខបញ្ចេញក្លិនស្អុយទ្រាំមិនបាន, ស្អុយជាងខ្មោចដីវិសារទៅទៀត ហើយធ្វើឲ្យក្រុងភ្នំពេញអសោចចូលទៅជិតមិនបាន,
- ដោយយល់ឃើញថា អ្នកអន្ទ្រើស។ ដែលបំបែកសភានោះមានទំនោរខ្លាំងទៅរកសិរិមតៈជាសត្រូវធំរបស់ខ្ញុំ, មិនខុសពីកំទេចដែកដែលរត់ត្របាញ់គ្នាទៅរកមេដែក,
- ដោយយល់ឃើញថាកម្មុយនីស្តយួន, ថ្វីត្បិតតែបានសន្យានឹងខ្ញុំនៅមុខសាកសព អ៊ុំហូជា មិនបញ្ជូនយៀកមិញ និងយៀកកុងឲ្យមករុករានរាងកាយខ្ញុំ, តែតាមពិតនៅតែធ្វើបែបនេះដដែលនាខែមិនា ១៩៧០នេះ,
- ដោយយល់ឃើញថា មិត្តចិនរបស់ខ្ញុំបណ្តែតបណ្តោយធ្មេចភ្នែកឲ្យខ្មែរក្រហមធ្វើអ្វីតាមចិត្ត,
- ដោយយល់ឃើញថា ក្រៅអំពីសម្តេចប៉ែន នុតជាមហាមិត្តខ្ញុំ, គឺគ្មាននរណាម្នាក់ដែលយល់ថាមិនមែនលុយ។។នោះទេ ដែលកម្ពុជាត្រូវការ, តែគឺឯករាជ្យ, ឯករាជ្យរៀងរហូត,
- ដោយយល់ឃើញថា ព្រឹទ្ធាចារ្យប៉ែន នុត ថយកាយពលពុំអាចជួយខ្ញុំបានពេញដៃពេញជើង,
- ដោយយល់ឃើញថា ឧត្តមសេនីយ៍លន់ នល់, នាយករដ្ឋមន្ត្រីនិងជាមិត្តទីពីររបស់ខ្ញុំគ្រប់គ្រងទូដែករបស់គាត់ដោយមានប្រសិទ្ធភាពជាងគ្រប់គ្រងរដ្ឋរបស់ខ្ញុំ, ហើយថ្លើមប្រម៉ាត់របស់គាត់នោះនៅតែឯប្រទេសស៊ីស,
- ខ្ញុំប្រកាសថា ខ្ញុំហត់ហេវខ្លាំង, ឯកោ ហើយធ្លាក់ទឹកចិត្តអស់រលីង។

ដូច្នេះ ខ្ញុំធ្វើដំណើរទៅទីនេះទីនោះវិញ។ ទៅហាណូយពីម្សិលមិញ, ថ្ងៃនេះនៅប៉ារីស៍ដែលលែងជាប៉ារីស៍ទៀតហើយ។ ស្អែកទៅមូស្គូដែលនឹងនៅតែជាមូស្គូដដែល។ ខានស្អែក...

*(ឯកអគ្គរាជទូតខ្មែរប្រចាំក្រុងប៉ារីស៍ចូលមក)*

### ព្រះសីហនុ

*ម៉េចទៅ, លោកទូតកម្ពុជានៅប៉ារីស៍?*

### លោកទូត

*ក្រាបទូល, គឺសម្ដេចប៉េន នុត!*

*សម្ដេចប៉េន នុតផ្ទាល់តែម្ដង។*

### ព្រះសីហនុ

*ផ្ទាល់យ៉ាងម៉េច? ពន្យល់ខ្ញុំមកមើល!*

*(សម្ដេចប៉េន នុតចូលមក)*

*សម្ដេចជាទីស្រឡាញ់! យ៉ាងម៉េច? ម៉េចអញ្ចឹង?*

### សម្ដេចប៉េន នុត

*ក្រាបទូល, ទូលបង្គំអង្គុយសិន, ហើយទូលបង្គំនឹងទូលសព្វគ្រប់។*

### ព្រះសីហនុ

*សម្ដេចប៉េន នុត! យី ខ្ញុំអរណាស់! ឬមួយជារឿងទុក្ខសោក? ប្រាប់ខ្ញុំមក, សម្ដេចលែងឈឺហើយមែនទេ? ម្ដេចក៏ខ្ញុំត្រេកអរផងបារម្ភផងយ៉ាងនេះ?*

### សម្ដេចប៉េន នុត

*និយាយឲ្យពិតទៅ, នេះគឺមកពីទូលព្រះបង្គំទេ ដែលបារម្ភ, ហើយបារម្ភនោះក៏គ្មានអ្វីជាផ្ទាល់ខ្លួនឡើយ, គឺបារម្ភចំពោះព្រះអង្គ។ លន់ នល់យកលេសថា ឈឺស្នាមួយចំហៀង, ហើយក៏ផ្ទេរអំណាចឲ្យសិរិមតៈ ដោយចាត់តាំងជានាយករដ្ឋមន្ត្រីស្ដីទី។*

*លន់ នល់ ឈឺដេកនៅលើគ្រែ, តែទូលព្រះបង្គំវិញ, ឮដំណឹងនេះហើយធ្វើឲ្យងើបក្រោកដើរឡើងវិញបាន។ ទ្រង់សិរិមតៈឥឡូវនេះ មានអំណាចណាស់។ តែមួយពព្រិចភ្នែកទេ គាត់នោះនឹងរំលាយស្នាដៃនយោបាយទាំងប៉ុន្មានដែលព្រះអង្គខំសាង។ ព្រះអង្គមានព្រះតម្រិះយ៉ាងណា? ទូលព្រះបង្គំអាចជួយធ្វើអ្វីបានខ្លះ?*

*មើលទៅ, ព្រះអង្គមិនទាន់ជ្រាបទេថា គ្រោះមហន្តរាយនឹងមកដល់បន្តិចទៀតនេះហើយ។*

### ព្រះសីហនុ

ចោរអាកាសជាជីដូនមួយរបស់ខ្ញុំនេះ សង្ឃឹមថានឹងពង្វាងយន្តហោះខ្មែរឲ្យទៅចុះនៅវាលយន្តហោះក្រុងវ៉ាស៊ីនតោន។ វាយល់ច្រឡំទេ ព្រោះយន្តហោះនេះ ស្តាប់បញ្ជាពីខ្ញុំតែប៉ុណ្ណោះ។

### សម្តេចប៉ែន នុត

ទ្រង់សិរិមតៈអាចនឹងធ្វើរដ្ឋប្រហារ។

### ព្រះសីហនុ

មិនអាចទេ, ព្រោះទាល់តែមានទ័ពទាហាននៅពីក្រោយ, មានន័យថាទាល់តែ លន់ នល់ គាំទ្រ។ គាំទ្រម្ដេចកើតបើលន់ នល់ស្មោះពេញទីនឹងខ្ញុំ។ សិរិមតៈនឹងធ្វើអ្វី។ អាក្រក់គ្រប់បែបយ៉ាង។ ម្យ៉ាងដែរ! ប្រទេសយើងស្គាល់តែរស់ជាតិច្នាញ់ពិសា, ឥឡូវគួរឲ្យស្គាល់ល្វីងជូរចត់ម្ដងដើម្បីថ្លឹងថ្លែងកើត។ ទុកឲ្យផ្អមម្ដងសិនចុះ, ដល់ពេលយើងត្រឡប់ទៅវិញ គេនឹងកាន់តែឲ្យតម្លៃយើង។

### សម្តេចប៉ែន នុត

ព្រះអង្គយល់ខុសស្រឡះ, ក្រាបទូល។ ច្បាស់ជាផុងខ្លួនខូចការអស់។ សូមព្រះអង្គដេញទ្រង់សិរិមតៈចេញ ហើយឲ្យលន់ នល់មកវិញ។

### ព្រះសីហនុ

ខ្ញុំនឹងធ្វើតាម, តែចាំខ្ញុំត្រឡប់មកពីមូស្គូវិញសិន!

### សម្តេចប៉ែន នុត

យាងពីមូស្គូវិញ?

### ព្រះសីហនុ

ពីមូស្គូ និងពីប៉េកាំង!
កង្វល់របស់ខ្ញុំមិនមែនត្រឹមតែសិរិមតៈនោះទេ! កម្លាំងរបស់គាត់នៅក្រៅខ្លួនគាត់ មិនមែននៅក្នុងឡើយ, ព្រោះ កម្លាំងនោះកើតឡើងដោយសារយួនចិត្តវៀចវេរ។ ប្រជាជនយើងមិនសប្បាយចិត្តអំពីរឿងអ្វី? មិនមែនអំពីសង្គមនិយមព្រះពុទ្ធសាសនារបស់ខ្ញុំឯណា! គឺមិនសប្បាយចិត្តនឹងពួកលេបទឹកដីចូលមកកាន់តែច្រើនឡើងៗ។ វាអង្វៀមដីយើងទាំងស្រស់ម្ដងបន្តិចៗ, ហើយវានាំបណ្ដាលឲ្យអាមេរិកាំង

ទម្លាក់គ្រាប់បែកលើយើង ទៀត។ មិនមែនសិរិមត:ទេ ដែលឲ្យខ្ញុំបារម្ភ គឺយក្សអាមេរិកាំង, ព្រោះអាគាំងនេះ វាមិនសំឡេះយួនហាណូយ ទាល់តែសោះ, គ្រាប់បែកដែលទម្លាក់នោះ គឺបំផ្លាញជីវិតកូនចៅយើងនៅស្រែចម្ការ, ដោយសារយើងមិនដឹងថា សង្គ្រាម ក៏វាត្រូវបាញ់មករកយើងដែរ។ ពួកយួន, កាលណាតែឮសូរសម្លេងយន្តហោះ, គេរត់គេចខ្លួនបាន។ រត់ទៅឯណា? គឺមកជ្រកក្រោមម្លប់ទឹកដីយើង, នៅពេលដែលយើងឯនេះ ពុំទាន់ចេះស្តាប់សម្លេងកប៉ាល់ហោះផង! ឥឡូវគ្នាវាប៉ុន្មានទៅហើយដែលកំពុងនាំវាសនាចង្រៃមកលើទឹកដីយើង?

## សម្តេចប៉ែន នុត

បពិត្រព្រះករុណាថ្លៃវិសេស, កាលយន្តហោះមិនទាន់ទម្លាក់សម្រុកគ្មានពេលឈប់នោះ គឺមានចំនួន ៣ ម៉ឺននាក់។ ឥឡូវនេះ ប្រហែលឡើងដល់ ៤ម៉ឺនហើយ។

## ព្រះសីហនុ

ទេ! ខ្ញុំលែងស្តាប់ជំនួសពួកវាទៀតហើយ,
មិនមែនជាមួយរឿតណាមទេដែលយើងត្រូវនិយាយឲ្យប្រយត្ន័ប្រយែងបន្តិច។ គឺត្រូវទៅដល់មូស្គូនិងប៉េកាំងទៀត, បានកើត!
មានតែខាងនោះហើយ ដែលបញ្ជាពួកយួនឲ្យបត់បែនដូចភ្លៀងខ្យល់ដែលបោកបក់លើឬស្សីបាន។ ខ្ញុំនឹងពន្យល់គេថា សីហនុជាមិត្តដ៏ល្អបំផុតរបស់គេ, ដូច្នេះមិនត្រូវធ្វើអ្វីឲ្យរបបខ្ញុំរង្គោះរង្គើឡើយ។ សម្តេចមកជួយបានទេ? កុំឲ្យសីហនុស្រែកឮៗពេក ហើយឲ្យជ្រើសរើសយកតែពាក្យណាសមសួនមកនិយាយ។

## សម្តេចប៉ែន នុត

ទូលបង្គំនឹងមកតាមព្រះអង្គ។ សូមបន់ព្រះ ឲ្យព្រះអង្គមានបន្ទូលទៅ, ចូលត្រចៀកពួកមិត្តចិត្តរឹងទាំងនោះផង។

## ព្រះសីហនុ

ខ្ញុំនឹងទៅថ្វាយដំណឹងនេះ ដល់ហ្លួងម៉ែជាទីគោរព។ ខ្ញុំនឹងសូមឲ្យលន់ នល់ ធ្វើរឿងមួយ, គឺថាឲ្យឃ្លាំសិរិមត: ហើយ ពេលដែលយើងកំពុងធ្វើដំណើរនោះ, ឲ្យរៀបចំបាតុកម្មរកេតរកូត តាមនេះតាមនោះ, បង្ហាញថាប្រជាជនមិនសប្បាយចិត្តនឹងអំពើជ្រុលហួសហេតុរបស់យួន។ ពីក្រោមកគេនឹងឃើញថាប្រទេសកម្ពុជាទាំងមូល ដែលទាមទារឲ្យគេគោរពខ្លួនឲ្យត្រឹមត្រូវ។

**សម្តេចប៉ែន នុត**

បាតុកម្មកេតរកូតប្រឆាំងយួន... ទូលបង្គំមិនយល់ថាជាការល្អសោះ។ លទ់ នល់នឹងបកស្រាយគំនិតនេះរបៀបផ្សេង ហើយហេតុការណ៍របៀបបាត់ដំបងនោះអាចកើតឡើងទៀតបាន។

**ព្រះសីហនុ**

ទុកឲ្យខ្ញុំគិតម្តងទៀតចុះ។ សម្តេច! ទៅយើង! ទៅមួស្គូ។ ដល់ពេលយើងត្រឡប់មកវិញ, អ្វីៗនឹងផ្លាស់ប្តូរទៅជាល្អអស់ហើយ។

*(ទាំងពីរនាក់ចេញទៅ)*

**លោកទូត**

*យី! សម្តេចព្រះសីហនុនេះពិបាកនិយាយគ្នាណាស់! នរណាក៏ខ្លាចលោកដែរ។ គឺជាស្តេចមែនទែនតែម្តង! មិនស្រួល។ ខ្វាល់ក្លាម, ហើយខ្វាល់ខ្លាំងទៅទៀត! យើងធ្លាប់ឃើញហើយថា ព្រះអង្គដេញរដ្ឋមន្ត្រីពីដំណែងដោយមិនបាច់និយាយវែងឆ្ងាយ ហើយមិនទាំងឲ្យដម្ងឺចិត្តអ្វីទៀតផង។ ដេញគេ, គឺដេញមែន។ បើអរគុណគេវិញ, គឺគ្មានទាល់តែសោះ។ ទាល់តែធ្វើជាឪពុកគេជានិច្ច ទើបសុខព្រះទ័យ។ កុំភ្លេចថាលោកយើងនេះផ្លាស់ប្តូរ! មិនព្រមយល់ថា ធ្វើឪគេនោះ, ហួសសម័យហើយ។*
*គេស្រឡាញ់ព្រះអង្គខ្លាំងមែន, ប៉ុន្តែអ្នកស្រឡាញ់នោះគឺរាស្ត្រ។ ដល់គេស្រឡាញ់ពេកទៅ នឹកស្មានថាទាំងអស់គ្នាស្រឡាញ់ព្រះអង្គ។ នែ, កុំប្រឡំ, កុំប្រឡំឲ្យសោះ, មិនមែនទាំងអស់គ្នាទេ ដែលស្រឡាញ់លើសលប់នោះ! នេះហើយខ្មែរ, ស្រឡាញ់លើសលប់ក៏លើសលប់, តែមិនសូវប៉ុន្មាន ក៏មិនសូវប៉ុន្មានដែរ។ ព្រះអង្គគ្មានស្តាប់នរណាទេ។ ពេលបាយ, មានបន្ទូលតែម្នាក់ឯង ហើយពុំដែលស្តាប់នរណាឡើយ។ ព្រះអង្គយល់ថា ដោយសារខ្ញុំទទួលទានបាយជិតព្រះអង្គ, ដូច្នេះខ្ញុំត្រេកអរ។ មួយវិញទៀត បើស្តាប់, គឺស្តាប់តែអ្នកម្នាងជាព្រះជាយាប៉ុណ្ណោះ។ ប៉ុន្មានខែមកនេះ ខ្ញុំឃើញថា ព្រះអង្គមិនមែនអត់សត្រូវប៉ង់បៀតបៀនទេ ក្នុងផ្នែកនយោបាយ។*
*ព្រះអង្គជាមនុស្សឯករាជ្យ។ ឯករាជ្យផ្នែកគំនិត, តាមពិតជាគុណសម្បត្តិដ៏ល្អមួយ។ ខ្ញុំស្រឡាញ់ណាស់ឯករាជ្យ។ ប៉ុន្តែ ឯករាជ្យព្រះអង្គនោះ គឺជ្រុលរហូតទៅជាជម្ងឺក៏ថាបាន!*
*ក្នុងនាមជាខ្មែរ ខ្ញុំមិនចោលសម្តេចព្រះសីហនុទេពេលនេះ។ ពេលនេះខ្ញុំនៅខាងព្រះអង្គ។ ឥឡូវ ខ្ញុំត្រូវយកដំណឹងថ្មីៗទៅទូលថ្វាយ។ ចាំមើល! អាចមានរឿងអីទៀតកើតឡើង?*

*(លោកទូតចេញទៅ)*

## ឆាកទី២

*(ភ្នំពេញ។ លោកលន់ នល់ ចូលមក)*

**លន់ នល់**

ខ្ញុំទៅឲ្យគេទស្សន៍ទាយដូច្នោះហើយ, ព្រោះម្សិលមិញនេះ ខ្ញុំចាប់ផ្ដើមឈឺខ្នាក។ ធ្វើឲ្យលែងទុកចិត្តខ្លួនឯង។

មកទល់ពេលនេះ មានតែភ្លៅឆ្វេងទេដែលញ័រ។ ច្បាស់ហើយឥឡូវ, ព្រោះម្សិលមិញចាប់ផ្ដើមញាក់ខាងស្ដាំ ទៀត។ មិនដឹងគិតធ្វើម៉េច។ ត្របៀកវិញក៏ដូចគ្នា។ តាំងពីឲ្យទ្រង់សិរិមតៈស្ដីទីមក, បន្តិចចាក់សៀតខាង ឆ្វេង, បន្តិចចាក់សៀតខាងស្ដាំ។ ទ្រង់សិរិមតៈទៅលឿនពេក។ យកធានាគារនិងសហគ្រាសទាំងប៉ុន្មានមកឲ្យឯកជនកាន់កាប់វិញ, ដូរដោះអ្នកស្រឡាញ់សម្ដេចសីហនុឲ្យអស់ពីក្រសួង! តែមួយអាទិត្យសោះ! យីអើ! ហាមឃាត់មិនឲ្យមន្ត្រីរាជការផ្សព្វផ្សាយសារាចរនានាទៅដល់សម្ដេច។ ធ្វើនេះជ្រុលបន្តិចហើយ។ សម្ដេចច្បាស់ជានឹងសម្រុកមកដាក់ទូតជាមួយអាមេរិកាំងវិញ។ តើខ្ញុំត្រូវទូលសម្ដេចឲ្យជ្រាបឬអ្វី? តើខ្ញុំត្រូវនៅខាងព្រះអង្គ? ឬទៅខាងមួយអង្គទៀតវិញ?

សង្ខេបមក, តើខ្ញុំត្រូវឡើងយន្តហោះទៅតាមសម្ដេចសីហនុ? ពេលទៅដល់ហើយ, ខ្ញុំត្រូវបំភាន់ព្រះអង្គឬអ្វី? ខ្ញុំភាន់ច្រឡំតែខ្លួនឯង? នរណាដែលខ្ញុំត្រូវបំភាន់? គិតបន្តិចសិន!

*(អនុសេនីយ៍ឯក អ៊ិន សូផាតចូលមក)*

**អនុសេនីយ៍ឯក**

ទានប្រោស, ទ្រង់សិរិមតៈយាងមកហើយ, ហើយកំពុងខឹងដាច់ក្បាលដាច់កន្ទុយ!

**លន់ នល់**

ដូចតែរាល់ដងដូច្នេះឯង!

**អនុសេនីយ៍ឯក**

ខឹងប្រៀបបាននឹងត្មាត ដែលគេដណ្ដើមយកគម្រង់ពីមាត់បាន។

*(ទ្រង់សិរិមតៈមកដល់)*

**ទ្រង់សិរិមតៈ**

លោកឧត្ដមសេនីយ៍, លោកជ្រាបទេអំពីអាស័យដ្ឋានរបស់សីហនុបន្ទាប់ពីនេះ?

### លន់ នល់

មិនគង់នៅប៉ារីស៍ទៀតទេ?

### ទ្រង់សិរិមត:

ចេញពីប៉ារីស៍ទៅហើយ។ ប្អូនជីដូនមួយខ្ញុំនេះ មិនមែនជាអ្នកដឹកនាំប្រទេសទេ, គឺជាសត្វកណ្ដុប! មើល! ជ្រាបថាដំណាក់កាលខាងមុខជាអ្វីទេ? ពីរថ្ងៃទៀត គឺសីហនុទៅដល់មូស្គូ! ទៅមូស្គូ- ក្រឹមឡាំង- លាន ក្រហម!

### លន់ នល់

មូស្គូ! ទេ, បើអញ្ចឹងខ្ញុំមិនទៅទេ, មូស្គូ។

### ទ្រង់សិរិមត:

ម៉េចក៏គិតទៅមូស្គូ? លោកបម្រុងទៅមូស្គូ? កំពុងតែរមួលរឿចស្មាមួយចំហៀងយ៉ាងនេះ! ហើយយ៉ាងណា ក៏គ្មាននរណាអញ្ជើញលោកទៅដែរ។ គឺមានតែសម្ដេចប៉ែន នុតទេដែលតាមប្អូនខ្ញុំទៅទីចង្រៃឧបទ្រព នោះ។

### លន់ នល់

ទៅមូស្គូ! ជាមួយប៉ែននុត! ដូចជាជ្រុលពេក!

### ទ្រង់សិរិមត:

មូស្គូ! បន្ទាប់មកទៀតគឺប៉េកាំង!
ចំណែកឯលោកវិញ, សម្ដេចសីហនុទទូចសូមឲ្យលោករៀបចំបង្កើតបាតុកម្មប្រឆាំងយួនតាមទីនេះ ទីនោះខ្លះ, រៀបចំឲ្យគេឃើញថាផ្ទុះឡើងឯងៗ ដើម្បីព្រះអង្គចញ្ចុះបញ្ចូលចិត្តគេ។ លោកសប្បាយចិត្ត នឹងធ្វើទេ?

### លន់ នល់

បាតុកម្មប្រឆាំងយួន? ចង់បានប៉ុន្មានក៏ធ្វើបាន, តាមតែចិត្តចង់!

ទ្រង់សិរិមត:

ធ្វើបានតាមចិត្តចង់, ចុះបើលើសពីចិត្តចង់ទៅទៀត? តាមគំនិតខ្ញុំទាន់ទេ?

លន់ នល់

ប្រហែលជាតាមទាន់។ តែមិនទាន់ច្បាស់ទេ។ គំនិតនោះទៅដល់ណា?

ទ្រង់សិរិមត:

បាតុកម្មប្រឆាំងយួននោះ គឺលោកជាអ្នករៀបចំ, ប៉ុន្តែសូមគិតថា ធ្វើដើម្បីខ្ញុំវិញទៅចុះ! សូមធ្វើឲ្យហួសចត់, ដុតដៃដុតជើងឲ្យមែនទែន។ យួននឹងខ្លាតទៅក្រៅ! ប្រទេសយើងនឹងមានមុខមាត់វិញដូចមុន។

លន់ នល់

ខ្ញុំតែងតែស្រម័យថានឹងបានទៅជាដូច្នោះវិញដែរ! កម្ពុជាមួយដែលបរិសុទ្ធ, ប្រក្រតី! ប៉ុន្តែសម្តេចនឹងមិនបណ្តោយឲ្យយើងធ្វើទេ។ ច្បាស់ជានឹងយាងមកវិញ។

ទ្រង់សិរិមត:

មិនយាងមកវិញទេ។ យើងនឹងកាន់កាប់ភ្នំពេញ។ យើងទុកអាស៊ីនិងពួកកម្មុយនីស្តឲ្យសីហនុទៅចុះ!

លន់ នល់

រដ្ឋប្រហារ! ទ្រង់ច្បាស់ថាធ្វើអញ្ចឹងកើត, មែនទេ?

ទ្រង់សិរិមត:

គឺជារដ្ឋប្រហារដែលខ្ញុំអញ្ជើញលោកឲ្យមកចូលរួមដោយសុទ្ធចិត្ត។ ចាត់ចែងឲ្យរថក្រោះមកពាត់រដ្ឋសភាមក, ខ្ញុំនឹងដឹងគុណស្របតាមជោគជ័យដ៏ធំធេងនោះ។ ឥឡូវនេះលោកយល់ពីគំនិតនោះហើយនៅ? ខ្ញុំលែងរារែកដោយសារជំនឿរបស់លោកលើមេឃ លើផ្កាយ លើហោរ លើយល់សប្តិទៀតហើយ។ លើកនេះ ខ្ញុំនឹងទៅសង្គ្រប់សត្វជាចំណីខ្ញុំ, ហើយខ្ញុំបង្ហើយជីវិតវាឲ្យផុត។ មើល, រឿងរថក្រោះ! សុខចិត្តហើយ, មែនទេ?

**លន់ នល់**

ឱ! ព្រះជាម្ចាស់ខ្ញុំត្រូវក្បត់នឹងសម្តេចសីហនុឬយ៉ាងម៉េច?

*(ងាកទៅទ្រង់សិរិមត:)*

អម្បាញ់មិញ ខ្ញុំបាននិយាយថាម៉េច?

**ទ្រង់សិរិមត:**

ទេ, ខ្ញុំទេដែលនិយាយ។ ខ្ញុំជម្រាបថា៖ រថ-ក្រោះ!

**លន់ នល់**

អីយ៉ា, រថក្រោះ! ខ្ញុំមិនបានយកចិត្តទុកដាក់ស្តាប់ទេ, មុននេះ។ ឱ! គួរឲ្យអនិច្ចាមែន, កំពុងនិយាយគ្នា ហើយភ្លេចថានិយាយពីអ្វី, ហើយនិយាយដល់ណា!
រថក្រោះ, ទ្រង់នឹងបានចម្លើយមុនយប់នេះ។

**ទ្រង់សិរិមត:**

ឲ្យតែប្រគល់រថក្រោះមែន, គឺឯកឧត្តមនឹងក្លាយជាប្រមុខរដ្ឋ។

**លន់ នល់**

ខ្ញុំ! ប្រមុខរដ្ឋ?

**សិរិមត:**

លោកនឹងដឹកនាំប្រទេសដោយស្មោះស្មគ្រ និងដោយតឹងរ៉ឹងមាំទាំដូចជាស្តេចដែរ។

**លន់ នល់**

ទ្រង់ប្រាកដជាជឿហើយ ថាខ្ញុំនឹងធ្វើអ្វីៗទាំងអស់មិនឲ្យទ្រង់ខកចិត្តឡើយ, ព្រោះបានទទួលសេចក្តីទុកចិត្តខ្លាំងយ៉ាងនេះ ប៉ុន្តែ ខ្ញុំត្រូវពិគ្រោះសួរទៅហោរ... អឺ... សួរទៅខាងអគ្គមេបញ្ជាការសិន។

**សិរិមត:**

កុំភ្លេចរឿងផ្កាយ! *(ចង្អុលទៅស្នាអាវ)*

**លន់ នល់**

ខ្ញុំនឹងសម្រេចចិត្តយ៉ាងម៉េចឲ្យស្របតាមប្រយោជន៍ជាតិ។

**សិរិមត:**

ខ្ញុំក៏ជឿថាពិតជាយ៉ាងនោះមែន។

*(ទ្រង់សិរិមត:ចេញទៅ)*

**លន់ នល់**

អើ!ឥឡូវត្រូវធ្វើអីអញ្ចេះ? សិរិមត:ហ៊ាន, អង់អាចមែន, តែសីហនុរឹងមាំជាងគេស្មានទៅទៀត។ គាត់នឹងមិននៅស្ងៀមទេ។ ខ្ញុំមិនលូង៍ហ៊ានទាយមុនឡើយ, ទាល់តែឃើញថាសជញ្ជាំងផ្អៀងទៅខាងណាសិន។ លើដីនេះកុំទុកចិត្តនរណាឲ្យសោះ។ ក្រុមគ្នាឯងក៏មិនត្រូវទុកចិត្ត, សូម្បីតែខ្លួនឯងក៏ទុកចិត្តមិនបានផង, តាមពិតទៅ! អ្វីៗដែលលន់ នល់នឹងត្រូវធ្វើនោះ, លន់ នល់ខ្លួនឯងកុំដឹងមុនល្អជាង។ ឬមួយក៏កុំគិតល្អជាង។ គង់តែឃើញទេ។ តែចំពោះរឿងបាតុកម្មប្រចាំងយួន, រឿងនេះច្បាស់ជានឹងកើត, ហើយគ្មានអ្វីលំបាកឡើយ។

*(លោកលន់ នល់ចេញទៅ)*

## ជាកទី៣

*(ភ្នំពេញ។ ព្រះរាជវាំង។ លោកឱិត សុផុន, អ្នកបម្រើដែលត្រូវជាក្មួយឱិតប៊ុនសួ, អ្នកស្រីខៀវ សំណុល និងអ្នកស្រីឡាំណៃ)*

**ឱិត សុផុន**

កុំទៅណា, សូមនៅលើរានហាលនេះសិនទៅ, មីងទាំងអស់គ្នា, ចាំព្យុះកំណាចនេះទៅផុតសិន។ អូ! ឥឡូវនេះលែងភ័យទៅ, ពួកបះបោរច្បាស់ជានឹងមិនមកដល់ឯនេះទេ។

**ខៀវ សំណុល**

មីងបន់សូមឲ្យទេវតាជួយឯងណា, សុផុន! ហើយឲ្យទេវតាកាច់ពួកអាស្វាក្ឆួតឡប់អស់នេះ ដែលសម្លាប់យួនអ្នកស្លូតត្រង់!

*(លោកឱិត សុផុនចេញទៅ)*

ឃើញទេ, នៅឯនេះគ្រាន់បើមែនទែន។ ព្រឹកមិញនេះសោះ, យើងភ្ញាក់ពីដេកភ្លាម ស្រាប់តែមានការបះបោរយ៉ាងសាហាវ។ ខ្ញុំនឹកថាគេនឹងសម្លាប់ខ្ញុំ និងអ្នកឡាំណៃជាអ្នកជិតខាងព្រមទាំងយួនប៉ុន្មានដែលរស់នៅក្នុងសង្កាត់ជាមួយខ្ញុំហើយ! ចេះនឹកឃើញទាន់ទៅដល់ឱិត សុផុន ដែលត្រូវជាបងកូនប្រសាររបស់ប្អូនថ្លៃស្រីខ្ញុំ! ព្រោះជីតារបស់គេជាជំនួយការទី៥របស់កូនកំបិតទី៤នៃចុងភៅដែលធ្វើព្រះស្ងោយសម្រាប់សម្តេចឪ។ ហេតុនេះហើយបានជាយើងមកដល់ទីនេះ, គឺជាមកដល់វាំង។ ដូចជាមកដល់ស្ថានសួគ៌ដែរ គ្រាន់តែថាយើងនៅរស់ទាំងពីរនាក់, សំណុលនិងឡាំណៃ។

**ឡាំណៃ**

បើបានមកដល់ស្ថានសួគ៌ដោយមិនញ័ររបេះដូងរន្ធត់ស្ទើរស្លាប់ដោយសារពួកអាចោរទាំងនេះមកបំផ្លិចបំផ្លាញផ្ទះខ្ញុំដូចព្រឹកមិញនេះផង, គឺច្បាស់ជាកាន់តែប្រសើរទៀត!

*(ព្រះកុសុមៈ, អ្នកមុំសាវី, លោកហគីនស័យាងនិងដើរចូលមក។ ស្រីពីរនាក់នៅពួន)*

**ព្រះកុសុមៈ**

ចុះប៉ូលីសវិញ? គ្មាននរណាយកប៉ូលីសមកឲ្យមើលសណ្តាប់ធ្នាប់ទេឬអី?

## មុំសាវ៉ៃ

ក្រាបទូល, ពួកប៉ូលីសក៏វាតត្បាតគេជាមួយក្រុមមនុស្សព្រៃនោះដែរ។

## ហគីនស៍

ស្ពានទូតវៀតណាមទាំងពីរខ្ទិចខ្ទីអស់, ចាប់មនុស្សតាមផ្លូវ, ហាងទំនិញក៏រងគ្រោះ, ទាំងអស់នេះសុទ្ធតែចេញពីគម្រោងអ្វីមួយច្បាស់លាស់, គឺថារដ្ឋមន្ត្រីខ្លះរបស់ព្រះរាជបុត្រព្រះអង្គជាអ្នករៀបចំ, ក្រាបទូល។

## ព្រះកុសុមៈ

រដ្ឋមន្ត្រីកូនខ្ញុំ! ទេ,ពិបាកជឿណាស់! ម៉េចក៏អញ្ចឹង? ម៉េចក៏អាក្រក់យ៉ាងនេះ? ធ្វើកលវៀចវេរ ហើយសម្លាប់គេ!

## មុំសាវ៉ៃ

ម៉េចអញ្ចឹង? កាលណាភ្លើងឆេះផ្ទះ យើងត្រូវតែរកអ្នកមកពន្លត់ភ្លើង, មិនមែនរវល់រកហេតុថាម៉េចអញ្ចឹងទេ។ ក្រាបទូលព្រះម៉ែម្ចាស់, សូមធ្វើម្ដេចយាងសម្ដេចមកវិញឲ្យទាន់ពេល។ ត្រូវតែយាងមកវិញយ៉ាងប្រញាប់បំផុត។

## ព្រះកុសុមៈ

អញ្ចឹងហើយ, អញ្ចឹងហើយ។ ខ្ញុំនឹងវាយខ្សែលួសឲ្យយាងមកវិញជាបន្ទាន់។ តែយាងមកដល់កាលណា, ជម្លោះក្រុមមនុស្សនេះនឹងស្ងប់ទៅវិញពុំខាន។

## ហគីនស៍

ទូលបង្គំសូមអនុញ្ញាតថ្វាយយោបល់បន្តិច៖ ភ្លើងនេះមិនមែនឆេះដោយចៃដន្យទេ គឺមានគេបញ្ឆេះដោយចេតនា។ ព្រះអង្គឈ្ងយល់ពីដើងអុកនោះទេ?

## ព្រះកុសុមៈ

ដើងអុក? ទេ, ដើងអុកយ៉ាងដូចម្ដេច?

### ហគីនស៏

គេរៀបចំនេះ ដើម្បីឲ្យព្រះអង្គព្រួយបារម្ភខ្លាំង, ព្រះករុណាថ្លៃវិសេស។ មុខព្រួញគេ គឺតម្រង់ទៅសម្ដេចព្រះរាជបុត្រឯណោះ ដើម្បីកែប្រែផ្លូវដើរនយោបាយ។ តែដើម្បីប៉ះសម្ដេច, គេយកព្រះអង្គឯនេះធ្វើជាស្ពាន។

### ព្រះកុសុមៈ

យ៉ាងម៉េចឯចេះ?

លោកចង់ថា ឲ្យខ្ញុំយាងកូនខ្ញុំមកវិញ, មែនទេ?

### ហគីនស៏

មិនមែនទេ, កុំ, ក្រាបទូល។ នេះហើយបំណងគេ, គឺគេជម្រុញឲ្យព្រះអង្គយាងព្រះរាជបុត្រមកវិញយ៉ាងនេះឯង, ច្លាតណាស់ពួកអស់នេះ! នោះហើយអន្ទាក់របស់គេ។

### មុំសាវ៉

អន្ទាក់អី? គេសម្លាប់ជនជាតិយួននៅស្រុកយើង។ នៅរេរាអីទៀត? សម្ដេចត្រូវតែយាងមកវិញបញ្ចប់ហេតុភេទនេះ, ដាក់ទណ្ឌកម្មដល់មេនាំភ្លើង, ហើយផ្សះផ្សាជំជៅប្រជារាស្ត្រវិញ។

### ព្រះកុសុមៈ

លោកហគីនស៏, សូមមានប្រសាសន៏តទៅទៀត។

### ហគីនស៏

នេះបង្ហាញថាត្រូវធ្វើអ្វីក៏គេធ្វើដែរ ដើម្បីបង្អាក់ដំណើរសម្ដេចដែលត្រូវយាងទៅមូស្គូ។ សូមព្រះអង្គជឿទូលបង្គំចុះ, សម្ដេចមានវាសនាត្រដែត។ ការងារព្រះអង្គគឺនៅកំពូល, លើឆាកពិភពលោកដែលជាកន្លែងសម្រេចវាសនាឲ្យមនុស្សជាតិទូទៅ។ បើរវល់តែឲ្យលោកយាងត្រឡប់មកបោសសំអាតផ្ទះឯនេះវិញ, គឺអស់ឱកាសនឹងរកសន្តិភាពទៀតហើយ។

### មុំសាវ៉

គាត់នេះឯង, មិនដឹងនរណាជួលប្រើឲ្យមកនិយាយដូច្នេះ!

### ព្រះកុសុម:

សូមទុកឲ្យខ្ញុំគិតបន្តិច។ អញ្ជើញចេញសិនចុះ។

### ហគីនស៍

*(ដើរចេញទៅ)*

សិរិមត:នេះអើ! គួរតែឲ្យខ្ញុំដឹងមុនថា ព្រះមហាក្សត្រិយនីយ៍មានថ្ងៃមួយនៅជិត ដើម្បីខ្ញុំរកក្បួនធ្វើឲ្យទៅឆ្ងាយសិន។

*(គាត់ដើរចេញទៅ)*

### មុំសាវ៉េ

បើខ្ញុំម្ចាស់វិញ, គឺខ្ញុំម្ចាស់មិនស្តាប់ទេ លោកហគីនស៍នោះ។ នេះហើយភ្នាក់ងារសេអ៊ីអា។ គឺអ្នកស៊ើបការណ៍ហើយដើរផ្សាយពាក្យចាមអារាម។ គាត់នេះហើយជាអ្នកផ្គុំត្រចៀកទ្រង់សិរិមត:។

### ព្រះកុសុម:

កុំគិតអីជំនួសខ្ញុំ។ លោកហគីនស៍គ្រាន់តែជាភារធារីស្តានទូតប៉ុណ្ណោះ, ទោះជាផ្គុំត្រចៀកក៏គាត់មានហេតុផលដែរ។

*(ស្រីពីរនាក់ដែលពួនសម្ងំបម្រុងនឹងគេចកុំឲ្យគេឃើញ)*

យី, មកពីណាមក, នេះ?

### ឡាំណេ

*(និយាយទៅខៀវសំណុល)*

ខ្ញុំនៅដឹងខ្លួនទេ ឬមួយសន្លប់ទៅហើយ?

### ខៀវសំណុល

នៅដឹងខ្លួន!

ទូលព្រះសុវណី ព្រះម៉ែម្ចាស់! ខ្ញុំម្ចាស់ទាំងពីរអ្នកនេះបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ផង ហើយរងទុក្ខភិតភ័យផង ទាល់តែដើរអួសលោងទៅមុខលែងរួច។

អ្នកខាងនេះឈ្មោះឡាំណេ, អ្នកលក់ត្រីតាមផ្លូវដែលខ្ញុំម្ចាស់រស់នៅដែរ។ គាត់ជាយួន, នេះហើយជារឿងហេតុវែងឆ្ងាយដែលធ្វើឲ្យខ្ញុំម្ចាស់ទាំងពីររសាត់អណ្តែតមកដល់ទីនេះដោយចៃដន្យ, ក្រាបទូល។ ព្រះម៉ែ

ម្ចាស់ជ្រាបហើយថា មានហេតុអាក្រក់សែនអាក្រក់ ដែលធ្វើទុក្ខទោសដល់ជនជាតិយួនទៅពាសពេញក្រុង។ នេះហើយដើមហេតុដែលធ្វើឲ្យខ្ញុំម្ចាស់ទាំងពីរបានទទួលកិត្តិយសរកស្ថានមិនត្រូវថាមកដល់ទីនេះ។

### ព្រះកុសុមៈ

នរណាជាអ្នកផ្តល់កិត្តិយសនេះ, ប្រាប់មកមើល!

### ខៀវ សំណុល

ក្រាបទូល, គឺបងប្អូនជីដូនមួយនៃកូនប្រសាប្រុសរបស់ប្អូនថ្លៃស្រីខ្ញុំម្ចាស់។ គាត់ឈ្មោះឱត សុផុន។

### ឡាំណេ

តែគាត់ប្រាប់ខ្ញុំម្ចាស់ទាំងពីរថា រានហាលនេះជាកន្លែងបោះបង់ចោល, អត់នរណានៅទេ។

### ព្រះកុសុមៈ

ប្រាប់នេះត្រូវហើយ។ យើងមិនដែលមកអញ្ចឹងមែន។ អ្នកឯងនេះជាយួនដែរមែនទេ?

### ខៀវ សំណុល

ខ្ញុំម្ចាស់? ទេ,ទេ, អត់មានយួនអីសោះឡើយ!

### ឡាំណេ

ព្រះម៉ែម្ចាស់, អ្នកខៀវ សំណុលនេះ លក់បន្លែស្រស់។បំផុតនៅសង្កាត់យើង។ គាត់ចេះព្យាបាលជម្ងឺ, ហើយចេះបង្កើតកូន, រហូតដល់កូនក្លោះទៀត, ហើយចេះអន្ទងហៅខ្មោចទៀតផង។

### មុំ សាវៃ

អន្ទងហៅខ្មោច? មែនឬអី?

### ខៀវ សំណុល

ចាសបាន, តែមិនមែនចេះតែបានរាល់គ្នាទេ។ ព្រោះខ្មោចនោះ, បើអន្ទង គឺត្រូវមកដោយចង្វងស្ពាន ស្នេហា។ ដូច្នេះបើគ្មានស្នេហា... ប៉ុន្តែចំពោះព្រះម៉ែម្ចាស់វិញ, បើព្រះអង្គសព្វព្រះទ័យឲ្យខ្ញុំម្ចាស់ធ្វើ, ខ្ញុំម្ចាស់អាចអន្ទងយាងព្រលឹងព្រះសពដ៏ថ្លៃថ្លារបស់ព្រះករុណាព្រះបាទសុរាម្រឹត...

### មុំ សាវៃ

ព្រះសុរាម្រឹតរបស់យើង...

### ព្រះកុសុមៈ

ការដែលត្រូវធ្វើឥឡូវនេះ គឺយាងកូនខ្ញុំមកវិញសិន, ណាអ្នកសាវៃ។

### ខៀវ សំណុល

មែន, ក្រាបទូល។ មុននេះខ្ញុំម្ចាស់និយាយគ្នាជាមួយអ្នកឡាំណោដែរ, គឺគិតដូចគ្នានិងលោកស្រីសាវៃ ដែលថាត្រូវសម្ដេចឪយាងមកវិញនោះ។

### ឡាំណោ

មែនហើយ!

### ខៀវ សំណុល

សម្រេចព្រះទ័យទីបញ្ចប់ គឺយ៉ាងដូចម្ដេច?

### ព្រះកុសុមៈ

ខ្ញុំទៅឲ្យគេវាយខ្សែរលួសទៅកូនខ្ញុំ។ ចាំជួបគ្នាទៀត, អ្នកទាំងពីរ ។

*(ព្រះអង្គយាងចេញទៅ)*

### មុំ សាវៃ

ក្រាបទូល, ហ្លួងម៉ែនឹងមានបន្ទូលថាម៉េច?

**ព្រះកុសុមៈ**

ខ្ញុំនឹងថា...

**មុំសាវៃ**

បើខ្ញុំម្ចាស់ជាហ្លួងម៉ែ....

**ព្រះកុសុមៈ**

ឯងមិនមែនខ្ញុំទេ...

*(ទាំងពីរទាក់យាងនិងចេញទៅ)*

**ឡាំណៃ**

អ្នកស្រីសាវៃនេះ ខ្ញុំដូចជាចូលចិត្តគាត់ណាស់។ បន្ទាប់ពីព្រះមហាក្សត្រីយានីមក គឺគាត់នេះហើយដែលខ្ញុំយល់ថាស្អាតជាងគេ។ អញ្ចឹងមែនទេ?

**ខៀវសំណុល**

ព្រះករុណាព្រះសុភាម្រឹត, កាលព្រះអង្គនៅមានព្រះជន្ម... *(និយាយខ្សឹបដាក់ត្រចៀកអ្នកឡាំណៃ)*

**ឡាំណៃ**

ធម្មតាទេ! មានអីប្លែក?

*(ទាំងពីរអ្នកចេញទៅ)*

## ឆាកទី៤

*(ចាំរីស៍។ ព្រះសីហនុយាងចូលមកដោយមានសម្ដេចប៉ែនទុតមកតាម)*

**ព្រះសីហនុ**

ស្អែកនេះ, មូស្គូ! ៨ថ្ងៃទៀត, ប៉េកាំង។ យើងទៅមុខហើយ, សម្ដេច, យើងទៅមុខហើយ។

*(ព្រះសីហនុទតទៅឃើញលោកទូត)*

មានការអី, លោកទូត?

**លោកទូត**

សម្ដេចព្រះមហាក្សត្រីយានី ស្ដេចវាយទូរលេខមួយមក, ក្រាបទូល។ ព្រះអង្គមានបន្ទូលថា មានក្រុមហ្វូងទាហាននិងនិស្សិតបញ្ចេញកំហឹងហើយផ្ដុំគ្នានៅមុខស្ថានទូតហាណូយ។

**ព្រះសីហនុ**

អញ្ចឹង? ល្អហើយ, ល្អហើយ!

**លោកទូត**

ល្អហើយ? ល្អមែនឬក្រាបទូល?

**ព្រះសីហនុ**

តទៅទៀត! មានអ្វីទៀត?

**លោកទូត**

ហើយមានមនុស្សផ្ដុំគ្នាមួយកន្លែងទៀត នៅមុខទូតយៀកកុង។

**ព្រះសីហនុ**

ល្អ, ល្អហើយ, អញ្ចឹង!

**លោកទូត**

*អញ្ចឹង, ក្រាបទូល? បន្ទាប់មកសម្តេចព្រះមហាក្សត្រីយានីមានបន្ទូលថាព្រះអង្គពិបាកព្រះទ័យណាស់ ហើយសូមទូលព្រះអង្គជ្រាបថា ហ្វូងមនុស្សទាំងនោះចូលលុកលុយស្ថានទូតទាំងពីរអស់។*

**ព្រះសីហនុ**

*លុកលុយ? ទេ, មិនមែនទេ! លោកនិយាយថាម៉េច?*

**លោកទូត**

*លុកលុយហើយកម្ទេចអ្វីៗហ្នឹង, ក្រាបទូល។ បន្ទាប់មក...*

**សម្តេចប៉ែននុត និងព្រះសីហនុ**

*លុកលុយកម្ទេច?*

*(លេខាធិការម្នាក់កាន់ទូរលេខចូលមក)*

**ព្រះសីហនុ**

*ឲ្យមកខ្ញុំ! (ព្រះអង្គទតអាន) យី, សម្តេច! គេចូលសម្រុកក្នុងស្ថានទូត! ហ្លួងម៉ែមានបន្ទូលថាគេបំផ្លាញ, ដុត, យកឥវ៉ាន់អស់! ហា!ជួយស្តាប់៖ "ហើយវាចាប់អ្នកធ្វើការយួនដប់នាក់ បោះទម្លាក់មកក្រៅតាមបង្អួច។ ពួកជនពាលនេះហ៊ានយកព្រះនាមកូន ថាជាអ្នកបញ្ជាឲ្យធ្វើអំពើឃោរឃៅព្រៃផ្សៃនេះ!", នែ, មើលទៅមើ!*

**សម្តេចប៉ែននុត**

*ឱ! ព្រះម្ចាស់ថ្លៃ!*

**ព្រះសីហនុ**

*យី, លន់ នល់ ជាពស់កំណាចមែន! ហ៊ានធ្វើរំលងបញ្ជាខ្ញុំយ៉ាងព្រងើយ!*

**សម្តេចប៉ែន នុត**

*ទូលព្រះបង្គំវិញ មើលឃើញស្រមោលទ្រង់សិរិមតៈនៅពីក្រោយរឿងអាស្រូវនេះ។*

**ព្រះសីហនុ**

*ទេ, គឺលន់ នល់! ហើយគឺសិរិមតៈដែរ។ ក្រុមពស់វែកនេះនៅក្នុងកញ្ច្រោងជាមួយគ្នា! ឱ! ខ្ញុំឆោតមែន, ទុកឲ្យពួកវារំលាយយុទ្ធសាស្ត្រដ៏ជ្រៅរបស់ខ្ញុំ។ ខ្ញុំបម្រុងថានឹងសូមឲ្យយួនស្ងប់ស្ងាត់បន្តិចនៅតាមជាយដែន, ស្រាប់តែគេចាប់យួនបោះតាមបង្អួចមកកណ្ដាលក្រុង!! យី អាពស់កំណាចលាក់ពីសនេះ, វាចង់បង្ខំខ្ញុំ! លន់ នល់គិតថាធ្វើ ឲ្យ សីហនុនិងយួនឈ្លោះគ្នា! ប្រហែលវាគិតថាហ្លួងម៉ែមិនដែលរវីរវល់នឹងខ្ញុំទេឬអ្វី? យើញទេ, លោកទូត, បើអ្វីៗខ្ញុំចាំតែបានពីលោក....! ប៉ុន្មានថ្ងៃហើយដែលលោកភ្លេចយកទូរលេខនេះឲ្យខ្ញុំ?*

**លោកទូត**

*ភ្លេច? អត់មានទេ, ក្រាបទូល។*

**ព្រះសីហនុ**

*សារខែ្សល្ហួសនេះមកដល់៣ម៉ោងមុននេះម្ល៉េះ, រវល់យកទៅស្ងោឲ្យឆ្អិនសិនមុននឹងឲ្យខ្ញុំឬយ៉ាងម៉េច?*

**លោកទូត**

*អ្នក... បកប្រែ... អ្នកប្រែលេខកូដ...*

**ព្រះសីហនុ**

*នែ, លោកទូត! បើសិនជាគេកាត់ទោសប្រហារជីវិតខ្ញុំ, គឺច្បាស់ជាខ្ញុំស្លាប់រួចទៅហើយ ទើបលោកមកប្រាប់!*

**សម្ដេចប៉ែននុត**

*ក្រាបទូល, សូមព្រះអង្គមេត្តាប្រោស, ទោះជាព្រះអង្គខ្ញាល់...*

**ព្រះសីហនុ**

*យី! អាជ្រូកខ្លាញ់ញ៉ុកនេះ!*

**លោកទូត**

*ក្រាបទូល...*

**ព្រះសីហនុ**

ពួកអាម្រើមព្រះពាក់ឯកសណ្ឋាន, ពួកអាឈ្លើងទាម, អាជន្ទេន, អាម្សៀ លន់ នល់...!

**សម្តេចប៉ែន នុត**

ទូលបង្គំសូមទូលព្រះអង្គបន្តិចបានទេ?

**ព្រះសីហនុ**

និយាយមក, ស្រែកមកចុះ, ទាល់តែស្រែកទើបលប់សម្លេងកំហឹងខ្ញុំបាត់, ហើយទើបខ្ញុំស្តាប់ឮ។

**សម្តេចប៉ែន នុត**

ទូលបង្គំមិនចេះស្រែកទេ, ក្រាបទូល! ភ្នំពេញត្រូវការឲ្យព្រះអង្គយាងទៅ។ ព្រះអង្គត្រូវលប់គម្រោងយាងទៅមូស្គូសិន។

**ព្រះសីហនុ**

*ពួកវាលប់គម្រោងដំណើរខ្ញុំបានមែន! វាលប់មូស្គូ, វាលប់ប៉េកាំងចោលអស់! គម្រោងការណ៍ផ្លូវទូតខ្ញុំរលាយអស់! ណ្ហើយ, ខ្ញុំចូលស្រុកវិញ! លោកទូត, សូមឲ្យគេវាយខ្សែរលួសទៅព្រះមហាក្សត្រីយានី, ទូលលោកថាខ្ញុំត្រឡប់ទៅវិញភ្លាមនេះឯង។ អញ្ជើញទៅ, កុំមើលមុខខ្ញុំធ្វើភ្នែកស្លក់ដូចភ្នែកត្រីស្ងោរយ៉ាងនេះ!*

*(លោកទូតចេញទៅ)*

**សម្តេចប៉ែននុត**

សូមព្រះអង្គប្រយ័ត្នបន្តិចនឹងលោកទូតយើង, ក្រាបទូល។ មាត់គាត់មិនសូវបើកទេ, តែត្រចៀកវិញចំហចាំតែស្តាប់អ្វីៗគ្រប់បែបយ៉ាង។

**ព្រះសីហនុ**

ខ្ញុំដឹងហើយ, រឿងរបៀបនេះ។ ដប់ឆ្នាំមកហើយដែលភ្នែកគាត់ប៉ប្រិមដាក់ខ្ញុំ តែត្រចៀកលបស្តាប់ការដែលមិនត្រូវស្តាប់។

ឱ, ដំណើរខ្ញុំ! មូស្គូនឹងថាម៉េចទៅវិញ, ហ្ន! ធ្វើទាល់តែខ្ញុំត្រូវទៅភ្នំពេញវិញ! លន់ នល់អើយ, ម្សៀងឯងមិនរួចខ្លួនទេ, គង់តែដល់ពេលខ្ញុំចាប់ស្ងោរទាំងរស់។

**សម្តេចប៉ែននុត**

ទូលបង្គំជឿជាក់ថា ព្រះទ័យព្រះអង្គយ៉ាងណាក៏មិនវែងឆ្ងាយដូចព្រះបន្ទូលដែរ។

**ព្រះសីហនុ**

*ទេ, គឺអញ្ចឹងមែន! បើសិនជា១០០ឆ្នាំមុននេះ ខ្ញុំច្បាស់ជាយកវាទៅចៀនទាំងរស់។ ខ្ញុំឲ្យគេចាប់វាយកទៅកាត់ទោសជាអ្នកឃុបឃិតបះបោរ។ អូ! ខ្ញុំអន់ទឹងហើយឥឡូវនេះ! យី, ចេវចាវមែន! នែ, ឱត ប៊ុនសួ, ឲ្យគេរកអាស្ពីរីនមានវីតាមីនសេមកឲ្យខ្ញុំ។*

*យើងទៅអង្គាល់, សម្តេចព្រឹទ្ធាចារ្យ?*

**សម្តេចប៉ែន នុត**

ស្អែកព្រលឹមនេះ, ក្រាបទូល។ នៅចន្លោះពេលនេះ ទូលបង្គំនឹងប្រមូលពត៌មានឲ្យបានគ្រប់គ្រាន់ថាតើនៅភ្នំពេញ យើងនឹងជួបអ្វីខ្លះ?

*(លោកទូតចូលមកវិញ)*

**លោកទូត**

ក្រាបទូល, មានទូរលេខមួយទៀតទើបនឹងមកដល់។

**ព្រះសីហនុ**

*យកមកនេះ!*

*(ទតអានសារនោះ)*

**សម្តេចប៉ែននុត**

មានអីទៀតហើយ, ម្ចាស់ថ្លៃ!

**ព្រះសីហនុ**

*ព្យុះកំណាចបក់ទៅឆ្ងាយហើយ! ឥឡូវធ្លាក់ខ្យល់ធម្មតាមកវិញ, រីឯផ្ទៃសមុទ្រក៏ស្ងប់! ដូច្នេះយើងបើកក្តោងទៅមូស្គូបាន!*

**សម្តេចប៉ែន នុត**

សូមព្រះអង្គមានបន្ទូលឲ្យច្បាស់មកមើល, ពិបាកស្តាប់ណាស់, ក្រាបទូល។

### ព្រះសីហនុ

*បើអីចឹង, និយាយឲ្យងាយស្ដាប់ទៅចុះ! ទូរលេខដ៏ចង្រៃមុននោះសាបពីសហើយ ដោយសារទូរលេខថ្មីនេះមកដល់។ លើកនេះជារឿងធូរស្រាលគួរឲ្យរីករាយ។ ហ្លួងម៉ែប្រាប់ខ្ញុំថាស្ថានភាពនៅរាជធានីមិនធ្ងន់ធ្ងរហួសហេតុដូចបច្ចាមិត្រខ្ញុំសង្ឃឹមថាបង្កើតឲ្យបាន ឲ្យខ្ញុំភ័យព្រួយនោះទេ។ និយាយឲ្យខ្លី គឺថាពួកគេនោះរារាំងមិនឲ្យខ្ញុំទៅមូស្គូ, យល់ទេសម្ដេច?*

### សម្ដេចប៉ែន នុត

*រារាំងមិនឲ្យយាងទៅមូស្គូ...*

### ព្រះសីហនុ

*ពីព្រោះ បើខ្ញុំបានជោគជ័យនៅទីនោះដូចរាល់ដងទៀត, សម្ដេចយល់ទេ? បើសិនជា, ដោយសារខ្ញុំក្បាលរឹងដូច្នេះ, គេសុខចិត្តទទួលស្គាល់ធានាអព្យាក្រិតភាពរបស់យើង, ឃើញទេ? សិរិមតៈ, លន់ នល់។ ល។ នឹងយំបោកខ្លួនរឹងរៃជាពុំខាន!*

### សម្ដេចប៉ែន នុត

*មែន! មែន! អញ្ចឹងមែន!*

### ព្រះសីហនុ

*អើហ្ន! ខ្ញុំរិះតែចាញ់បញ្ឆោតគេ, សម្ដេចក៏អញ្ចឹងដែរ។ ចោតណាស់ខ្ញុំ, សម្ដេចក៏អញ្ចឹងដែរ, មែនទេ? កញ្ច្រោលមើលតែសេះ! តែលើកនេះ, ការប្រុងប្រយត្ន័របស់សម្ដេច...*

### សម្ដេចប៉ែន នុត

*ទូលបង្គំភ័យមែនទែន, ក្រាបទូល, ស្មានតែបាត់បង់ប្រទេសកម្ពុជារបស់យើងហើយ។ ទូលបង្គំគិតអ្វីលែងត្រូវ, មុននេះបន្តិច។*

**ព្រះសីហនុ**

*សំណាងល្អ, ទេព្តានៅរក្សាយើង។ សិរិមតៈនិងក្រុមគេនោះមិនចង់ឲ្យខ្ញុំនៅមូស្គូទេ។ ដូច្នេះ ខ្ញុំត្រូវតែទៅ។*

*(សម្តេចយាងចេញជាមួយសម្តេចប៉ែន នុត)*

*(លោកទូតចូលមក)*

**លោកទូត**

*យី, ថាខ្ញុំក្អែកដូចត្រីស្វោរ! ព្រះអង្គហ៊ានធ្វើឲ្យឯកអគ្គរាជទូត កម្ពុជាបាក់មុខ! ខ្ញុំលែងបណ្តោយទៀតហើយ, ពីថ្ងៃនេះទៅអ្នកឯងមិនអាចថាខ្ញុំក្អែកដូចត្រីស្វោរទៀតទេ!*

*ខ្ញុំនឹងឲ្យដំណឹងទៅទ្រង់សិរិមតៈភ្លាម។ ខ្ញុំនឹងថា៖ "អ្នកអង្គម្ចាស់ជាទីគោរព, ជនកាន់អំណាចផ្តាច់ការហ៊ានប្រមាថព្រះអង្គថាជាឈ្លើង, ជាពស់មានពិស, ជាពស់វែក, ជាជ្រូកទៀតផង។ ចំណែកឯទូលបង្គំវិញទទួលពាក្យ ប្រមាថថាក្អែកដូចត្រីស្វោរ។ ជននោះបានស្បថស្បែថាឲ្យតែត្រឡប់ទៅដល់វិញភ្លាមនឹងកាត់ក្បាលក្រុមព្រះអង្គទាំងអស់យកទៅអាំង, មានគ្រឿងហិរសម្រាប់លាយជាមួយផង"។ អញ្ចឹងហើយ!*

*ក្រោយពេលធ្វើសារនេះទៅ ខ្ញុំជឿជាក់ថាជនផ្តាច់ការមិនអាចចូលស្រុកវិញទេ។*

*ហ៊ឺះ! កុំឃើញទូតធ្វើមឹះៗ ស្មានតែកេះច្នាំងបាយមិនផ្លុះ!*

*(គាត់ដើរចេញ)*

# ឈុតទី៤

## ឆាកទី១

*(ព្រៃនគរ។ លោកគីស៊ីងហ្គ័រ, លោកលែរដ៍ និងលោកអាប្រាមស៍ចូលមក)*

**គីស៊ីងហ្គ័រ**

អស់មិត្តទាំងអស់, អញ្ជើញអង្គុយ។ យើងជួបជុំគ្នានេះដើម្បីបញ្ចប់វគ្គចុងក្រោយបង្អស់អំពីវគ្គមានយើងនៅវៀតណាម។

**អាប្រាមស៍**

លើកនេះ បើគ្រាន់តែមកនិយាយថាទៅកេះចាក់ក្រឡេកទល់ដែនខ្មែរប៉ុណ្ណឹងទេ គឺពុំចាំបាច់ប្រជុំគ្នាក៏បាន។ ពួកយួនទៅចាក់ឫសនៅតំបន់យ៉ាងធំមួយ នៅភាគឦសាន ហើយទីបញ្ជាការធំក៏លួចលាក់នៅទីនោះដែរ។ បើកដៃឲ្យខ្ញុំចាត់ការខាងឦសាននោះមក, ខ្ញុំនឹងរំលាយសំបុកមេរោគឲ្យអស់។

**លែរដ៍**

លោកឧត្តមសេនីយ៍, អ្នកសង្កេតការណ៍ជាច្រើនយល់ថា ទីបញ្ជាការធំនោះពុំដែលមានទេ។

**អាប្រាមស៍**

ឱ! អញ្ចឹងបើខ្លួនឯងមើលពុំឃើញ មានន័យថាគ្មាន? ហេតុអ្វីបានជាមើលពុំឃើញ? ព្រោះគេសង់ក្រោមដី។ បើអត់មានមែននោះ, គ្មានទេទ័ពព្រៃ។ គឺជាអាគារបេតុងយ៉ាងក្រាសកប់នៅ៤០ម៉ែត្រក្នុងដី... ពិបាករកឃើញណាស់ ព្រោះទីនោះជាព្រៃក្រាសរាងមូលប៉ោងឡើងលើគ្របដណ្ដប់នៅផ្ទៃដីភូមិភាគនោះ។ ប៉ុន្តែគឺមានមែន, នៅកន្លែងដែលហៅថា "តំបន់ផ្លែសន្ទូច", រឿងនេះខ្ញុំជឿជាក់គ្មានសង្ស័យអ្វីទាំងអស់។

**លែរដឺ**

ចុះក្រែងលោកធ្លាប់ទម្លាក់គ្រាប់បែក ១៥៦ដងនៅតំបន់ផ្លែសទ្រូចនោះរួចហើយ ដោយយកលេសថា កម្ទេចទីតាំងបញ្ជាការយួននោះ, មែនទេ?

**អាប្រាមស៍**

ទម្លាក់ម្ដងៗនោះតិចតួចណាស់, យកជាការមិនបានឡើយ។

**លែរដឺ**

គ្រាប់បែក២ម៉ឺន៩ពាន់តោនហើយ ថាស្ដួចស្ដើងទៀត?

**គីស៊ីងហ្គ័រ**

ជជែកប៉ុណ្ណឹងបានហើយ។ ឧត្ដមសេនីយ៍អាប្រាមស៍, លោកប្រធានាធិបតីអនុញ្ញាតឲ្យបើកយុទ្ធនាការជំឆេង មួយនៅកម្ពុជា ដើម្បីកំចាត់សត្រូវឲ្យអស់ពីទីកន្លែងដែលវាលាក់ខ្លួន។ បញ្ជាមកគឺ៖ បាញ់តាមចិត្ត។

**លែរដឺ**

លោកទីប្រឹក្សា...

**គីស៊ីងហ្គ័រ**

ខ្ញុំដឹងមុនថា លោកបម្រុងនិយាយអ្វីមកខ្ញុំ, លោកលែរដឺ។ លោកចង់ថា៖

១- សភានឹងមិនសុខចិត្ត ហើយដេញដោលរករឿងទៅដល់ណាក៏ទៅដែរ,

២- ព្រឹទ្ធសភានឹងប្រឆាំងតាមគ្រប់មធ្យោបាយអាក្រក់អម្បាលម៉ាន ដើម្បីមិនឲ្យយើងផ្ដល់អាវុធឲ្យ លន់ នល់ឲ្យបានសមរម្យដើម្បីវាយពួកកុម្មុយនីស្ដ៍។

លោកដឹងថាខ្ញុំឆ្លើយទៅលោកវិញថាម៉េចទេ, លើកនេះទៀត? លើកនេះទៀត ខ្ញុំនឹងឆ្លើយថា នៅប្រទេស យើង ម្នាក់ៗមាននាទីរបស់ខ្លួនដោយឡែកពីគ្នា។ នាទីរបស់ព្រឹទ្ធសភាខ្ពង់ខ្ពស់ជាងគេ គឺថាស្រែកជំទាស់។ នាទីប្រធានាធិបតីយ៉ាប់យ៉ឺនណាស់ ព្រោះត្រូវសម្រេចអ្វីតែម្នាក់ឯងក្នុងឋានៈជាប្រមុខរដ្ឋ។ ឯនាទីខ្ញុំ គឺ បណ្ដុះគំនិតទទួលខុសត្រូវជាអាមេរិកាំងនៅក្នុងក្បាលពួកអ្នកធ្លាប់ធ្វើការចាំតែគេប្រើ, មិនរវីរវល់អី។

ខ្ញុំមិនចង់ឃើញថាស្អែកនេះ មានយន្តហោះទម្លាក់គ្រាប់បែក ដែលដេកសម្ងំក្នុងរោងធ្វើព្រងើយ, នៅទីនានាក្នុងអាស៊ីនេះទៀតទេ។ លោកចង់ថាអ្វីទៀតដែរ?

## ល៊ែរដឺ

ចង់ថាតែប៉ុណ្ណោះទេ គឺៈ ចំពោះថវិកាផ្គត់ផ្គង់គម្រោងធំធេងនេះ, យើងត្រូវការលុយច្រើន, ច្រើនលើសឆ្ងាយពីថវិកាដែលនៅសល់សម្រាប់កម្មវិធីកម្ពុជានេះ។ ហើយកុំសង្ឃឹមថា សភានឹងអនុម័តឲ្យសូម្បីតែ១ដុល្លារក៏ដោយ។

## គីស៊ីងហ្គ័រ

កាលណាថវិកាសម្រាប់រឿងសំខាន់យ៉ាងនេះ អស់ ចំពេលដែលត្រូវការ, មិនត្រូវគិតវែងឆ្ងាយ ពេកទេ, គឺត្រូវដកហូតថវិកាមួយភាគពីគម្រោងឯទៀតដែលនៅក្បែរៗនោះ។ ឧទាហរណ៍, ថវិកាសម្រាប់កូរ៉េ អាចទ្រាំទ្រនឹងឲ្យគេដកមួយភាគសម្រាប់កម្ពុជា។

## ល៊ែរដឺ

សូមលោកទីប្រឹក្សា កុំភ្លេចថា ព្រឹទ្ធសភាចេះរាប់ ១, ២, មួយចប់ដែរ។ លើសពីនោះទៅទៀត, គេអាចបារម្ភ ឬមួយសង្ឃឹមថា ដោយការខិតខំប្រឹងប្រែងរបស់លោកព្រឹទ្ធសភា Cooper និង Church, ថវិកាយោធានឹងចុះថយហើយ ទទួលការត្រួតពិនិត្យតឹងរ៉ឹងផង។ តែមួយខែទៀត, យ៉ាងយូរ២ខែទៀត, គេច្បាស់ជានឹងហាមមិនឲ្យបញ្ជូនទាហានមកក្នុងដីកម្ពុជាទៀតទេ។

## គីស៊ីងហ្គ័រ

ឈប់និយាយទៅ, មាត់នេះចង្រៃណាស់! ២ខែ? លោកឧត្តមសេនីយ៍, អញ្ចឹងក៏អញ្ចឹងទៅ, គឺថាក្នុង២ខែនោះ យើងទម្លាក់គ្រាប់បែកទាំងថ្ងៃទាំងយប់, មិនថាសៅរ៍ អាទិត្យអ្វីទាំងអស់!

## អាប្រាមស៍

ពីនេះទៅ២ខែទៀត យើងច្បាស់ជាឈ្នះហើយ, លោកទីប្រឹក្សា, ច្បាស់ជាឈ្នះ! ឥឡូវខ្ញុំត្រូវការយន្តហោះ B52 ចំនួន ៥០ថែមទៀត។

**គីស៊ីងហ្គ័រ**

លោកលែរដឺ, ត្រូវរកឲ្យបានមកឲ្យខ្ញុំ។

**លែរដឺ**

មានត្រូវការស្អីទៀតទេ?

**គីស៊ីងហ្គ័រ**

រកយន្តហោះឲ្យគ្រប់គ្រាន់ឲ្យខ្ញុំ, ឮទេលោកលែរដឺ? បើចាំបាច់, យកមកពីអឺរ៉ុបប៉ុន្មានសិនក៏យកមក។ ខ្ញុំត្រូវតែធ្វើម៉េចឲ្យឈ្នះសង្គ្រាមដើម្បីលោកប្រធានាធិបតី។ ត្រូវអុជអាស៊ីឲ្យខ្លោចម្តង, ឲ្យចប់រឿង។

**លែរដឺ**

យើងកំពុងសម្លាប់អ្នកជម្ងឺហើយ។

**គីស៊ីងហ្គ័រ**

គិតទៅ, លោកប្រធាធិបតីត្រូវតែមានជនក្បត់នៅជាមួយរហូតទៅឬយ៉ាងណា? ខ្ញុំត្រូវការរដ្ឋមន្ត្រីដែលមិនមែនជាមនុស្សកំសាកញី! ខ្ញុំត្រូវការ B52 ថែមទៀតយកទៅទុកនៅបាងកក, ស្អែកនេះ, ឮទេលោកលែរដឺ, ត្រូវរកឲ្យខ្ញុំ។ ត្រូវបាញ់ទម្លាក់លើស្រុកខ្មែរ, លោកអាប្រាមស៍! បាញ់ទម្លាក់តាមតែចិត្តចង់!

**អាប្រាមស៍**

បាញ់, បាញ់!

**លែរដឺ**

កម្ពុជាមិនមែនវៀតណាមទេ!

**គីស៊ីងហ្គ័រ**

នែលោកអាប្រាមស៍, សូមតម្រង់កាំភ្លើងទៅលោកលែរដឺ! ត្រូវបាញ់ជនក្បត់! បញ្ចប់រឿងនេះទើបបាន! ឲ្យចប់!

*(លែរដឺដើរចេញទៅ)*

**អាប្រាមស៊**

ជាំង, ជាំង, ជាំង, ជាំង! តែប៉ុណ្ណោះច្បាស់ជាចប់ហើយ ចម្បាំងនៅវៀតណាម! ចប់ The end!

*(ទាំងពីរនាក់ដើរចេញទៅ)*

## ឆាកទី២

*(មូស្គូ។ ព្រះសីហនុយាងចូលមកជាមួយអ្នកម្នាងនិងលោកជាសាន, ទូតកម្ពុជានៅមូស្គូ)*

### ព្រះសីហនុ

លោកទូត, លោកក៏ដូច្នេះដែរ, សូមចេញទៅក្រៅសិន។

*(លោកទូតចេញក្រៅ)*

នាងមានសង្កេតទេ, នៅឯនេះនរណាក៏ហាក់ដូចជាព្រលឹងមិននៅនឹងរូប, ហើយទឹកមុខមើលមកយើងរបៀបជាកំញើញផង។ ចិញ្ចើមជ្រួញនោះ ប្រៀបបានទៅចម្រឹងរបាដែលគេជ្រកនៅពីក្រោយដោយសារខ្លាចគ្រោះថ្នាក់។

### អ្នកម្នាង

ខ្ញុំម្ចាស់មិនដែលឃើញព្រះអង្គព្រះភក្ត្រស្លេកដូច្នេះសោះ។ អ្នកអស់នោះបានគម្រាមព្រះអង្គឬអ្វី?

### ព្រះសីហនុ

*ទេ! តែថាមែនក៏បាន។ បងបាននិយាយថា៖ "អស់លោកអាចប្រាប់ទៅមិត្តវៀតណាមរបស់អស់លោកថាឲ្យល្មមៗបានហើយ, នៅតាមទល់ដែនបានដែរឬទេ?" គេឆ្លើយខ្លាំងៗថា៖ "យើង? សូវៀត?", "លូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងនៃវៀតណាម? ទេ, ទេ, យើងមិនធ្វើអន្តរាគមប្រវេងប្រវាងយ៉ាងដូច្នោះទេ! ម្នាក់ៗគ្រប់គ្រងខ្លួនដោយខ្លួនឯង។ រឿងវៀតណាមមិនមែនជារឿងយើងទេ"។ ពួកអស់នេះ, បើនិយាយពីការលាក់ពុត, គឺគួរតែឲ្យមេដាយមាសអូឡាំពិកទើបសម!*

### អ្នកម្នាង

ខ្ញុំម្ចាស់គិតមកត្រូវមែន។ ក្រៅពីនេះ គេមានសន្យាអ្វីនឹងព្រះអង្គទេ?

### ព្រះសីហនុ

មាន, មិនដែលអត់ទេ៖ គេសន្យាផ្តល់ជំនួយឲ្យបង, ក្រោយពីបងស្លាប់ទៅ។ មុនដំបូងបងនិយាយរឿងប្រាប់គេទាំងអស់ដោយត្រង់ៗ។ គឺថាកងទ័ពអាចនឹងដាករចេញពីបង ដោយសារមេទ័ពយើងស្តាយសព្វាវុធទំនើបរបស់អាមេរិកាំង ដែលបងពុំដែលរវីរវល់។ ប៉ុន្តែបងបន្ថែមថា បើមានសព្វាវុធរុស្ស៊ីមកទាន់ពេល, ទាហានយើងនឹងធូរចិត្តវិញ ហើយអាចនឹងបែបចុងកាំភ្លើងទៅទិសត្រឹមត្រូវវិញផង។ គេបាត់មាត់ស្ងាត់

យ៉ាងយូរ, ស្ងាត់ដូចចោរលួចសេះអញ្ចឹង, ហើយទើបនាយករដ្ឋមន្ត្រីគេចេញពាក្យសរសើរប្ដី, ពីការដែលប្ដីនិយាយត្រង់ៗឲ្យងាយស្ដាប់។

**អ្នកម្នាង**

គេមិនឲ្យជំនួយអ្វីទាំងអស់ឬយ៉ាងម៉េច?

**ព្រះសីហនុ**

ឲ្យ! ឲ្យអាវុធ, ឡានកាមីញ៉ុង, សម្ភារៈ។

**អ្នកម្នាង**

ឲ្យអង្កាល់?

**ព្រះសីហនុ**

អង្កាល់? បងក៏សួរគេដែរថាអង្កាល់។
គេឆ្លើយថាប្រហែល៦ទៅ៨ខែទៀត។
បងថា៖ "ឯកឧត្តម, កុំថាឡើយដល់ទៅ៦ខែ, តែ៦អាទិត្យទៀតក៏យឺតពេលទៅហើយ!
ហើយបងនិយាយស្រែកថា៖ "តែ៦ថ្ងៃទៀតខ្ញុំស្លាប់ទៅហើយក៏មិនដឹង! ខ្ញុំកំពុងតែស្រេកទឹកខះក, ខ្ញុំសូមទឹកទទួលទាន, លោកឆ្លើយថាចាំមើល៦ខែទៀត!"
បងចង់តែត្រឡប់ចូលស្រុកវិញឲ្យឆាប់។ ឱ!កម្ពុជារបស់ខ្ញុំ, សួនច្បារដ៏ត្រកាលដែលឥឡូវត្រូវគេពាត់, ផ្ទះសម្បែងខ្ញុំ ដែលគ្មានអ្វីការពារ, ឱ!កូនទ្វីបអាស៊ីរបស់ខ្ញុំ...

**អ្នកម្នាង**

យើងឈប់មកជួបពួកមនុស្សព្រៃនេះទៀតទៅ, វាគ្រាន់តែជារុស្ស៊ីតែប៉ុណ្ណោះ។ មិនអីទេ, នៅស្ដារបាន, គឺនៅស្រុកចិនទៀត។

**ព្រះសីហនុ**

នៅស្រុកចិនទៀត។ ប៉ុន្តែខ្ញុំគួរអរឬគួរព្រួយ?

*(លោកជា សានចូលមក)*

**ជាសាន**

ក្រាបទូល, រថយន្តផ្លូវការមកហើយ។ លោកនាយករដ្ឋមន្ត្រីកុស៊ីហ្គីនក៏អញ្ជើញមកដែរ ដើម្បីអមដំណើរព្រះអង្គទៅវាលយន្តហោះ។

**ព្រះសីហនុ**

មើល! ធ្វើទឹកមុខឲ្យធម្មតាស្រួលបួលវិញបានទេ, លោកទូត, ហើយអមដំណើរយើងទៅផង។

**ជាសាន**

ដោយរីករាយបំផុត, ក្រាបទូល។

**ព្រះសីហនុ**

ឱ! ធ្វើម៉េចឲ្យដល់ស្រុកចិនភ្លាម, ហ្ន!

*(លោកកូស៊ីហ្គីននិងសហការីចូលមក)*

*(មានបន្ទូលទៅអ្នកម្នាង)*

មុខស្លេកស្លាំងណាស់, លោកកូស៊ីហ្គីននេះ។ ម្ដេចគេពុំរកនរណាជម្រុងឲ្យធ្វើនាយករដ្ឋមន្ត្រី ដើម្បីកុំឲ្យគេឯងមើលទៅខ្លាចចង់រត់យ៉ាងនេះ?

**កូស៊ីហ្គីន**

*(និយាយរុស្ស៊ី)*

សម្ដេច, យន្តហោះត្រៀមចាំព្រះអង្គស្រេចបាច់ហើយ។ ទូលបង្គំសូមទូលយ៉ាងខ្លីបំផុតថា៖ ទូលបង្គំសោកស្ដាយជាពន់ពេកដោយត្រូវឲ្យព្រះអង្គជ្រាបថា គេទម្លាក់ព្រះអង្គពីតំណែងហើយ។

*(គេប្រែភាសា)*

**ព្រះសីហនុ**

ទម្លាក់!

**អ្នកម្នាង**

ទម្លាក់!

### ព្រះសីហនុ

*ទំ..លាក់! ឱ ម្ចាស់ថ្លៃ! សម្លាប់ខ្ញុំវិញមក, ល្អជាង, កុំឲ្យខ្ញុំខ្មាសគេ។*
ទម្លាក់ពីដំណែង, ទៅមិនរួចទេ, ឯកឧត្តម, ធ្វើនេះខុសច្បាប់ទាំងស្រុង។

### កុស៊ីហ្គីន

*(និយាយជារុស្ស៊ី)*

ខុសច្បាប់ពិតហើយ, សម្ដេច, ប៉ុន្តែទម្លាក់ហើយមែន តាមសំណូមពររដ្ឋាភិបាលព្រះអង្គ។ ហើយថែមទាំងទទួលស្គាល់ដោយសភាទាំងពីររបស់ព្រះអង្គផង។

*(អ្នកប្រែភាសា)*

### ព្រះសីហនុ

អំពើក្បត់ដល់កំពូលនោះ កើតឡើងពីពេលណា?

### កុស៊ីហ្គីន

*(និយាយជារុស្ស៊ី)*

ម្សិលមិញ។

### ជា សាន

ម្សិលមិញព្រឹក, ក្រាបទូល។

### ព្រះសីហនុ

អញ្ចឹងគឺលោកជាសានឯងដឹងដែរ? ឱ! អញ្ចឹងហើយបានជាធ្វើមុខសស្លេកដូចខ្មោច! លោកដឹងហើយមិនប្រាប់ខ្ញុំទៀត?

### ជា សាន

ក្រាបទូល, យ៉ាងដូច្នោះមែន....ទេ, ក្រាបទូល។ នេះគឺមកពីទូលព្រះបង្គំកើតទុក្ខខ្លាំងពេក។

### អ្នកម្នាង

ព្រះករុណា, សូមព្រះអង្គកុំឲ្យរឿងនេះមកញាំញីយើងបានឲ្យសោះ។

### ព្រះសីហនុ

ញាំញី? បងមិនចេះរីងរៃទេ, ពេលមានរឿងគ្រោកអរខ្លាំងនិងពេលមានទុក្ខខ្លាំងនេះហើយ, ដែលចិត្តបងហោះខ្ពស់ត្រដែតឡើង។ លោកនាយករដ្ឋមន្ត្រីកុស៊ីហ្គីន, យើងសល់ពេលតិចណាស់មុននឹងខ្ញុំចេញទៅប្រទេសចិនបន្តិចទៀតនេះ។ ខ្ញុំសូមសួរលោកខ្លីយ៉ាងកំបុតថា លោកមានបំណងធ្វើអ្វី ដើម្បីប្រទេសខ្ញុំ?

### កុស៊ីហ្គីន

*(និយាយរុស្ស៊ី)*

យើងពុំទាន់មានពេលពិគ្រោះគ្នានៅឡើយទេ។

*(គេបកប្រែ)*

### ព្រះសីហនុ

បើខាងលោកមិនធ្វើអ្វីយ៉ាងរួសរាន់ទេ, គឺច្បាស់ជាប្រទេសចិនហើយដែលនឹងបង្ហាញពីទឹកចិត្តមិត្តភាពខ្ពង់ខ្ពស់មករកយើងខ្ញុំ។ ពេលនោះលោកអាចនឹងអាប់ឱនមុខមាត់ជាមួយសម្ព័ន្ធមិត្តផ្សេងៗរបស់លោក។

### កុស៊ីហ្គីន

*(និយាយជារុស្ស៊ី)*

ចិនគាំទ្រសីហនុដរាបណាសីហនុមានអំណាច។ ប៉ុន្តែឥឡូវគេរំលំព្រះអង្គហើយ...

*(គេបកប្រែ)*

### ព្រះសីហនុ

រំលំដួល? មិនមែនអញ្ចឹងទេ។ សីហនុក៏មិនដួល, កម្ពុជាក៏មិនដួលដែរ។ យើងទាំងពីរគ្រាន់តែបែកគ្នាទេតើ។ គ្មានអំពើក្បត់ណាមួយ, គ្មានមហាអំណាចណាមួយ ធ្វើមិនឲ្យសីហនុនិងកម្ពុជាជួបគ្នាក្នុងពេលមុខបានទេ។ ទៅយើង! ទៅប្រទេសចិន។

*(ទាំងអស់គ្នាចេញទៅ)*

## ឆាកទី៣

*(ភ្នំពេញ។ ព្រះរាជវាំង។ ព្រះមហាក្សត្រិយានីកុសមៈ យាងមកជាមួយអ្នកមុំសាវ៉េ)*

ព្រះកុសមៈ

ទៅបាត់ហើយ? អ្នកទស្សន៍ទាយយល់សប្តិខ្ញុំ, ហោរាខ្ញុំទៅបាត់ហើយ?

មុំសាវ៉េ

ក្រាបទូល, យើងបានទៅរកនៅគ្រប់វីឡាគាត់។ គ្មានវីឡាណាមួយមានឥវ៉ាន់ទេ, ក្រហេតទាំងអស់។ គាត់ទៅប្រទេសបារាំងបាត់ហើយ, ក្រាបទូល, ទៅរហូត។ ហ្លួងម៉ែកុំខ្វាល់នឹងខ្ញុំម្ចាស់។

ព្រះកុសុមៈ

នៅឲ្យស្ងប់ស្ងៀម, ណាអ្នក! គ្រោះទាំងប៉ុន្មានធ្លាក់មកនៅលើខ្ញុំនេះហើយ ខ្ញុំត្រូវតែកោរសក់។ ឃើញទេ, ឥឡូវនេះវា រោទិ៍មកដល់ក្រោមបង្អួចយើងតែម្តង។ អ្នកសាវ៉េឃើញទេ, រថក្រោះទាំងនេះ។

មុំសាវ៉េ

ព្រះម៉ែម្ចាស់, វានៅពាសពេញគ្រប់កន្លែង។ វាពាត់អាគាររដ្ឋាភិបាល, ក្រសួង, អាគារសាធារណៈបានអស់ហើយ, វាឈប់នឹងថ្កល់, លែងទៅណាទៀត។

ព្រះកុសុមៈ

យីឯងនេះ, អ្នកសាវ៉េឯងនេះ! ខ្ញុំមិនភ្លេចទេ ដែលបណ្តោយឲ្យខ្ញុំផ្ញើទូរលេខទៅកូន, ធ្វើឲ្យកូនឃ្លាតឆ្ងាយពីខ្ញុំ។

មុំសាវ៉េ

ទូរលេខ! ខ្ញុំម្ចាស់មិនទាំងដឹងថាហ្លួងម៉ែផ្ញើទូរលេខផង! ខ្ញុំម្ចាស់ស្មានតែសម្តេចត្រូវយាងមកវិញ។ បើខ្ញុំម្ចាស់ដឹង, គឺខ្ញុំម្ចាស់ច្បាស់ជាឃាត់ហ្លួងម៉ែកុំឲ្យផ្ញើ, ពីព្រោះខ្ញុំម្ចាស់យល់ថា ដែលផ្ញើទៅនោះ, គឺហ្លួងម៉ែស្តាប់តាមពួកសេអ៊ីអា, ហើយមិនតែប៉ុណ្ណោះស្តាប់ហោរាចង្រៃដែលឥឡូវនេះរត់ចោលហ្លួងម៉ែទៅទៀត។

ព្រះកុសុមៈ

អើមែន, អញ្ចឹងមែន! ចូលខ្លួនឯងណាស់, ម៉េចបានទៅជាធ្វើអញ្ចឹង? ស្មានតែធ្វើនោះត្រឹមត្រូវ!

**មុំសាវ៉េ**

ដូច្នេះ ព្រះម៉ែម្ចាស់យាងសម្ដេចមកវិញមក, ប្រហែលមិនទាន់ជ្រុលពេលទេដែលឲ្យបញ្ញាផ្ទុយវិញដូច្នេះ។ ទុកឲ្យខ្ញុំម្ចាស់ធ្វើ។

**ព្រះកុសុម:**

យាងកូនមកវិញ! អឺអញ្ចឹងហើយ, យាងមកវិញ, ខ្ញុំចង់ឲ្យយាងមកវិញ! ទៅ, លឿនឡើងអ្នក។ ទៅធ្វើតាមរយៈស្ថានទូតបារាំងទៅ។

**មុំសាវ៉េ**

ខ្ញុំម្ចាស់រត់ទៅធ្វើភ្លាមនេះឯង!

*(មុំសាវ៉េចេញទៅ)*

*(ទាហានម្នាក់ចូលមក)*

**ទាហាន**

ព្រះករុណាថ្លៃវិសេស, មាននារសារម្នាក់របស់លោកឧត្ដមសេនីយលន់នល់មក។

**ព្រះកុសុម:**

ឲ្យគេចូលមកចុះ, ខ្ញុំទទួល។

*(ទាហានចេញទៅ)*

*(អនុសេនីយឯក ស៊ឹម ណាវ៉ាង, នារសាររបស់*
*ឧត្ដមសេនីយលន់ នល់ចូលមក, បន្ទាប់មកគឺ អ្នកមុំសាវ៉េ)*

លោកមកពីខាងណា?

**ស៊ឹម ណាវ៉ាង**

អនុសេនីយឯកស៊ឹម ណាវ៉ាង, ព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំជាអង្គរក្សលោកឧត្ដមសេនីយលន់នល់។

**ព្រះកុសុម:**

មានប្រសាសន៍មក, ខ្ញុំចាំស្ដាប់, លោកនារសារ។

### ស៊ីម ណាវ៉ាង

ព្រះករុណាថ្លៃវិសេស, ឯកឧត្តម ឧត្តមសេនីយលន នល់ បញ្ជូនទូលព្រះបង្គំឲ្យមកគាល់ទាំងព្រឹកព្រលឹមយ៉ាងនេះ មកពីលោកសូមព្រះរាជទានទោសពីព្រះអង្គ។ លោកឧត្តមសេនីយខ្វល់លំបាកចិត្តក្រៃលែង ដែលបង្ខំចិត្តត្រូវតែធ្វើការទម្លាក់ពីដំណែងនោះ ដើម្បីប្រទេសជាតិ។ មានតែការប្រណីសណ្ដោសមិនយកទោសពីសំណាក់ព្រះករុណាថ្លៃវិសេសប៉ុណ្ណោះ ដែលអាចឲ្យចិត្តត្រង់បរិសុទ្ធរបស់គាត់ស្ងប់បាន។

### ព្រះកុសុមៈ

លោកសក្តិបី, ក្នុងឋានៈជាព្រះមហាក្សត្រីយានី, ខ្ញុំមិនអាចអត់ទោសឲ្យលន់ នល់ជនក្បត់ទេ ព្រោះជននោះលួចយកឈាមជ័រប្រទេសយើង ដែលហូរសព្វសរសៃក្នុងខ្លួនខ្ញុំ។ ធ្វើនេះមិនមែនដោយស្រឡាញ់ជាតិទាល់តែសោះ ឡើយ, គឺដោយសារចិត្តលោភលន់។ ស្ដេចមិនដែលនៅក្នុងគណបក្សណាមួយទេ, តែពេលនេះខ្ញុំនៅខាងបក្សកូនខ្ញុំ។

### ស៊ីម ណាវ៉ាង

សូមព្រះអង្គថ្លឹងថ្លែងព្រះសុវនីនៅមុខទូលព្រះបង្គំបន្តិច។ នរណាក៏ដោយដែលប្រកាសថានៅខាងអតីតប្រមុខរដ្ឋរបស់យើងគឺជាជននៅក្រៅច្បាប់តាំងពីថ្ងៃនេះទៅ, ទោះបីអ្នកនោះជាព្រះអង្គក៏ដោយ។ សារមានតទៅទៀតគឺថា ៖ ទូលបង្គំទទួលបញ្ជាមកឲ្យទូលថ្វាយព្រះអង្គថា បើជាអកុសលព្រះអង្គមិនយោគយល់លោកឧត្តមសេនីយ៍ទេ, លោកឧត្តមសេនីយក៏នឹងដកសេចក្ដីទុកចិត្តរបស់លោកវិញដែរ។

### ព្រះកុសុមៈ

និយាយឲ្យងាយស្ដាប់មក គឺថាម៉េច?

### ស៊ីម ណាវ៉ាង

ថាលោកឧត្តមសេនីយ៍នឹងបង្ខំចិត្តខ្លួនឯង រំលាយរាជាធិបតេយ្យ។

### មុំ សាវៃ

ស្អីអញ្ចោះ? មើល, ឲ្យគាត់ធ្វើលមើល?

### ស៊ីម ណាវ៉ាង

លោកស្រី, លោកឧត្តមសេនីយ៍មិនរារែកទេ, អាចធ្វើល្ងាចនេះតែម្ដងក៏បាន។

លោកចោទព្រះអង្គថា ចូលដៃយួន ហើយឲ្យគេចាប់ព្រះអង្គភ្លាម។ ពេលនោះព្រះអង្គលែងបានជួបព្រះរាជបុត្រហើយ, ចៅៗ ក៏លែងបានជួបដែរ។ ទូលព្រះបង្គំសូមព្រះរាជទានទោស ដោយគោរព។ ប៉ុន្តែសូមព្រះករុណាជាអម្ចាស់មានព្រះសុវទីអ្វីល្អទៅលោកឧត្ដមសេនីយ៍ផង, ក្រាបទូល។

**ព្រះកុសុមៈ**

*លោកសក្ដិបី, សូមលោកយកទំនាយខ្ញុំទៅជម្រាបចៅហ្វាយលោកចុះ ថា៖*
*លន់នល់! ដោយសារឯងបែមកប្រឆាំងជាមួយម្ចាស់ឯងនោះ*
*អ្វីៗទាំងអស់នឹងប្រែជាសត្រូវចំពោះឯងវិញ*
*បើឯងមានថ្ពក, ថ្ពកនោះនឹងខាំឯង*
*បើឯងមានកាំបិត, កាំបិតនោះនឹងកាត់ម្រាមដៃឯង*
*បើឯងមានពួកម៉ាក, ពួកម៉ាកនោះនឹងចាក់សម្លាប់ឯង*
*ឯងនឹងមិនទុកចិត្តសិរិមតៈ ហើយនឹងដេកលែងលក់រហូតដល់ថ្ងៃស្លាប់។*

**ស៊ឹម ណាវ៉ាង**

*ព្រះករុណាថ្លៃវិសេស... យីអភ័ព្វមែន, អភ័ព្វមែន!*

**ម៉ុំ សាវ៉ៃ**

*ចេញទៅភ្លាម! ឲ្យលឿន! ព្រោះខ្ញុំមិនមែនចិត្តល្អដូចទឹកព្រះទ័យហ្លួងម៉ែទេ!*

*(ស៊ឹមណាវ៉ាងចេញទៅ)*

*(អ្នកទាំងពីរចេញទៅដែរ)*

# ឆាកទី៤

*(នៅលើយន្តហោះកាត់ទីបអាស៊ី, ពីមួស្គូទៅប៉េកាំង។ ព្រះសីហនុ និងអ្នកម្នាង យាងចូលមក)*

**អ្នកម្នាង**

*អើហ្ន! បើយើងផ្តាច់ខ្លួនពីរឿងអស់នេះបាន, ឃើញថាស្រួលមែន!*

**ព្រះសីហនុ**

*បងចេះតែឃ្លាតចាកពីធម៌ព្រះពុទ្ធអង្គពេក។ កម្មអាក្រក់របស់បង គឺមកពីបារាំងយកមកឲ្យសោយរាជ្យ។ មុន នោះបងជាក្មេងដែលសប្បាយរីករាយរកអ្វីប្រៀបគ្មាន។ ខ្វាចតែរឿងមួយទេកាលនោះ គឺប្រឡងបាក់ (Bac)។ ឥឡូវនេះ ធ្វើម្តេចក៏លប់បំបាត់ការស្រមៃដែលដុះក្រោយមកទៀតក្នុងចិត្តចោលវិញមិនកើត ដែរ។ បងក្លាយទៅជាប្រទេសកម្ពុជាតែម្តង។ បងជាទន្លេ, ជាស្រែ, ជាត្នោត, ជាអ្នកស្រែទាំងអស់ ដែលផ្គុំគ្នា ទាំងអស់ទៅកើតជាកម្ពុជា, មានន័យថាកើតជាខ្លួនបង។ ធ្វើម៉េចឲ្យភ្លេចគំនិតនេះ ដើម្បីមានជីវិតផ្សេង ទៀតវិញ? តែមិនដឹងធ្វើម៉េច, មានតែស្លាប់សិន។ នាងសុខចិត្តស្លាប់តាមបងទេ?*

**អ្នកម្នាង**

*ព្រះករុណាសុំឲ្យខ្ញុំម្ចាស់ទៅតាម, មែនទេ?*

**ព្រះសីហនុ**

*បើនាងព្រមសុខចិត្ត, យើងនឹងចាប់ជាតិឡើងវិញជាមួយគ្នា។ បើកើតជួបគ្នាឡើងវិញ នាងចង់ធ្វើអ្វីឬក្លាយ ជាអ្វី?*

**អ្នកម្នាង**

*ជាអ្វី? ជាស្រីទៀត, ហើយជាប្រពន្ធព្រះអង្គទៀត។ មែន, គឺអញ្ចឹងមែន។ ខ្ញុំម្ចាស់ចង់ទៅជាអ្នកគំនូរ។*

**ព្រះសីហនុ**

*បើកុំតែមានព្រហ្មលិខិតចារមក ហើយបើគ្មានបារាំងទេ, បងទៅជាអ្នកផ្លុំសាក់សូហ្វូន (saxophone) យ៉ាងល្បីម្នាក់។*

**អ្នកម្នាង**

ឬមួយជាអ្នកទាត់បាល់ក៏មិនដឹង។

**ព្រះសីហនុ**

មែន, ប្រហែលជាអញ្ចឹងមែន។

**អ្នកម្នាង**

ឬមួយក៏អាចជាអ្នកចុងភៅម្ហូបចិន ក៏ថាបាន!

**ព្រះសីហនុ**

ចិន?...

និយាយនេះធ្វើឲ្យប្តីភ្ញាក់ពីយល់សប្តិវិញហើយ។

**អ្នកម្នាង**

ព្រះអង្គខ្លាចស្រុកចិនឬអ្វី? គ្មានអ្វីគួរឲ្យខ្លាចសោះ។ លោកដូអេនឡាយ គ្រាន់តែញញឹមបន្តិចមកច្បាស់ជាព្រះអង្គស្រួលព្រះទ័យវិញភ្លាម។

**ព្រះសីហនុ**

បងចង់ឲ្យតែបានជួបគាត់ភ្លាមនេះឯង។ គាត់ជាមនុស្សពិសេស, មានអ្វីមួយដែលទាក់ទាញយើង, មិនខុសពីនាងតួកុន Greta Garbo ទេ។ កាលបានជួបគាត់លើកទីមួយ, គាត់ទទួលបាយបង។

បងមិនដែលឃើញប្រុស ណា ស្អាតសង្ហាយ៉ាងនេះសោះ។ ពេលគេលើកម្ហូបទីមួយមកដល់តុ

បងហាក់ដូចជាត្រូវស្នេហ៍អ្វីមួយ អញ្ចឹង។ តិច លោកគាត់ក្បត់បងដែរទេដឹង?សម្តេចប៉ែន នុត, សម្តេចប៉ែន នុត? យើងនៅឯណាហ្នឹង? ម៉ោង ប៉ុន្មានហើយ?

**ប៉ែន នុត**

តែ១ម៉ោងទៀត យើងដល់ប៉េកាំងហើយ, ក្រាបទូល។

**ព្រះសីហនុ**

មួយម៉ោងទៀត? សម្តេច, ឲ្យតែទៅដល់ភ្លាមខ្ញុំនឹងផ្ញើសារយ៉ាងត្រចះត្រចង់មួយទៅប្រជារាស្ត្រយើង។

ខ្ញុំនឹងនិយាយថា៖

នែ, កូនចៅខ្ញុំ មក-វិញ-ហើយ, មែនទេ?

យី, ឯណាទៅប្រជាជនខ្ញុំ?

ប្រជាជនខ្ញុំទៅណា?

ឯខ្ញុំវិញ, ខ្ញុំទៅណាដែរ? ពេលណាទៅទើបខ្ញុំជួបប្រជាជនខ្ញុំ?

ពពកយ៉ាងក្រាស់ពាសជុំជិតមេឃ ធ្វើឲ្យដីនេះស្អុះស្អាប់រកតែច្លងទៅដីត្រជាក់ត្រជុំមិនបាន!

*(ទាំងអស់គ្នាចេញទៅ។ ពពកក៏រសាត់ទៅដែរ)*

# ឈុតទី៥

## ឆាកទី១

*(ប៉េកាំង។ វាលយន្តហោះ។ លោកដូ អេនឡាយ, លោកលីវ កៀង និងលោកទូតខ្មែរនៅប៉េកាំងចូលមក)*

**លោកទូត**

ឯកឧត្តមដ៏ខ្ពង់ខ្ពស់, ខ្ញុំទទួលបញ្ជាពីរដ្ឋាភិបាលថ្មីនៅភ្នំពេញឲ្យជម្រាបមកឯកឧត្តមជាផ្លូវការពេញលេញថា គេដកសម្តេចសីហនុចេញពីដំណែងហើយ។

**ដូ អេនឡាយ**

ខ្ញុំសោកស្តាយណាស់, លោកឯកអគ្គរាជទូតកម្ពុជានៅប៉េកាំង, គ្មានអ្វីបង្ខំលោកឲ្យនាំពាក្យព្រហើននេះមកខ្ញុំទេ។ យើងគ្មានដូរផ្លាស់អ្វីទាំងអស់, សូមឯកឧត្តមជ្រាប។ ប្រទេសចិននៅតែជាមិត្តនៃមិត្តសីហនុរបស់ខ្ញុំ។

**លោកទូត**

ឱ, ឯកឧត្តមដ៏ខ្ពង់ខ្ពស់បំផុត, ស្តាយណាស់, បើកុំតែសម្តេចយឺតយ៉ាវយ៉ាងនេះ!

**ដូ អេនឡាយ**

តាមពិតទៅ, ខ្ញុំខ្លួនឯងក៏ក្រហល់ក្រហាយចិត្តដែរ ក្នុងអាទិត្យនេះ, ដោយឃើញថា សម្តេចសីហនុជាមិត្តបណ្តែតបណ្តោយព្រងើយធ្វើហី, នៅពេលដែលវាយោបោកបក់លើផ្ទៃទឹកយ៉ាងខ្លាំងនោះ។

**លោកទូត**

សម្តេចមិនសូវខ្វល់ទេ, ទុកចិត្តវាសនាព្រះអង្គខ្លាំងពេក, ជួនកាលពេលបើកនាវា, គឺលែងចង្កូតចោលទៅតែងចម្រៀងធ្វើមិនដឹង! លោកនាយករដ្ឋមន្ត្រី, ខ្ញុំទ្រាំរង់ចាំអស់ចិត្តអស់ចង់ហើយក្រែងមានសេចក្តីសម្រេចអ្វីមួយ។ ព្រឹកមិញនេះ ខ្ញុំត្រូវតែទទួលខុសត្រូវលើវាសនាបុគ្គលិករបស់ខ្ញុំ, ព្រោះជម្លោះនេះគ្មានពាក់ព័ន្ធអ្វីនឹងពួកគេទេ។ ខ្ញុំឲ្យសេរីភាពពេញទីទៅម្នាក់ៗ ឲ្យជ្រើសរើសផ្លូវដើរ។ ទាំងអស់គ្នា គេសម្រេចចិត្តទៅស្រុកវិញ ព្រោះមិនទាន់ហួសពេលនៅឡើយ។

**ដូ អេនឡាយ**

ចុះលោកវិញ?

**លោកទូត**

ខ្ញុំក៏អញ្ចឹងដែរ លោកនាយករដ្ឋមន្ត្រី។ យើងស្នេហាមាតុភូមិ, ដូច្នេះគ្មានទោសអ្វីនឹងត្រូវនិរទេសខ្លួនទេ។

**ដូ អេនឡាយ**

លោកបោះបង់ចោលមេកើយនៅពេលដែលនឹងត្រូវធ្វើសង្គ្រាម, មែនទេ?

**លោកទូត**

យោបល់យើងវិញ គឺសម្ដេចទេដែលបោះបង់យើងចោល។

**ដូ អេនឡាយ**

មានន័យថា ពេលនេះ គឺទូតរបស់លន់ នល់ដែលកំពុងនិយាយមកខ្ញុំ?

**លោកទូត**

ត្រូវហើយ, ឯកឧត្ដម។ ខ្ញុំបម្រុងនឹងថាដូច្នេះឯង នៅពេលខ្ញុំមកដល់ភ្លាម។

**ដូ អេនឡាយ**

សូមលោកជ្រាបថាប្រទេសចិនមិនទទួលអ្នកនាំសាររបស់លន់ នល់ទេ។ ខ្ញុំស្មានតែខ្លួនឯងកំពុងនិយាយជាមួយ មិត្តរបស់សីហនុ, ឬទេលោក? ឱ! មុខក្រាសអ្វីម្ល៉េះ? ឈរនៅមុខខ្ញុំ ហើយក្លាយខ្លួនវារលើដីជាសត្វជន្លេន, គ្មាន ខ្មាស់គ្មាន អៀនអ្វីសោះ!
លោកទូត, ខ្ញុំមិនទទួលឲ្យលោកជួបទេ។ សូមលោកដកខ្លួនចេញទៅឲ្យបាត់ស្រមោលភ្លាម។

**លោកទូត**

ទៅជាមហាបុរសយ៉ាងម៉េចក៏ចេះតែបានដែរ, កាលណាឈ្មោះថាដូ អេនឡាយហើយ។ ពេលណាដែលលោកក្បត់, គេហៅថាបដិវត្តន៍ឬក៏បន្ទាត់នយោបាយថ្មី។ តែពួកយើងវិញ ដែលនៅក្រោមអំណាចនៃមេដែលចិត្តមិនទៀង, ទាល់តែយើងជាខ្ញុំកញ្ជះដាច់ថ្លៃទើបគេហៅថាមានភក្ដីភាព។

*(គាត់ចេញទៅ)*

### ជូ អេនឡាយ

ឱ, សម្ដេច! ពីថ្ងៃនេះទៅចប់ហើយជីវិតកុមារភាព។

តែពីរថ្ងៃមុននេះសោះ, ដែលអ្វីៗក៏នៅអាចស្រង់ស្មារបាននៅឡើយ។ ខ្ញុំខំនិយាយជាមួយបារាំង, ហើយបារាំងសុខចិត្តយកយន្តហោះដឹកយាងចេញឲ្យផុតមក។ ពេលមកដល់ឯនេះហើយ គឺនឹងមានអនុភាពត្រឡប់ទៅយកអំណាចមកកាន់ក្នុងដៃត្រឹមត្រូវឡើងវិញ។

ពីរថ្ងៃនេះ គឺស្មើនឹង២ពាន់ឆ្នាំនៃរាជាធិបតេយ្យ, ណាសម្ដេច! ហើយចំពោះយើងខ្ញុំជាចិនវិញ គឺបាត់សម្ព័ន្ធមិត្តដ៏ប្រសើរមួយ។ មិត្តឯងក៏អញ្ចឹងដែរ, លីវកៀង, គឺធ្លាប់តែស្រឡាញ់សម្ដេចសីហនុយ៉ាងស្និទ្ធស្នាល, មែនទេ?

### លីវកៀង

គឺមិត្តភាពដែលមិនដែលស្និតស្រពោនពេលណាមួយសោះ, តាំងពី១២ឆ្នាំមកនេះ។

### ជូ អេនឡាយ

ហ្នឹងហើយ, គឺដោយចងចាំឲ្យខ្ជាប់អំពីមិត្តភាពនេះឯង ដែលខ្ញុំសូមឲ្យមិត្តធ្វើដំណើរដ៏លំបាកមួយ។ គឺឲ្យមិត្តឯងទៅជួបលន់ នល់, តាងនាមឲ្យប្រទេសចិន។

ត្រូវធ្វើម៉េចឲ្យលន់ នល់ ព្រមទាំងអស់, គឺអនុញ្ញាតគ្រប់រឿងដូចសម្ដេចជាទីស្រឡាញ់របស់យើងធ្លាប់អនុញ្ញាតយើងដូច្នោះ។ អនុញ្ញាតឲ្យជម្រកដល់មិត្តវៀតណាមរបស់យើង, អនុញ្ញាតឲ្យប្រើកំពង់ផែក្រុងព្រះសីហនុ, ធានាសុវត្ថិភាពដល់ការដឹកជញ្ជូនឥវ៉ាន់យើង។ និយាយឲ្យខ្លីគឺអនុញ្ញាតរាល់អ្វីៗ ដែលយើងត្រូវការ, ដោយគ្មានផ្លាស់ប្ដូរអ្វីទាំងអស់។

### លីវកៀង

ច្បាស់ជាមិនងាយទេ។ គេទម្លាក់សីហនុដោយសាររឿងនេះឯង, ឥឡូវយើងឲ្យលន់ នល់ធ្វើដូច្នោះដដែល! ទាល់តែខ្ញុំចេះធ្វើអាគមដាក់ស្នេហ៍គាត់ទើបទៅរួច។

### ជូ អេនឡាយ

អើ! ដាក់ស្នេហ៍ទៅ! ពេលចរចារ កុំនិយាយច្រើនពេក ហើយត្រូវនិយាយបញ្ចិតបញ្ចៀង, កុំត្រង់ៗពេក។ ត្រូវឲ្យលន់ នល់មើលឃើញថាទឹកមុខនិងអាកប្បកិរិយាមិត្តឯងបង្ហាញពីវិសាលភាពធំធេងដែលមិនអាចមើលធ្លុះនៃមហាអំណាចចិន។

ប៉ុន្តែ, ក្នុងការនិយាយ ត្រូវនិយាយជាអ្នកនយោបាយ, គ្មានយកមនោសញ្ចេតនាមកដាក់នៅមុខ, គឺថាជាការពិតហើយដែលយើងស្រឡាញ់សីហនុ, តែជើងយើងក៏ឈរនៅជាប់ដី, ហើយចេះទទួលស្គាល់ថាមានការផ្លាស់ប្តូរដែរ។

**លេខាធិការម្នាក់**

លោកនាយករដ្ឋមន្ត្រី, យន្តហោះសម្តេចចុះបន្តិចទៀតនេះ។

*(លោកលីវ គៀងចេញទៅ)*

*(យន្តហោះចុះ)*

*(ព្រះសីហនុយាងចូលមក ដោយមានលោកឌិត ប៊ុនសួ និងទូតផ្សេងៗមកហែរហម, ក្នុងនោះមានលោកអេចេន ម៉ាណាក់(Etienne Manac'h) ដែលជាទូតបារាំងប្រចាំប៉េកាំង)*

**ម៉ាណាក់**

សម្តេច, សូមព្រះអង្គកុំអស់សង្ឃឹម, ព្រះអង្គមានមិត្តភក្តិច្រើន។

**ព្រះសីហនុ**

ខ្ញុំមានសត្រូវដែរ, តែទឹកចិត្តខ្ញុំដូចដំរីសារ, ដូច្នេះកុំស្រងូតស្រងាត់លើសខ្ញុំទៀតនោះ។ ខ្ញុំពុំទាន់ចាញ់សង្គ្រាមទេ។ មិនយូរប៉ុន្មានទេខ្ញុំនឹងឈ្នះវិញ។

**ម៉ាណាក់**

ឲ្យតែព្រះអង្គត្រូវការពេលណា, ទូលបង្គំនឹងមកដល់ភ្លាម។

*(ម៉ាណាក់ដើរចេញទៅ)*

**ព្រះសីហនុ**

ឱ! នេះគឺជាមិត្តជូ អេនឡាយដ៏ខ្លាំងក្លា, ជាស្តេចលើរដ្ឋមន្ត្រីទាំងអស់។ តែម៉េចក៏មុខដែលគួរឲ្យគោរពនេះរាងមាំម្ល៉េះ? ខ្ញុំកំពុងសប្បាយចិត្តដែលបានមកដល់នេះ, តិចលោកគេមិនសូវរាក់ទាក់រាប់រកទៅ?

**ជូ អេនឡាយ**

សម្តេច, សូមសម្តេចជ្រាបថាប្រទេសចិននៅតែគាំទ្រនិងស្រឡាញ់ព្រះអង្គដូចធម្មតា។ ព្រះអង្គមិនបាក់ទឹកចិត្តនឹងការក្រឡាប់ចាក់... នេះទេ, មែនទេ?

**ព្រះសីហនុ**

លោកនាយករដ្ឋមន្ត្រី, ខ្ញុំដឹងថាស្ថានភាពខ្ញុំធ្ងន់ធ្ងរដល់ណាឥឡូវនេះ, តែខ្ញុំមិនបង្ហាញឲ្យគេឃើញមានអ្វីផ្លាស់ប្តូរទាំងអស់តាមទឹកមុខខ្ញុំ, ជាពិសេសការព្រួយបារម្ភយ៉ាងខ្លាំងដែលកំពុងញាំញីខ្ញុំ។ ជុំវិញនេះសុទ្ធតែភ្នែកគ្នាតដែលមើលមកយើង។ ខ្ញុំមិនចុះញ៉មទេ។ ខ្ញុំច្បាស់ជានៅមិនយូរទេក្នុងភាពនិរទេសប្រៀបបាននឹងយប់ងងឹតនេះ។

**ជូ អេនឡាយ**

សូមសរសើរភាពក្លាហានរបស់ព្រះអង្គ។ ទូលបង្គំចង់ទូលរឿងខ្លះៗ។ សូមសម្តេចយាងមកតាមទូលបង្គំ។

**ព្រះសីហនុ**

ខ្ញុំតាមលោក, ប៉ុន្តែទាល់តែលោកបញ្ជាក់ឲ្យច្បាស់ថា លោកមិនទឹងនឹងខ្ញុំទេដែលបណ្តែតបណ្តោយ... ឲ្យទៅយ៉ាងនេះ។

**ជូ អេនឡាយ**

មិនទឹងទៀតទេ, ក្រាបទូល។

**ព្រះសីហនុ**

ដូច្នេះ ខ្ញុំលែងភ័យថាមានរឿងធ្ងន់ធ្ងរទៀតហើយ។

*(ទាំងអស់គ្នាចេញទៅ, លើកលែងតែឌិត ប៉ុនសួ, អ្នកក្លែងម្នាក់,*
*និងអនុសេនីយ៍ឯកអ៊ុង មាង, អង្គរក្សសម្តេច។ លោកម៉ាណាក់ចូលមក)*
*(ព្រះសីហនុយាងចូលមក)*

**ម៉ាណាក់**

សម្តេច, ម្តេចក៏ដូចជាបាក់ទឹកព្រះទ័យដូច្នេះ? កាលទើបនឹងយាងមកដល់, ព្រះអង្គរីករាយទេតើ, មើលទៅឃើញថា អនុភាពព្រះអង្គមិនចាញ់មេគ្រាក់ៗលើលោកនេះទេ។

**ព្រះសីហនុ**

ដូច្នេះ, ឥឡូវនេះ ខ្ញុំរួញខ្លួនមកនៅតូចហើយ! មែន, គួរចម្លែកមែន។ តាំងពីខ្ញុំធ្លាក់បុណ្យមក, នរណាក៏ចង់ឲ្យខ្ញុំធ្លាក់កាន់តែទាបទៅទៀតដែរ។ តាំងពីរដ្ឋប្រហារនោះមក, អ្វីៗដែលខ្ញុំគិត ក៏បែកប្រេះជាពីរខាង

ដែលផ្ទុយពីគ្នា។ លោកជាមិត្តខ្ញុំឬទេ? ឯលោកដូ អេនឡាយ, គាត់ជាមិត្តដែលមានភក្តីភាពចំពោះខ្ញុំ ឬក៏ជាមិត្តជិតក្បត់?

**ម៉ាណាក់**

គាត់ជាមិត្តស្មោះស្មគ្រ។

**ព្រះសីហនុ**

គាត់ទើបនឹងនិយាយការជាមួយខ្ញុំ, តែខ្ញុំគ្មានយល់អ្វីទាំងអស់។ គាត់ទទួលខ្ញុំរាក់ទាក់ ណាស់, ប៉ុន្តែនៅពីក្រោយការគួរសមរាក់ទាក់ស្និទ្ធស្នាលនោះ ខ្ញុំឃើញហាក់ដូចជាមានការរាថយបន្តិច។ គាត់ឈរក៏ដូចជាដកឃ្លាពីខ្លួនឯង។ គាត់ឲ្យខ្ញុំនិយាយមិនឈប់មិនឈរពីប្រទេសខ្ញុំ, ប្រទេសរុស្ស៊ី, ប្រទេសខ្ញុំ, ប្រទេសរុស្ស៊ី, ប៉ុន្តែអំពីប្រទេសចិនវិញ ខ្ញុំមិនបានឮអ្វីទាំងអស់។ ក្នុងកិច្ចសន្ទនានោះ, ប្រទេសចិនមានបង្កើប ពាក្យពាម៉ាត់, តែខ្ញុំមិនយល់ថារឿងអ្វីឡើយ។

**ម៉ាណាក់**

គាត់ទូលព្រះអង្គថាដូចម្ដេច?

**ព្រះសីហនុ**

គាត់សួរខ្ញុំថា៖ "សម្ដេចមានបំណងចង់តស៊ូទេ?", ឮតែប៉ុណ្ណឹងភ្លាមខ្ញុំពុះកញ្ជ្រោលឆ្លើយថា៖ "ឲ្យតែអាវុធខ្ញុំមក, លោកនឹងឃើញជាពុំខាន"។ ប៉ុន្តែគាត់ធ្វើឲ្យខ្ញុំអន់កញ្ជ្រោលបន្តិចទៅវិញ ព្រោះគាត់ថា៖ "សម្ដេច, កុំឆ្លើយឆាប់ពេក, សូមទុកពេលគិតបន្តិច។ ចាំ២៤ម៉ោងទៀត ចាំយើងយកមកនិយាយគ្នាទៀត", ថាតែប៉ុណ្ណោះគាត់ក៏ដើរចេញទៅ, ហាក់ដូចជាលែងខ្ញុំឲ្យនៅក្នុងព្រៃតែម្នាក់ឯង។

**ម៉ាណាក់**

តាមយោបល់ទូលបង្គំ, គាត់ពុំអាចនិយាយលើសពីនោះទេ, ព្រោះមិនមែនមានតែគាត់ឯណា, នៅពីក្រោយនោះ មានអ្នកមុខអ្នកការដទៃៗទៀត ដែលយើងមើលពុំឃើញ។ តាំងពី៤ឆ្នាំមកនេះ ស្រុកចិនប្រែប្រួលពុំឈប់ពុំឈរ។ ដើម្បីឲ្យដូ អេនឡាយនិយាយអ្វីមួយម៉ាត់បាន គឺទាល់តែមានការអនុញ្ញាតដប់ម្ដៃនៅពីក្រោយ។

ព្រះសីហនុ

គាត់សម្លឹងមុខខ្ញុំ ហាក់ដូចជាគិតទៅនរណាឬទៅអ្វីផ្សេងទៀត។

ម៉ាណាក់

ប្រហែលជាគិតទៅលន់ នល់ក៏មិនដឹង។

ព្រះសីហនុ

ខ្ញុំក៏គិតថាដូច្នោះដែរ។ ប៉ុន្តែ ម៉េចអញ្ចឹង?

ម៉ាណាក់

ច្បាស់ជាគាត់ទើសទាល់រារែក ដោយសារគាត់ត្រូវបង្ខិចិត្តបញ្ជូនអ្នកនាំសារទៅលន់ នល់នោះ។

ព្រះសីហនុ

ទៅជួបលន់ នល់? អ្នកនាំសារ? បើអញ្ចឹងគាត់ក៏ប្រញាប់ប្រញាល់ដូចគេឯងទៀតដែរ! គាត់ក៏យល់ដូចគេឯងដែរថា ដែលសំខាន់នោះគឺមុខដំណែង! ខ្ញុំនឹងដកខ្លួនថយហើយបើដូច្នោះ។ ប្រទេសបារាំងរបស់លោកនឹងទទួលខ្ញុំទេ?

ម៉ាណាក់

បារាំងច្បាស់ជារីករាយនឹងទទួលព្រះអង្គ, ក្រាបទូល។

ព្រះសីហនុ

អើហ្ន! អត់ប្រទេស, អត់រដ្ឋ, អត់បក្ស, អត់ប្រយោជន៍?

ម៉ាណាក់

ប្រវត្តិសម្ដេចសីហនុមិនទាន់ចប់នៅឆ្នាំនេះទេ, ទូលបង្គំជឿជាក់។ គ្រាន់តែថាឆ្នាំនេះ ជាឆ្នាំមិនល្អ។ ដូច្នេះត្រូវតែលោតរំលងបោះតែមួយជំហានឲ្យផុត, ដូចលោតកន្លងរណ្ដៅធំមួយដែរ។

### ព្រះសីហនុ

ទេ, ខ្ញុំមិនអាចសង្ឃឹមរង់ចាំអ្វីទៀតបានទេ។ ពីថ្ងៃនេះទៅ ខ្ញុំជាមនុស្សពីអតីតកាលហើយ។ ហើយខ្ញុំគ្មានបំណងកូតករខ្លួនឯងថាទៅហើយមកវិញឡើយ។ ឃើញទេ, ខ្ញុំទៅបាត់ហើយ, ខ្ញុំកំពុងរលាយបាត់ខ្លួន។ ថ្ងៃនេះ ថ្ងៃអី?

### ម៉ាណាក់

ថ្ងៃ២២ មិនា, ក្រាបទូល។

### ព្រះសីហនុ

ថ្ងៃ២២ មិនា ១៩៧០នេះ សីហនុសូមជម្រាបលាសាកលលោកទាំងមូល។ លោកម៉ាណាក់ បើស្រឡាញ់ខ្ញុំ សូមជួយរៀបចំឲ្យខ្ញុំចាកចេញដំណើរផង។ ចិនសម្លាប់ខ្ញុំហើយ។ ធ្វើអ្វីៗឲ្យខ្ញុំផង, ខ្ញុំលែងដឹងអ្វីហើយ។ ហើយសូមជួយធ្វើម្ដេច កុំឲ្យគេមើលមកខ្ញុំ, ពេលខ្ញុំកំពុងចាកចេញ។

### ម៉ាណាក់

ទូលបង្គំនឹងរៀបចំដំណើរព្រះអង្គឲ្យស្រួល, ក្រាបទូល។

*(លោកម៉ាណាក់ដើរចេញ)*

*(សម្ដេចប៉ែន នុតចូលមក)*

### ព្រះសីហនុ

ស្មានតែអាចតម្រង់ប្រវត្តិសាស្ត្របាន!
ខំភ្ជួររាស់, ខំប្រយុទ្ធ, ខំខ្លាច, ខំសង្ឃឹម
បានការអីទាំងអស់នេះ? យើងទាំងអស់គ្នាមិនបានស្មើសត្វក្របីផង។ នៅលើក្បាលយើង, គេអ្នកគ្រាក់។ គ្មានស្រឡាញ់យើងសោះ។ គេយកយើងទៅជួញដូរដូចសត្វគោក្របីអញ្ចឹង។ មើលទៅមុខសម្ដេចដូចជាស្លូតខ្លាំង ណាស់។ ខ្ញុំទៅជាយ៉ាងម៉េចទៅវិញ បើដូច្នោះ? មានដំណឹងមិនល្អ, មែនទេ?
បើមាន, ចាប់ប្រាប់ខ្ញុំមកដំណឹងណាដែលអាក្រក់បំផុត។ យ៉ាងណាក៏ពួកវាមិនធ្វើគតម្ដាយខ្ញុំដែរ, មែនទេ?

### សម្ដេចប៉ែន នុត

ទេ, ក្រាបទូល, អត់ទេ។ ព្រះមហាក្សត្រីយានីមិនអាចយាងចេញពីវាំងបានទេ, ប៉ុន្តែព្រះអង្គមានសុខភាពល្អធម្មតា។

**ព្រះសីហនុ**

បើអញ្ចឹងមិនអីទេ, គ្មានដំណឹងអ្វីអាក្រក់ខ្លាំងឡើយ។ ក្រៅពីនេះមានអ្វីខ្លះ?

*(លោកខិត ប៊ុនស្វ និងលោកអុង មាងចេញទៅ)*

**សម្ដេចប៉ែន នុត**

ដែលធ្វើឲ្យទូលបង្គំក្រៀមក្រំ គឺបានដំណឹងព្រឹកមិញនេះថា ទូតយើងទាំងប៉ុន្មាននៅក្រៅ ចុះចូលលន់ ទល់ជាបន្តបន្ទាប់គ្នា។

**ព្រះសីហនុ**

យ៉ាងណាក៏មិនទាំងអស់គ្នាដែរ, ដូចជាគឹម វ៉ាជាដើម។

**សម្ដេចប៉ែន នុត**

គឹម វ៉ាក៏ដូចគេដែរ។

**ព្រះសីហនុ**

ឱ, អញ្ចឹង? ចុះស៊ុម សេង?

**សម្ដេចប៉ែន នុត**

នោះក៏អញ្ចឹង។

**ព្រះសីហនុ**

ខ្ញុំស្មានតែអ្នកទាំងនោះស្រឡាញ់ខ្ញុំ។

**សម្ដេចប៉ែន នុត**

គេមិនដែលស្រឡាញ់ព្រះអង្គទេ។

**ព្រះសីហនុ**

អញ្ចឹងគឺទាំងអស់, មែនទេសម្ដេច? គ្មានទូតណាមួយដែលហ៊ានជ្រើសរើសយកកិត្តិយស។

**សម្តេចប៉ែន នុត**

មានដែរ, ក្រាបទូល, មានម្នាក់។ គឺលោកសាន ដែលនៅប្រចាំមូស្គូ។ គាត់នោះមកតាមយើង។ គាត់បានឲ្យដំណឹងថា គាត់មកដល់ល្ងាចនេះ។

**ព្រះសីហនុ**

*សាន, មែនហើយសាន, មានតែគាត់ប៉ុណ្ណោះ! ក្នុងចំណោមទូតទាំងអស់, សាននោះហើយដែលខ្ញុំធ្វើបាបជាងគេ។ សម្តេច, ក្នុងចំណោមដំណឹងអាក្រក់ទាំងអស់ដែលយកមកប្រាប់ខ្ញុំនេះ មានដំណឹងល្អប្រពៃមួយដែលស្ទើរ តែធ្វើឲ្យខ្ញុំត្រូវគ្នា លែងទឹងនឹងមនុស្សជាតិវិញ។*

*មានសានម្នាក់ដ៏ល្អនេះ។ អ្នកស្មោះម្នាក់ទល់នឹងអ្នកក្បត់៤៤នាក់។ បើមានអ្នកស្មោះតែ ៤ ឬ ៥ ខ្ញុំហ៊ានស្បថនឹងសម្តេចថាខ្ញុំទៅវាយយកភ្នំពេញវិញស្អែកនេះតែម្តង។*

**សម្តេចប៉ែន នុត**

មានដំណឹងផ្សេងទៀត, ក្រាបទូល។

**ព្រះសីហនុ**

*ដំណឹងផ្សេងទៀត?*

**សម្តេចប៉ែន នុត**

ព្រះរាជបុត្រព្រះអង្គទាំងអស់ត្រូវគេចាប់ ហើយអ្នកគាំទ្រព្រះអង្គទាំងប៉ុន្មាន គឺគេលែងឲ្យធ្វើអ្វីកើត ដោយយកទៅដាក់គុក ឬដោយគម្រាមកំហែង។ ប៉ុណ្ណោះហើយនៅមិនអស់ចិត្តទៀត។ វាយល់ថាព្រះអង្គ ខ្ពង់ខ្ពស់គួរឲ្យស្ញែងឥទ្ធិពល, ដូច្នេះហើយបានជាវាមិនត្រឹមតែបិទទ្វារមិនឲ្យព្រះអង្គចូលក្នុងស្រុកវិញប៉ុណ្ណឹងទេ, គឺវាខំរារាំងឲ្យល្អក់កករដល់អ្វីដែលជាស្លាកស្នាមព្រះអង្គ ដោយប្រើវិធីគ្រប់បែបយ៉ាង។ ព្រោះវាគិតថាបើទុកស្លាកស្នាមព្រះអង្គឲ្យនៅដក់ក្នុងថ្លើមប្រម៉ាត់ប្រជាជន គង់តែថ្ងៃណាមួយនឹងរាស្ត្រក្រោកឡើងបង្កើតកលិយុគ។ ដូច្នោះហើយបានជាវាធ្វើយុទ្ធនាការណ៍មួលបង្កាច់សំអុយព្រះនាមព្រះអង្គ។ វាបិតក្រដាស់រាប់ លានសន្លឹកឃោសនាផ្សព្វផ្សាយ ពាក្យចោទអាក្រក់។ ដែលទូលបង្គំមិនអាចនិយាយតាមបានទេ, ព្រោះអាក្រក់ ស្តាប់ពេក, សុទ្ធតែពាក្យថោកទាបល្ងង់ខ្លៅ។ វាយកទៅបិតលើដើមក្បោក, តាំងពីនៅតាមចុងកាត់មាត់ញកឡើងទៅ។

### ព្រះសីហនុ

ហើយគ្មាននរណាម្នាក់ហ៊ានធ្លើយ? គ្មាននរណានិយាយការពារខ្ញុំទេ?
ពួកវាលួចដីខ្ញុំ, ប្រជាជនខ្ញុំ, អំណាចខ្ញុំ
វាបោះខ្ញុំទៅក្នុងអណ្ដូង
ហើយឥឡូវនេះវាចង់បិតថ្លើមប្រម៉ាត់រាស្ត្រ
កុំឲ្យអ្វីដែលនៅសល់ពីសីហនុចូលទៅបាន
មិនមែនគ្រាន់តែដំណែងខ្ញុំទេដែលចង់បាន
មិនត្រឹមតែចង់ឲ្យខ្ញុំស្លាប់ទេ។ វាចង់ឲ្យខ្ញុំដកចង្កាមាន់រៀងរហូត, រហូតដល់កប់ក្នុងអាចម៍វា។
ឥឡូវនេះ មានបីតិសោមនស្សម្យ៉ាងគួរឲ្យរន្ធត់ ដែលកើតឡើងក្នុងចិត្តខ្ញុំ ដូចជាសន្ទុះខ្យល់មួយបោកបក់បោសសំអាតអ្វីៗដូច្នេះដែរ។
ខ្ញុំសម្រេចចិត្តហើយ, សម្ដេច, យើងទៅដឹកនាំប្រជាជនយើងឡើងវិញ។ ខ្ញុំចង់ជួបសាន, ពេលដែលគាត់មកដល់ភ្លាម។ សាន, សម្ដេចនិងខ្ញុំ, យើងនឹងបើកកិច្ចប្រជុំមួយល្ងាចនេះ។ មិនយូរទៀតទេ ខ្ញុំនឹងបំពង សម្លេង ហោះហើរកាត់ភ្នំដែលឆ្លងមកនិរទេស ឲ្យឮទៅដល់ត្រចៀកកម្ពុជា, នរណាក៏ដឹងឮសម្លេងសីហនុ។ ខ្ញុំនឹងទាក់ចិត្តថ្លើមប្រម៉ាត់រាស្ត្រមកវិញ។ ខ្ញុំនឹងប្រកាសសូមឲ្យប្រជាជនខ្ញុំ កាន់អាវុធឡើង។
ថ្ងៃនេះគ្នាយើងមានពនាក់, ស្អែកយើងនឹងកើនឡើងច្រើនពាន់នាក់។

### សម្ដេចប៉ែន នុត

ក្រាបទូល, ដើម្បីឲ្យកើនឡើងរាប់ពាន់នាក់ស្អែកនេះ, ទាល់តែយើងបើកកិច្ចប្រជុំជាមួយពួកកម្មុយនីស្ត៍។ គឺវាជាយួនក្រាបទូល!

### ព្រះសីហនុ

ជាមួយយួន?!! ទេ, ប្រទេសវៀតណាមយ៉ាងណាក៏មិនចិត្តល្អមកចាប់ដៃសីហនុដែរ។ ម៉េចក៏សម្ដេចយល់ប្លែក អញ្ចឹង? មិត្តភាពរវាងប្រជាជនយើងទាំងពីរ មិនអាចកើតឡើងស្អែកនេះទេ។

### សម្ដេចប៉ែន នុត

តែអម្បាញ់មិញនេះ, ក្រាបទូល, ឯកឧត្តមដូ អេនឡាយបានឲ្យគេទាក់ទងទៅហាណូយមុខទូលព្រះបង្គំផ្ទាល់។ គាត់បាននិយាយតែមួយឃ្លាយ៉ាងខ្លី លើកសរសើរព្រះអង្គកប់ពពករហូតដល់ផ្កាយក្រហមថ្ពិនថ្ពោ។

តែមួយឃ្លា យ៉ាងខ្លី គាត់បង្ក្រាបពួកហាណូយក្បាលរឹងនោះបាន។ គឺថាស្អែកនេះ ព្រះអង្គនឹងបានជួបលោក ផាំ វ៉ាន់ដុងនៅទីនេះតែម្តង, ក្រាបទូល។

### ព្រះសីហនុ

ផាំ វ៉ាន់ដុង? ទីនេះ? នៅប៉េកាំង? ស្អែកនេះ?

### សម្តេចប៉ែន នុត

ស្អែកនេះ។ ដោយស្ទាត់កំបាំងបំផុត។ ឲ្យតែព្រះអង្គងក់ព្រះកេសបន្តិចទៅ គាត់នឹងថ្វាយជំនួយកម្មុយនីយស្ត៍ ដែលផុសចេញពីទឹកចិត្តគាត់ភ្លាមៗ, យកមកពីកងទ័ពកុម្មុយនីយស្ត៍យ៉ាងខ្លាំងក្លារបស់គាត់។

### ព្រះសីហនុ

ដូចជាល្អពេក, មិនសមថាជាការពិត។

### សម្តេចប៉ែន នុត

ល្អពេក, ទូលព្រះបង្គំមិនច្បាស់ទេ, តែពិតនោះគឺពិតមែន។

### ព្រះសីហនុ

បើដូច្នេះ យើងត្រូវតែទទួលជំនួយគួរស្ញើបវន្ទត់នៃលោកដូ អេនឡាយចុះ, ព្រោះថាចៀសមិនរួច។ បើនេះ ជាព្រហ្មលិខិត យើងត្រូវតែទទួលដៃពីរដោយរីករាយហើយគ្មានរួញរា។

### សម្តេចប៉ែន នុត

មែនហើយ, ក្រាបទូល។ លើកលែងតែ... អាមេរិកាំងគេស្អាយយើង ហើយគេងាកមកប្រគល់អំណាច ឲ្យយើងវិញ...

### ព្រះសីហនុ

អាមេរិកាំង? យី, យល់សប្តិទេដឹង? បើអញ្ចឹងវង់ចាំឲ្យលន់ នល់អង្វរករឲ្យខ្ញុំទទួលម្កុដសារជាថ្មីទៅល្អ ជាង។ ខ្លាចឬយ៉ាងម៉េចបានជាមានប្រសាសន៍យ៉ាងនេះ? បើធ្វើយ៉ាងនេះ គឺដូចជាសម្លាប់ខ្ញុំអញ្ចឹងដែរ!

### សម្តេចប៉ែន នុត

ទូលបង្គំខ្លាចតែកិត្តិយសអ្វីដែលនាំឲ្យអាប់ឱនតែប៉ុណ្ណោះ។

*(លោកអ៊ុង មាងចូលមក)*

### អ៊ុងមាង

ក្រាបទូល, ទូលព្រះបង្គំមានសារយ៉ាងប្រញាប់បំផុតមួយដែលចិនគេផ្ញើមកថ្វាយព្រះអង្គ។

### ព្រះសីហនុ

សេចក្តីប្រកាសអំពីការគាំទ្រពេញទឹងដោយគ្មានលក្ខខ័ណ្ឌចំពោះព្រះអង្គម្ចាស់នរោត្តម សីហនុ,
ព្រះប្រមុខរដ្ឋ,
អំពីខ្មែរអ្នកតស៊ូក្នុងទឹកដីកម្ពុជា។
ខ្មែរ, គឺអក្សរ ១ , កម្ពុជាគឺអក្សរ ក

*អីយ៉ា! ១, ក, ខ្មែរក្រហម! ខ្មែរក្រហមគាំទ្រសីហនុដោយឥតលក្ខខ័ណ្ឌ?!!*

### សម្តេចប៉ែន នុត

ច្បាស់ជាមានការភាន់ច្រឡំអ្វីមួយហើយ!

### ព្រះសីហនុ

យី, យល់សប្តិឬមែនទែន? ក្រែងលោអរពេកដួលផ្កាប់មុខទេដឹង? ឃើញទេ, សម្តេច, សូមមើល ហត្ថលេខាចុះ, អស់លោក ខៀវ សំផន, ហ៊ូ យន់ ដែលសុទ្ធសឹងជារដ្ឋមន្ត្រីក្រហមរបស់ខ្ញុំ... ហើយ នរណាម្នាក់នោះឈ្មោះលោកប៉ុល ពត។

### សម្តេចប៉ែន នុត

ខៀវ សំផននិង ហ៊ូ យន់។ មិនដែលនឹកស្មានសោះ, ស្មានតែស្លាប់ដូចគេថា!

### ព្រះសីហនុ

យ៉ាងម៉េចក៏ដោយ, ទាំងពីរនាក់នោះ គេយកចិត្តនិងកាយមកថ្វាយខ្ញុំ, មកបម្រើខ្ញុំ។

### សម្តេចប៉ែន នុត

ព្រហ្មលិខិតដូចជាកាន់តែជ្រៅទៅ។, គួរឲ្យបារម្ភ!

### ព្រះសីហនុ

អញ្ចឹងមែន! ខ្ញុំមិនបានគិតប្រាថ្នាដល់ម្ល៉េះទេ
តែណ្ហីយ, ត្រូវតែទទួលយកវាសនាដែលគេចារមកនេះ
យើងនាំគ្នាឱបរិតថើបវាសនានោះឲ្យកាន់តែខ្លាំងទៅទៀត
អព្យាក្រិតសស្ដុះរបស់ខ្ញុំនោះចប់ហើយ, ឥឡូវ!
អាមេរិកល្ងង់ខ្លៅអើយ! ឯងជាយក្សខ្វាក់ភ្នែក, អត់ខួរ, ដូច្នេះហើយបានជាយកប្រជារាស្ត្រនានា
ដែលកំពុងរស់នៅសុខសាន្តក្នុងភូមិស្រុកគេ យកទៅឲ្យនាគក្រហមលេបត្របាក់អស់។
សម្ដេច, ខ្ញុំស្មានថាពួកខ្មែរក្រហមស្អប់ខ្ញុំ។ តាមពិតគេត្រូវការខ្ញុំ, សម្ដេចឃើញទេ? គេត្រូវការខ្ញុំ,
មានន័យថា គេខ្សោយដូចខ្ញុំដែរ។

### សម្តេចប៉ែន នុត

ក្រពើត្រូវការស្បែកស្អាតម៉ត់របស់ព្រះអង្គយកទៅពាសលើខ្លួនដើម្បីឲ្យស្រស់សង្ហា។

### ព្រះសីហនុ

ទេ, សម្ដេច! កុំធ្វើមុខព្រួយស្ដាយ នាំឲ្យខ្ញុំធ្លាក់ទឹកចិត្ត, ពេលដែលខ្ញុំកំពុងតែពុះកញ្ជ្រោលចង់លោតពី
ដែនដីមួយទៅទុំលើដែនដីមួយទៀតយ៉ាងនេះ។ បើពុំដូច្នោះទេ ខ្ញុំនឹងទម្លាក់ខ្លួនចុះឲ្យស្លាប់។
ផ្លូវទាំងអស់ដែលបើកចំហរមកចំមុខខ្ញុំនេះ សុទ្ធតែមិនគួរឲ្យទុកចិត្តដូចគ្នា។ តែខ្ញុំត្រូវការជ្រើសរើសយក
មួយ។ ខ្ញុំនឹងទៅតាមផ្លូវនោះ ក្នុងថ្ងៃមួយដែលមានតែយប់ឥតថ្ងៃ, ដែលសម្បូណ៌ទៅដោយអន្ទាក់។
ទៅ, សីហនុ, ទៅ! ទៅកុំងាកក្រោយ!

### សម្តេចប៉ែន នុត

ឱ! អស់ទេព្ដាទេពនិករដែលរក្សាប្រទេសកម្ពុជា,
អស់លោកដែលនៅតាមព្រៃព្រឹក្សាលតាវល្លិ
តាមជ្រោះជ្រលង, តាមផ្លូវតូចធំ, តាមដុបតាមវាល
សូមអស់លោកកុំបែប្រាណបង់ស្ថានទៅទីណា
នៅតែកន្លែងអស់លោកនោះហើយ

ឱ! ទេព្តាទេព្រក្ស អារុក្ខ អារក្សទាំងឡាយ
អស់លោកធ្លាប់ស្រឡាញ់ថែរក្សាយើងខ្ញុំ
កាលពីយើងខ្ញុំមានបានថ្កុំថ្កើង
សូមលោកកុំភ្លេចអញ្ជើញយាងមកពេលយប់
យាងអញ្ជើញមកមាត់ទន្លេ
ហើយដង្ហោយហៅយើង
យើងនឹងត្រឡប់មកវិញ, ត្រឡប់មកវិញពុំខាន។

*(សម្តេចប៉ែន នុតដើរចេញទៅ)*

# ចប់សម័យកាលទីមួយ

# សម័យកាលទី២

# បុព្វកថា

ឱ, សូមឲ្យការពិតលេចផុះឡើង, ផុះលើមៗព្រាលៗក៏ដោយ។ ក្នុងស្នូរអឺងកងខ្ទរខ្ទារនៃការនិយាយដើមគ្នា និងសម្លេងគ្រាប់បែកគ្រាប់ផ្លោងទាំងនេះ, ធ្វើម៉េចឲ្យអស់លោកបានឮការពិតផង។ បើលោកអ្នកស្រឡាញ់ការពិត, គឺទាល់តែខំផ្ទៀងត្រចៀកឲ្យមែនទែន, ត្បិតការពិត, មិនខុសអ្វីពីពាក្យភូតភរឡើយ, គឺស្ថិតនៅបានដោយសារមានគេស្តាប់។

គ្មានត្រចៀក គឺគ្មានការពិត។

គ្មានការពិត គឺគ្មានល្ខោន។

បានជាយើងមកទីនេះជុំគ្នា គឺមកពីយើងចង់ឮ,

ចង់ឮដើម្បីទាញយកការពិត

ចេញឲ្យផុតអំពីល្បាក់ជំនន់លិចលង់នៃការភូតភរ។

ប្រហែលជាយើងធ្វើកើតទេ? ខ្ញុំមិនហ៊ានថាទេ, តែខ្ញុំសង្ឃឹម, ខ្ញុំជឿថាកើត។

ខ្ញុំដែលកំពុងនិយាយទៅអស់លោកអ្នកនេះ, ខ្ញុំខ្លួនឯងនេះក៏ជាការជឿដែរ។

ខ្ញុំជឿថា ការពិតកំពុងលាក់ខ្លួនក្នុងចំណោមយើងទាំងអស់គ្នា,

ទោះបីខ្ញុំមិនមែនចេះតែអាចមើលឃើញក៏ដោយ, ដោយសារភ្នែកខ្ញុំអន់ខ្សោយមើលមិនច្បាស់។

សូមអាធ្យាស្រ័យឲ្យខ្ញុំចុះ, ល្ខោននេះខ្ញុំឧទ្ទិសទៅការពិតនោះឯង, ទោះបីមានការភាន់ប្រឡំតិចតួច ឬប្រឡំស្មើខ្នាក់ក៏ដោយ។

# ឈុតទី១

## ឆាកទី១

*(ប៉េកាំង។ ព្រះសីហនុយាងមកតែមួយអង្គឯង)*

**ព្រះសីហនុ**

*(មានបន្ទូលទៅទស្សនិកជន)*

យ៉ាងម៉េចទៅហើយ, យើង, នៅខែមិនា ១៩៧០ដ៏ចង្រៃនេះ?

ព្យុះកំណាចប្រវត្តិសាស្ត្របោកបក់វាសនាខ្ញុំឲ្យមកជ្រកកោននៅប៉េកាំង, ហើយគឺពីពេលនេះហើយដែលខ្ញុំត្រូវផ្ញើនយោបាយវាយតដៃទៅវិញ។ នៅភ្នំពេញ, លន់ នល់, ជនក្បត់ផុតលេខដែលខ្ញុំប្រដូចទៅយ៉ាហ្គូ (Iago) ឬក៏ទៅនឹងហ្គាណឺឡុង (Ganelon), លន់ នល់នេះបានលក់ប្រទេសខ្ញុំដែលធ្លាប់រស់ក្នុងសេរីភាព, ក្នុងភាពថ្លៃថ្នូរ ទៅឲ្យចក្រពត្តិអាមេរិក។ រឿងនេះច្បាស់ជាលោកអ្នកជ្រាបរួចហើយ។

ខ្ញុំសូមបញ្ជាក់បន្ថែមថា ក្នុងរឿងទាបថោកអាស្រូវនេះ ស៊ីសុវត្ថិសិរិមតៈដែលជាបងជីដូនមួយរបស់ខ្ញុំ ផ្ទាល់ជាម៉ាក់បិត (Macbeth) តែម្តង, គឺថាវាដូចតែលន់ នល់ ដូច្នោះដែរ។

ឥឡូវនេះ កម្ពុជារបស់ខ្ញុំដែលធ្លាប់តែឯករាជ្យនៅក្រោមម្លប់និងការគ្រប់គ្រងរបស់ខ្ញុំ ក្លាយទៅជាទាសកររនៃដុល្លារហើយ។ លើសពីនេះទៅទៀត អាមេរិកាំងយកប្រជាជនខ្ញុំទៅធ្វើជាអុសដុតភ្លើងសង្គ្រាមវិនាសកម្មប្រឆាំងនឹងវៀតណាម, ហើយគ្មានទាំងបានជោគជ័យផង, ហិនហោចខ្ទោចផ្សារមិនថាចាស់មិនថាក្មេងឡើយ។ ប្រជាជននឹងរងទុក្ខវេទនា, លែងស្គាល់សន្តិភាព, លែងបានជួបសម្តេចឪទៀត។ ខ្ញុំត្រូវធ្វើម៉េច, បើអញ្ចឹង? ឃើញថាក្នុងពេលចាប់ៗខាងមុខនេះ ខ្ញុំត្រូវប្រើមធ្យោបាយដែលពោរពេញទៅដោយគ្រោះថ្នាក់ក្រៃលែងចំពោះខ្លួនខ្ញុំ។

អញ្ចឹងមែនហើយ, ខ្ញុំគ្មានលាក់លៀមអ្វីទេ, ខ្ញុំត្រូវតែរត់រកវៀតណាមដែលជាសត្រូវស្លូពូជរហូតដល់អាទិត្យមុននេះ។

លោកអ្នកយល់ទេ? ឃើញថាខ្ញុំត្រូវច្លងកាត់អ្វីខ្លះ? ខ្មែរដែលជាកូនច្បាតូចមួយនឹងទៅវាយដេញអាគាំងជាមេផ្ទើម ជាមួយយួនដែលជាមេខ្លាយ៉ាងសាហាវ។

លោកអ្នកដឹងទេថា លោកផាំ វ៉ាន់ដុង, រដ្ឋមន្ត្រីទីមួយនៃវៀតណាម, ធ្វើឫកពារយ៉ាងម៉េចមកទល់ឆ្នាំទៅមិញនេះ? គាត់ធ្វើគរធ្វើថ្លង់មិនដឹងមិនឮពាក្យអង្វររបស់ខ្ញុំ។ ស្រាប់តែឥឡូវនេះ អ្វីៗដូរប្លែកទាំងអស់។ ប៉េកាំងទូរសព្ទតែមួយក្រឹង, គាត់ទៅជាស្លូតបូតរាបសាដូចកន្ទេល។ មិត្តភាពមិនមែនផុសឡើងពីដួងចិត្តទេ គឺកើត

ឡើងពីស្ថានការណ៍ប្រែប្រួល។ ការប្រែកាឡានោះកើតឡើងពីចំណង់ចំណូលចិត្តរបស់ប៉េកាំង។ ហាណូយនិងខ្ញុំរស់នៅជាមួយគ្នាក្រោមម្លប់អំណាចប៉េកាំង។ បើអាមេរិកវិញ, កាន់តែច្បាស់ទៅទៀត, គឺថាជាសត្រូវរួម។ យួនឥឡូវកាន់តែកុនការជាងមុន, ព្រោះអ្នកជិតខាងគាត់មិនមែនជាសីហនុទៀតទេ, តែគឺលន់ នល់។ បានជាថាដូច្នេះ ព្រោះអាមេរិកលែងខ្វាចរអែងអ្វីនឹងដើរជាន់កំទេចយោធាយួនដែលហាណូយយកមកលាក់ក្រោមសីហនុទៀតហើយ។ ត្រូវតែយករឿងហេតុទាំងប៉ុន្មាននេះមកធ្វើជាធំក្នុងការសម្រេចចិត្ត, មិនត្រូវយកមនោសញ្ចេតនាមកធ្វើជាធំទេ។

*(សម្តេចប៉ែន នុតចូលមក)*

## ព្រះសីហនុ

ផាំ វ៉ាន់ដុងមកជួបយើងនៅម៉ោងប៉ុន្មាន, សម្តេច?

## សម្តេចប៉ែន នុត

ត្រូវមកឥឡូវនេះឯង, ក្រាបទូល។ ប៉ុន្តែព្រះអង្គច្បាស់ថា ការជួបដែលអាចបង្ករគ្រោះថ្នាក់នេះ ពិតជាត្រូវតែធ្វើឡើងដោយការស្វែងរកកិត្តិយសបរិសុទ្ធ, គឺថាមិនមែនដោយសារកំហឹងមោហោ ឬសេចក្តីស្រេកឃ្លានសងសឹកមែនទេ, ក្រាបទូល?

## ព្រះសីហនុ

មិនមែនខ្ញុំទេ ដែលធ្វើឲ្យវៀតណាមទាស់នឹងកម្ពុជាគ្រប់បែបគ្រប់យ៉ាងនោះ, គឺព្រហ្មលិខិត។ ដូច្នេះ យើងត្រូវតែក្លាហានទទួលស្គាល់ថា យើងទាំងពីរត្រូវតែត្រូវគ្នា។ មើលទៅដែនទីពិភពលោកទៅ យល់ហើយថាត្រូវតែដូច្នេះជៀសមិនរួច។

## សម្តេចប៉ែន នុត

ចុះបើសិនជាព្រះអង្គទុកពេលបន្តិចឲ្យព្រហ្មលិខិតវិញ! ឬមួយទុកបណ្តោយឲ្យពេលដើរទៅមុខគ្រប់គ្រាន់ល្មមឲ្យលន់ នល់ ផ្អួមរលួយស្អុយអស់វិញ!

## អ៊ុង មាង

ចិនគេទើបនឹងប្រាប់ថា ឯកឧត្តមផាំ វ៉ាន់ដុង រដ្ឋមន្ត្រីទីមួយនៃវៀតណាមអញ្ជើញមកដល់ហើយ។

*(គាត់ចេញទៅ)*

**ព្រះសីហនុ**

ជួយទប់ខ្ញុំផង, សម្តេច, ព្រោះពេលដើរលឿនដូចគេហោះ, ឯខ្ញុំក៏ត្រូវតែទៅតាមពេលនោះឲ្យទាន់
កុំខ្លាច, កុំខ្លាចអ្វីនឹងចងសម្ព័ន្ធមេត្រីយ៍ដ៏ចម្លែកនេះ!
ចូរយើងអបអរចំពោះអាពាហ៍ពិពាហ៍រវាងខ្លានិងច្នា ក្រោមក្រសែភ្នែកទន់ភ្លន់ស្មើរបិទនៃនាគប៉េកាំងទៅចុះ!
ចូរយើងធ្វើខ្លួនឲ្យជាចិនពេញទី! កុំខ្មាសអៀនអ្វីនឹងឱបក្រសោបហាណូយ។

*(លោកផាំ វ៉ាន់ដុងនិងអ្នកបំរើហែរហមចូលមក)*

សូមស្វាគមន៍, សូមស្វាគមន៍លោកនាយករដ្ឋមន្ត្រី!
យើងខ្ញុំរំភើបចិត្តដោយឃើញថា ឯកឧត្តមអញ្ជើញមកយ៉ាងរួសរាន់យ៉ាងនេះ។

**ផាំ វ៉ាន់ដុង**

វៀតណាមមិនដែលភ្លេចអំពើប្រមាថឬអំពើល្អដែលគេធ្វើមកលើខ្លួនទាល់តែសោះ។ ស្ទឹងទន្លេ, ព្រៃស្បាត, ភ្នំនានានៃប្រទេសព្រះអង្គ តែងទទួលឲ្យគ្នាយើងស្នាក់ជ្រកនៅ ពេលដែលបច្ចាមិត្រតាមដេញ។ យើងនឹងសំដែងឲ្យឃើញថា យើងដឹងគុណនោះជានិច្ច។

**ព្រះសីហនុ**

ត្រូវហើយ, គឺរឿងនោះតែម្តង ដែលយើងខ្ញុំចង់ពិភាក្សា។

**ផាំ វ៉ាន់ដុង**

ចិនពិតជាគិតត្រូវមែន ដែលសូមឲ្យយើងរួបរួមគ្នានេះ ព្រោះយើងប្រើពេលរំដោះប្រទេសលឿនមួយជាពីរ។

**ព្រះសីហនុ**

ឈប់សិន, កុំទាន់លឿនពេក! បើប្រទេសកម្ពុជាមានតែមួយចំហៀង ច្បាស់ជាសម្ព័ន្ធមិត្តនោះរខេករខាកហើយ! យើងត្រូវការឲ្យខ្លួនយើងមូលពេញលេញ ដើម្បីទៅជិតអស់លោក។ ដូច្នេះ ដំបូងបង្អស់ប្រទេសខ្ញុំត្រូវមានបូរណភាពទឹកដីពេញលេញ,
ឯកឧត្តមយល់ទេ?

**ផាំ វ៉ាន់ដុង**

សូមឲ្យមិត្តភាពថ្មីរបស់សម្ដេច ទុកចិត្តលើមិត្តភាពថ្មីរបស់ទូលបង្គំយើងខ្ញុំចុះ។

**ព្រះសីហនុ**

សីហនុតែងតែទុកចិត្តជានិច្ច, ឯកឧត្តម។ ដូច្នេះហើយបានជាថ្មីៗនេះអស់ប្រទេសមួយ។ ម្ល៉ោះហើយ ខ្ញុំមិនចង់ឲ្យគេយកជាលើកទីពីរទៀតទេ។

**ផាំ វ៉ាន់ដុង**

ទូលបង្គំហ៊ានស្បថថាយើងនឹងគោរពជានិច្ចនូវខ្សែបន្ទាត់ព្រំដែន។ ម្សិលមិញទូលបង្គំ បានស្បថយ៉ាងច្បាស់ដូច្នេះឯង, គ្មានខុសពាក្យអ្វីមួយម៉ាត់ទេ, ទៅឯកឧត្តមដូ អេនឡាយ។

**សម្ដេចប៉ែន នុត**

*(ទូលទៅព្រះសីហនុ)*

ចុះស្អែក, ហ៊ានស្បថនៅសន្និសិទប្រជាជនឥណ្ឌូចិនទេ? សូមព្រះអង្គសួរមើល, ក្រាបទូល...

**ព្រះសីហនុ**

ចុះស្អែក, នៅមុខសន្និសិទប្រជាជនឥណ្ឌូចិនដែលខ្ញុំកោះប្រជុំ, ឯកឧត្តមនឹងស្បថទេ? ខ្ញុំផ្ទាល់, ខ្ញុំទុកចិត្តឯកឧត្តម, តែឯកឧត្តមប៉ែន នុតត្រូវការឲ្យមានការធានាបន្ថែម។

**ផាំ វ៉ាន់ដុង**

ទូលបង្គំស្បថថា នឹងស្បថសាជាថ្មី។

**សម្ដេចប៉ែន នុត**

បញ្ហាកោះ, ក្រាបទូល, កុំភ្លេចរឿងកោះ។

### ផាំ វ៉ាន់ដុង

ទូលបង្គំស្បថថា យើងមិនប៉ះពាល់កោះនានាដ៏ស្អាតស្រស់នៃប្រទេសព្រះអង្គឡើយ។

ហើយទូលបង្គំសូមបញ្ជាក់បន្ថែមថា យើងខ្ញុំនឹងគោរពជារៀងដរាបទៅនូវព្រះទ័យដ៏ត្រឹមត្រូវអំពីឯករាជ្យ និងអព្យាក្រិតភាព។

លោកទីប្រឹក្សាដ៏វាងវៃ, លោកស្ងប់ចិត្តហើយឬនៅ?

### ព្រះសីហនុ

តាមមើលទៅ ខ្ញុំជឿលោកហើយ,

ហើយខ្ញុំក៏ស្បថទៅវិញដែរ, កុំឲ្យខុសគ្នា,

ថាអ្វីៗដែលខ្ញុំត្រូវបំភ្លេច, ខ្ញុំស្បថថាខ្ញុំនឹងបំភ្លេច,

ដើម្បីឲ្យអាពាហ៍ពិពាហ៍រវាងអង្គរនិងហាណូយប្រារព្ធឡើងបានសមជាមង្គលការ។

ខ្ញុំភ្លេចថាវៀតណាមជាបរទេស តែងតែចង់បានដីខ្មែរជានិច្ច។ រឿងនេះគឺខ្ញុំភ្លេច។ ខ្ញុំភ្លេចថា នៅសតវត្សមុននេះ, ក្រោយពីយកកូសាំងស៊ីនបានហើយ, នៅឆ្នាំមុននេះលោកមកតាំងទីនៅខេត្តរតនគិរីជាទីស្រឡាញ់របស់ខ្ញុំ។ រឿងនេះក៏ខ្ញុំភ្លេចដែរ។

ណ្ហើយ, នេះជារឿងអតីត, លែងលើកយកមកនិយាយទៅចុះ។

ខ្ញុំភ្លេចអស់ហើយ។

អ្វីដែលខ្ញុំនឹកឃើញ គឺឆ្នាំក្រោយនៅភ្នំពេញ។

មើល, ដើម្បីយករាជធានីខ្ញុំមកវិញ, តើយើងត្រូវធ្វើយ៉ាងម៉េច, សូមមិត្តប្រាប់ខ្ញុំមកមើល!

### ផាំ វ៉ាន់ដុង

យើងខ្ញុំនឹងជួយកងទ័ពខ្មែរយ៉ាងពេញទំហឹង, គឺកងទ័ពឯករាជ្យដែលព្រះអង្គបានអំពាវនាវកោះហៅតាមវិទ្យុ។ កាលណាប្រជាជនព្រះអង្គចូលព្រៃមករួបរួមនឹងក្រុមខ្មែរក្រហមយ៉ាងអង់អាចមួយក្ដាប់ ដែលយើងខ្ញុំធ្លាប់ជួយតាមផ្លូវគំនិតផង តាមសព្វាវុធផងហើយនោះ, គេនឹងឃើញថា យើងខ្ញុំមានគ្នាច្រើនកុះករ ហើយដោយមានបេដ្ឋាចិត្តផង។

*(លោកអុង មាងចូលមក)*

**អុង មាង**

ព្រះករុណាថ្លៃវិសេស, លោកខៀវ សំផនដែលជាប្រីសិទ្ធនៃកងទ័ពប្រចាំងពីខាងក្នុង ទទូចសុំព្រះរាជានុញ្ញាត ថ្វាយពតិមានយ៉ាងសំខាន់និងយ៉ាងប្រញ៉ាប់មួយ, ក្រាបទូល។

**ព្រះសីហនុ**

សម្ដេចប៉ែន នុត, ពុទេ? ខៀវ សំផន!

*(ងាកទៅលោកដាំ វ៉ាន់ដុងដែលធ្វើហាក់ដូចជាចង់ចេញក្រៅ)*

កុំអញ្ជើញទៅណា, មហាមិត្ត។ ឃើញទេ ឥឡូវនេះយើងជាបងប្អូនគ្នាទាំងអស់!

*(លោកខៀវ សំផន និងលោកហ៊ូ យន់ចូលមក)*

**ខៀវ សំផន**

សូមថ្វាយបង្គំ, ព្រះប្រធានក៏ខ្ពង់ខ្ពស់!

**ព្រះសីហនុ**

លោកខៀវ សំផនជាទីស្រឡាញ់! លោកហ៊ូ យន់ក៏ដូច្នោះដែរ, ខ្ញុំមិនទឹកថា បានប្រសើរយ៉ាងនេះសោះ! យី អស្ចារ្យមែន, ថ្ងៃនេះ, ត្រឡប់មកវិញគ្រប់គ្នា! មើលចុះ, គេថាខ្ញុំសម្លាប់អ្នកទាំងនេះអស់ហើយ! មែន, គឺដូច្នេះ មែន លោកដាំ វ៉ាន់ដុង។ មែនទេ សម្ដេចប៉ែន នុត? អស់លោកបាត់ខ្លួនពីពេលណា? បីឆ្នាំមុននេះ ឬក៏បួនឆ្នាំ?

**ខៀវ សំផន**

បីឆ្នាំមុន, ក្រាបទូល។

**ព្រះសីហនុ**

បីឆ្នាំ! មួយសតវត្ស! គេស្មានតែស្លាប់អស់ហើយ, ស្រាប់តែឥឡូវចេញមុខគ្រហើ។! ពូកែលាក់ខ្លួនមែន, មែនទេ? អស្ចារ្យតែម្ដង! ម៉េចបានជាមកដល់ទីនេះ?

## ខៀវ សំផន

ក្រាបទូល, គ្រាន់តែបានឮដោយរីករាយនូវព្រះបន្ទូលរបស់ព្រះអង្គតាមវិទ្យុប៉េកាំងសូមឲ្យប្រជាជាតិយើងរួមគ្នាប្រឆាំងពួកអាក្សត់នៅភ្នំពេញនិងចក្រពត្តិអាមេរិកភ្លាម, ទីបញ្ជាការធំរបស់យើងសម្រេចជាឯកច្ឆន្ទថា សូមគាំទ្រព្រះអង្គយ៉ាងពេញទំហឹង, ដោយស្មោះត្រង់ឥតរួញរា។

## ព្រះសីហនុ

ឥតរួញរា? ប៉ុន្តែបងប្អូនរួមជាតិដឹងហើយថា សីហនុមិនមែនជាកុម្មុយនីស្ដ៍ទេ។ យ៉ាងណាក៏មិនក្លាយទៅជាកុម្មុយនិស្ដ៍, ទៅជាអ្នកនិយមម៉ៅក៏មិនទៅដែរ។ តែខ្ញុំកោតសរសើរលោកប្រធានប្រទេសចិនដ៏ប្រសើរនេះខ្លាំងណាស់។ ខ្ញុំកោតស្ងើបគាត់ ហើយខ្ញុំស្រឡាញ់គាត់ ដូចដែលខ្ញុំស្រឡាញ់និងកោតសរសើរនាង Maria Callas ដ៏ល្បីដូច្នោះដែរ។ ប្រពន្ធខ្ញុំនិងខ្ញុំតែងតែទៅស្ដាប់គាត់ច្រៀងនៅ Opéra ។ គួរឲ្យកោត, គួរឲ្យស្ងើបណាស់, គាត់មានអនុភាពមែន! ខ្ញុំតែងងើបឈរទះដៃយ៉ាងខ្លាំងៗរហូតទល់តែទន់កម្លាំងទើបឈប់។ ប៉ុន្តែរួចទៅ ខ្ញុំនាំប្រពន្ធទៅទទួលទានស៊ុបនៅផ្ទះវិញ, ហើយមិនដែលនាំនាង Callas ទៅផ្ទះទេ។ ឯម៉ៅវិញក៏ដូចគ្នាដែរ, ខ្ញុំមិនត្រូវការឲ្យគាត់មកផ្ទះខ្ញុំទេ! នេះ ខ្ញុំយល់ថាគួរជម្រាបអស់លោកជាមុនសិន, សីហនុគ្មានគំនិតអ្វីជាចិនសោះឡើយ។

## ខៀវ សំផន

ទូលបង្គំយើងខ្ញុំមិនដែលយល់អ្វីខុសពីសម្ដេចព្រះនរោត្ដមសីហនុឡើយ។ ការគាំទ្រពេញទំហឹងហើយឥតលក្ខ័ណ្ឌដែលយើងខ្ញុំនាំមកនេះ គឺនាំមកថ្វាយសម្ដេចដែលជាព្រះប្រមុខរដ្ឋស្របច្បាប់នៃប្រទេសយើង។

## ព្រះសីហនុ

យើងត្រូវនិយាយឲ្យស្មោះ។ អស់លោកច្បាស់ថា, ដែលជាកុម្មុយនីស្ដ៍នោះ, អស់លោកអាចជាអ្នករាជានិយមដែរ? ខ្ញុំសួរនេះ ព្រោះថាកាលណាចូលទៅរាជធានីវិញបានដោយការរួបរួមពីគ្រប់កម្លាំងខ្មែរនានា ហើយដោយមានជំនួយពីមិត្តវៀតណាមផងនោះ, ខ្ញុំនឹងតែងតាំងរបបសង្គមនិយមតាមបែបសីហនុ, គឺសង្គមនិយមដែលមិនដាច់អហង្ការ, កាន់ព្រះពុទ្ធសាសនា ហើយនិយមស្ដេច។ អស់លោកត្រូវយកពាក្យអស់នេះមកថ្លឹងថ្លែងឲ្យមែនទែន។

### ខៀវ សំផន

អ្វីៗច្បាស់ហើយ, ក្រាបទូល។ ទូលបង្គំយើងខ្ញុំមកចុះចូលនឹងព្រះអង្គដោយគ្មានល័ក្ខខណ្ឌ, គ្មានលាក់គំនិតអ្វីទាំងអស់។

### ព្រះសីហនុ

ហេតុម្ដេចបានជាសម្រេចថាដូច្នេះបាន?

### ខៀវ សំផន

ដោយយករឿងជាតិជាធំ។ ទូលបង្គំយើងខ្ញុំស្អប់អាមេរិកាំងនិងពួកលន់ នល់ជាបាវបម្រើរបស់វា។ យើងទុកប្រជាជនខ្មែរទាំងមូលនៅខ្ពស់លើក្បាលដើម្បីប្រជាជនយើងសុខចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាង។ ឯប្រជាជននោះ គឺស្រឡាញ់សម្ដេចឪ, តើទូលបង្គំយើងខ្ញុំអាចដើរបញ្រ្ចាសបានទេ? គឺថាពុំអាចឡើយ។ យើងនឹងបម្រើប្រជាជន។ យើងនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីសុភមង្គលរបស់ប្រជាជន ព្រោះគាត់សក្ដិសមនឹងរស់នៅក្នុងសុភមង្គល។ កាលណាប្រជាជនជ្រួតជ្រាបថា សម្ដេចនៅជាមួយយើង ហើយខ្មែរក្រហមនៅជាមួយសម្ដេច, គឺច្បាស់ជាគេរីករាយពុះកញ្ជ្រោលជាមិនខាន។

### សម្ដេចប៉ែន នុត

*(ទូលទៅព្រះសីហនុស្ងាត់ៗ)*

និយាយឲ្យខ្លី គឺពួកគេត្រូវការព្រះអង្គខ្លាំងណាស់ដើម្បីបញ្ចុះបញ្ចូលអ្នកស្រុកឲ្យចូលចិត្តគេ។

### ព្រះសីហនុ

*(មានបន្ទូលស្ងាត់ៗ ទៅសម្ដេចប៉ែន នុត)*

ខ្ញុំដឹងហើយ។

*(មានបន្ទូលទៅខៀវ សំផន)*

សារុបមក, អស់លោកដើរតាមខ្ញុំ ហើយលែងដើរតាមផ្លូវលោកហើយ, មែនទេ?

**ខៀវ សំផន**

ទូលបង្គំយើងខ្ញុំសង្កេតឃើញថា ប្រទេសយើងមិនទាន់ទុំសម្រាប់របបកុម្មុយនីស្ត៍ទេ, ក្រាបទូល។

**សម្តេចប៉ែន នុត**

អញ្ចឹង?

**ខៀវ សំផន**

សម្រាប់បច្ចុប្បន្ននេះកម្មវិធីនយោបាយព្រះអង្គជាកម្មវិធីល្អបំផុតសម្រាប់ប្រជាជនយើង។

**ព្រះសីហនុ**

ចាស, ល្អហើយ, ចាស! សូមទោស *(ព្រះអង្គទាញសម្តេចប៉ែន នុតឲ្យឃ្លាតពីគេបន្តិច)*។ ដូច្នេះ, ចំពោះពេលនេះ ខ្ញុំមិនឃើញថា មានឧសគ្គអ្វីធំដុំដើម្បីបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិឲ្យបានឆាប់ៗទេ។ សម្តេចយល់ដូចម្តេចដែរ?

**សម្តេចប៉ែន នុត**

ទូលបង្គំមិនឃើញឧសគ្គអ្វីធំដុំទេ, ក្រាបទូល។ ទូលបង្គំគ្រាន់តែមិនសូវទុកចិត្ត ព្រោះការមិនទុកចិត្តនោះមានភ្នែកប្រៀបបាននឹងភ្នែកម្ចាស់ដែរ។ ខ្មែរក្រហមអស់នេះ...

**ព្រះសីហនុ**

ក្រហមមែនតែគេជាខ្មែរ។ ម្យ៉ាងទៀត, ម៉េចក៏មិនគិតផងថា លន់ នល់ លួចយកកងទ័ពខ្ញុំអស់ហើយ, ខ្ញុំមានតែខ្មែរក្រហមនេះឯង។ បើអ្នកនៅជុំវិញខ្ញុំសុទ្ធតែក្រហម, ខ្ញុំត្រូវធ្វើម៉េចកុំឲ្យទាំងអស់នោះសុទ្ធតែជាយួន។

**សម្តេចប៉ែន នុត**

ទូលបង្គំដឹងហើយថាគេជាខ្មែរ, ប៉ុន្តែយ៉ាងណាក៏ក្រហមដែរ។ ដូច្នេះទូលបង្គំត្រូវតែប្រឹងបើកភ្នែកមើលកុំឲ្យលង់លក់។ ឯព្រះអង្គវិញ, ព្រះអង្គត្រូវតែស្ទុះយាងយ៉ាងលឿនទៅមុខដូចផ្លេកបន្ទោល ដើម្បីកុំឲ្យអស់លោកនេះរៀបជើងព្រួលយកប្រជាប្រិយភាពព្រះអង្គទៅប្រើប្រាស់សម្រាប់ខ្លួនគេទាន់។

**ព្រះសីហនុ**

មែនហើយ, រឿងនេះត្រូវតែលឿន។

អស់លោក! ខ្ញុំឃើញថាអ្វីៗទាំងអស់ជម្រុញខ្ញុំឲ្យបង្កើតរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិនៅទីនេះតែម្តង ហើយដោយឥតយឺតយ៉ាវ។ អស់លោករដ្ឋមន្ត្រីចាស់របស់ខ្ញុំ, ឥឡូវនេះអស់លោកយល់ព្រមធ្វើជារដ្ឋមន្ត្រីថ្មីរបស់ខ្ញុំទេ? លោកខៀវ សំផន?

**ខៀវ សំផន**

ក្រាបទូល, ទូលបង្គំទទួលដោយរីករាយនិងដោយរំភើបក្រៃលែង។

**ព្រះសីហនុ**

ចុះលោកហ៊ូ យន់វិញ?

**ហ៊ូ យន់**

គឺជាកិត្តិយសធំណាស់ដែលទូលព្រះបង្គំអាចបម្រើទាំងព្រះអង្គទាំងប្រជាជនយើងដោយស្មោះស្ម័គ្រ។

**ព្រះសីហនុ**

ឯខ្ញុំវិញ, ខ្ញុំតែងតាំងឯកឧត្តម ជា សាន ព្រមទាំងសហជីវិនបីនាក់ទៀតដែលស្មោះស្ម័គ្រនៅនិរទេសជាមួយខ្ញុំ។ រីឯសម្តេចប៉ែន នុតវិញ, យើងពុំចាំបាច់គិតវែងឆ្ងាយទេ, លោកជានាយករដ្ឋមន្ត្រីដូចតែពីមុនមក, ដរាបណាព្រះនៅប្រទានពរឲ្យខ្ញុំ។

**ខៀវ សំផន**

*(និយាយទៅសម្តេចប៉ែន នុត)*

*សម្តេច! ខ្ញុំសូមថ្លែងសេចក្តីអបអរដោយគោរព។*

**ព្រះសីហនុ**

យើងបើកសម័យប្រជុំទីមួយស្អែកព្រឹកនេះតែម្តង។ របៀបវារៈគឺសម្ពន្ធភាពជាមួយវៀតណាមនិងផែនការធ្វើសង្គ្រាម។ អស់លោកយល់ព្រមទេ?

**ខៀវ សំផន**

ស្អែកនេះ? ល្អហើយ, ក្រាបទូល។

*(គាត់ទូលស្ងាត់ៗទៅព្រះសីហនុ)*

អំពីសម្ពន្ធភាពជាមួយវៀតណាម ទូលបង្គំយើងខ្ញុំនឹងមានរឿងនិយាយច្រើន, ក្រាបទូល។ ហាណូយជួយយើង ដើម្បីបានឱកាសចក់យកជ័យជំនះរបស់យើងនឹងលេបប្រទេសយើងតែប៉ុណ្ណោះ។

**ព្រះសីហនុ**

ទេ, ទេ, បានហើយ! យើងនឹងនិយាយរឿងនេះពេលស្អែក, ម៉ោង១០។

**ខៀវ សំផន**

ស្អែកម៉ោង១០, ទូលព្រះបង្គំយើងខ្ញុំនឹងនៅទីនេះ, ក្រាបទូល!

**ព្រះសីហនុ**

ប៉ុន្តែសម័យប្រជុំបន្ទាប់ទៅទៀត គួរតែកុំធ្វើនៅលើទឹកដីប្រទេសចិន, គួរធ្វើនៅលើទឹកដីជាទីសក្ការៈរបស់យើងវិញ។

**ខៀវ សំផន**

ទូលបង្គំយើងខ្ញុំនឹងរាយការណ៍ដោយមោទនភាពខ្លាំងក្លាអំពីថ្ងៃរួបរួមគ្នាជាប្រវត្តិសាស្ត្រនេះទៅមេបញ្ជាការនៃទ័ពតស៊ូប្រចាំងរបស់យើង, ពោលគឺ សមមិត្ត ប៉ុល ពត។

**ព្រះសីហនុ**

អញ្ជើញទៅចុះ, អស់លោក។ ចាំស្អែកជួបគ្នាទៀត, អស់លោករដ្ឋមន្ត្រីខ្មោចនៅរស់ជាទីស្រឡាញ់។ ស្អែកជួបគ្នាទៀត។

**ខៀវ សំផន**

ចាំស្អែក, ក្រាបទូល, ហើយដោយរីករាយបំផុត, ក្រាបទូល!

**ហ៊ួ យន់**

ចាំស្អែក, ក្រាបទូល!

*(លោកខៀវសំផននិងលោកហ៊ួ យន់ចេញទៅ)*

**ព្រះសីហនុ**

នរណាទៅ ប៉ុល ពតនោះ?

**ផាំ វ៉ាន់ដុង**

ក្រាបទូល, ទូលបង្គំសូមថ្វាយបង្គំលាសិន។ ពេលវេលានៅវៀតណាមពុះកញ្ជ្រោលខ្លាំងណាស់, ហើយសឹកសង្គ្រាមកំពុងរង់ចាំទូលបង្គំ។

**ព្រះសីហនុ**

យើងនឹងជួបគ្នាជាប់ៗ ទៀតឬទេ?

**ផាំ វ៉ាន់ដុង**

ព្រះអង្គផ្តល់កិត្តិយសឲ្យយើងខ្ញុំ ដោយយាងមកហាណូយឬទេ, ក្រាបទូល?

**ព្រះសីហនុ**

ដោយរីករាយ។

*(លោកផាំ វ៉ាន់ដុងចេញទៅ)*

*(ព្រះបាទសុរាម្រឹតយាងមកដោយជិះកង់)*

**ព្រះសុរាម្រឹត**

គូក!

## ព្រះសីហនុ

លោកឪពុកជាទីគោរព! មហាក្សត្រដែលគេស្រឡាញ់ទាំងអស់គ្នា, មិនថាអ្នករស់ឬអ្នកស្លាប់។

ឱ, លោកឪពុក! ពុកដូចជាហត់ហេវខ្លាំងណាស់, ផ្លូវឆ្ងាយដាច់សង្វែងយ៉ាងនេះ, តាំងពីភ្នំពេញមកដល់ប៉ៃកាំង! ពុកធ្វើម៉េចបានជាយាងមកបាន?

## ព្រះសុរាម្រឹត

ជិះកង់មក។ ជិះកាត់ព្រៃព្រឹក្សារបស់យើង។ ក្រៅពីនោះ ពុកដោះស្រាយតាមវិធីផ្សេងៗទៀត។

## ព្រះសីហនុ

យាងមកដោយកង់? លោកឪពុកខ្ញុំ ជិះកង់យាងមក?

## ព្រះសុរាម្រិត

កង់យ៉ាងល្អដែលស្រីពីរនាក់នៅភ្នំពេញឲ្យខ្ញី។

## ព្រះសីហនុ

ពុក, ពុកមានបន្ទូលកំបុតកំបុយដូចជាសោះអង្គើយខ្លាំងណាស់។ ពុកខ្វាល់ឬអ្វី?

## ព្រះសុរាម្រឹត

ខ្វាល់? ទេអត់មានខឹងអីទាំងអស់!

## ព្រះសីហនុ

ទេ, ច្បាស់ជាខ្វាល់ហើយ, ខ្វាល់នឹងកូនតែម្តង។

## ព្រះសុរាម្រឹត

ដែលពុកមិនចូលចិត្ត គឺអ្នកនៅជុំវិញកូននោះឯង។ ពុកឆ្ងល់កាត់លោកទាំងមូល, កាត់ភ្នំ, កាត់ស្ទឹងទន្លេ, កាត់ព្រៃដែលពោរពេញទៅដោយខ្លានិងកាំភ្លើង... ធ្វើនេះក៏ដើម្បីឆ្លើយតបតាមការបន់ស្រន់របស់កូនដែរ។ ពុកមកដល់ក្រុងវង្សាត្រជាក់ត្រោតត្រាតនេះ, រកតែដើមឈើមួយដើមក៏គ្មាន។ បើ ពុកនៅរស់កូនមិនអាចឃើញពុកនៅកន្លែងរបៀបនេះទេ, តាមផ្លូវស្ងាត់ប្រៀបដូចទឹកប៉ះខ្មោច, តែពុកចេះតែគិតថាខំធ្វើម៉េចឲ្យបានមកពញាក់កូនឲ្យអរសប្បាយ។ មកដល់ផ្ទះយ៉ាងអាក្រក់នេះដែលសុទ្ធតែបរទេសនៅ, មើលទៅរូបរាងហាក់ដូចជាសាប៊ូយក្សមួយដុំ។ ពុកដើរចូលមក ហើយស្រាប់តែឮសម្លេងកូនក្រលួចដូចសម្លេងសាក់សូ (Saxo) ហើយទីបំផុតក៏ឃើញកូន។ ពុកឃើញកូនរបស់ពុក, សម្តេចព្រះសីហនុ, ដួងព្រលឹងចុងក្រោយបង្អស់នៃបុរាណកាល, ពាត់ជុំវិញទៅ ដោយហ្វូងមនុស្សចិន, យួន និងខ្មែរវង្វេងកំណើត ដែលកូនថាក្រហមនោះ។ ទេ, ពុកឥតមានទឹងអ្វីទាំងអស់! ប៉ុន្តែរដ្ឋាភិបាលដ៏ខ្វង់ដែលកូនឯងប្រកាសក្តែង។យ៉ាងរីករាយ ពេលពុកមកដល់អម្បាញ់មិញនោះ, ពុកមិនចូលចិត្តសោះ។ ហើយពុកឃើញទៀតថា សូម្បី តែប៉ែន នុតជាទីស្រឡាញ់ក៏មិនអបអរដែរ។ ធ្វើមេលើពួកចែ្កក្រហម! គួរឲ្យអាណិតប៉ែន នុតណាស់!

## ព្រះសីហនុ

សម្ព័ន្ធភាពនេះជាការចាំបាច់ តែមិនស្ថិតស្ថេរចេរកាលឡើយ។ ដូច្នេះហើយបានជាកូនអោបរិតមិត្តយួនយើងដោយសុទ្ធចិត្តបំផុត, ព្រោះបើគេនោះមានបំណងប្រាកដមែន, គឺតែពីរបីថ្ងៃប៉ុណ្ណោះគេអាចលើកស្ទួយកូនក្នុងជ័យជំនះធំធេងមួយទៅដល់មាត់ទ្វារភ្នំពេញតែម្តង។

## ព្រះសុរាម្រឹត

បើអញ្ចឹងកូនឯងនិងប៉ែន នុតនៅចាំអ្វីទៀត?

## ព្រះសីហនុ

ចំពោះពុក, កូនអាចទូលការសម្ងាត់នេះបាន៖ យើងសង្ឃឹមថាបច្ចឹមប្រទេសនឹងងាកមកយើង។ ធ្វើម៉េចកុំឲ្យជំពាក់គុណពួកកុម្មុយនីស្តទៅហ្ន! បើតាមតែចិត្ត, គឺកូនចង់ចូលទៅក្រុងយើងវិញយ៉ាងឧឡារិក ដោយជិះឡានដេអែស ស៊ីត្រូអែន (Ds Citroën) ខ្មៅសង្ហារមួយ។ ឬជិះឡានកាឌីឡាក់ (Cadillac) ទៀតផង។

**ព្រះសុរាម្រឹត**

*នែ! កុំរវើរវាយខ្លាំងពេក! ជិះអីក៏ជិះទៅ។ ជិះដំរី, ជិះរទេះគង់យួន, ឬជិះកង់ក៏បាន, តែត្រូវត្រឡប់ទៅវិញដោយរួសរាន់!*

*(លោកអុង មាងចូលមក)*

**អុង មាង**

លោកម៉ាណាក់ទូតបារាំងប្រចាំប៉េកាំង សូមចូលគាល់, ក្រាបទូល។

**ព្រះសីហនុ**

ឱ, អ្នកនាំសារព្រហ្មលិខិតកូនមកដល់ហើយ។ លោកឪពុកជាទីស្នេហា, សូមជួយបទ់ឲ្យកូនផង។

*(លោកម៉ាណាក់ចូលមក)*

អញ្ជើញ, លោកម៉ាណាក់, មានប្រសាសន៍អីត្រង់ៗមកចុះ, ពុំចាំបាច់រៀបឃ្លោងឃ្លាអ្វីទេ។ សូមប្រាប់ដំណឹងអាក្រក់មកចុះ។ តើលោកបាននិយាយល្អពីសីហនុទៅអាមេរិកាំងទេ? ឬក៏អត់ទេ?

**ម៉ាណាក់**

សូមទូលព្រះអង្គដោយកំបុតថាអត់ទេ។ វ៉ាស៊ីនតោន គេមិនយកភ្នែកមើលលិខិតណាមួយគាំទ្រព្រះអង្គ ដែលបារាំងខំផ្ញើទៅឡើយ។ ព្រះនាមព្រះអង្គហាក់ដូចជាថ្នាំសម្រាប់ទទួលទានឲ្យក្អួតអញ្ចឹង។ នៅការិយាល័យរាងពងក្រពើនោះឲ្យតែឮភ្លាម គេខ្ជាក់ចេញវិញភ្លាម។ ទូលបង្គំឈប់ត្រឹមនេះឬយ៉ាងម៉េច?

**ព្រះសុរាម្រិត**

*ទេ, កុំឈប់, តទៅទៀត! ទាល់តែអញ្ចឹងទើបដឹងខ្លួន!*

**ព្រះសីហនុ**

ទេ, កុំឈប់, តទៅទៀតទើបខ្ញុំយល់មេរៀននេះច្បាស់។

**ម៉ាណាក់**

គឺថាទូលបង្គំគ្មានបានទូលអ្វីទាំងអស់។ លោកទីប្រឹក្សាគីស៊ីងហ្គ័រអះអាងថាព្រះអង្គជាមនុស្សអតីតកាលទេ ហើយព្រះអង្គគ្មានតំណាងនរណាទាំងអស់, ក្រៅពីតំណាងព្រះអង្គឯង។

**សម្តេចប៉ែន នុត**

ប៉ុន្តែមិត្តភាពចិនចំពោះព្រះអង្គ, ម៉េចក៏គាត់ធ្វើជាមិនដឹង?

**ម៉ាណាក់**

គ្មានអ្វីបញ្ជាក់ច្បាស់ថាចិនយកចិត្តទុកដាក់ពេញលេញនឹងព្រះអង្គទេ។ ដូច្នេះលោកទីប្រឹក្សានោះនឹងមិនជួប ព្រះអង្គឡើយ។ សូមព្រះរាជទានទោសទូលបង្គំទៅចុះ, ក្រាបទូល។

**ព្រះសីហនុ**

ចុះនៅប្រទេសលោកវិញ, នៅអេលីហ្សេ (Elysée) មានឮសួរអ្វីដែរទេ?

**ម៉ាណាក់**

ប្រទេសបារាំងមិនប៉ង់ប្រាថ្នាផ្តាច់ទូតជាមួយភ្នំពេញឡើយ។

**ព្រះសុរាម្រិត**

អញ្ចឹង! ឃើញទេ, ឧត្តមសេនីយដឺហ្គោល(De Gaulle) មហាមិត្តដែលកូនឯងតែងអួតមិនឈប់មិនឈរនោះ!

**ព្រះសីហនុ**

គឺប៉ុមពីឌូ (Pompidou) ទេ ដែលកាន់អំណាចនៅបារីស៍។ មហាមិត្តទាំងប៉ុន្មានចាកចោលយើងអស់ហើយ, នៅសល់តែស្រមោលរដឹបរដុបប៉ុណ្ណោះ។

**ម៉ាណាក់**

ព្រះអង្គជ្រាបហើយថា ចំពោះក្រុមបារាំងសព្វថ្ងៃនេះ, ម៉ាណាក់ជាមិត្តព្រះអង្គ និយាយអ្វីទៅមិនមានទឹកមាត់ប្រៃដូចថៅកែចំការកៅស៊ូឡើយ, ព្រោះព្រះអង្គធ្លាប់បន្ថយលាភសក្ការៈពួកនោះ ហើយគេរត់ទៅរកលោកប្រធានាធិបតី ប៉ុមពីឌូ (Pompidou) ដែលចូលចិត្តស្ដាប់គេ។

**សម្ដេចប៉ែន នុត**

*ជួយលន់ ទល់! ខ្ញុំមិនដឹងថាបារាំងល្ងង់ស្មើអាមេរិកាំងយ៉ាងនេះសោះ!*

**ព្រះសីហនុ**

*ណ្ហើយ, យើងសម្រេចឲ្យច្បាស់ចុះ! ការតស៊ូរបស់យើងត្រូវធ្វើដោយអាវុធ ហើយក្នុងសម្ព័ន្ធភាពអាស៊ី។ ខ្ញុំនឹងត្រឡប់ទៅស្រុកខ្មែរវិញ។ ប្រមុខរាជរដ្ឋាភិបាលរួបរួមជាតិ ត្រូវនៅជិតនរណាដែលប្រយុទ្ធប្រចាំងនិងពួកក្បត់នៅលើទឹកដីយើង។ សម្ដេចប៉ែន នុត, សម្ដេចសុខចិត្តតាមខ្ញុំរហូតទៅដល់តំបន់ដែលខ្មែរក្រហមកាន់កាប់ទេ?*

**សម្ដេចប៉ែន នុត**

*ក្រាបទូល, បើទូលបង្គំត្រូវស្លាប់, ទូលបង្គំចង់ស្លាប់នៅខ្ទមកំព្រូកណាមួយក្នុងប្រទេសយើង ជាជាងស្លាប់ក្នុងពេទ្យចិន។*

**ព្រះសីហនុ**

*អនុសេនីយ៍ឯក អ៊ុងមាង, សូមលោកទៅជម្រាបរដ្ឋមន្ត្រីគ្រប់រូបនៃរណសិរ្សយើង គឺថាលោកខៀវ សំផន, ហ៊ូ យន់, អៀង សារី ។ល។ និង ។ល។ ឲ្យមេត្តាមកជួបខ្ញុំឥឡូវនេះ។ ខ្ញុំចង់ពិគ្រោះគ្នាជ្រើសរើសទីតាំងធំ។*

*(លោកអ៊ុង មាងចេញទៅ)*

*(មានបន្ទូលទៅលោកម៉ាណាក់)*

ឯកឧត្ដម, ខ្ញុំត្រូវលាឯកឧត្ដមហើយ។ យើងកំពុងចូលក្នុងសម័យកាលមួយដ៏លំបាក ហើយគ្រោះថ្នាក់ផង។

*(លោកម៉ាណាក់ចេញទៅ)*

**ព្រះសីហនុ**

*សម្តេចប៉ែន នុត, បើរដ្ឋាភិបាលតាំងទីនៅតាកែវ, តើយ៉ាងម៉េចដែរ? រដ្ឋាភិបាលវាយប្រយុទ្ធនៅតាកែវ, ហាស់?*

**សម្តេចប៉ែន នុត**

ក្រចេះប្រហែលល្អជាង, ក្រាបទូល, ព្រោះស្ថានភាពក្រចេះនៅកៀកថ្លើមប្រម៉ាត់ប្រទេសជាង។

*(លោកអុង មាងចូលមក)*

**អុង មាង**

*ទៅអស់ហើយ! ទៅអស់ហើយ, ក្រាបទូល! ទៅអស់រលីង, ក្រាបទូល!*

**សម្តេចប៉ែន នុត**

*ទៅបាត់ហើយ?*

**ព្រះសីហនុ**

*ទៅបាត់ហើយ!*

**ព្រះសុរាម្រិត**

សម្ព័ន្ធមិត្តនេះ, មិនទាន់បានអីផង...

**អុង មាង**

ព្រះករុណាថ្លៃវិសេស, គេទៅអស់មែន។ ទូលបង្គំទៅទាន់ពួកគេនៅមាត់ទ្វារ។ ទូលបង្គំទ្រាំមិនបានក៏... សូមព្រះរាជទានទោសក្រាបទូល,...

**ព្រះសីហនុ**

*ទ្រាំមិនបានក៏...យ៉ាងម៉េចទៀត, និយាយមក!*

**អុង មាង**

ទូលបង្គំនិយាយជំទាស់។ ទូលបង្គំទ្រាំមិនបានក៏ស្រែកថា៖ "អស់លោកមិនអាចចេញទៅវិញដោយមិនបាន ថ្វាយបង្គំលាព្រះអង្គទេ, មុននឹងប្រជុំគណៈរដ្ឋមន្ត្រីលើកទីមួយ។ ធ្វើនេះខុសច្បាប់! ធ្វើនេះជាអំពើអាប់អោន!",

**សម្ដេចប៉ែន នុត**

*ចុះគេឆ្លើយថាម៉េចទៅវិញ?*

**អុង មាង**

គេនិយាយករកូត។ ខៀវ សំផនឆ្លើយមួយដុប។ (ដូចធ្លាប់ស្គាល់ទម្លាប់គាត់ហើយ) ថា អ្នកខ្លះត្រូវនៅតស៊ូជាប់ជាមួយប្រជាជន, អ្នកខ្លះទៅត្រូវតំណាងការតស៊ូនៅបរទេស។ ប៉ុន្តែទូលបង្គំនៅឈរពាំងទ្វារអ្នកទាំងអស់នោះ ហើយនិយាយថា យើងនឹងទៅចូលព្រៃស្អែកនេះហើយ។ សូមព្រះអង្គព្រះរាជទានទោស ដែលទូលបង្គំហ៊ាននិយាយដូច្នោះ, ក្រាបទូល។

**ព្រះសីហនុ**

ទេ, ធ្វើនោះត្រូវហើយ, គឺចេញពីចិត្តលោកដោយស្មោះដើម្បីខ្ញុំ។

**សម្ដេចប៉ែន នុត**

*ហើយយ៉ាងម៉េចទៀត? យ៉ាងម៉េចទៀត?*

**អុង មាង**

ហើយពួកគេប្រឆាំងគំនិតនេះទាំងស្រុង។ គេអះអាងថា គេខ្លាចមានគ្រោះថ្នាក់ដល់ព្រះជន្មព្រះអង្គ។ ហើយដើម្បីរារាំងកុំឲ្យព្រះអង្គយាងចេញបាន, គេទុកឲ្យមនុស្សក្បាលខូចអៀង សារីនៅប៉េកាំង, ឲ្យជនជាថ្កែមានពិសនេះចាំព្រុសតាមជំហានព្រះអង្គ, ពេលព្រះអង្គយាងដើរ។

**ព្រះសីហនុ**

ដូច្នេះ ខ្ញុំត្រូវធ្វើខ្លួនជាទង់ជាតិឬអ្វី? ខ្ញុំត្រូវបក់វីច? ឬក៏មិនដល់ប៉ុណ្ណឹងផងទេ, គឺត្រូវធ្វើជាអ្នកចែកសំបុត្រ?

*(ព្រះសុរាម្រិតទ្រង់ព្រះកន្សែងយ៉ាងខ្លាំង)*

**អុង មាង**

*(ទូលទៅព្រះសីហនុ)*

ព្រះករុណាថ្លៃវិសេស, សូមព្រះអង្គកុំទ្រង់ព្រះកន្សែង, ក្រាបទូល។ ទូលព្រះបង្គំនឹងសម្លាប់ពួកនោះ, ថ្ងៃណាមួយ, សម្លាប់ឲ្យបាន។

**ព្រះសីហនុ**

ទេ, សហជីវិនអុងមាង! ខ្ញុំគ្មានយំស្រែកអ្វីសោះឡើយ។ ឯលោកវិញក៏ដូច្នោះដែរ, លោកគ្មានត្រូវការទៅសម្លាប់នរណាទេ។ ខ្មែរក្រហមនិងយើងពុំមានអារ្យធម៌ដូចគ្នាឡើយ, តែយ៉ាងណាក៏គេតស៊ូប្រឆាំងនឹងសត្រូវរបស់យើងដែរ។

**សម្តេចប៉ែន នុត**

ក្រាបទូល, ជាកិត្តិយសធំណាស់ដែលទូលព្រះបង្គំនៅខាងព្រះអង្គ, ក្នុងសម័យកាលដែលមនុស្សមិនចេះខ្មាស មិនចេះអៀនដូច្នេះ។

**អុង មាង**

ទោះជាព្រះអង្គយាងទៅណា, ដីឯណាក៏ដោយ, ទូលព្រះបង្គំនឹងទៅតាមព្រះអង្គជានិច្ច។

**ព្រះសីហនុ**

ប្រទេសកម្ពុជាខ្ញុំកាន់តែសោត់ច្ងាយពីខ្ញុំហើយ។ មើលពីលើមាត់ទន្លេនេះ, ខ្ញុំឃើញថាកាន់តែឃ្លាតឆ្ងាយ, តូចទៅៗរហូតមើលលែងឃើញ។ ពិភពលោកក្លាយទៅជាធំធេងមហិមា, ឯខ្ញុំវិញរួញមកនៅតូចជាទីបំផុត។ ទេ, ទេ, ខ្ញុំនឹងទៅចក់យកវិញឲ្យបាន។

*(ទាំងអស់គ្នាចេញទៅ)*

## ឆាកទី២

*(វ៉ាស៊ីនតោន។ លោកគីស៊ីងហ្គ័រនិងលោកវ៉ាត់ស៍ចូលមក)*

**គីស៊ីងហ្គ័រ**

លោកវ៉ាត់ស៍ជាទីមេត្រីយ៍, ភ្នែកលោកបង្ហាញថា មិនសូវបានទទូលទានដំណេកប៉ុន្មានទេ, មែនទេ?

**វ៉ាត់ស៍**

យប់មិញលោកបានសូមឲ្យខ្ញុំមើលឡើងវិញនូវផែនទីដែលឧត្តមសេនីយ៍អាប្រាមស៍បានរៀបចំ ដើម្បីវាយលុកប្រទេសកម្ពុជា, ហើយព្រឹកមិញនេះឯកសារនោះបានដល់ខុទ្ទកាល័យលោកហើយ។ ខ្ញុំធ្វើការនោះពេញមួយយប់, ឥឡូវនេះខ្ញុំមកផ្ទាល់ដើម្បីរាយការណ៍។

**គីស៊ីងហ្គ័រ**

ខ្ញុំដឹងមុនថាលោកប្រាកដជាបំពេញការងារនោះបាន, ថ្វីត្បិតតែពេលដែលមាននោះខ្លីបន្តិចក៏ដោយ។

**វ៉ាត់ស៍**

វាយលុកស្រុកខ្មែរនោះសម្រាប់ចាប់ៗនេះហើយ, មែនទេ?

**គីស៊ីងហ្គ័រ**

អញ្ចឹងមែនហើយ។

**វ៉ាត់ស៍**

បាទ, អញ្ចឹងខ្ញុំសូមរាយការណ៍ថា ផែនការរបស់លោកអាប្រាមស៍គួរឲ្យស្ញែងណាស់, ដោយសារខ្លីក្រញ៉ុចៗ។ រកពតិមានអ្វីសំខាន់មួយក៏គ្មាន, គឺថាគ្មានផែនការអ្វីមួយសោះតែម្តង។ មើលទៅពុំដឹងថាព្រំដែនខ្មែរវៀតណាមប្រវែងប៉ុន្មានទេ។ ចំនួនស្ពាននៅលើទន្លេដែលឆ្លងកាត់កម្ពុជាក៏គ្មានប្រាប់, ចំនួនភូមិនៅក្នុងតំបន់ដែលយើងត្រូវបោសសំអាតក៏គ្មានដែរ។

**គីស៊ីងហ្គ័រ**

នេះមកពីប្រញាប់ខ្លាំង ហើយត្រូវតែលាក់ជាការសម្ងាត់ទៀត, ដូច្នោះហើយបានជាលោកឧត្តមសេនីយ៍មិនអាចឲ្យពត៌មានក្បោះក្បាយបាន។

**វ៉ាត់ស៏**

ត្រូវរៀបចំយ៉ាងម៉េចក្នុងប្រតិបត្តិការរួមជាមួយទ័ពលន់ នល់ក៏គ្មានប្រាប់ដែរ។

**គីស៊ីងហ្គ័រ**

ផែនការនោះគឺសម្រាប់ប្រតិបត្តិការរួមរវាងអាមេរិកាំងនិងព្រៃនគរ។

**វ៉ាត់ស៏**

គេមិនដែលបញ្ជូននរណាម្នាក់ទៅភ្នំពេញដើម្បីពិនិត្យស្ថានការណ៍ផ្ទាល់ទីកន្លែងសោះ។ គ្មាននរណាដឹងអ្វីទាំងអស់ពីស្ថានការណ៍នៅខេត្តនានានៅខាងកើត។ គ្មាននរណាដឹងអ្វីទាំងអស់ពីចលនាទ័ពកុម្មុយនីស្ត៍នៅក្នុងទឹកដីកម្ពុជា។ ស្អែកនេះយើងនឹងចាប់ផ្តើមវាយលុកតាមផ្លូវអាកាស, ប៉ុន្តែអ្នកបើកយន្តហោះយើងដែលគ្មានផែនទីលំអិតអ្វីមួយនោះ នឹងទម្លាក់គ្រាប់បែកដោយបិទភ្នែក។ សង្ខេបមកគឺថា យើងគ្មានដឹងអ្វីទាំងអស់, គ្មានឃើញអ្វីទាំងអស់, ហើយត្រូវវាយលុកស្អែក។ លោកឲ្យខ្ញុំធ្វើរបាយការណ៍ប្រវែងមួយទំព័រស្តីពីផលវិបាកនៃប្រតិបត្តិការនេះ។ ម៉េចក៏មិនរួមឲ្យខ្លីឲ្យនៅតែមួយម៉ាត់តែម្តងទៅ?

**គីស៊ីងហ្គ័រ**

លោកចង់រករឿងនឹងខ្ញុំឬយ៉ាងម៉េច?

**វ៉ាត់ស៏**

ខ្ញុំនិយាយតែមួយម៉ាត់ទេ គឺខ្ញុំលាលែងឈប់។

នែលោក, ពីមុនមក ខ្ញុំស្មានតែលោកទីប្រឹក្សាជាអ្នកមានមានះតែល្អិតល្អន់ក្នុងការងារ។ ប៉ុន្តែយប់មិញនេះ ពេលដែលសិក្សាផែនការនោះទៅ ខ្ញុំឃើញថាលោកគ្មានវីរវល់អ្វីទេ, ដូចតែផ្តាច់ការអញ្ចឹង, គឺធ្វើឧក្រិដ្ឋកម្មសាហាវយង់ឃ្នងធំធេង, ភ្នែកមនុស្សមើលលែងជុំរហូតទៅជាមើលមិនឃើញ។ កំពុងធ្វើឃាតកម្មប្រទេសកម្ពុជាហើយ, លោកព្រមទាំងមនុស្សធ្វើបូកមីះ។ ដែលគ្រប់គ្រងយើងទាំងអស់គ្នានេះ!

លោកទីប្រ៊ីក្សា, ខ្ញុំខ្ពើមលោកណាស់!

*(លោកវ៉ាត់ស៍ដើរចេញទៅ)*

**គីស៊ីងហ្គ័រ**

សាហាវមែន! សាហាវមែន! ម៉េចក៏សាហាវយ៉ាងនេះ?

*(គាត់ដើរចេញទៅ)*

# ឈុតទី២

## ឆាកទី១

*(ភ្នំពេញ។ អ្នកឡាំណោចូលមក)*

**អ្នកឡាំណោ**

ឱព្រះសាវ: Saint-Antoine, សូមជួយនាំអ្នកខៀវសំណុលបងស្រីខ្ញុំមកទីនេះវិញ, ផ្ទះលេខ៤ផ្លូវផ្ការំយោល។ បើពុំដូច្នោះ ខ្ញុំនឹងស្លាប់មុនគាត់មកដល់វិញជាពុំខាន។ ខ្ញុំស្គាល់គាត់ច្បាស់ណាស់, គឺថាពេលនោះគាត់នឹងកើតទុក្ខរីងរៃដោយបាត់បង់ប្អូនស្រី, គឺឡាំណោដ៏កំសត់នេះ។ យើងទាំងពីរនាក់នឹងអស់ទីពឹង, គ្មានអ្វីរំសាយទុក្ខបានឡើយ។ ឱព្រះជាម្ចាស់, ព្រះអង្គតែងតែអាណិតខ្ញុំម្ចាស់ ដោយជ្រាបថាខ្ញុំម្ចាស់ជាឃ្លួន, ដូច្នេះហើយតែងភិតភ័យគ្មានពេលល្ហែ។ ខ្ញុំម្ចាស់មិនអាចរត់ប្រសេចប្រសាចទៅគ្រប់ទិសទី, គ្រប់ច្រកល្ហកដើម្បីរកបងសំណុលជាទីស្រឡាញ់ឡើយ, ដោយសារតែបម្រាមគោចរចង្រៃនេះ ធ្វើឲ្យឈានជើងទៅណាមិនកើត, ចំពេលដែលត្រូវចេញទៅក្រៅផ្ទះ។

*(អ្នកស្រីខៀវសំណុល និងយុគន្ធរចូលមក)*

**អ្នកឡាំណោ**

*យីអើ! ទៅណាមុនហ្នឹង? ហាស់? ដឹងម៉ោងប៉ុន្មានហើយទេ?*

**អ្នកស្រីខៀវសំណុល**

*ខ្ញុំទៅវត្ត។ មកយឺតបន្តិចមែនហើយ, តែពុំអត់ប្រយោជន៍ទេ។*

**អ្នកឡាំណោ**

*មិនអត់ប្រយោជន៍! បើសិនជាប្អូនស្រីជាទីស្រឡាញ់ដែលស្មានថាបងខ្លួនស្លាប់នោះ ស្លាប់ទៅវិញ ក៏នៅតែមិនអត់ប្រយោជន៍ទេឬអ្វី?*

**អ្នកស្រីខៀវ សំណុល**

អង្គុយមកកូន។ តែប្រាំនាទីទៀតនឹងស្រួលវិញហើយ។ វាវាល់តែពេលដូច្នេះឯង, ឲ្យតែពេលបម្រាមគោចរមកដល់ហើយ, អ្នកនេះគាត់ស្លន់ស្លក់ យល់ថាមានមនុស្សមករកគាត់ចាប់អាករសម្រក់ឈាមក្នុងថ្នាំងមិនដែលខានទេ។

**អ្នកឡាំណៅ**

នៅវត្ត! បើអញ្ចឹងវល់នៅវត្ត ហើយទុកឲ្យខ្ញុំស្លាប់នៅផ្ទះដោយសុខសាន្តចុះ, អញ្ចឹងមែនទេ?

**អ្នកស្រីខៀវ សំណុល**

យី, ម៉េចអញ្ចេះយប់នេះ! មួម៉ៅនាំរឿងចំពេលដែលខ្ញុំនាំរឿងសប្បាយមក។ យីអើ!

**អ្នកឡាំណៅ**

រឿងសប្បាយ?

**អ្នកស្រីខៀវ សំណុល**

ហ្នឹងហើយ, គឺយប់នេះតែម្ដងដែលខ្ញុំនាំជំនូនមួយមក, ហើយស្រាប់តែមកបង្កើតរឿង, ដែលពីមុនមកមិនធ្លាប់ធ្វើដូច្នេះសោះ!

**អ្នកឡាំណៅ**

ជំនូនអីទៅ, បង, ដែលនឹងឲ្យខ្ញុំនោះ?

**អ្នកស្រីខៀវ សំណុល**

*(ចង្អុលទៅយុគន្ធរ)*

នេះ!

**អ្នកឡាំណៅ**

ស្អីអញ្ចេះ! វ៉ាហ្នឹង? នាំមនុស្សមកដែលមិនបានត្រៀមចាំសោះ ហើយដែលគ្មានបាយទឹកអ្វីនឹងចិញ្ចឹមសោះ! នេះហើយឬដែលហៅថាជំនូនវង្វាន់នោះ?

### អ្នកស្រីខៀវ សំណុល

មិនមែនអ្នកក្រៅទេ, គឺកូនយើង។

### អ្នកឡាំណោ

កូនយើង? អូយយ៉ូយ, អូយយ៉ូយ, ឈប់សិន។ យី, ខ្ញុំហួសពីខឹងទៅទៀត។ កូនយើងយ៉ាងម៉េច? កូនណាមួយ?

### អ្នកស្រីខៀវ សំណុល

នែ, អូនសម្លាញ់, នេះ ឯងដែលបានមកពីវត្ត។ គឺព្រះបាទសម្តេចព្រះសុរាម្រិត, សម្តេចព្រះបិតា, លោកប្រទានមក។ ព្រះបិតុលាយើងចាំយើងពេញមួយថ្ងៃ, អាណិតព្រះអង្គណាស់, ព្រោះព្រះអង្គប្រទ្បំអាស័យដ្ឋានទៅលើខ្នងចុតហ្មាយ។

### អ្នកឡាំណោ

ចុតហ្មាយអី? នរណារង់ចាំយើងនោះ?

### អ្នកស្រីខៀវ សំណុល

ទុកឲ្យខ្ញុំផ្តើមឃ្លានិយាយឲ្យស្រួលបន្តិចបានទេ? បើកាត់ខ្ញុំរបៀបនេះធ្វើម៉េចបានចប់មួយឃ្លា។? គឺថាព្រះបិតុលាជាទីសក្ការៈរបស់យើង ដែលបានសរសេរចុតហ្មាយមកយើង ដើម្បីអរគុណយើងពីការឲ្យខ្ចីកង់កញ្ចាស់នោះទៅព្រះអង្គ, ព្រមទាំងព្រះរាជទានដ៏អស្ចារ្យនេះ! ហ! ខ្ញុំមើលឲ្យស្តាប់៖ “ក្មួយស្រីទាំងពីរជាទីស្រឡាញ់, ពេលដែលឃើញថាក្មេងកំសត់នេះ ជាមនុស្សតែម្នាក់គត់ដែលរួចរស់ជីវិតពីគ្រាប់បែកអាមេរិកាំងដែលទម្លាក់ទៅលើភូមិមេមត់, អុំនឹកដួចមកដល់ក្មួយក្លាម ដែលរស់នៅគ្មាននរណាជាទីពឹងពំនាក់, គ្មានកង់ជិះនៅក្នុងក្រុងភ្នំពេញយ៉ាងធំនេះ។ ដូច្នេះ អុំផ្ញើក្មេងដែលអុំពុំបានចិញ្ចឹមនេះ។ នៅលើលោកទាំងមូល ក្មេងនេះគ្មាននរណាទំនុកបម្រុងទេ ក្រៅពីក្មួយទាំងពីរនិងអុំដែលគ្រាន់តែជាស្រមោលប៉ុណ្ណោះនោះ។ តែឥឡូវអុំធូរចិត្តហើយ ព្រោះបានក្មួយជួយយកចិញ្ចឹម។ អាចប្រើវ៉ាជំនួសកង់បានឲ្យទៅផ្សារទិញឥវ៉ាន់។ វ៉ានឹងការពារអ្នកឡាំណោមិនឲ្យចោរ

ឃ្មួញមកបៀតបៀន។ ម្យ៉ាងទៀត ម្ហូបអាហារដែលក្មួយទាំងពីរប៉ិនប្រសប់ធ្វើដូចគ្នានោះ នឹងធ្វើឲ្យវាធាប់ធំធាត់ ហើយថ្ងៃក្រោយទៅនឹងក្លាយជាវីរបុរសនាំកេរ្តិ៍ឈ្មោះឲ្យឪពុកម្តាយដែលស្លាប់ទៅហើយនិងដែលនៅរស់។ ពីសពសុរាម្រិតដែលយល់ចិត្តថ្លើមអ្នកច្បាស់"។

**អ្នកឡាំណេ**

*យី, ពិរោះមែន! ពិរោះណាស់! ព្រះករុណាជាអម្ចាស់មានព្រះតម្រិះល្អមែន!*

**អ្នកស្រីខៀវ សំណុល**

*យ៉ាងម៉េចដែរ, ព្រះអំណោយនេះ? យល់ព្រមទេ?*

**អ្នកឡាំណេ**

*និយាយមិនព្រមយ៉ាងម៉េច? ឲ្យខ្ញុំសូមទោសទៅចុះអម្បាញ់មិញនេះ។ អូ, វិលមុខណាស់! មានកូនប្រុសមួយ! ចំណាស់យើងហើយមានកូនទៀត? ហើយព្រះករុណាថ្លៃវិសេសជាអ្នកប្រទានទៀត! យី, បដិហាដូចក្នុងរឿងព្រេងទេដឹង?*

**អ្នកស្រីខៀវ សំណុល**

*បដិហានោះ, ចំពោះខ្ញុំគឺមួយភូមិស្លាប់ទាំងអស់, នៅសល់តែមួយនេះ, គួរឲ្យអាណិតណាស់។*

**អ្នកឡាំណេ**

*បងសម្លាញ់, កូនយើងនេះ គិតដាក់ឈ្មោះថាម៉េច?*

*(គេឮសម្លេងយន្តហោះទម្លាក់គ្រាប់បែកអាមេរិកាំងហោះលើក្រុងភ្នំពេញ)*

**យុគន្ធរ**

*ខ្ញុំចង់សម្លាប់អាមេរិកាំងឲ្យបានម្នាក់!*

**អ្នកស្រីខៀវ សំណុល**

*ឮទេ, និយាយតែពាក្យនេះឯងដដែល។, តាំងពីវ័ត្តមក គឺនិយាយតែពាក្យនេះ។ ឈប់រមួលខ្លួនយ៉ាងនេះទៅកូន។ កូនឯងឃ្លានបាយទេ? ឃ្លានហើយ។ អូនស្រី, ដាំបាយឲ្យកូនបន្តិចមក, ណា!*

**អ្នកឡាំណេ**

ចាស, ខ្ញុំនឹងទៅដាំក្លាម។ គួរដាក់ស្ករបន្តិចផង, មែនទេ?

**អ្នកស្រីខៀវ សំណុល**

*ស្ករ? ក្រែងយើងអស់ស្ករហើយ, មែនទេ?*

**អ្នកឡាំណេ**

គឺថាខ្ញុំបានទុកប្រហែលកន្លះគីឡូសម្រាប់ព្រះយេស៊ូនិងនាងម៉ារី។

ចុះយើងគិតដាក់ឈ្មោះថាម៉េចទៅ, បងសម្លាញ់? ខ្ញុំដូចជាចង់ដាក់ថា “Antoine អ្នកស្រោចស្រង់“ ។

**អ្នកស្រីខៀវ សំណុល**

Antoine អ្នកស្រោចស្រង់? !!! ទេ, ទេ, មិនកើតទេ! ខ្ញុំដាក់ឈ្មោះយុគន្ធរ, ដូចព្រះនាមព្រះអង្គម្ចាស់ជីទូត មួយរបស់ព្រះបិតុលាយើង។ ចាំទេ, អ្នកឡាំណេ, ព្រះអង្គនោះស្រស់សង្ហា ហើយសុភាពរាបសាណាស់។

**អ្នកឡាំណេ**

មែនហើយ, អញ្ចឹងមែនហើយ, ដូចព្រះអង្គម្ចាស់យុគន្ធរមែន។ បងសម្លាញ់, ទម្រាំបាយថ្ងៃត្រង់, បងមើលព្រះចុត ហ្មាយឱ្យស្ដាប់ម្ដងទៀតបានទេ?

**អ្នកស្រីខៀវ សំណុល**

សូត្រឱ្យស្ដាប់ក៏បានដែរ ៖ “ក្មួយទាំងពីរជាទីស្រឡាញ់, ពេលដែលឃើញថា ក្មេងកំសត់នេះជាមនុស្សតែម្នាក់គត់ ដែលរួចជីវិតនៅភូមិមេមត់...”

*(ទាំងពីរនាក់ចេញទៅ, យុគន្ធរទៅតាម។ គេឮសូរយន្តហោះទម្លាក់គ្រាប់បែកហោះ)*

# ជាកទី២

*(ភ្នំពេញ, ទ្រង់សិរិមត:និងលោកចេងហេង ចូលមក)*

**ទ្រង់សិរិមត:**

លោកប្រធានរដ្ឋសភា, លន់ នល់ត្រូវតែលាលែងពីតំណែង។

**ចេង ហេង**

អញ្ចឹងមែន, តាំងពីឈឺមក, លោកលន់ នល់ ថយកាយពលនិងប្រាជ្ញា ដែលប្រមុខរដ្ឋត្រូវតែមាន, ជាពិសេសប្រមុខនៃរដ្ឋមួយដែលស្ថិតនៅក្នុងសភាពធ្ងន់ធ្ងរយ៉ាងនេះ។

**ទ្រង់សិរិមត:**

គាត់ខ្ជិននោះធ្វើឲ្យយើងខ្ជិនតាម។ យើងប្រឈមមុខនឹងគ្រោះថ្នាក់ធំណាស់។ ម្សិលមិញខ្ញុំឃើញទ័ពសត្រូវដើរយ៉ាងព្រងើយលើទ្រូងយើង។ ពួកយៀកកុងចូលមកដល់វាលយន្តហោះយើង, កៀកនឹងថ្លើមប្រម៉ាត់យើងទៅហើយ, គ្មានអ្វីរាំងរាទាំងអស់, ហាក់ដូចជាប្រទេសយើងជាសួនច្បាររបស់គេដូច្នោះ។ ពេលដែលការទម្លាក់គ្រាប់បែកកើតឡើង, លោកប្រធានាធិបតីយើងគ្មានកម្រើកអ្វីសោះ។ ខ្ញុំសួរគាត់ដដែលៗ ១០ដងថា៖ "យើងត្រូវធ្វើម៉េច? សូមបញ្ជាមក!"។ គ្មានចម្លើយអ្វីទាំងអស់, គាត់ចាំសញ្ញាអ្វីមួយពីមេឃពីផ្កាយ, ពីគ្រូទាយសិន។ វាយប្រយុទ្ធគ្នាអស់៥ម៉ោង។ ឥឡូវនេះ យើងគ្មានសល់យន្តហោះអ្វីមួយទៀតទេ។ វាសនាប្រទេសយើងដូចចកអញ្ចឹង, គ្មានទីពឹងទេ។ ម្សិលម៉្ងៃគាត់ថ្ងង់, មកដល់ម្សិលមិញគាត់ខ្វាក់។ ខ្ញុំបានបង្ហាញផែនទីឲ្យមើល, គាត់នៅតែមិនឃើញថា ទ័ពយើងដកថយគួរឲ្យបារម្ភក្រៃលែង។ នៅសល់តែភ្នំពេញនិងដីមួយដុំតូចៗ តាមនេះតាមនោះប៉ុណ្ណោះ។ ស្អែកនេះ សត្រូវនឹងចូលមករុងថ្លើមយើងបញ្ចប់ហើយ គាត់នឹងទុកឲ្យវាចូលមក។

**ចេង ហេង**

យើងមិនគួរតម្លើងងារគាត់ជាសេនាប្រមុខសោះ។ នៅពេលថ្ងៃត្រង់ គាត់ធ្វើហាក់ដូចជានឹងលាលែងពីតំណែង, ល្ងាចឡើងមកវិញទាំងដំណើរខ្ញើចៗ។

**ទ្រង់សិរិមត:**

បើយើងមិនបង្ខិតបង្ខំទេ, គាត់មិនបោះបង់អ្វីទាំងអស់៖ មួយដុល្លារក៏មិនចោល, តំណែងក៏មិនចោល, អំណាចអ្វីប៉ុនសរសៃសក់ក៏មិនចោល, សូម្បីតែសម្ដេចព្រះមហាក្សត្រីយានី ដែលគាត់ឃុំឃាំងតាមអំពើចិត្តនោះក៏គាត់មិនលែងដែរ។

*(លោកលន់ នល់ចូលមក, អនុសេនីយ៍ឯក អ៊ុន សូផាតនិងអ្នកបម្រើមកតាម)*

**លន់ នល់**

ធ្វើអ្វីខ្សឹបៗនៅមុខទ្វារខ្ញុំហ្នឹង? ខ្ញុំមិនទៅណាទេ, ខ្ញុំមិនលាលែងពីតំណែងទេ, ខ្ញុំនៅតទៅទៀត។ បើខ្សឹបគ្នាពីរឿងនេះ, នេះហើយចម្លើយខ្ញុំ។

**ទ្រង់សិរិមត:**

លោកសេនាប្រមុខ, អម្បាញ់មិញខ្ញុំនិយាយទៅលោកប្រធានរដ្ឋសភាអំពីសម្ដេចព្រះមហាក្សត្រីយានីដែលត្រូវយាងចេញ។ តាំងពីឃុំឃាំងព្រះអង្គមក, ព្រះអង្គចុះខ្សោយព្រះកាយពលខ្លាំងណាស់, លោកជ្រាបទេ?
*សាធារណរដ្ឋមានអីនឹងត្រូវការស្ដេច!, ឲ្យព្រះអង្គយាងទៅ! វាជាការសមរម្យផង...*

**លន់ នល់**

ខ្ញុំមិនឲ្យយាងទៅណាទេ។ ខ្ញុំត្រូវអំពើព្រះអង្គ បានជាខ្ញុំខ្វិនខ្វង់, លើកដៃលើកជើងមិនរួចឲ្យខ្ញុំលែងព្រះអង្គយ៉ាងម៉េច? ដរាបណាព្រះអង្គមិនដោះអំពើឲ្យដៃជើងខ្ញុំធម្មតាវិញទេ, កុំចាំបាច់យករឿងព្រះមាតុលារបស់ទ្រង់មកនិយាយណា, លោកអ្នកអង្គម្ចាស់។ ណ្ហើយនិយាយរឿងផ្សេងវិញ។
ខ្ញុំថាម៉េច, *អម្បាញ់មិញនេះ? លោកមានរៀបចំបុណ្យនៅក្រុងយើងនេះសម្រាប់ជ័យជំនះនៅកំពង់ធំទេ? ជ័យជំនះយ៉ាងខ្ទង់របស់ខ្ញុំ!*

**ចេង ហេង**

ស្រេចបាច់ហើយ។ អ្នកបាញ់កាំជ្រួចចាំតែបញ្ជាពីលោកប៉ុណ្ណោះ ដើម្បីបាញ់, ឯអ្នករបាំក៏ចាំតែលោកអញ្ជើញដល់ភ្លាមដើម្បីរាំដែរ។

**លន់ នល់**

ខ្សឹបខ្សៀវគ្នារឿងអី? មិនមែនជាជ័យជំនះខ្ញុំទេឬយ៉ាងម៉េច? ការប្រយុទ្ធគ្នានោះគឺខ្ញុំដឹកនាំពីលើគ្រែខ្ញុំទៅតាំងពី១ខែមកហើយ, គ្រប់ម៉ោង, គ្រប់ជំហាន។

**ចេង ហេង**

គាត់ពុស្សូវយើងគិតក្នុងចិត្ត។

**លន់ នល់**

ប្រយ័ត្នណា, អស់លោក! ខ្ញុំពួអ្វីៗ ដែលលោកគិតទាំងអស់។

**ទាហានម្នាក់**

លោកឧត្តមសេនីយ៍, អុះ, លោកសេនាប្រមុខ, មាននារសារមួយមកពីកំពង់ធំ, ពីលោកវីរៈសេនីយ៍ឯក អ៊ុំ សាវុធ, ទានប្រោស។

**លន់ នល់**

ឲ្យមក, ឲ្យចូលមក! អស់លោកចាំមើលចុះ, ហោរ ៥០នាក់របស់ខ្ញុំបានទស្សន៍ទាយថា យើងនឹងឈ្នះយ៉ាងត្រចះត្រចង់នៅកំពង់ធំ។

*(នារសារលោកសក្តិ៥ អ៊ុំ សាវុធចូលមក។ គាត់នៅសល់ដៃតែមួយ, ត្រចៀកតែម្ខាង ហើយស្រវឹងផង)*

**អនុសេនីយ៍ទោ**

ព្រះករុណាជាអម្ចាស់, ទូលបង្គំស្រវឹងបន្តិច, ដោយរំភើបពេក។

**អ៊ិន សូផាត**

ឯកឧត្តម, មិនមែនព្រះករុណាថ្លៃវិសេសទេ។

ឯកឧត្តម, លោកសក្តិ២ភ្លេចភ្លាំងបន្តិច។

**អនុសេនីយ៍ទោ**

ខ្ញុំបាទស្រវឹងនឹងសង្គ្រាម, ក្រាបទូលឯកឧត្តម, ថ្ងៃនេះធ្ងន់ធ្ងរយ៉ាប់ខ្លាំងណាស់, ហើយមិនទាន់ចប់ទេ, តែគួរឲ្យតាមដាន។ យុទ្ធនាការណ៍ដ៏អស្ចារ្យនេះ! រៀបជើងព្រួលល្អមែន! គួរឲ្យស្ញើច!

ដំបូងឡើយអ្វីៗល្អឥតខ្ចោះ។

យើងដើរជាជួរយ៉ាងស្ងប់ស្ងៀម, ដូចស្រមោលដូរទឹកខ្លែងដូច្នោះដែរ។ យើងទៅមុខក្រោមពន្លឺផ្កាយរបស់ឯកឧត្តម, គ្មានជំពប់ជើងដួលអ្វីតិចតួចឡើយ ក្រោមស្នូរគ្រាប់កាំភ្លើងខ្លាំង។ ល្អសមតែយល់សប្តិ!

បន្ទាប់មកដល់កំពង់ធំ, អ្វីៗគួរជាទីរីករាយ, ហើយនៅតែមិនឃើញមានយួនម្នាក់ទេ។ មេឃស្រឡះភ្លឺថ្លា, គ្មានស្រមោចសង្ការអ្វីមួយមករំខានទាល់តែសោះ...!

ស្រាប់តែក្ខាំង, ក្ខាំង! ឱម្ចាស់ថ្លៃ! ប្រសាចដូចទឹកភ្លៀងដែលព្រះភិរុណបង្អុរមក។ តទៅនេះគឺ តុល្យការបណ្តោះអាសន្ន, ឧត្តមសេនាប្រមុខ។ និយាយតែពីក្រុងបារាយនិងកំពង់ធំគឺ រថក្រោះ៤, ឡានធំ២០, ឡានក្រោះ៤ថ្មីថែស, ឡានកាមីញ៉ុងទម្ងន់២តោនកន្លះចំនួន៨, ឡានដឹកជញ្ជូនខ្នាតតូចចំនួន២១។ កាណុង១០៥ម.ម. មួយ, ជាពិសេសមនុស្ស៣០០នាក់, កាំភ្លើងរះខ្នាតធំរាប់រយ។ ហើយ, នៅពេលដែលរៀបនឹងចាកចេញនោះ, ស្លាប់៥០នាក់ទៀត។

**លន់ នល់**

យើងចាញ់ឬឈ្នះដែលនិយាយនេះ?

**អនុសេនីយ៍ទោ**

មិនទាន់បានឈ្នះផង, យើងចាញ់គេទៅវិញ។ យួនវាវាយតបមកយើង។ វារៀបចំនោះល្អមែន, គ្មានអ្វីធ្ងល់ទេ, ដែលយើងចាញ់នោះ, ព្រោះយើងគួរតែបានរៀបចំឲ្យល្អដូចវាជាមុនសិនដែរ។

**ទ្រង់សិរិមតៈ**

ចុះទាហានយើង?

**អនុសេនីយ៍ទោ**

ទាហានយើងរត់យកព្រះអាយុ៉សប្រសេចប្រសាចដូចពស់ចូលក្នុងព្រៃរនាមអញ្ចឹង។ ធ្វើនោះត្រូវហើយ។ មានលុយពេញហោប៉ៅ, មានបាយឆ្អែតពោះ ហើយស្លាប់, មិនស្រួលប៉ុន្មានទេ។ តែបើបីខែហើយមិនទាន់បើកប្រាក់ខែ ដោយសារតែមេទ័ពរង អ៊ិត សួងជាមេដ៏សែនគម្រក់ក្នុងទ្វីបនេះ, មិនតែប៉ុណ្ណោះជាកូនកាត់ ហើយកំសាកញីទៀតផង គឺរិតតែអាក្រក់យ៉ាប់យឺនទៅទៀត! បើសិនជាពួកទាហានមិនរត់ គឺយើងច្បាស់ជាអស់មនុស្សពាពាន់នាក់។ សំណាងល្អណាស់ដែលការបាក់ទ័ពនេះជាការបាក់ទ័ពទាំងស្រុង។

ខ្ញុំបាទកោតស្ញើបខ្លាំងយើងមែន។ ពួកទាហានយួននេះមិនមែនជាទាហានអារាត់អារាយទេ, មានរបៀបណាស់, ហើយអាវុធក៏សម្បើមដែរ!

**លន់ នល់**

លោកសក្ដិពីរច្បាស់ជាអស់កម្លាំងហើយ, ទៅសម្រាកចុះ។

**ចេង ហេង**

លោកសេនាប្រមុខ, បន្ទុករបស់លោកទាំងប៉ុន្មានធ្ងន់ណាស់។ មនុស្សដប់នាក់ក៏ទ្រាំទ្រមិនបានដែរ។ លោករែកបញ្ហាផ្ទៃក្នុង, បញ្ហាក្រៅប្រទេស, សង្គ្រាម, សន្តិភាព, ការងារកងទ័ព... លើស្មាដ៏ថ្លៃថ្លារបស់លោក។ ខ្ញុំសូមអង្វរឲ្យលោកសម្រាលបន្ទុកនោះខ្លះទៅលើស្មាអ្នកណាដែលលោកចង់រំលែកទៅ។

**ទ្រង់សិរិមតៈ**

សូមលោកឈប់កាន់អគ្គមេបញ្ជាការទៅ, លោកសេនាប្រមុខ។ ទុកឲ្យឧត្តមសេនីយ៍ផ្សេងៗ ដឹកនាំយុទ្ធនាការណ៍ដោយខ្លួនគេទៅ។ លោកមិនអាចប្រយុទ្ធនៅគ្រប់សមរភូមិពីបន្ទប់លោកទេ។ អំណាចនោះ ចែកទៅគេឯងខ្លះទើបបាន បើចង់កុំឲ្យអស់រលីងពេលណាមួយ។

**លន់ នល់**

ចែកអំណាច! ចែកនោះច្រើនពេកទៅហើយ។ នៅជុំវិញខ្ញុំនេះ ម្នាក់ៗមានរឿងនិយាយគ្រប់គ្នា, តែគ្មានដែលឃើញធ្វើអ្វីសោះ។ គេអួតរហូតដល់ថានឹងជំនុំជម្រះប្រមុខកំពូលរបស់រដ្ឋ, ហើយម្នាក់ៗ ចេះលើសព្រះទៅ

ទៀត! កំពុងតែពិបាកប្រមូលអារម្មណ៍ឲ្យស្ងប់ធ្វើការងារផង, ទ្រង់មកវ៉ៅចានមិនចេះចប់។ ទ្រង់គ្រាន់តែជាចៃសង្កើចមួយក្នុងសក់ប្រទេសខ្មែរតែប៉ុណ្ណោះ, តែចេះតែនឹកស្មានថាធ្វើផ្គរធ្វើព្យុះបាន!

**ទ្រង់សិរិមត:**

ខ្ញុំនឹងលើកយកបញ្ហានេះទៅឲ្យរដ្ឋសភាពិនិត្យ!

**លន់ នល់**

រដ្ឋសភារបស់ទ្រង់នោះ, ខ្ញុំនឹងព្យួរការងារ។ ខ្ញុំធុញណាស់ ដែលគេលេងល្បែងប្រជាធិតេយ្យនិងសេរីភាពនេះ។ ខ្ញុំព្យួរអ្វីៗទាំងអស់។ យើងកំពុងមានសង្គ្រាមណាអស់លោក! ខ្ញុំនឹងដឹកនាំក្ដោបក្ដាប់ប្រទេសជាប់ក្នុងដៃរហូតដល់ជ័យជំនះ!

**ទ្រង់សិរិមត:**

ខ្ញុំមិនឆ្ងល់ទេ ថាលោកនឹងដឹកនាំប្រទេសដ៏អកុសលរបស់យើងនេះ ដោយគ្មានញាប់ញ័រអ្វីរហូតដល់រលាយនៅទីបញ្ចប់។ យកអ្វីៗទាំងអស់ទៅព្យួរលើផ្កាយលោកទៅ, គង់តែបាកធ្លាក់មកទេ។ ពេលនោះមេឃរលំមកលើលោក ដែលជាទីងមោងកញ្ចាស់មួយ, ហើយនឹងគ្របលប់បាត់ប្រទេសកម្ពុជាទៅជាមួយជនផ្ដាច់ការជាមេនោះ! ខ្ញុំមិនយកខ្លួនឲ្យប្រឡាក់ប្រឡូសនឹងការលោកលន់ដ៏ក្រខ្វក់របស់លោកទេ។ ខ្ញុំសូមលាលែងពីតំណែងហើយ។

**លន់ នល់**

សាធុ! អស់ក្រុមស្ដេចមែនទែនហើយ! ផ្កាយជោគជតាសន្សាមកត្រូវមែន, ខ្ញុំខំតែមន្ទិលសង្ស័យ។ មានតែខ្ញុំហើយ, ឥឡូវនេះ, ដែលឲ្យកំណើតដល់សាធារណរដ្ឋពិតប្រាកដ, ស្អាតស្រឡះអស់អំពីកំទិចស្ដេចដែលធ្វើឲ្យក្រខ្វក់ដល់របបយើង!

**ទ្រង់សិរិមត:**

នៃលោកលន់ នល់, ខ្ញុំឃើញលោកវារជើងបួនមករករាជ្យបល្ល័ង្កយើងជាយូរមកហើយ។ ប៉ុន្តែ ចំពោះភ្នែកប្រជារាស្ត្រយើងវិញ លោកគ្រាន់តែជាជន្លេនមួយពាក់មកុដប៉ុណ្ណោះ។

*(ទ្រង់សិរិមត:ចេញទៅ)*

**លន់ នល់**

យ៉ាងម៉េច? យ៉ាងម៉េច? គាត់ថាស្អី?

**ចេង ហេង**

ទ្រង់សិរិមគៈ ថាលោកនឹងក្លាយទៅជាជន្លេនពាក់មកុដតែប៉ុណ្ណោះ។

**លន់ នល់**

យី, លោកចេង ហេង, ខ្ញុំជាអ្នកលើកលោកឲ្យឡើងដល់កំពូលរដ្ឋ, ឥឡូវលោកយកពាក្យនេះមកថាតាម!

**ចេង ហេង**

ទេ, លោកសេនាប្រមុខ, លោកទេតើជាអ្នកឲ្យខ្ញុំនិយាយប្រាប់...

**លន់ នល់**

លោកចេង ហេង, ខ្ញុំមិនត្រឹមតែមិនថ្កូវប៉ុណ្ណោះទេ, គឺខ្ញុំឮលោកនិយាយអ្វីៗទាំងអស់តាំងពីពាក្យនោះចេញពីមាត់លោកមិនទាន់ផុតផង។ ហ! ឥឡូវនេះខ្ញុំឮលោកថា "ខ្ញុំលាលែងពីដំណែងដែរ" ។ លោកនឹងថាពាក្យនេះមែនទេ?

**ចេង ហេង**

យល់ច្រឡំហើយ, លោកសេនាប្រមុខ, ខ្ញុំនឹងមិនលាលែងទេ!

**លន់ នល់**

អូមែន, លោកមិនមែនជាស្តេចឯណា! ទាល់តែគេជួយឲ្យលាលែងបន្តិចទើបកើត។ អញ្ជើញទៅចុះ។ ប្រធានរដ្ឋសភាដែលគ្មានរដ្ឋសភា, មានតែច្នួតទើបទៅអញ្ជើងកើត។ ខ្ញុំទាញលោកឲ្យចុះពីលើនោះមកវិញ។

*(លោកចេង ហេងដើរចេញ)*

ទៅបាត់ហើយ?

**អ៊ុន សុផាត**

*ដោយរត់ផង, ទានប្រោស។*

**លន់ នល់**

*លោកសក្តិបី, នេះសំបុត្រមួយ។*

**អ៊ុន សុផាត**

*ទៅលោកប្រធានាធិបតីសហរដ្ឋអាមេរិកដូចតែសព្វដង, មែនទេ, ទានប្រោស?*

**លន់ នល់**

*ដូចតែសព្វដង។*

*"លោកបង* Richard Nixon *ជាទីស្រឡាញ់,*

*ខ្ញុំមានកិត្តិយសនឹងជម្រាបលោកបងថា ខ្ញុំទើបតែនឹងរំលាយរដ្ឋសភាខ្ញុំចោល, ទម្លាក់ប្រធានរដ្ឋសភាពព្រម ទាំងប្រកាសខ្លួនខ្ញុំថា ជាប្រមុខនៃរដ្ឋខ្ញុំ, នៃកងទ័ពនិងជារដ្ឋមន្រ្តីនៃក្រសួងទាំងអស់។ សុខភាពខ្ញុំល្អណាស់។ ខ្ញុំសូមប្រកាសដោយមានទំនុកចិត្តនិងកោតស្ញប់ស្ញែងថា លោកបងនិងមហាប្រទេសលោកបងមានតម្លៃលើស អ្វីទាំងអស់ចំពោះរូបខ្ញុំ។ ជាមួយគ្នា, យើងនឹងកំទេចក្រុមទ័ពវៀតណាមឲ្យទៅជាផេះ។*

*លោកមហាប្រធានាធិបតីជាទីមេត្រីយ, ខ្ញុំសូមឲ្យលោកដែលជាមិត្តតែមួយគត់មេត្តាបញ្ជូនយន្តហោះ* B52 *ចំនួន ៦០ ឬក៏* T28 *ចំនួន២០០, ស្រេចតែចិត្តលោកបង, ព្រោះយន្តហោះយើងខ្ញុំ, គេកំទេចអស់ហើយ..."*

*(ទាំងអស់គ្នាចេញទៅ)*

## ចាកទី៣

*(ប៉េកាំង។ ព្រះសីហនុយាងមក ដោយលោកអ៊ុង មាងមកតាម)*

### ព្រះសីហនុ

បេះដូងខ្ញុំរួញតូចដោយសារបារម្ភ។

លោកមេទ័ពយ៉ាប, មេខ្លាំងពូកែឈ្នះគេនៅឌៀនបៀនភូ ពេលមកជួបសីហនុម្ដងៗ គឺដើម្បីត្អូញត្អែរថាខ្មែរក្រហមធ្វើអាក្រក់និងថាចិនចិត្តមិនស្មោះតែប៉ុណ្ណោះ។ ផ្លូវដើរខ្ញុំយ៉ាងចង្អៀតស្រាប់នោះ ចេះតែវែងអន្លាយឆ្ងាយទៅ, រីឯ មេឃវិញក៏មានពពកមកបាំង។ ថ្ងៃណាមួយនឹងបានចេញផុតប្រកនេះ, ហ្ន!

### អ៊ុង មាង

ព្រះករុណាថ្លៃវិសេស, ទូលបង្គំនឹកស្រុកទេសណាស់។ ទូលបង្គំចង់ចូលទៅវិញ, ទៅប្រយុទ្ធជាមួយព្រះអង្គលើទឹកដីយើង!

### ព្រះសីហនុ

ខ្ញុំក៏អញ្ចឹងដែរ។ ឥឡូវនេះ ផ្លូវលំហូដីមិញស្ងប់ស្ងាត់បន្តិចហើយ។ ខ្ញុំបានសូមឲ្យសម្ដេចប៉ែន នុតផ្ញៀតឱកាសនេះដើម្បីនិយាយទាមទារឲ្យយើងបានចូលទៅជិតមេញ្ញាការខ្មែរក្រហមផង។ ប៉ុន្តែគ្មានសង្ឃឹមទេថាលោកនឹងធ្វើបានសម្រេច។

៣ឆ្នាំ, លោកមាង, ៣ឆ្នាំហើយដែលខ្ញុំចូកចែវក្នុងភាពនិរទេសនេះ។ ៣ឆ្នាំហើយដែលយើងនិយាយដដែលៗថានឹងកំទេចលន់ នល់ឲ្យទៅជាផេះ។ រីឯសម្ពន្ធ័មិត្តខ្មែរក្រហមនិងវៀតណាមរបស់ខ្ញុំនេះ រវល់តែអារកគ្នាទៅវិញទៅមក ច្រើនជាងយកពេលទៅកំចាត់ពួកឈ្លានពាន។ អើ, លន់ នល់, ឯងមានសំណាងមែន។ ឯងបន្លំក្អែកគេបាន៣ឆ្នាំ ដោយសារតែជម្លោះជូរចត់រវាងពួកដៃគូអញ។ មាងអើយ, យើងនេះចុះទឹកក្រពើឡើងលើខ្លា។ បើហាណូយបោះបង់យើងចោល, យើងនឹងធ្លាក់ចុះក្នុងកណ្ដាប់ដៃខ្មែរក្រហមហើយ។

### អ៊ុង មាង

តែហាណូយមិនអាចបោះបង់យើងចោលបានទេ, ក្រាបទូល!

## ព្រះសីហនុ

វៀតណាមអាចនឹងអួតក្អេង។ ប្រាប់គេថា ខ្មែរក្រហមបង្កើតរឿងដល់ខ្លួនរាប់ពាន់ដង។ ពេលនោះគេអាចផ្ដាច់ចំណងជាមួយយើង, ហើយងាកមកចងសត្រូវនឹងយើងវិញ, រហូតដល់ពេលមួយនោះ, គ្មានអី, គ្មាននរណានឹងទប់គេមិនឲ្យមកសង្គ្រប់លើយើងទាំងរស់ទេ។

កាលណាអស់ពីជូ អេនឡាយទៅ, កាលណា...

## អ៊ុង មាង

ឱព្រះជាម្ចាស់, ប្រសិនបើលោកជូ អេនឡាយជាទីគោរពចាកលោកទៅ, នរណានឹងការពារព្រះអង្គទៀត?

## ព្រះសីហនុ

ខ្ញុំមើលជោគជតាទីបញ្ចប់របស់ខ្ញុំទៅ ឃើញថាយ៉ាងនេះ៖

បើខ្លាខ្មែរក្រហមយកភ្នំពេញបាន, ហើយខ្ញុំបង្ហាញថាចង់ទៅជិតនោះដែរ, គឺគេនឹងហែកហួរខ្ញុំជាដុំៗ ដោយគ្មានរួញរា។

បើក្រពើយួនវិញជាអ្នកវាយបាន, គេនឹងលេបប្រទេសខ្ញុំនៅមុខខ្ញុំ ដូចលេបមាន់ទាដែរ, ហើយខ្ញុំនឹងពួសូរសម្រែកយ៉ាងខ្លាចផ្សា ដែលអន់ខ្សោយបន្តិចម្ដងៗ រហូតបាត់ក្នុងពោះក្រពើនោះ។

## អ៊ុង មាង

ប៉ុន្តែអម្បាញ់មិញទូលបង្គំឮឧត្តមសេនីយ៍យ៉ាបនិយាយទូលព្រះអង្គច្បាស់ថា មិនកែប្រែពាក្យសម្ដីទេ។ ហាណូយសន្យាថា នឹងមិនប៉ះពាល់ព្រះអង្គជាដាច់ខាត។ ព្រះអង្គមិនជឿពាក្យគាត់ទេឬ, ក្រាបទូល?

## ព្រះសីហនុ

ខ្ញុំនៅជឿនៅឡើយ។ ប៉ុន្តែអ្វីក៏តែងទៅមុខបាត់ដែរ, យុវវ័យ, មិត្តភាព, ផ្ការីក, ទឹកទន្លេ។ ឯសំដីក៏ដូចតែគ្នា។

## អ៊ុង មាង

តែ, មើលទៅមុខគាត់ដូចជាត្រង់ណាស់។

**ព្រះសីហនុ**

អញ្ចឹងមែន លោកអនុសេនីយ៍ឯក។ តែខ្ញុំក៏បានឃើញដែរថា នៅមុខដែនទីប្រទេសកម្ពុជា ក្មេកគាត់បិទ តែចង្អុលដៃគាត់ចុចទៅលើចំណុចដែលមានទឹក ដែលមាននៅក្នុងប្រទេសយើងក្នុងខែប្រាំង, គ្មានខុស ត្រង់ណាមួយឡើយ។

**អ៊ុង មាង**

*ឱ! ទូលបង្គំមិនដឹងថាព្រះករុណាអស់សង្ឃឹមដល់ម្ល៉េះសោះ, ក្រាបទូល!*

*(សម្ដេចប៉ែន នុតចូលមក)*

**សម្ដេចប៉ែន នុត**

*ព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំទើបនឹងទទួលជ័យជំនះមួយ! ជ័យជំនះតូចល្អមួយ!*

**ព្រះសីហនុ**

*បើប្រាប់ខ្ញុំថា អៀង សារីយល់ព្រមនោះ ខ្ញុំមិនជឿទេ!*

**សម្ដេចប៉ែន នុត**

*ទេ, គឺយល់ព្រមមែន, ទូលបង្គំហ៊ានស្បថ។ ទូលព្រះបង្គំប្រញ៉ាប់ប្រញ៉ាល់មកទូលព្រះអង្គបណ្ដើរ, អស់សំណើច បណ្ដើរ។ និយាយឲ្យពិត គឺទូលបង្គំយំ! ទូលបង្គំឈ្នះ, ក្រាបទូល។ គេយល់ព្រមតាមហើយ! ព្រះអង្គនឹងយាងទៅ ក្នុងស្រុក។ លោកអនុសេនីយ៍ឯក, ព្រះករុណានឹងយាងទៅស្រុកខ្មែរបាន!*

**ព្រះសីហនុ**

*យើងចូលទៅវិញ? ពេលណា? ពេលណា? ឱម្ចាស់ថ្លៃ! យើងចូលទៅវិញ។ មាងអើយ, ខ្ញុំសប្បាយចិត្តមែន! ខ្ញុំថា អ្វីមុននេះ, បំភ្លេចចោលទៅ, កុំយកជាការ!*

**អ៊ុង មាង**

*ព្រះករុណាថ្លៃវិសេស, ក្រាបទូល! យើងត្រឡប់ទៅវិញពេលណា, ទានប្រោស?*

**សម្តេចប៉ែន នុត**

ទេ, លោកអនុសេនីយ៍ឯក, មានតែព្រះករុណានិងអ្នកម្នាងប៉ុណ្ណោះដែលអាចត្រឡប់ទៅវិញ! ព្រះករុណាយាងទៅស្អែកនេះ។ ក្រៅពីព្រះអង្គគ្មាននរណាទៀតទេ ក្នុងពេលនេះ។ ថ្នាក់ដឹកនាំនៃចលនាតស៊ូយើង។ ល។ និង ។ល។ ទូលបង្គំទូលព្រះអង្គហើយថា ជាជ័យជំនះតូចមួយ, ក្រាបទូល។

**ព្រះសីហនុ**

មិនអីទេ! មិនអីទេ! ដំណឹងល្អយ៉ាងនេះ! ស្អែក! សម្តេច, សម្តេចធ្វើឲ្យខ្ញុំស្វាហាប់ឡើងវិញ, ធ្វើឲ្យខ្ញុំងើបឈររឹងមាំវិញ, សម្តេច... សម្តេចធ្វើឲ្យខ្ញុំសោមនស្សពន់ពេក។ ខ្ញុំកោតស្ញែងសម្តេចណាស់!

**សម្តេចប៉ែន នុត**

យាងទៅនោះតែមួយជុំខ្លីទេ, ក្រាបទូល។ ពីរបីអាទិត្យទៅតាមផ្លូវលំ។ តែមួយខែប៉ុណ្ណោះក៏ត្រូវយាងត្រឡប់មកប៉េកាំងវិញ។

**ព្រះសីហនុ**

ឱ, ខ្ញុំនឹងដើរស្មុកគគ្រុកគ្រប់ទិសទី។ ពេលដើរតាមផ្លូវនោះ ខ្ញុំនឹងឮបេះដូងខ្ញុំថា៖ សីហនុមកវិញហើយ! សីហនុមកវិញហើយ! ត្រឡប់មកស្រុកវិញហើយ! ពេលខ្ញុំទៅដល់ ធាតុអាកាសនឹងលែងស្អុះស្អាប់ហើយ។ ឱ, សម្តេច! បារម្ភរយពាន់យ៉ាងនោះ ឥឡូវរលាយអស់។ ទុក្ខគ្រាំគ្រាបីឆ្នាំក៏រសាត់ទៅឆ្ងាយដូចជាយល់សប្តិដែរ។

*(ទាំងអស់គ្នាចេញទៅ)*

# ឆាកទី៤

*(ភ្នំពេញ, លោកលន់ នល់ចូលមកដោយមានលោកនាយករដ្ឋមន្ត្រីឡុង បូរេតនិងលោកអនុសេនីយ៍ឯកអ៊ិន សូផាត និងអ្នកបម្រើមកតាម)*

**លន់ នល់**

មិនតែប៉ុណ្ណោះ ការវេកម្មមិនបានសម្រេចនេះ ធ្វើឡើងដោយកូនប្រសារសីហនុម្នាក់ ដែលជាអ្នកនិយមសីហនុ! ឥឡូវនេះ លោកយល់យ៉ាងម៉េចដែរ?

**ឡុង បូរេត**

អ្នកបើយន្តហោះ T28 ជាកូនប្រសារសីហនុ! យី, ពួករាជានិយមនេះជាបីសាចតែម្តង! សុទ្ធតែជាពួកថ្កែយាមទ្វារ, គិតតែពីព្រុសការពារជនផ្តាច់ការ!

**លន់ នល់**

ឯខ្ញុំវិញ, ខ្ញុំត្រូវធ្វើអ្វី?
ចាប់ដាក់គុកទាំងអស់! អញ្ចឹងមែនហើយ! ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់ដែលហ៊ាននៅកណ្តាលក្រុងយ៉ាងគ្រហើៗទាំងនេះ, ត្រូវចាប់ឲ្យអស់ៗ ទៅ! លោកនាយករដ្ឋមន្ត្រីចាប់ពួកនោះឲ្យអស់មក!

**ឡុង បូរេត**

ចាប់ទាំងអស់ឬ, ឯកឧត្តម?

**លន់ នល់**

ទាំងអស់, ចាប់ទាំងអស់, កុំឲ្យសល់!
នាគកំណាចរបស់ស្តេចនេះ ត្រូវតែយកមកអាករសម្រក់ឈាមទាល់តែដល់ដំណាក់ចុងក្រោយ។ ជយោសាធារណរដ្ឋ! ហើយកុំភ្លេចសិរិមត:។

**ឡុង បូរេត**

*សិរិមតៈឬឯកឧត្តម? ពិតជាអញ្ចឹងមែនឬ? ប៉ុន្តែ ទ្រង់ជាអ្នកសាធារណរដ្ឋដែលខ្ញុំយល់ថានិយមដោយស្មោះ។ ម្យ៉ាងទៀត ទ្រង់គ្មានពាក់ព័ន្ធអ្វីនឹងការវកម្មនេះទេ, ហើយមិនទាំងគង់នៅភ្នំពេញទៀតផង។ តាំងពីលាលែងពីដំណែងមក ទ្រង់រស់នៅស្ងប់ស្ងាត់តែឯង។*

**លន់ នល់**

*ទែ, លោកឡុង បូរេត, លោកគិតតែឯង, ជឿស្មានទ។ តែឯងប៉ុណ្ណោះ។ ខ្ញុំវិញ, ខ្ញុំដឹង, ខ្ញុំឃើញហើយខ្ញុំដឹកនាំប្រទេស។ លោកថា "ទ្រង់" ! ថា "ទ្រង់" អញ្ចឹង? លោកនៅតែជាប់ក្អែលស្តេចឬយ៉ាងម៉េច? ខ្ញុំបញ្ជាឲ្យលោកចាប់ស៊ីសុ- វត្ថសិរិមតៈ ដែលជាជនក្បត់! ជនប្រឆាំង! គាត់នោះផ្សព្វផ្សាយប្រាប់គេឯង, ហើយប្រាប់អាមេរិកាំងថារបបខ្ញុំមិនកើតជាការទេ។ ទៅ! ទៅចាប់ក្លាម!*

**ឡុង បូរេត**

*បាទទាន, ខ្ញុំទៅ, តែខ្ញុំសូមអនុញ្ញាតសួរសំនួរមួយទៀត។ ចំពោះរឿងកូដកម្មគ្រូបង្រៀននិងនិស្សិត ដែលចេះតែរីកទៅៗប៉ុន្មានថ្ងៃមកនេះ, យើងត្រូវធ្វើអ្វី?*

**លន់ នល់**

*ទេ, មានទៅពិបាកអី? ក្រែងមានប៉ូលីសដែរ, មិនអញ្ចឹង? បាញ់ទៅ។ ខ្ញុំមិនត្រូវការឲ្យមានចលាចលទៀតទេ។ ថ្ងៃនេះជាថ្ងៃជា, ដោះស្រាយគ្រប់រឿងឲ្យអស់។ កាសែតដ៏ដូច្នោះដែរ, បិទផ្អាកកុំឲ្យចេញ, ហើយប្រកាសភាពអាសន្នទៅ។ ហើយឈប់ខ្លាចនេះ ខ្លាចនោះមិនចេះចប់ទៀតទៅ។ ខ្ញុំសុខស្រួលគ្មានកើតអីទេ។ ពួកសត្រូវយើងនឹងងាប់មុខខ្ញុំទាំងអស់។ សាធារណរដ្ឋនឹងគ្មានពើបប្រទះគ្រោះថ្នាក់អ្វីឡើយ។ លោកសក្តិបី, ជូនដំណើរទៅ!*

**ឡុង បូរេត**

*(និយាយម្នាក់ឯង)*

*គ្មានគ្រោះថ្នាក់អ្វី! រដ្ឋាភិបាលមិនធ្លាប់រាស្ត្រស្អប់ខ្លាំងដូចពេលនេះទេ។ អ្វីៗគាំងទាំងអស់។ ផ្លូវទៅបាត់ដំបងដាច់។ ប្រេងសាំងក៏មកមិនដល់។ រស់នឹងជំនួយអាមេរិកាំងពេញទី។ ឱ, គុណបុណ្យព្រះរតនត្រៃ, ខ្ញុំបារម្ភអ្វីម្ល៉េះទេ?* *(លោកឡុង បូរេតចេញទៅដោយមានលោកអ៊ិន សូផាតទៅតាម)*

**លន់ នល់**

សាធារណរដ្ឋគ្មានពើបប្រទះនឹងគ្រោះថ្នាក់អ្វីឡើយ។ ឧមសិទ្ធិស្វាហៈ! មិនតែប៉ុណ្ណោះភ្នំពេញគ្មាននរណាអាចវាយយកបានទេ តាំងតែពីខ្ញុំឲ្យធ្វើខ្សែក្រវ៉ាត់ពីដីខ្សាច់សក្តិសិទ្ធនោះមក។

*(អនុសេនីយ៍ឯកអ៊ិន សូផាតចូលមកវិញ)*

**អ៊ិន សូផាត**

ឯកឧត្តម, លោកឯកអគ្គរដ្ឋទូត លោក ចន ហ្គន់ធ័រ ឌីន (John Gunther Dean) នៃសហរដ្ឋអាមេរិកអញ្ជើញមកហើយ។

**លន់ នល់**

អីយ៉ា!

**ឌីន**

ចាញ់គេហើយ, លោកសេនាប្រមុខ។ ខ្ញុំមកដោយមិនបានជម្រាបមុននេះ គឺបញ្ជាក់ថាកុំឲ្យមានចាញ់ទៀត, តទៅមុខ។

**លន់ នល់**

អញ្ជើញ, អញ្ជើញ, ឯកឧត្តម...

**ឌីន**

កងកម្លាំងលោកទើបនឹងចាញ់នៅកំពង់ហ្លួង ដែលជាការមិនគួរសោះ, តែសមតែដូច្នេះឯង, គួរឲ្យស្តាយណាស់។ ខ្ញុំថា "ចាញ់"។ មែនទែនខ្ញុំត្រូវថា "បាក់ធ្មុង"។
ខ្ញុំមកពីកន្លែងវាយគ្នាតែម្តង។ ខ្ញុំបានត្រួតពិនិត្យកងទ័ពលោកទាំងអស់នៅគ្រប់ខេត្ត។

**លន់ នល់**

យី, ឯកឧត្តមខំហួសពេកហើយ! តែយ៉ាងនេះច្បាស់ជាទៀយបាក់កម្លាំងជាមិនខាន។ ឯកអគ្គរដ្ឋទូតទាំងមូលមិនគួរទៅដល់សមរភូមិទេ។ យើងមិនធ្លាប់ឃើញមិនធ្លាប់ឮសោះ, មែនទេលោកសក្តិបី?

**ឌីន**

ចុះអគ្គមេបញ្ជាការកងទ័ព ដែលមិនធ្លាប់ចុះដល់សមរភូមិសោះវិញ, ធ្លាប់ឮធ្លាប់ឃើញទេ? ក្រុមលោកនឹងរលំគ្រេង, បើមិនចាត់វិធានការជាបន្ទាន់ដូចតទៅនេះ៖ លោកត្រូវធ្វើយ៉ាងម៉េចឲ្យយើងជឿថា ទាហានលោកមានពិតប្រាកដ, គឺមិនមែនជាទាហានខ្មោច។ លោកបានប្រាប់យើងថាមាន៩សែននាក់, តាមពិតមានមិនលើសពី២សែននាក់ទេ, ខ្លះមានឯកសណ្ឋានទៅ, ខ្លះទៀតអត់! ៣សែននាក់ទៀតគឺជាការនិយាយបង្កើតរបស់លោកសុទ្ធសាធ។ ខ្ញុំសូមហាមលោកមិនឲ្យបើកប្រាក់ខែឲ្យខ្មោចទៀតទេ។ ខ្ញុំសូមបញ្ជាឲ្យលោកបើកប្រាក់ខែឲ្យទាហានទ័ពលោកដែលរខេករខាក ដោយដៃលោក ផ្ទាល់, ហើយរៀងរាល់ខែ។ ខ្ញុំសូមបញ្ជាលោកឲ្យហាមពួកមេទាហានលោកមិនឲ្យយកប្រាក់ខែទ័ពដាក់ក្នុងហោប៉ៅផ្ទាល់ខ្លួន។

**លន់ នល់**

យ៉ាងម៉េច, នាយទាហានខ្ញុំ?

**ឌីន**

មិនទាន់និយាយអស់ទេ។ សម្រាប់រដូវនេះ យើងបានឲ្យឡានក្រោះ៣០០ គ្រឿងបន្ថែមទៀត, កាំភ្លើងត្បាល់ ៨០ម.ម. រាប់រយ, កាំភ្លើងត្រយ៉ូងចេកមួយពាន់...

**លន់ នល់**

ត្រូវហើយ, ខ្ញុំសូមជម្រាបថា លោកឧត្តមសេនីយ៍ ហេក (Haigh) ...

**ឌីន**

កាំភ្លើង M16 បួនម៉ឺនប្រាំពាន់ដើម។ ទាំងអស់នោះលោកបានយកទៅធ្វើអ្វី? ពេលយកទៅប្រើ, មិនបាញ់ឲ្យត្រឹមត្រូវទេ! គឺយកទៅរះបង្ហើរតាមខ្យល់ពីចម្ងាយ ដោយគិតថាគ្រាប់កាំភ្លើងដូចគ្រាប់ភ្លៀង, ទៅធ្វើឲ្យសត្រូវលិចលង់។ បើវាយប្រយុទ្ធពិតប្រាកដគឺគ្មានឡើយ។ នាយទាហានលោកថ្នមខ្លួនល្អណាស់, ដូច្នេះមួយអាទិត្យទៅច្បាំងតែម្ដងទេ, ឧទាហរណ៍ថាថ្ងៃអង្គារពីម៉ោង៧ ដល់ម៉ោង១១, បើអត់មានភ្លៀងឬថ្ងៃមិនក្ដៅពេកផង! នេះនិយាយឲ្យខ្សោយផង, ព្រោះស្ទើរតែអាចពោលថាអត់មានសង្គ្រាមទេ, បើនិយាយពីខាងពួកលោកវិញ។

នាយទាហានលោកអត់អាវុធ។ អត់អាវុធ? ចុះអាវុធដែលរដ្ឋសភាយើងផ្ញើមកនោះ, យកទៅណាអស់? កាំភ្លើងយើងផ្ញើមកគឺនៅលានប្រយុទ្ធមែន, តែនៅខាងម្ខាងទៀត។ នាយទាហានលោកលក់គ្រាប់ផ្លោងយើងទាំងកេស។ទៅអ្នកក្រៅ។ ទៅនរណា? ទៅសៀម? ទេ, បើបានតែប៉ុណ្ណោះ រាប់ថាគ្រាន់បើហើយ! ទេ! ទេ! គឺលក់ឲ្យខ្មែរក្រហម! កុំស្មានតែខ្ញុំមិនដឹង! ប៉ុណ្ណឹងហើយ! ឧត្តមសេនីយ៍សេក សំអៀត, ចៅហ្វាយខេត្តបាត់ដំបងនោះគ្មានគ្រាប់មួយគ្រាប់ទេ។ គាត់លក់សព្វាវុធដែលគាត់មានទាំងអស់ឲ្យខ្មែរក្រហម, ហើយគ្មានទាំងលាក់លៀមអ្វីទៀតផង ព្រោះគាត់អាចអួតប្រាប់គេថា គាត់ចេះរស់ធ្វើអ្នកមាន។ មើល, លោកសេនាប្រមុខ, មែនឬមិនមែន ដែលគាត់ទទួលការធានាអះអាងពីឧត្តមសេនីយ៍ ហ៊ូ យន់ថា អាវុធទាំងនោះ, អាវុធអាមេរិកាំងទាំងនោះ, គេមិនយកទៅវាយក្រុងបាត់ដំបងរបស់គាត់ទេ? គាត់ប្រាប់រឿងនេះដល់ខ្ញុំដោយត្រង់ៗ ហើយញញឹមញញែមទៀតផង! បើកុំតែឃើញកូនចៅគាត់ម្នាក់យំ, ខ្ញុំមិនដឹងជាហួសចិត្តដល់ណាដល់ណីទេ! បើសហរដ្ឋអាមេរិកដឹងថាខ្លួនកំពុងចិញ្ចឹមនរណានោះ, យ៉ាងម៉េច ទៅហ្ន!

លោកសេនាប្រមុខ, ខ្ញុំត្រូវប្រាប់ថាម៉េចទៅសហរដ្ឋអាមេរិក? ប្រាប់ខ្ញុំមកមើល!

**លន់ នល់**

ខ្ញុំពិបាកចិត្តណាស់, ឯកឧត្តម។ សេក សំអៀតជាមិត្តជិតដិតយូរមកហើយ។ គាត់ខូចណាស់៖ ឡើងជាវីរៈសេនីយ៍ឯកកាលពីអាយុ៣០ឆ្នាំ, ឡើងជាឧត្តមសេនីយ៍...

**ឌីន**

បកសក្តិគាត់ទៅ!

**លន់ នល់**

ខ្ញុំនឹងកោះហៅគាត់ឲ្យមក។ ប្រហែលមានការយល់ច្រឡំអ្វីមួយហើយ។ មាននរណាចង់ធ្វើបាបគាត់។

**ឌីន**

ពកសក្តិទៅ! គាត់នោះជាឃាតករ!

**លន់ នល់**

ខ្ញុំព្រួហើយ! ខ្ញុំព្រួហើយ! ខ្ញុំព្រួ, ព្រោះលោកនិយាយស្រែកខ្លាំង!

**ឌីន**

ធ្វើរបៀបនេះ គឺសម្លាប់តែខ្លួនឯង! នេះជាការឡប់សតិវិលខួរ! ជួយសាធារណរដ្ឋរបស់លោកបន្តិចទៅមើល! ខ្ញុំ, ដែលស្រឡាញ់ប្រទេសលោក, ខ្ញុំ, ដែលចង់ឃើញពួកកុម្មុយនិស្ដ៍ជកថយ, ហើយមកឃើញអំពើទាបថោក ដូច្នេះ, ខ្ញុំយំដោយអាណិតប្រទេសលោក, ខ្ញុំយំដោយអាណិតប្រទេសខ្ញុំ។ យើងខ្ញុំជាអ្នកបំពាក់អាវុធឲ្យខ្មែរក្រហម! យើងខ្ញុំជាអ្នកគាំទ្រអំពើទាបថោក និងគាំទ្រអំពើពុករលួយ!

**លន់ នល់**

ខ្ញុំក៏អញ្ចឹងដែរ, ជួនកាលខ្ញុំយំ, ពេលណាដែលខ្ញុំហៅហត់ពេក, ជាពិសេសពេលយប់។ ប៉ុន្តែជឿខ្ញុំចុះ, ឯកឧត្តម, នេះមកពីមានសង្គ្រាម។ មនុស្សលោកតែងតែខ្សោយដូច្នេះឯង, អាមេរិកាំងក៏ដូចតែគ្នា។

**ឌីន**

ងើបឈរឲ្យត្រង់វិញមក, កុំទោរទន់! កាន់អាវុធឡើង, ទាន់យើងនៅជួយនៅឡើយ។ ប្រញ៉ាប់ឡើង! ប្រយុទ្ធឲ្យស្វាហាប់ទៅ! មិនយូរមិនចាប់ទេនឹងលែងសម្បូណ៌អាវុធទៀតហើយ! បន្តិចទៀតទៅយើងឈប់នៅទីនេះដើម្បីឲ្យអស់លោកក្រោកមិនឈប់មិនឈរដូច្នេះទៀតហើយ។

ហើយខ្ញុំសូមជូនដំបូន្មានមួយ! លោកគួរតែបង្កើតរដ្ឋាភិបាលមួយដែលសមស្របជាងនេះ, គឺថាយកនរណាដែលបានធ្វើ "បដិវត្តន៍" ជាមួយលោកនោះឲ្យមកធ្វើការផង, ងាកទៅរកទ្រង់សិរិមតៈជាដើម...

**លន់ នល់**

ងាកទៅរកសិរិមតៈ? មែនហើយ, អញ្ចឹងមែន, យីដំបូន្មាននេះល្អមែន! អម្បាញ់មិញនេះឯងដែលខ្ញុំគិតទៅដល់គាត់។ គិតទៅគាត់មែនទែន, មែនទេលោកសក្ដិបី? អញ្ចឹងមែនហើយ, ខ្ញុំនឹងចាត់ការតាមនោះភ្លាម។ ចាំជួបគ្នាទៀត, ឯកឧត្តម។ សូមអរគុណខ្លាំងណាស់, អរគុណណាស់!

*(លោកឌីនចេញទៅ)*

ខ្ញុំមិនមែនយកអំណាចមកកាន់ដើម្បីគ្រវែងចោលតាមបង្អួចវិញទេ។ នេះជាស្រុកខ្មែរ, ស្រុកដែលមានអារ្យធម៌ចាស់ជាងស្រុកលោកឯងឆ្ងាយណាស់! កុំភ្លេចឲ្យសោះ! ឲ្យតែអាវុធមក, តែមិនបាច់ឲ្យដំបូន្មានទេ!

*(ទាំងអស់គ្នាចេញទៅ)*

# ឆាកទី៥

*(តំបន់អង្គរ។ ព្រះសីហនុនិងអ្នកម្នាងយាងមក)*

**អ្នកម្នាង**

ម្ដេចក៏ព្រះអង្គក្រៀមក្រំយ៉ាងនេះ, ក្រាបទូល?

**ព្រះសីហនុ**

បងកោតស្ញែង។ បងក្រៀមក្រំដោយសារកោតស្ញែង។ យុវជន, នេះហើយគន្លឹះសម្ងាត់។ យុវជនជំនាន់មុនប្រវត្តិសាស្ត្រទៅទៀត។ យុវជនជំនាន់មនុស្សនៅរូងភ្នំ។ កងទ័ពគេនោះអាចយកមកលើកតម្កើងថា ក្មេងស្រស់ជាងគេ, មានវិន័យជាងគេ, មិនចេះអក្សរមួយតួណាឡើយ, ខ្វាក់ងងឹតជាងទ័ពនៅអាស៊ីណាៗទាំងអស់។ ជាងទ័ពណាៗនៅពិភពលោកទាំងមូលនេះផង។ នាងឃើញទេ ? មាត់នោះបិទជិត, ភ្នែកក៏គ្មានក្រឡេកទៅណា, ជង្ហើមស្ទើរតែមិនដក ពេលដែលយើងដើរត្រួតពលនោះ។ ខ្មោចស្រស់តែម្ដង! ខ្មោច១ម៉ឺន៥ពាន់នាក់តម្រៀបជួរនៅព្រៃតំបន់អង្គរជាទីប្រសិទ្ធ។

**អ្នកម្នាង**

ឯលោកប៉ុល ពតនោះវិញ! ញញឹមចេញធ្មេញស្វាញ! សុន្ទរកថានោះក៏សម្បើមដែរ! ពាក្យស៊ីសាច់ដាច់ឈាមដែលនិយាយរាប់ម៉ោង, សមថាជាបិសាចដែលរេរាំនៅមុខជួរកុមារ-យោធាដែលបាក់ចិត្តនោះ! ខ្ញុំម្ចាស់ធ្លាក់ថ្លើមក្ដុក!

**ព្រះសីហនុ**

ហើយអស្ចារ្យត្រង់ថា ប៉ុល ពតនោះជាសាឡុត សរសោះ, គ្រូបង្រៀនប្រវត្តិសាស្ត្រ-ភូមិសាស្ត្រ! បើនិយាយទៅ, ក្រៅពីបង, ទាំងនោះជាសាស្ត្រាចារ្យទាំងអស់។ នាងឃើញទេ? សាស្ត្រាចារ្យទាំងអស់៖ លោកខៀវ សំផន, លោកសុន សេន, លោកអៀង សារីនិងអ្នកស្រីប្រពន្ធគាត់, គឺអ្នកស្រីអៀង ធិរិទ្ធ ដែលខ្ញុំសូមបន់ស្រន់កុំឱ្យជួបមុខនៅពេលយប់ងងឹតណាមួយឲ្យសោះ។ លោកហ៊ូ យន់, លោកសាឡុត ពត...

**អ្នកម្នាង**

*លោកសាឡុតពត! ពេលព្រះអង្គហៅគាត់យ៉ាងនោះ, គាត់ធ្វើមុខល្អមើលណាស់!...*

**ព្រះសីហនុ**

*យី, ដូចជាក្រឡាប់ចាក់អស់ហើយ! ប៉ុលពតជាអ្នកនិយាយ, ឯសីហនុវិញគេបិទមាត់ជិត។ គាត់យកអ្វីៗពីបងអស់ហើយ! ផ្លូវទាញព្រ័តចូលទៅអង្គរធំ, លានដល់ដំរី, អង្គរវត្តជាទីស្នប់ស្ងែង, បន្ទាយស្រីយ៉ាងប្រឡឹង, ព្រៃព្រឹក្សាតាំងពីដូនតាមក, ក្របីត្រាំភក់បញ្ចេញតែរន្ធច្រមុះ, ក្មេងជិះក្របី, ភ្លៀង, ថ្ម, ខ្យល់, ដីដ៏ត្រជាក់ត្រជុំ, ត្នោត! អស់, យកអស់! ក្នុងមួយខែពេញ ខ្ញុំគ្មានឃើញអ្វីក្រៅពីទាហានខ្មែរក្រហម, កម្មាភិបាលខ្មែរក្រហម, រដ្ឋមន្ត្រីខ្មែរក្រហម, ឯអ្នកស្រែវិញតែម្នាក់ក៏គ្មានឃើញដែរ។នៅជិតកៀកនឹងរាស្ត្រ, តែមិនឃើញរាស្ត្រ, មិនបានឱបរិតនរណា, មិនបានឲ្យពរនរណាទាំងអស់។ គឺនិរទេសក្នុងស្រុករបស់ឯង! បងគិតខុសទេក៏មិនដឹង! បងនៅទីនេះធ្វើអ្វី? គួរតែទៅឲ្យបាត់មុខកុំឲ្យគេឃើញវិញទេដឹង?*
*រដ្ឋមន្ត្រីខ្មែរក្រហមរបស់បងចង់ឲ្យបងថា ជូនពរសព្វសាធុការលើអ្វីៗទាំងអស់ដែលគេធ្វើ។ ហើយបងក៏ស៊ីញ៉េដាក់ឈ្មោះខ្លួនឯងលើរឿងភាគដែលក្រុមគេសរសេរនោះ។ គេចង់យកមាសច្និនច្នៅនៅលើម្កុដបងទៅលាបមុខឲ្យល្អឈ្មោះ។ ឯបងវិញ កំទេចបុកកិនម្កុដនោះឲ្យដូចផង់ជាម្សៅមាសឲ្យគេលាប។ លែងយល់ខ្លួនឯងហើយ, យូរៗទៅ។ នាងយល់បងដែរឬទេ?*

**អ្នកម្នាង**

ខ្ញុំម្ចាស់យល់ព្រះអង្គ, ក្រាបទូល។ កាលណាខ្មែរក្រហមកំចាត់ពួកលន់ នល់រួចរាល់ហើយ, ព្រះអង្គនឹងដឹកនាំប្រទេសជាថ្មីទៀត។ ព្រះអង្គនឹងធ្វើឲ្យប្រទេសដើបឡើងវិញបន្តិចម្តងៗ, ព្យាបាលដំបៅឈឺចាប់នោះសះស្បើយបន្តិចម្តងៗ រហូតដល់ជាស្រឡះ។

**ព្រះសីហនុ**

នាងយល់អញ្ចឹងមែន? យល់អញ្ចឹងមែន? បើអញ្ចឹងយើងចាកចេញពីពិភពនេះ ដែលសីហនុគ្រាន់តែជាស្រមោល ហើយត្រឡប់ទៅប៉េកាំងវិញ។ ទៅឲ្យឆ្ងាយពីនេះ, ឆ្ងាយពីនេះ, ក្រែងលោបងអាចអះអាងប្រាប់ខ្លួនឯងថាសីហនុនឹងនាំសុខដុមរមនាឲ្យប្រទេសខ្លួនវិញថ្ងៃណាមួយ។

*(គេពុសម្លេងយន្តហោះ)*

### អ្នកម្នាង

សម្លេងនេះគឺ T28

*(ទាំងពីរអង្គយាងចេញទៅ។ លោកសាឡុត សរដែលហៅថាប៉ុលពតអំណើះតទៅ, លោកអៀង សារី, អ្នកស្រីអៀង ធីរិទ្ធ, លោកខៀវ សំផន និងលោកហ៊ូ យន់ចូលមក)*

### អ្នកស្រីអៀង ធីរិទ្ធ

សម្តេចនៅមានឥទ្ធិពលខ្លាំងពេក។ គ្រាន់តែឃើញព្រះអង្គភ្លាម អ្នកស្រែចោលនង្គ័ល, ចោលចបអ្វីទាំងអស់ ហើយរត់មកតាមឡាន Jeep ពីក្រោយ ភ្លេចការងារអស់។ ច្រើនគ្នាណាស់ ដែលជឿជំនឿអកុសលដោយចារ យកដីដែលជាប់ស្នាមកង់ឡានទុក ហើយរត់កៀសបុកទាហានដែលមិនឃើញដើរចេញពីគន្លងឡាននោះ។

### អៀង សារី

ព្រះអង្គមិនទាន់យាងដល់ប៉ែកាំងទេ, នៅលើផ្លូវលំហូជីមិញនៅឡើយ ដែលគ្រោះថ្នាក់តែងកើតឡើងរាល់ថ្ងៃ!

### ប៉ុលពត

ក្នុងដំណាក់កាលនេះព្រះអង្គនឹងយាងទៅដោយសុខសាន្ត។ ព្រះអង្គមិនសំខាន់ទេ ព្រោះមិនមែនជាបុព្វហេតុ ការតស៊ូយើង, គឺគ្រាន់ជាតែជាឱកាសមួយប៉ុណ្ណោះ។ ដែលសំខាន់នោះ គឺកសិករដែលយើងត្រូវអប់រំបំភ្លឺឲ្យ ស្វាងជាស្ថាពរ។

ម៉េចទៅមិត្តហ៊ូ យន់, ការងារសហករណ៍ដល់ណាហើយ? ដើរជាជំហានលោតផ្លោះឬទេ?

### ហ៊ូ យន់

កសិករមិនសកម្មប៉ុន្មានទេ, រវល់តែបន់ព្រះមិនឈប់មាត់ និងខ្មោចដេញតាមមិនល្ហែ។ គេងាយពត់ណាស់, យប់ឡើងពេលប្រជុំអប់រំនយោបាយ គេស្តាប់យើងនិយាយយ៉ាងយូរ។ បន្ទាប់មកគេអុជថ្នាំជក់, ហើយមានម្នាក់ ងើបក្បាលឡើងនិយាយថា៖ “ឱ! នោះសម្តេចឪ! នោះព្រះសីហនុ, ខ្ញុំមើលឃើញហើយ, នោះ! ព្រះអង្គគង់នៅ ក្នុងវង្វង់លោកខែ, ខាងស្តាំ!”, ហើយការរៀនសូត្រអ្វីៗក៏នៅទ្រឹងមួយយប់នោះ។ ប្រញ៉ាប់ប្រញ៉ាល់មិនកើតទេ, ជាមួយប្រជាជន ទាល់តែទុកពេលឲ្យគាត់។

**អៀង សារី**

បើនិយាយឲ្យត្រូវគឺថា ហ៊ូ យន់ទុកឲ្យពួកក្រុមយើងដក់ថ្នាំយ៉ាងព្រងើយក្នុងពេលប្រជុំនយោបាយ, ព្រោះហ៊ូ យន់ចង់ឲ្យប្រជាជនស្រឡាញ់ខ្លួនជាងស្រឡាញ់បដិវត្ត។

**ប៉ុលពត**

យើងមិនត្រូវបែកបាក់គ្នាទេ។ មិត្តហ៊ូ យន់, យើងទុកពេលរង់ចាំមកប៉ុណ្ណោះក៏គ្រប់គ្រាន់ហើយ។ យើងបានដាក់ចិត្តគោរពរបៀបរបបចាស់ប៉ុណ្ណោះក៏ល្មមដែរ។ឥឡូវពេលមកដល់ហើយ, ដែលយើងត្រូវដកស្មៅទាំងឫស។ អ្វីក៏ដោយដែលរាំងខ្យល់បដិវត្តន៍ដ៏ត្រចះត្រចង់របស់យើង, យើងត្រូវទាញកន្ត្រាក់យកចេញ។ សង្គមចាស់គម្រិលដែលជាពស់មានពិសនោះ នៅសល់ចង្កូមបីទៀត។ យុវជននិងកុមារទាំងអស់នឹងជួយយើងបំបាក់ធ្មុងវា។ ត្រូវដកចេញឲ្យអស់នូវពុទ្ធសាសនា, រាជានិយមនិងកម្មសិទ្ធិនិយម។

**អៀង សារី**

ជម្រុំកលោកសង្ឃឈប់ឲ្យស្លៀកស្បង់ទៀតទៅ, ហើយឲ្យទៅភ្ជួរស្រែ, ឲ្យហូរញើសដូចគេដូចឯង! គេនឹងឃើញថាអ្នកទាំងនោះរោយ, ស្ទើរបាក់ចង្កេះ ហើយចេះងាប់ដូចគេគ្រប់គ្នាដែរ។ ចប់ហើយស្បង់លឿង។ មានតែពណ៌ខ្មៅទេដែលបង្រួមគ្នានិងបំពត់ចិត្តប្រជាជនឲ្យក្លាហ៊ានអង់អាច, គឺពណ៌កសិករ!

**ប៉ុលពត**

ខ្ញុំគ្មានទាស់អ្វីទាំងអស់នឹងសំណើអៀង សារី។

**ខៀវ សំផន**

តាំងពីយូរមកហើយ ដែលខ្ញុំបានសូមឲ្យគេដូរលំនៅសហគមន៍ដែលរស់ចាក់ឫសក្នុងដីដូចសត្វល្អិតចង្រៃនោះ។ ឥឡូវខ្ញុំសូមម្តងទៀត ឲ្យរំលាយទីប្រជុំជនឲ្យអស់ ហើយយកមនុស្សទៅនៅតាមទីថ្មីដែលមានបង់លេខចំណាំ, តាមលំនៅដ្ឋានរួម, ឲ្យមនុស្ស១០០នាក់ជ្រកក្រោមដំបូលមួយ, ធ្វើដូច្នេះទើបល្អ។

**អ្នកស្រីអៀង ធីរិទ្ធ**

ម៉េចមិនឲ្យបានច្រើនជាង១០០?

### ខៀវ សំផន

មែន, ម៉េចមិនលើសពីនោះ? មែនហើយ, ២០០, ៣០០!

### ហ៊ូ យន់

ត្រូវបំបែកក្មេងឲ្យចេញពីចាស់, បើពុំនោះទេវានឹងល្ងង់សំគិះ ព្រោះចាស់ៗបង្វឹកក្បាលវា។ ខ្ញុំសូមឲ្យបំបែកជាពីរក្រុមតាមអាយុ។

### ប៉ុលពត

និយាយពីសម្តេចម្តងទៀត។ លោកគ្មានអ្វីឲ្យយើងខ្វល់ទេ, ដូចខ្ញុំបាននិយាយហើយ។ ប៉ុន្តែនៅមានបញ្ហាពួកនិយមសីហនុ ដែលធ្វើឲ្យខូចដួរយើង ហើយធ្វើឲ្យកម្មាភិបាលយើងមិនសូវដើបមុខបានខ្ពស់។ មិត្តអៀង សារីអាចដោះស្រាយបំពេញបេសកកម្មលំបាកនេះបានសម្រេច។

### អៀង សារី

ចំពោះការកំចាត់ពួកនិយមសីហនុ, ដោយសារនេះជារឿងពិបាក, ខ្ញុំសូមជំនួយការពីតាម៉ុកនិងទ័ពស្រួចគាត់ហើយនិងសិទ្ធិអ្វីៗគ្រប់បែបយ៉ាងជាមុន។

### ប៉ុលពត

អង្គការឲ្យសិទ្ធិពេញទីទៅមិត្ត។ ឃើញទេ, ឃើញខ្ញុំគិតត្រូវទេ ដែលអនុញ្ញាតឲ្យសម្តេចយាងចូលមកមួយភ្លែតនោះ? ដោយសារដូច្នេះហើយ បានជាយើងអាចធ្វើសេចក្តីសម្រេចចិត្តចាំបាច់ទាំងនេះយ៉ាងចាប់រហ័ស។ មើល, លោកមេបញ្ជាការដាន់ខ្ពស់, ជ័យជំនះបន្ទាប់ទៅទៀតកើតឡើងអង្កាល់?

### ខៀវ សំផន

ខ្ញុំកញ្ជ្រោលពុះពោរចង់ឲ្យដល់ភ្នំពេញតែម្តងក្នុងមួយខែកន្លះទៀត។

### ប៉ុលពត

ខ្ញុំជឿជាក់ថា តែមួយខែទៀតទេ យើងទៅដល់ហើយ, បើយើងប្រឹងប្រែង២ដងលើសនេះទៀត។

**ខៀវ សំផន**

មិត្តប៉ុលពត, បើឲ្យតែជាការដែលមនុស្សអាចធ្វើបាន, គឺកងទ័ពយើងនឹងទៅដល់ពេលនោះ។

**ប៉ុលពត**

អនាគតនៅក្នុងកណ្ដាប់ដៃយើង! ស្អែកនេះហើយ, ជ័យជំនះ, ណាអស់មិត្ត!

*(លោកប៉ុលពត, លោកអៀង សារី និងអ្នកស្រីអៀង ធិរិទ្ធចេញទៅ)*

**ហ៊ូ យន់**

យើងធ្វើឲ្យលោកនេះក្រឡាប់ចាក់យ៉ាងខ្លាំងក្លា រហូតដល់ខ្ញុំគិតថាយើងនឹងទៅកាត់ឫសធាតុមនុស្សជាតិ តែមួយកាំបិតប៉ុណ្ណោះក៏ដាច់ភឹង!

ម៉េចក៏មិត្តគ្មានប្រពន្ធ?

**ខៀវ សំផន**

ខ្ញុំបានស្បថថានឹងមិនយកប្រពន្ធទេ ដរាបណាមិនទាន់ឈ្នះជាទីបញ្ចប់។

**ហ៊ូ យន់**

ខ្ញុំវិញ, គឺកូនទេ ដែលខ្ញុំមិនចង់បាន។

**ខៀវ សំផន**

និយាយរឿងនេះបានការអី? ទៅយើង!

*(ទាំងអស់គ្នាចេញទៅ)*

# ឈុតទី៣

## ឆាកទី១

*(ភ្នំពេញ។ លោកឌីននិងព្រឹទ្ធសមាជិកម៉ាក់ក្លូស្គី)*

**ឌីន**

ខ្មែរក្រហមមុខតែឈ្នះសង្គ្រាមជាមិនខាន។ ឯយើងវិញ គ្រាន់តែអាចពន្យាពេលឈ្នះនោះឲ្យបានយូរបន្តិចតែប៉ុណ្ណោះ! យើងត្រូវតែជួយមិត្តយើងឲ្យបានឆ្លងកាត់រដូវក្តៅ។
ដូច្នេះក្នុងពេលស្ងប់ដោយសារគុណបុណ្យភ្លៀងជួយនោះ, គេនឹងព្យាយាមធ្វើយ៉ាងម៉េចឲ្យបានចរចារគ្នា។

**ម៉ាក់ក្លូស្គី**

ប៉ុន្តែមានបញ្ហារឿងលន់នល់នោះទៀត។ លោកដឹងទេ, មានល្អប៉ុន្មាន, ដែលយើងនៅតែគាំទ្រមនុស្សដែលគេលែងឲ្យតម្លៃទៅហើយ, គឺថានៅតែគាំទ្រសេនាប្រមុខដែលកំពុងរលាយដូចក្រមួននេះ។ លោកដឹងទេថាគាត់នោះឡប់ខ្លួនមែនទែនហើយ?

**ឌីន**

ទេ, មិនមែនគិតរឿងលន់នល់ទៀតទេ។ បញ្ហាឥឡូវនេះគឺខ្មែរក្រហមនិងបញ្ហាកម្ពុជា។ កម្ពុជាមិនមែនជាលន់នល់ឡើយ។

**ម៉ាក់ក្លូស្គី**

មើលពីចម្ងាយតាំងពីវ៉ាស៊ីនតោនមកគឺអញ្ចឹងមែនហើយ។ លោកជួយធ្វើម៉េចទាញគាត់ឲ្យឃ្លាតថយពីកណ្តាលឆាកបន្តិចបានទេ, ដើម្បីស្រួលខ្ញុំបង្ហាញសំណុំរឿងឲ្យគេយល់?

**ឌីន**

ខ្ញុំនឹងចាត់ការថ្ងៃនេះតែម្តងណា, លោកព្រឹទ្ធសមាជិកម៉ាក់ក្លូស្គី។ គីលី! *(លេខាធិការចូលមក)*។ ទៅសូមឲ្យលោកឡុងបូរេតមកជួបខ្ញុំនៅស្ថានទូតឥឡូវនេះមក។ ឯលោកសុខាំខូយក៏ហៅឲ្យមកដូចគ្នា។ គាត់នោះល្ងិល្ងើមែន, តែធ្វើម៉េច, ឥឡូវនេះជាប្រមុខរដ្ឋ។

**គីលី**

បាទ, ខ្ញុំនឹងទៅភ្លាម។

*(គាត់ចេញទៅ)*

**ម៉ាក់ក្លូស្គី**

អញ្ចឹងចុះ។ ប៉ុន្តែក្រោយពីខែឧសភាទៅ, ពេលភ្លៀងចាប់ផ្តើមធ្លាក់ពេលណា, យើងបញ្ចប់ត្រឹមនោះ, ហ្នឹះ? សហរដ្ឋអាមេរិកលែងមានទាហានសូម្បីតែម្នាក់ទៀតឡើយ, តែមួយដុល្លារក៏គ្មានសម្រាប់កម្ពុជាទៀតទេ, ចាប់ពីពេលនោះទៅ។

**ឌីន**

យ៉ាងណាក៏ខ្មែរក្រហមគ្មានមកសួរយោបល់អ្វីពីយើងសិនដែរ, ជឿខ្ញុំចុះ។

**ម៉ាក់ក្លូស្គី**

ពួកខ្មែរក្រហមដ៏សម្បើមនោះ, វានឹងធ្វើអ្វីកាលណាវាឈ្នះហើយ?

**ឌីន**

៦ខែមុន, ក្រោយពីវាយយកភូមិសសរស្តម្ភនៅខេត្តសៀមរាបបានហើយ, ពួកខ្មែរក្រហមដុតភូមិកំទេចចោលទាំងស្រុង ក្រោយពីបានសម្លាប់ប្រជាជនចំនួន៣០០នាក់របៀបតទៅនេះ៖ មនុស្សប្រុសគឺវាក្រៀវនិងវះពោះ។ ស្រីក្មេងវាកប់ទាំងរស់។ ស្រីចាស់ វាបោះដែកគោលឲ្យនៅជាប់ជញ្ជាំងផ្ទះ។ ក្មេងៗវិញ វាទាញហែកដៃជើងឲ្យរយះរយាយពីខ្លួនអស់, ឯសត្វគឺវាកាត់ជើងទាំងបួន។

**ម៉ាក់ក្លូស្គី**

លោកដឹងពីណាមករឿងសាហាវបែបនេះ? ខ្មែរណាម្នាក់ប្រាប់, មែនទេ?

**ឌីន**

លោកសង្ឃបារាំងម្នាក់ប្រាប់ខ្ញុំ។ លោករស់នៅភូមិមួយក្បែរនោះ, ហើយបានពត៌មាននេះពីមនុស្សដែលរួចរស់ជីវិតតែម្នាក់គត់ ពីការសម្លាប់នោះ។

**ម៉ាក់ក្លូស្គី**

*បើអញ្ចឹងដូចតែខ្មែរដែរ។*

*ទេ ចន(John) , អ្នកដែលរត់រួចតែងតែនិយាយអំពីអំពើសាហាវរបៀបនេះឯង, រកតែជឿប៉ុនសសៃសក់ក៏មិនបានផង។ នរណាក៏ដឹងដែរបញ្ហានេះ, ជឿយ៉ាងម៉េចកើត?*

**ឌីន**

*ព្រឹទ្ធសភាម៉ាក់ក្លូស្គី, ខ្ញុំចង់តែតប់លោកមួយដៃឲ្យអស់ធ្មេញ។ មិនដែលព្រមជឿអ្វីទេ! ចង្រៃណាស់, មនុស្សរបៀបលោក, របៀបពួកអ្នកកាសែតនានា, រឿងអ្វីមួយដែលខ្លួនជឿ គឺទាល់តែខ្លួនពេញចិត្ត! ព្រះសង្ឃបារាំងនោះអាយុ៦០ឆ្នាំ, មានជ្រាជ្ញាស្មារតីមាំមួន, រស់នៅស្រុកខ្មែរ៣០ឆ្នាំហើយ។ លោកនោះមិនមែនខ្មែរ, មិនមែនកាន់ជើងលន់នល់, មិនមែនឡឹកឹអីទាំងអស់, ហើយលោកខំប្រមូលខ្មោចរខេករខាកពាសវាលពាសកាលទាំងនោះទៅដុតបញ្ចាប់ដោយព្រះអង្គឯង, ព្រោះច្រើនពេកកប់មិនកើត។*

**ម៉ាក់ក្លូស្គី**

*ក្នុងសង្គ្រាមបែបនេះ គឺតែងតែមានការជ្រុលជ្រួសគួរឲ្យស្តាយដូច្នេះឯង, សូម្បីតែពួកយើង...*

**ឌីន**

*ជ្រុលជ្រួស! ទេ, មិនមែនជ្រុលជ្រួសទេ! ហើយកុំនិយាយថា"គួរឲ្យស្តាយ" ដូច្នេះ! គ្មានពាក្យអ្វីយកមកលប់កំហុស, យកមកសុំទោសបានទេ។ គ្មានជ្រុលជ្រួសអ្វីទាំងអស់! មានតែរឿងពិត, មានតែអ្នកស្រុកដែលវេទនា! បដិវត្តខ្មែរក្រហមនោះនឹងសាហាវយង់ឃ្នង, ធ្វើដោយលួង់, តែមិនមែនជ្រុលជ្រួសទេ!*

**ម៉ាក់ក្លូស្គី**

*នែចន(John) , ម៉េចក៏ចេះចោទម្លេះ? មើល, ប្រាប់ខ្ញុំមកមើល, ម៉េចក៏គ្មានកាសែតណាមួយនិយាយរឿងនោះសោះ?*

**ឌីន**

*មានខ្លះដែរ, ខ្ញុំស្គាល់, គ្នាខំស្រែកប្រាប់ការពិត, តែគ្មាននរណាស្តាប់, គ្មាននរណាព្យុសោះ!*

ប្រហែលមកពីយើងមិនបានឈឺចាប់ហើយ បានជាយើងមិនទទួលស្គាល់ថាមានគេឈឺចាប់, មើលទៅ។ ទាល់តែមានឡដុតហ្គាសបំពុលឲ្យច្រើនទៀត ទើបយើងទទួលស្គាល់ថាឧក្រិដ្ឋកម្មនៅតែចង់វាតទីលើពិភពលោកហើយមែនទេ?

**ម៉ាក់ក្លូស្គី**

លោកជាពូជ Juif, មែនទេ, ចន?

**ឌីន**

ទេ, អត់សោះ! ខ្ញុំគ្មាន Juif អីទេ! ខ្ញុំជាខ្មែរ។ ឯលោកវិញជាព្រឹទ្ធសមាជិក។ នែ, កុំនិយាយច្រើន, ខំបន្តិចឡើង, ជួយស្រុកខ្មែររបស់ខ្ញុំផង, ខ្ញុំសុំតែប៉ុណ្ណោះឯង, គ្មានសុំអ្វីទៀតទេ។

*(លោកគីលីចូលមកដោយមានលោកឡុងបូរេតនិងលោកសូខាំខូយផង)*

**ឌីន**

អញ្ជើញ, សូមអញ្ជើញអស់លោកជាមិត្ត! បាទ, ខ្ញុំទើបនឹងពិគ្រោះគ្នាជាមួយព្រឹទ្ធសមាជិកម៉ាក់ក្លូស្គី ដែលនឹងទៅបញ្ចុះបញ្ចូលរដ្ឋសភាអាមេរិកឲ្យបន្ទូរបន្ថយការសម្រេចចិត្ត។ តែក្នុងល័ក្ខខណ្ឌដែលអស់លោកធ្វើយ៉ាងណាយកលោកសេនាប្រមុខចេញដោយមិនឲ្យក្ដុងក្ដាំង។

**សូខាំខូយ**

យកចេញដោយមិនក្ដុងក្ដាំង?

**ឌីន**

គាត់ត្រូវតែចេញពីស្រុកឲ្យផុត២៤ម៉ោងនេះ។

**ម៉ាក់ក្លូស្គី**

ជម្រាបគាត់ត្រង់ៗតែម្ដងទៅ! ត្រូវតែដកខ្លួនចេញ, បើពុំដូច្នោះទេ រដ្ឋសភាយើងនឹងផ្ដាច់ស្បៀងហើយ។

**សូខាំខួយ**

គាត់នឹងមិនស្តាប់យើងទេ។

**ឌីន**

កុំនិយាយពីរឿងប្រទេស។ និយាយពីដុល្លារទៅវិញទៅ។Money!!! ទិញគាត់ឲ្យចេញតែម្តង។ កម្រិតតម្លៃទៅ! យ៉ាងណាអស់លោកចំណេញដែរ។

**ឡុង បូរេត**

បាទ, ខ្ញុំទៅចាត់ការរឿងនេះ។ ខ្ញុំត្រូវកាត់ថ្លៃប៉ុន្មាន, លោកសូខាំខួយ? ៣០ម៉ឺនដុល្លារ?

**សូខាំខួយ**

សមរម្យហើយ៣០ម៉ឺន។

**ឌីន**

មិនចាំបាច់ថាំត្បិតត្បៀតពេកទេ, នេះជាការប្រញ៉ាប់។ លោកអាចហៅពីការិយាល័យខ្ញុំទៅក៏បាន, លោកនាយករដ្ឋមន្ត្រី។

**ឡុង បូរេត**

បាទ! អរគុណ។

*(លោកឡុង បូរេតចេញទៅ)*

**សូខាំខួយ**

ឱ! គុណព្រះរតនត្រ័យ, សូមជួយយើងខ្ញុំឲ្យបានសម្រេចផងណា, ព្រះគុណម្ចាស់។ យើងខ្ញុំរួមស្រុះស្រួលគ្នាថែរក្សាស្រុក, លើកលែងតែលន់ នល់ប៉ុណ្ណោះ។

**ម៉ាក់ក្លស្គី**

ចុះលោកវិញ, លោកសូខាំខួយ, លោកយល់ថានឹងទៅជាយ៉ាងណាដែរ បើសិនជាខ្មែរក្រហមឈ្នះ?

*(លោកឡុង បូរេតចូលមកវិញ)*

**ឡុង បូរេត**

សូមទោស។ ខ្ញុំតម្លើងទៅដល់៥០ម៉ឺនបានទេ?

**សូខាំខួយ**

បាន!

*(លោកឡុង បូរេតចេញទៅម្តងទៀត)*

បាទ, លោកព្រឹទ្ធសមាជិក, កាលណាខ្មែរក្រហមឈ្នះហើយ គេនឹងធ្វើដូចដំរីចុះប្រេងដែលបានធូរស្បើយដោយបានញី, គឺថានឹងស្ងប់ស្ងៀមទៅវិញ។ លោកជ្រាបទេ, នេះហើយខ្មែរ។ យើងនិយាយមិនត្រូវគ្នា, យើងឈ្លោះគ្នា, ហើយក្រោយមកយើងជាគ្នាវិញ។ ម្យ៉ាងទៀតលោកខៀវ សំផនដែលជាអនុប្រធានរាជរដ្ឋាភិបាលក៏បានប្រកាសដែរថាខ្មែរម្នាក់នឹងមានតួនាទីរៀងៗខ្លួនក្នុងសង្គម, ទោះបីជាអតីតកាលដូចម្តេចក៏ដោយ។ មានន័យថាកាលណាខ្មែរក្រហមឈ្នះហើយនឹងមាននយោបាយបង្រួបបង្រួមជាតិ។

**ម៉ាក់ក្លស្គី**

លោកមានដែលឮគេនិយាយពីការសម្លាប់រង្គាលទៅ... ទៅ...

**ឌីន**

នៅសសរស្តម្ភ។

**សូខាំខួយ**

ថីមិនឮ? ប៉ុន្តែលោកដឹងទេ, ខ្មែរតែងតែដូច្នេះឯង។ តែចាក់ គឺលោតកញ្ចែងក្លាម, ប៉ុន្តែហើយទៅក៏ស្ងប់ទៅវិញ។

**ម៉ាក់ក្លូស្គី**

ចុះលោកជឿងសម្តីរបស់លោកខៀវ សំផនដែរទេ?

**សូខាំខូយ**

ជឿ, ជឿពេញទី។ គាត់ធ្លាប់ជាសហសេវិកខ្ញុំ, ខ្ញុំស្គាល់គាត់ច្បាស់។ យើងពីមុននៅក្នុងក្រុមមិត្តភក្តិជាមួយគ្នា។

*(លោកឡុង បូរេតចូលមកវិញ)*

**ឡុង បូរេត**

សូមទោស, ខ្ញុំសូមតម្លើងដល់ទៅ ៧០ម៉ឺនចុះ។ ហើយយើងនឹងឲ្យគោរពម្យងារគាត់ថាជាវីរបុរសជាតិដែលបានចូលរួមស្រោចស្រង់ជាតិយ៉ាងត្រចះត្រចង់។ បានទេ, ធ្វើដូច្នេះ?

**សូខាំខូយ**

បាន, បាន! ត្រូវហើយ, គំនិតនេះល្អ។ វីរបុរសជាតិ! ល្អណាស់!

*(លោកឡុង បូរេតចេញទៅវិញទៀត)*

**ម៉ាក់ក្លូស្គី**

អីយ៉ា, លោកប្រធានាធិបតី, ខ្ញុំស្មានតែក្រុមអ្នកសាធារណរដ្ឋយល់ថា ខ្មែរក្រហមនឹងរាតត្បាតសង់សឹក!

**សូខាំខូយ**

មិនមែនគ្រប់គ្នាទេដែលភ័យនោះ។ លោកជ្រាបទេថា សម្តេចសីហនុបានប្រកាសប្រាប់យើងច្បាស់ណាស់ថា អ្នកក្បត់ថ្នាក់ខ្ពស់តែ៧នាក់ប៉ុណ្ណោះ ដែលនឹងត្រូវប្រហារជីវិត។

*(លោកឡុង បូរេតចូលមកវិញ)*

**ឡុង បូរេត**

ពិបាកមែន, ប៉ុន្តែខ្ញុំជឿថានឹងដោះស្រាយរួច។ គាត់ទាមទារឲ្យអាមេរិកាំងធានារឿងនេះ។

**ឌីន**

ឲ្យគាត់ទៅណាឲ្យបាត់ពីមុខភ្លាម! ឡើងដល់១លានទៅ, ហើយប្រាប់គាត់ថា បើក្នុង៩នាទីទៀត លោកព្រឹទ្ធសមាជិកត្រឡប់ទៅវិញដោយរឿងនេះមិនសម្រេចជាបញ្ចប់, នោះលោកនឹងដកពាក្យស្នើយកវិញទាំងស្រុង, ១សេនក៏គ្មានដែរ។

**ឡុង បូរេត**

បាទ!

*(លោកឡុង បូរេតចេញទៅវិញ)*

**ម៉ាក់ក្លស្គី**

លោកមានប្រសាសន៍អំពីអ្នកក្បត់ថ្នាក់ខ្ពស់៧នាក់, នរណាទៅអ្នកទាំងនោះ?

**សូខាំខូយ**

គឺលន់ នល់, សិរិមតៈ, អ៊ិន តាំ, សូស្តែន ហ្វែរណង់ដេស, ចេង ហេង, សឺង ង៉ុកថាន់ នឹងលោកឡុង បូរេត ដែលកំពុងនិយាយទូរសព្ទ។

**ឌីន**

លោកសូខាំខូយ, លោកមិនជ្រាបទេថា បញ្ជីនោះឡើងដល់២១នាក់ហើយ, ឥឡូវនេះ។

**សូខាំខូយ**

បាទ, ចឹមិនដឹង ប៉ុន្តែ...

**ឌីន**

តែគ្មានឈ្មោះលោកទេ, ក្នុងនោះ, លោក...

*(លោកឡុង បូរេតចូលមកវិញ)*

**ឡុង បូរេត**

*អស់លោក! រួចរាល់ហើយ, កុំខ្វល់ទៀត! មួយលានដុល្លារ! គាត់នឹងចេញ!*

**ឌីន**

*ល្អណាស់, ខ្ញុំសូមសរសើរ, លោកនាយករដ្ឋមន្ត្រី! លោកព្រឹទ្ធសមាជិក, ប៉ុណ្ណឹងអស់ចិត្តទេ?*

**ម៉ាក់ ក្លូស្គី**

*ខ្ញុំសន្យាថា ខ្ញុំនឹងខំឲ្យអស់សមត្ថភាពដើម្បីកម្ពុជារបស់លោក។ ហើយដើម្បីកម្ពុជារបស់លោកដែរ, លោកឡុង បូរេត។*

**ឌីន**

*សូមជូនពរឲ្យបានជោគជ័យ, លោកព្រឹទ្ធសមាជិក។*

*(លោកម៉ាក់ក្លូស្គីចេញទៅ)*

**ឡុង បូរេត**

*ធ្វើម៉េចហ្ន៎, ឲ្យរដូវភ្លៀងចាប់មកដល់! ពេលនោះ ខ្ញុំគ្មានរារែកអ្វីនឹងអង្វរសីហនុឲ្យមកកាន់អំណាចវិញទេ។*

**សូខាំខូយ**

*ខ្ញុំក៏អញ្ចឹងដែរ។*

**ឡុង បូរេត**

*ខ្ញុំទៅជាអ្វីក៏ទៅចុះពេលនោះ, ធ្វើម៉េចឲ្យតែស្រោចស្រង់ប្រទេសបាន។*

**សូខាំខូយ**

*!!?*

*(លោកគីលីចូលមក)*

**គីលី**

លោកឯកអគ្គរដ្ឋទូត, អស់លោក, សូមអត់ទោស, តែខ្ញុំត្រូវតែជម្រាបអស់លោកថាខ្ញុំទើបនឹងទទួលទូរលេខមួយ។ ក្រុងអ្នកលឿងធ្លាក់ទៅក្នុងកណ្ដាប់ដៃខ្មាំងហើយ។ កងពលធំលេខ១និង លេខ២របស់សាធារណរដ្ឋបាក់ទ័ពរត់ចោលអាវុធអស់។ បាទ, សូមទោស។

**ឡុង បូរេត**

អ្នកលឿង! បានទៅគេហើយ! តំបន់មេកុងខាងក្រោមទៅជាកុម្មុយនីស្ដ៍ហើយ, លោកឌីន!

**ឌីន**

ឱ! អស់លោកជាមិត្ត! អវសានខិតមកហើយ។ ប៉ុន្តែ...

**សូខាំខូយ**

ព្រះជាម្ចាស់! លោកនាយករដ្ឋមន្ត្រី, សូមអញ្ជើញទៅចរចារឲ្យបាប់ទៅ, ហើយប្រាប់គេថាលន់ នល់ចេញទៅបាត់ហើយ, ហើយ...

**ឌីន**

អស់លោកជាអ្នកចាញ់សង្គ្រាម, ខ្ញុំបារម្ភថាហួសពេលនឹងសម្រុះសម្រួលអ្វីទៀតហើយ។

**ឡុង បូរេត**

យើង *ទាំងអស់គ្នា*ចាញ់សង្គ្រាម, ទាំងសាធារណរដ្ឋ, ទាំងកម្ពុជា, ទាំងអាមេរិក។ ប៉ុន្តែវង់គ្រោះបង់ខាតវិញនឹងមិនស្មើគ្នាទេ។

**ឌីន**

នែមិត្ត, កុំយំអី! ខ្ញុំមានទាន់ទៅណា? ខ្ញុំនៅជួយលោក, ខ្ញុំនៅចាំជួយលោក។

**ឡុង បូរេត**

ខ្ញុំមិនមែនយំពីរឿងឡុង បូរេតទេ។ ឡុង បូរេតជាស្អីទៅ? ខ្ញុំយំអាណិតស្រុក, ខ្ញុំកើតទុក្ខអំពីស្រុកខ្ញុំ។

*(ទាំងអស់គ្នាដើរចេញទៅ)*

# ឆាកទី២

*(ប៉េកាំង។ ព្រះសីហនុយាងមកដោយមានសម្ដេចប៉ែន នុត និងលោកអេដែន ម៉ាណាក់មកតាម)*

**ព្រះសីហនុ**

ក្នុងខែនេះ, អ្នកណាទៅដល់ភ្នំពេញមុនគេ អ្នកនោះនឹងទៅជាមេកើយប្រទេសកម្ពុជា។ បើខ្ញុំរត់ប្រណាំងឈ្នះខ្មែរក្រហមដោយលើសតែមួយជំហ៊ាន, ពេលនោះអ្វីៗក៏ដូរទាំងអស់។ ប្រជាជនខ្ញុំនិងខ្ញុំជួបជុំគ្នាវិញ, ហើយហើយទាំងអស់គ្នានឹងទទួលខ្មែរក្រហម។ ពេលនោះខ្ញុំនឹងចរចាររកការដោះស្រាយសមរម្យមួយសម្រាប់ប្រទេស។ មិនទាន់ហួសពេលនៅឡើយទេ។ ហើយអ្វីៗក៏នៅលើអាមេរិកាំងដែរ។ ងាយសោះ, ឲ្យតែគេយល់ថាខ្លួនគេក៏ដោយ ក៏ត្រូវការសីហនុដែរ ហើយទុកឲ្យខ្ញុំចូលទៅក្នុងអាទិត្យនេះ, ប៉ុន្តែចំណុចនេះឯងដែលគេមុខជាភាំង។

**សម្ដេចប៉ែន នុត**

ដឹងអីថា, ក្រាបទូល, លើកនេះអាមេរិកាំងអាចភ្ញាក់ពីដេកឡើងស្វាងជាងរាល់ដង, ប្រែជាមិត្តល្អ, យល់ច្បាស់ពីប្រយោជន៍ខ្លួនទាន់ពេលវេលា! យ៉ាងណាក៏ឥឡូវនេះ ហ្វត (Ford) ឡើងជំនួសនិចសុន (Nixon) ដែរ។

**ព្រះសីហនុ**

តែគីស៊ីងហ្គ័រជាអ្នកជំនួសគីស៊ីងហ្គ័រ, មានអ្វីផ្លាស់ប្ដូរកើត, មានតែខ្លាំងជាមុន។ ខ្មែរក្រហមនឹងបោលត្របាញ់ចូលទៅវិញ, ឯចិននឹងអន់ស្រឡាញ់យើងជាមុន។

**ម៉ាណាក់**

ឯកឧត្តមជូ អេនឡាយប្រាថ្នាចង់ឲ្យតែព្រះអង្គរត់លើសខ្មែរក្រហមមួយជំហ៊ានដូច្នោះឯង, ទូលបង្គំជឿជាក់ថាដូច្នោះ។ នៅមានសង្ឃឹមនៅឡើយទេ។

**ព្រះសីហនុ**

ប៉ុន្តែតាម៉ៅ សេទុង, លោកតាម៉ៅកម្លាំងមាននេះ ទោរទន់ដូចត្រូវស្នេហ៍ទៅរកតែប៉ុល ពត។

**សម្តេចប៉ែន នុត**

*ត្រូវចាត់ការឲ្យបានរហ័ស, ក្រាបទូល។*

**ម៉ាណាក់**

*ក្រាបទូល, ព្រះអង្គយល់ព្រមប្រគល់ការងារស្លាប់រស់នេះឲ្យទូលបង្គំទេ?*

**ព្រះសីហនុ**

*ខ្ញុំប្រគល់ជូនលោកកាន់ទាំងអស់, ប្រគល់កព្វសំណាង, ប្រគល់មន្ទិលសង្ស័យ, ប្រគល់ក្តីសង្ឃឹមដែលលុបបំបាត់មិនបាន, ណាមិត្ត! អាមេរិកាំងឲ្យតែកូនកប៉ាល់ហោះមួយមកដឹកសីហនុមក, ហើយលោកឌីន ចាំខ្ញុំនៅវាលយន្តហោះមក, ពេលនោះទ្វីបអាស៊ីទាំងមូលនឹងជូរមុខមាត់!*

*ប៉ុន្តែសូមប្រយត្ន័, កុំភ្លេចថាគេពាត់យើងជុំជិត។ មហាកំពែងចិនមានបង្កប់ក្បាលមេក្រូខ្មែរក្រហមគ្រប់កន្លែង។ ប្រយត្ន័ឲ្យមែនទែន, កុំឲ្យខូចការដល់ខ្ញុំ...*

*(លោកអៀង សារីចូលមក)*

*ប្រយ័ត្ន, នោះ, ថ្លៃប៉ុល ពតមកហើយ, អៀង សារីជាប្អូនថ្លៃដ៏អាក្រក់របស់គាត់... គឺតែអញ្ចឹងឯង, មកគឺមកស្ងាត់ៗដល់ក្រោយខ្នងខ្ញុំតែម្តង។ សំណាងល្អខ្ញុំដឹងទាន់... ដោយសារស្គាល់ក្លិន។*

*អូ, លោកអៀង សារី! លោកស្គាល់ទេ, លោកទូត, នេះគឺប្អូនថ្លៃលោកប៉ុល ពត។ បានមួយគូនេះគឺពិសេសណាស់, សរ និងសារី, ដូចCastor និងPollux ដូច្នោះដែរ។ ហះ, ហះ, ហះ! គ្មាននរណាចិត្តស្មោះជាងនេះទៀតទេ, ក្រៅពីសីហនុ!*

**អៀង សារី**

*សូមសម្តេចកុំក្បត់យើងខ្ញុំឲ្យសោះ, ណា! អត់ចរចារ! អត់សន្តិភាពក្លែងក្លាយ! អត់បែកបាក់គ្នា!*

**ព្រះសីហនុ**

*នោះហើយ, ខ្ញុំទើបនឹងនិយាយថា អត់បែកបាក់គ្នា។ រដ្ឋាភិបាលខ្ញុំនឹងប្រយុទ្ធរហូតដល់ជ័យជំនះទីបញ្ចប់។ ខ្ញុំតែងតែប្រកាសក្តែងៗយ៉ាងនេះឯង។*

### អៀង សារី

ទូលបង្គំធ្លាប់ទប់ស្កាត់គម្រោងចរចារ៤លើកហើយ ៖

កញ្ញា ៧៤

តុលា ៧៤

ធ្នូ ៧៤

មករា ៧៥

កុម្ភៈ ៧៥។ ល្មមហើយ, ប៉ុណ្ណឹង!

សូមព្រះអង្គជ្រាប, ក្រាបទូល, បើសម្តេចសីហនុធ្វៀតក្បត់ពេលទូលបង្គំរវល់ចូលព្រៃទៀតនោះ, ខ្មែរក្រហមនឹង...

### ព្រះសីហនុ

មានប្រសាសន៍តែមួយម៉ាត់ទៀតមក ខ្ញុំនឹងយកទៅជម្រាបលោកប្រធានម៉ៅទាំងអស់។ ខ្ញុំនឹងជម្រាបគាត់ថា លោកអៀង សារីបានគម្រាមសម្លាប់ខ្ញុំនៅមុខគេឯងជាសាក្សី!

### អៀង សារី

ទូលបង្គំមិនបានថាអីទាំងអស់។

*(ទាំងអស់គ្នាចេញទៅ)*

## ឆាកទី៣

*(នៅមាត់ទន្លេមេគុង។ លោកខៀវ សំផន, លោកអៀង សារី, អ្នកស្រីអៀង ធីរិទ្ធ, លោកប៉ុល ពត នឹងលោកហ៊ូ យន់ ស្លៀកពាក់ខោអាវយោធាទាំងអស់គ្នា, ចូលមក)*

**ប៉ុល ពត**

យកក្រុងភ្នំពេញ, មានន័យថាម៉េចចំពោះពួកយើង?

**ហ៊ូ យន់**

មានន័យថា ជ័យជំនះជាបញ្ចប់, ថាសុភមង្គល។

**ប៉ុល ពត**

មានន័យមុនដំបូងបង្អស់ថា ជ័យជំនះធំបង្អស់លើលោក។ ប៉ុន្តែយើងកុំភ្លើតភ្លើនដោយសារឈ្នះផ្លូវទ័ពនោះ។ យកភ្នំពេញ, គ្មានពិបាកអីទេ។ ខ្ញុំយកភ្នំពេញបានហើយ, បន្ទាប់មកខ្ញុំឃើញថាមានអ្វី?

**ខៀវ សំផន**

មានមនុស្សអត់បាយពីរលានកន្លះ។

**ហ៊ូ យន់**

គឺបទមួយរញ៉េរញ៉ៃ, រីកវរ, វិលវល់, វ៉ាល់វ៉ី, មនុស្សឈរជើងជាន់ករគ្នា, រកបាយស៊ីគ្មាន, ពីព្រោះមនុស្សស្ទើរតែមួយចំហៀងស្រុកទៅហើយដែលមករស់កកកុញនៅក្រុងនេះ។ ដើម្បីគ្រប់គ្រងឲ្យបាន យើងប្រាកដជាលំបាកគួរសមហើយ។

**ប៉ុល ពត**

ខ្ញុំវិញ ខ្ញុំដឹងថា យើងគ្មានចាំបាច់គ្រប់គ្រងអ្វីទាំងអស់។ ខ្ញុំមើលឃើញថាសង្គ្រាមថ្មីមួយទៀតនឹងកើតឡើងភ្លាម។ ខ្ញុំមើលឃើញថា បដិវត្តយើងនឹងមានប្រតិកិរិយាមកវាយប្រចាំង។

**អៀង សារី**

ខ្ញុំបម្រុងនិយាយថាដូច្នេះដែរ។ ស្អីទៅភ្នំពេញ? ភ្នំពេញពុំគ្រាន់តែជាជម្រកយ៉ាងធំស្កឹមស្កៃនៃភាពពុករលួយ, សំបុកបុណ្យសក្តិ, ប្រយោជន៍ផ្ទាល់ខ្លួន, ភាពកំសាកញីប៉ុណ្ណោះទេ, តែជាសំបុកចារកម្មអាមេរិកាំង, ចារកម្មពួកសាធារណរដ្ឋនិងចារកម្មពួកនិយមសីហនុទៀតផង។

**អ្នកស្រីអៀង ធីរិទ្ធ**

ក្រុងទាំងមូល, ពោរពេញទៅដោយមនុស្សមុខពីរ, ចាំស៊ីរះ។ អន្ធាក់, អង្គប់, មាននៅគ្រប់ជំហាន។

**ហ៊ូ យន់**

ប៉ុន្តែមនុស្សភាគច្រើននៅភ្នំពេញមិនមែនជាអ្នកក្រុងទេ, គឺភៀសខ្លួនពីស្រែចំការមកនៅទីនោះ។

**អ្នកស្រីអៀង ធីរិទ្ធ**

អ្នកភៀសខ្លួនដែលចាំតែអបអរហៃហេអើនឹងសីហនុ ឬសាធារណរដ្ឋប៉ុណ្ណោះ។

**ខៀវ សំផន**

តាមពិតទៅភ្នំពេញនោះទុកយើងជាសត្រូវ។ ខ្ញុំមើលមិនឃើញថា យើងអាចគ្រប់គ្រងឲ្យសមរម្យបានទេ, ក្រុងដែលស្អុយរលួយអស់ដោយសារសង្គ្រាមនេះ។

**ហ៊ូ យន់**

បើដូច្នេះ, គិតធ្វើយ៉ាងម៉េច? មើលឃើញថាត្រូវធ្វើម៉េចវិញ?

**ប៉ុល ពត**

ខ្ញុំគ្មានត្រូវការឲ្យចំណីដល់ក្រពើដែលនឹងហែកហួរខាំស៊ីយើង ក្រោយពេលដែលវាឆ្អែតឆ្អាមនោះទេ។ ខ្ញុំមិនធ្វើទេ, របៀបនេះ!

**ខៀវ សំផន**

ខ្ញុំយល់ស្របតាមគំនិតនេះ។ ចិញ្ចឹមភ្នំពេញដូចជាចិញ្ចឹមមនុស្សឱ្យសម្លាប់យើងដូច្នោះដែរ។

**អ្នកស្រីអៀង ធិរិទ្ធ**

ហ៊ូ យន់មិនយល់ស្របទេ។

**ហ៊ូ យន់**

ទេ…អឺ, ស្រប។ ខ្ញុំគ្រាន់តែមិនដឹងថាយើងត្រូវធ្វើដូចម្ដេច។

**ប៉ុល ពត**

ខ្ញុំចង់ទុកភ្នំពេញឬមិនចង់? អង្គការថាម៉េច? អង្គការឆ្លើយថា៖ ទេ!

**អៀង សារី**

ត្រូវតែធ្វើឱ្យភ្នំពេញអស់មនុស្ស!

**ប៉ុល ពត**

ត្រូវហើយ! ត្រូវដោះស្រាយយ៉ាងដូច្នេះ។ ធ្វើរបៀបនេះទើបត្រូវ, គ្មានផ្លូវអ្វីផ្សេងពីនោះទេ។

**ហ៊ូ យន់**

យី, គិតអ្វីប្លែកម្ល៉េះ? អស់មិត្តស្មានថា ឱ្យមនុស្សចេញនោះប្រើពេលខ្លីជាងរៀបចំបណ្ដាញគ្រប់គ្រងឬយ៉ាងម៉េច? ឱ្យមនុស្ស២លានកន្លះចាកចេញ? គ្រាន់តែពេលរៀបចំយានដឹកជញ្ជូន, រៀបចំកន្លែងទទួល, រៀបចំស្បៀងអាហារនោះ មិនដឹងអស់ពេលយូរយ៉ាងណាទៅហើយ!

**អៀង សារី**

មាននរណាថាត្រូវរៀបចំទទួល? គឺយើងត្រូវទម្លាយបួសតែមួយលំពែងឱ្យធ្លាយ។ យើងត្រូវបណ្ដេញខ្មាំងចេញ, កំចាត់សម្បុកកណ្ដុរប្រមេះឱ្យអស់, ការពារយ៉ាងណាកុំឱ្យមានវិទ្ធង្សនា, ដោយប្រើមធ្យោបាយដាច់ណាត់ដែលគ្មាននរណាធ្លាប់ប្រើ។

**អ្នកស្រីអៀង ធិរិទ្ធ**

ពិបាកអីគ្រាន់តែចាក់សម្រាមចោល។ ត្រឡប់តែផុងឲ្យបែទៅក្រោមទៅក៏បានទៅហើយ។

**អៀង សារី**

ទាំងអស់គ្នាចេញឲ្យផុតពីទីនេះភ្លាម។ យី, យូរណាស់ហើយនឹកមិនឃើញ!

**ហ៊ូ យន់**

តែមានពូជធញ្ញជាតិល្អដែលកប់នៅតាមស្មៅព្រៅចម្រៃដែរ។

**ប៉ុល ពត**

មិនអីទេ, ហ៊ូ យន់, យើងអាចរើសយកចេញបាន។ យើងនឹងរើស។

**ហ៊ូ យន់**

ចុះសម្រាមសុទ្ធវិញ, យកទៅណា?

**ប៉ុល ពត**

យកទៅជនបទ, ទៅស្រែចំការឲ្យលើកទំនប់, ឲ្យធ្វើស្រែ។

**អ្នកស្រីអៀង ធិរិទ្ធ**

ខ្ញុំស្នើថា ត្រូវឲ្យហ៊ូ យន់...

**ហ៊ូ យន់**

ទេ, យ៉ាងណាក៏ដោយ, មនុស្សពីរលានកន្លះ, ឲ្យដើរកណ្ដាលផ្លូវខែក្ដៅយ៉ាងនេះ, ហើយប្រទេសកំពុងហិនហាច បាទដៃទទេ។ បានអីហូប, បានទឹកមកពីណា? គ្រាន់តែស្មានក៏មិនអាចត្រូវផង!

### ខៀវ សំផន

*(និយាយទៅលោកហ៊ូ យន់)*

*ឈប់និយាយភ្លាម! ឈប់និយាយ!*

### អ្នកស្រីអៀង ធីរិទ្ធ

*ហ៊ូ យន់, មិត្តមិនទុកចិត្តអង្គការទេឬអ្វី?*

### ហ៊ូ យន់

*ខ្ញុំប្រឆាំងនឹងការសម្រេចចិត្តនេះ។ ខៀវ សំផន, ខ្ញុំសុំចិត្ត, គ្រួសារញាតិយើងទាំងអស់គ្នានៅក្នុងនោះដែរ។ យើងមានឪពុកម្ដាយ បងប្អូន មិត្តភក្ដិនៅភ្នំពេញ។ ម្ដាយរបស់មិត្តក៏កំពុងនៅភ្នំពេញ!*

### ខៀវ សំផន

*ឈប់និយាយ! ហ៊ូ យន់, មិនទាន់យល់ទេថាយើងទាំងអស់គ្នាមិនសប្បាយចិត្តនឹងមិត្តឯង។ មែន, ម្ដាយខ្ញុំនៅភ្នំពេញ, ហើយខ្ញុំគ្មានរារែកអ្វីសោះឡើយ។*

### ហ៊ូ យន់

*ច្បាស់ជាវាលស្មសានមនុស្សស្លាប់គរជើងគ្នាហើយ!*

### ខៀវ សំផន

*ថាឲ្យឈប់និយាយ! ខ្ញុំតែងតែចង់ឃើញសង្គមថ្មីមួយកើតឡើង, បរិសុទ្ធស្អាតផង, គ្មានក្រុង, គ្មានហាងលក់ដូរ, គ្មានមេរោគមកសម្ងំឲ្យផ្អូមរលួយ។ ខ្ញុំធ្លាប់សរសេរដូច្នេះទៀតផង, មិត្តឯងក៏ដូច្នេះដែរហ៊ូ យន់។ ខុសគ្នាត្រង់ខ្ញុំមិនទាត់ចោលទ្រឹស្ដីខ្លួនឯងឡើយ។ ខ្ញុំសូមឲ្យយកមនុស្សចេញពីភ្នំពេញឲ្យអស់, ហើយក្រុងទាំងប៉ុន្មាននៅកម្ពុជាយើងក៏ត្រូវឲ្យអស់មនុស្សដែរ, ទុកជាឧទាហរណ៍ឲ្យគេឯងឃើញ។ ខ្ញុំស្នើឲ្យមានការឃ្លាំតាមដានមិត្តហ៊ូ យន់របស់យើងក្នុងរយៈពេលមួយមិនកំណត់។*

**អ្នកស្រីអៀង ធីរិទ្ធ**

ខ្ញុំរៀបនឹងស្នើដូច្នេះដែរ។

**ប៉ុល ពត**

*អនុម័តហើយ! តទៅទៀត។*

**ហ៊ូ យន់**

*(និយាយមកលោកខៀវ សំផន)*

មិនមែនតែខ្ញុំម្នាក់ឯងទេ ដែលស្តាយភ្នំពេញ, ខ្ញុំជឿជាក់, ហើយខ្ញុំមិនជឿថាមិត្តនិយាយដោយស្មោះអស់ពីចិត្តឡើយ។

*(លោកហ៊ូ យន់ចេញទៅ)*

**ប៉ុល ពត**

ខៀវ សំផន, មិត្តនឹងចាត់ការដេញមនុស្សចេញសំអាតនេះជាមួយមិត្តអៀង សារី។

**អ្នកស្រីអៀង ធីរិទ្ធ**

យើងសំអាតយកចែឲ្យអស់ពីភ្នំពេញ, តែទុកឲ្យហ៊ូ យន់នៅស្រួលឬយ៉ាងណា? ១០ឆ្នាំមកហើយដែលគាត់រារាំង និងជញ្ជក់ឈាមយើង។ គាត់ជាភ្នាក់ងារសេអ៊ីអា។

**ខៀវ សំផន**

*ភ្នាក់ងារសេអ៊ីអា? អូ, ខ្ញុំពុំដែលបានគិតសោះ!*

**អ្នកស្រីអៀង ធីរិទ្ធ**

មានទៅពិបាក, បានជាមើលមិនឃើញ? នេះមកពីមិត្តស្រឡាញ់គាត់ហួស។

**អៀង សារី**

នៅប៉េកាំង, ខ្ញុំធ្លាប់ឃើញគាត់មើលកាសែតញូយ៉កថៃមស៍ (New York Times)។

**ប៉ុល ពត**

កាលណាយើងឈ្នះហើយ, ពេលនោះត្រូវតែកំចាត់ចោលគាត់ភ្លាម។ អៀង ធីរិទ្ធ, មិត្តឯងត្រូវមើលរឿងនេះឲ្យបានសម្រេច។

**អៀង សារី**

ហ៊ូ យន់ជាមេមួយដែលគេចូលចិត្តខ្លាំងណាស់។

**ប៉ុល ពត**

ស្អែកនេះយើងត្រូវច្លងទន្លេ។

*(ទាំងអស់គ្នាចេញទៅ)*

# ចាកទី៤

*(ភ្នំពេញ, នៅមាត់ទន្លេមេកុង។ ទ្រង់សិរិមតៈ, លោកសូខាំខូយនិងលោកឡុង បូរេតចូលមក)*

**សូខាំខូយ**

ឯឧត្តមអើយ! គ្នាគេនៅត្រើយម្ខាង! គេរំកិលមក, គេរំកិលមក, ជិតមកដល់ហើយ។

**ឡុង បូរេត**

សូមអរគុណទ្រង់ណាស់ដែលយាងមក។ ខ្ញុំត្រូវការយោបល់ទូន្មានពីទ្រង់ក្នុងពេល... ថាម៉េចទៅហ្ន! ...ក្នុងពេលទឹកដល់ច្រមុះនេះ។ ទូកវិលវល់ទៅគ្រប់ទិស, ខ្ញុំចង់ធ្វើម៉េចឲ្យជួយអ្នកជិះបាន។

**ទ្រង់សិរិមតៈ**

ខ្ញុំទេ, ដែលអរគុណដល់ឡុង បូរេត, ដែលនៅទុកចិត្តនឹកឃើញដល់សិរិមតៈនៅឡើយ។ អ្វីៗដែលសល់ពីខ្លួនខ្ញុំគឺជារបស់ប្រទេសកម្ពុជានិងនាយករដ្ឋមន្ត្រីដល់ខ្លង់ខ្លស់។ និយាយឲ្យត្រង់ទៅគឺគ្មានអ្វីលំបាកជាងការសូមចុះចាញ់ដោយគ្មានខូចខាតអន្តរាយឡើយ។ យើងត្រូវធ្វើយ៉ាងណាចុះចាញ់គេដោយមិនបាក់មុខ, ដោយមិនលុតជង្គង់។

**សូខាំខូយ**

រឿងនេះមិនមែនស្រេចលើយើងទេ, ឯកឧត្តម!

**ទ្រង់សិរិមតៈ**

ហើយគ្មានធ្វើអីឲ្យតែស្របចិត្តបច្ចាមិត្តប៉ុណ្ណោះទេ។ ដើម្បីចូលមកព្រះរាជធានីយើងបាន ពួកនោះត្រូវតែយល់ថានឹងបង់ខាតខ្លាំងជាទីបំផុត!

**ឡុង បូរេត**

ទាហានយើងនឹងប្រយុទ្ធរហូតដល់គ្រាប់កាំភ្លើងចុងក្រោយ!

**សូខាំខួយ**

ឥឡូវនេះអាមេរិកាំងលែងជួយយើងហើយ, គួរតែយើងបែរទៅរកមហាអំណាចមួយទៀតទៅ, មែនទេ?

**ទ្រង់សិរិមត:**

មហាអំណាចណា? ចិន? លោកចង់ក្លាយជាខ្មែរក្រហម?

**សូខាំខួយ**

ទេ, ទេ, តែរុស្ស៊ី? យើងអាចក្លាយទៅជាសង្គមនិយមបានឬអត់? បើបានគេនឹងជួយយើង។

**ឡុង បូរេត**

ឈប់និយាយទៅ! គ្មាននរណានៅជិតស្តាប់ឮមែន, តែខ្ញុំទ្រាំស្តាប់ពាក្យល្ងង់ខ្លៅយ៉ាងនេះមិនបានទេ! លោកប្រធានាធិតី, កុំរវើរវាយទៅណា, ឥឡូវនេះ...

*(លេខាធិការម្នាក់ចូលមក)*

**លេខាធិការ**

លោកឯកអគ្គរដ្ឋទូតអាមេរិកាំងអញ្ជើញមកហើយ, នេះជាការប្រញ៉ាប់។

**ឡុង បូរេត**

ឲ្យគាត់អញ្ជើញចូលមក, ឲ្យអញ្ជើញចូលមក

*(លោកឌីន ចូលមក)*

អញ្ជើញមិត្តជាទីមេត្រីយ៍!

**ឌីន**

អូ, សាធុ, បានអស់លោកនៅជុំគ្នា!

មិត្ត, អស់មិត្តជាទីមេត្រីយ៍, ដល់ពេលយើងចេញហើយ, យើងត្រូវតែចេញ, ខ្ញុំនាំអស់លោកទៅ។ ខ្ញុំសូមអស់លោកអញ្ជើញទៅស្ថានទូតអាមេរិកភ្លាមឥឡូវនេះឯង។ កុំគិតពីរឿងឥវ៉ាន់, ធ្វើម៉េច! ហួសពេលគិតហើយ,

ព្រោះអស់លោកគ្មានពេលគិតទៀតទេ។ នាំគ្រួសារលោករៀងៗខ្លួនមក, តែគ្មានអ្នកក្រៅ, មិត្តភក្តិ ឬឈ្នួលបម្រើអ្វីទាំងអស់, អស់លោកយល់ទេ?

បីម៉ោងទៀតយ៉ាងយូរបំផុត បើយន្តហោះកន្ទុំរុយខ្ញុំទាំងប៉ុន្មានមិនបានចេញផុតពីដីខ្មែរទេ, នោះគឺច្បាស់ជាលែងហោះផុតពីដីហើយ។ យ៉ាងម៉េច? គ្មានរារែកអ្វីបានទេ។ បាទ, ខ្ញុំយល់, ខ្ញុំយល់ច្បាស់ណាស់ថាពិបាកនឹងចាកចោលញាតិមិត្ត។ ខ្ញុំក៏មានអារម្មណ៍ដូច្នេះដែរ។

យើងមិនអាចឲ្យគ្រប់គ្នាទៅជាមួយបានទេ, យឺតពេលហើយ, យឺតពេលហើយ! នែ, ឲ្យខ្ញុំសូមចិត្តទៅអស់មិត្ត, ប្រញាប់រួសរាន់ឡើង។ អស់លោកមានពេលមួយម៉ោងដើម្បីប្រមូលរបស់របរមានតម្លៃ, តែមិនអាចយកអ្វីលើសពីនោះទេ។

## សូខាំខូយ

មួយម៉ោង!

## ឌីន

យើងសំដៅត្រង់ទៅប្រទេសថៃឡង់ដ៏។ តាមនោះគ្មានអ្វីឲ្យភ័យព្រួយឡើយ។

## ទ្រង់សិរិមតៈ

ឯកឧត្តមដែលជាប្រិយមិត្ត, ខ្ញុំសូមអរគុណនឹងការស្នើជួយឲ្យយើងបានទៅរកសេរីភាព។ បើខ្ញុំយល់ព្រម, ខ្ញុំនឹងស្លាប់។ ខ្ញុំគ្មានសល់អ្វីទៀតទេ, នៅសល់តែសេចក្តីស្លាប់ប៉ុណ្ណោះ, ដូច្នេះខ្ញុំមិនចង់ឲ្យបាត់ទាល់តែសោះ។ ខ្ញុំចង់ស្រោចស្រង់មរណភាពយ៉ាងថ្លៃថ្លារបស់អ្នកអង្គម្ចាស់សិរិមតៈ។ ស្លាប់នៅក្នុងប្រទេសដែលខ្លួនបានកើត, មិនមែនជាការស្លាប់ទេ, គឺជាការទៅរកជួបមុខអ្នកម្តាយខ្លួនវិញ។ បើលោកយកខ្ញុំទៅជាមួយ, មានន័យថាក្នុងកន្ទុំរុយលោកមានតែកំហុសនិងការអៀនខ្មាសរបស់សិរិមតៈប៉ុណ្ណោះ។

ចំណែកឯលោកនិងមហាប្រទេសរបស់លោក, ឯកឧត្តមទូត, ខ្ញុំមិនធ្លាប់គិតទាល់តែសោះថា លោកនឹងមានសេចក្តីក្លាហានគួរឲ្យស្រងេាចចិត្តនេះ ដើម្បីបោះបង់ប្រជាជនមួយទាំងមូលដែលបានជ្រើសរើសយកសេរីភាព*របស់លោក*។

## ឌីន

ឯកឧត្តមនិយាយគ្មានប្រណីខ្ញុំសោះ!

**ទ្រង់សិរិមត:**

យើងយល់គ្នាច្រឡំតាំងតែពីដើមមក។ លោកមិនព្រមការពារយើងតាមពាក្យយើងសុំ, ហាក់បីដូចជាព្រះដែលគ្មានអាសូរដល់យើងដែលជឿគោរពព្រះអង្គដូច្នោះដែរ។ ឯយើងវិញ គឺត្រូវតែតាមកម្ម។

**ឌីន**

តែយើងក៏ដូច្នោះដែរ, ខ្ញុំក៏តាមតែកម្មដូចគ្នាដែរ!

**ទ្រង់សិរិមត:**

លោកចាកចេញទៅ។ ខ្មែរឈរមើលលោកចេញ ហើយយំក៏មិនចេញដែរ។ ពេលទៅបានឆ្ងាយបន្តិចហើយ, មិត្តបរទេសងាកមកមើលក្រោយ។ អ្នកអស់នោះមិនត្រឡប់មកវិញទេ។ ឯខ្មែរវិញញញឹមសម្លឹងមើលទៅមុខមនុស្សដែល ធ្លាប់ស្គាល់ជាលើកក្រោយបង្អស់។

**ឌីន**

អ្នកអង្គម្ចាស់, ឯកឧត្តម...ទេ, និយាយអ្វីក៏គ្មានប្រយោជន៍ដែរពេលនេះ។ លោកនាយករដ្ឋមន្ត្រីក៏មិនអញ្ជើញតាមខ្ញុំដែរ. ...អញ្ចឹង?

**ឡុង បូរេត**

សូមអរគុណដែលឯកឧត្តមខំប្រឹងយល់ចិត្តយើង។ ខ្ញុំមិនទៅទេ។ ខ្ញុំមានអ្វីសព្វគ្រប់ត្រូវធ្វើនៅឯណេះ។ ខ្ញុំគ្មានពេលអ្វីបន្តិចនឹងសោកស្ដាយទាល់តែសោះ។ បើមាននោះ គឺស្ដាយថាគ្មានពេលគ្រប់គ្រាន់នឹងចរចារជាមួយកុម្មុយនីស្ដ៍ ដើម្បីដោះស្រាយឲ្យបានសមរម្យឲ្យទាហានយើងដាក់អាវុធ, ហើយពេលនោះខ្ញុំអាចចាកចេញបានដោយធូរចិត្ត។

ឯលោកវិញ, លោកឌីន, ខ្ញុំសូមឲ្យលោករស់នៅសុខសាន្តបានអាយុ១០០, ជួបជុំគ្រួសារ, ក្រោមមេឃដែលពោរពេញដោយផ្កាយនៃអាមេរិកខាងជើង។

**ឌីន**

ចុះលោកវិញ, លោកសូខាំខូយ, លោកក៏មានកាតព្វកិច្ចបំពេញដូចគ្នាដែរ, មែនទេ?

**សូខាំខូយ**

បាទលោកឯកអគ្គរដ្ឋទូត, ខ្ញុំដូចជាចង់បំពេញដែរ។

**ឌីន**

អស់លោក... មានពេលខ្លះ គឺអ្នកដែលត្រូវទៅទៅវិញទេ ដែលមានអារម្មណ៍ថាគេបោះបង់ខ្លួនចោល។ ឥឡូវនេះខ្ញុំត្រូវទៅ, ហើយខ្ញុំមានអារម្មណ៍ថាលោកទូតម្នាក់ឈ្មោះឌីនកំពុងមើលខ្ញុំចេញដំណើរ, ដោយខ្លួនគាត់ពុំព្រមមកជាមួយខ្ញុំដូចគ្នាដែរ។

អ្នកអង្គម្ចាស់, សូមជ្រាបថា ដោយសារតែទ្រង់និងអស់លោកទាំងអស់, ដោយសារទឹកមុខ, ដោយសារការញញឹមរបស់អស់លោក, ខ្ញុំមិនទៅអស់ទាំងខ្លួនទេ, គឺថ្លើមប្រម៉ាត់មួយភាគជាប់នៅភ្នំពេញ។ ខ្ញុំសូមលាជារហូតហើយ។

*(លោកឌីនចេញទៅ)*

**សូខាំខូយ**

*គាត់ទៅហើយ! ទាំងអស់គ្នាគេទៅហើយ! ទៅទាំងអស់!*

**ទ្រង់សិរិមតៈ**

គេទៅតាំងតែពីយូរមកហើយ។

**សូខាំខូយ**

*១ម៉ោងទៀតគេនឹងទៅផុត!*

**ឡុង បូរេត**

លោកប្រធានាធិបតី, សូមប្រញាប់បន្តិចទៅ, ព្រោះលោកត្រូវទៅដែរមែនទេ, ឯកឧត្តម?

**ទ្រង់សិរិមត:**

ខ្ញុំក៏បានគិតយ៉ាងនោះដែរ។ លោកត្រូវធ្វើតាមពាក្យស្នើជួយរបស់លោកឱនទៅ។ លោកគ្មានហេតុផលខ្លាំងក្លាអ្វី នឹងនៅរង់ចាំពួកខ្មែរក្រហមដូចយើងទេ។

**សូខាំខូយ**

អញ្ចឹងមែន?

**ទ្រង់សិរិមត:**

គ្មាននរណាកាត់ទោសប្រហារជីវិតលោក ដូចលោកឡុង បូរេត និងខ្ញុំទេ។ ដូច្នេះលោកអាចទៅជ្រកកោនកន្លែងផ្សេងបាន ដោយមិនបាក់មុខមាត់។

**សូខាំខូយ**

ច្បាស់ជាអញ្ចឹងមែន, មែនទេ?

**ទ្រង់សិរិមត:**

អញ្ជើញទៅឲ្យលឿន, អញ្ជើញទៅ, ហើយខ្ញុំសូមផ្ដាំជម្រាបលាទៅលោកជំទាវផង។ អញ្ជើញទៅ, លឿនឡើង។ កុំរារែកនាំសៅហ្មងចិត្ត!

**សូខាំខូយ**

អញ្ចឹងមែន. ខ្ញុំទៅពិគ្រោះជាមួយប្រពន្ធខ្ញុំ... យី, ខ្ញុំមិនដែលគិតថាដល់ថ្នាក់នេះសោះ... ជម្រុញឲ្យយើងធ្វើសង្គ្រាមហើយ បោះបង់យើងចោលធ្វើព្រងើយ!

*(លោកសូខាំខូយចេញទៅ)*

**ឡុង បូរេត**

សូខាំខូយអើយ សូខាំខូយ!

**ទ្រង់សិរិមត:**

កម្ពុជាអើយ កម្ពុជា! រងគ្រោះដោយសារយើងកំសាកញី, ដោយសារយើងឡើងឫកក្អេងក្អាង។

*(គេឮសម្លេងយន្តហោះកន្ទុំរុយ)*

យី, ចម្លែកមែន!

ពេលនេះតែម្តងដែលខ្ញុំនឹកឃើញចម្រៀងយ៉ាងពិរោះមួយដែលសម្តេចសីហនុប្អូនជីដូនមួយខ្ញុំតែង, ព្រោះធម្មតាខ្ញុំគ្មានដែលពេញចិត្តនឹងភ្លេងចម្រៀងគាត់ទេ។ ចម្រៀងនោះច្រៀងលាក្រុងភ្នំពេញ។

*(ទ្រង់ច្រៀងចម្រៀងនោះ)*

*(សម្លេងកាំភ្លើងធំនិងគ្រាប់បែកបន្លឺកាន់តែខ្លាំង។ ទាំងអស់គ្នាចេញទៅ)*

# ឆាកទី៥

*(ភ្នំពេញ។ យុគន្ធរចូលមកយ៉ាងរីករាយក្រៃលែង, ដោយមានអ្នកស្រីខៀវសំណុល និងអ្នកឡាំណោមកជាមួយ)*

**យុគន្ធរ**

ខ្ញុំឃើញពួកនោះហើយ! យាយ! យាយឡាំណោ! នោះ! ពួកខ្មែរក្រហម!, នោះ! សង្គ្រាមចប់ហើយណាយាយ!

**អ្នកស្រីខៀវសំណុល**

ចប់សង្គ្រាម! កូនឯងឃើញពួកនោះ! ឃើញយ៉ាងម៉េច?

**យុគន្ធរ**

ឃើញជិះឡានកាមីញ៉ុង! ហ្នឹងហើយ, ជិះកាមីញ៉ុង! ជិះកាមីញ៉ុង!

**អ្នកស្រីខៀវសំណុល**

ជិះកាមីញ៉ុងយ៉ាងម៉េច? ប្រាប់ឲ្យច្បាស់ជាងនេះមកមើល, ជិះកាមីញ៉ុងយ៉ាងម៉េច?

**យុគន្ធរ**

បាទ, ខ្ញុំទៅមើលឲ្យច្បាស់បន្តិច!

**អ្នកស្រីខៀវសំណុល**

នែ, ក្រម៉ាយាយ! ឲ្យក្រម៉ាយាយមកវិញ។

**យុគន្ធរ**

ខ្ញុំយកទៅចងជាទង់ជាតិដើម្បីទទួលអបអរ។ ទង់ជាតិសម្រាប់សម្តេចឳ, ណាយាយ!

**អ្នកឡាំណោ**

សម្តេចព្រះសីហនុ? យាងមកដល់ហើយ?

## អ្នកស្រីខៀវ សំណុល

*សម្ដេចឪ? ឱ, គុណបុណ្យព្រះជាម្ចាស់! កូនឯងបានឃើញព្រះអង្គ, ហើយគ្មានប្រាប់យាយអ្វីទាំងអស់! ព្រះអង្គទ្រង់យ៉ាងម៉េច?*

## យុគន្ធរ

ខ្ញុំមិនបានឃើញព្រះអង្គទេ, យាយ។ ប៉ុន្តែគង់តែយាងមកឥឡូវហើយ, ព្រោះអីគេចាំទទួលព្រះអង្គគ្រប់គ្នា។

*(ភ្លាមនោះគេឮសម្លេងមេក្រូស្រែកប្រកូកប្រកាសនៅក្នុងទីក្រុង)*

## សម្លេងមេក្រូ

*ប្រជាជននៅក្រុងភ្នំពេញទាំងអស់! ក្រុងយើងទើបនឹងរំដោះបានដោយកងទ័ពរំដោះជាតិខ្មែរក្រហមដ៏អង់អាចរបស់យើង។ ពួកក្បត់កម្រិតខ្ពស់ដែលបោលប្រសេចប្រសាចឡប់ឡិនស្មារតី, ហើយដែលរត់ទៅគោះទ្វារគេសូមជ្រកទាំងប៉ុន្មាននោះ, យើងបានកំទេចវារលាយដូចផេះ។ ឥឡូវនេះ, សូមប្រជាជននៅភ្នំពេញស្ដាប់ដោយប្រុងប្រយត្ន័! ទីបញ្ជាការជាន់ខ្ពស់នៃបដិវត្តចេញបញ្ជាឲ្យ ប្រជានជនទាំងអស់ចេញពីទីក្រុងឥឡូវនេះតែម្ដង, គឺឥឡូវនេះឯង។*

*ចេញឲ្យផុតពីទីក្រុង, ឲ្យផុតពីទីក្រុង។ ស្អែកនេះច្បាស់ជាចក្រពត្តិអាមេរិកមកទម្លាក់គ្រាប់បែក។ ប្រជាជននៅភ្នំពេញ, មុនយប់មកដល់, អ្នកទាំងអស់គ្នាត្រូវចេញឲ្យផុតពីក្រុង។*

*ពួកអាមេរិកាំងឈ្លានពានគម្រាមគំហែងយើងថានឹងទម្លាក់គ្រាប់បែក។ ចេញឲ្យផុតពីក្រុង!ទាំងអស់គ្នាត្រូវច្លងស្ពានមុនីវង្ស។*

*ឲ្យផុតមុនយប់មកដល់, ឲ្យផុតមុនយប់...*

## អ្នកស្រីខៀវ សំណុល

*ទាំងអស់គ្នាចេញក្រៅ? ពួកនេះឆ្កួតឬជា? ចុះអ្នកណាដែលឈឺ? គិតដើរចោលអ្នកជម្ងឺដេកក្នុងពេទ្យឬយ៉ាងម៉េច?*

## អ្នកឡាំណៃ

*បងយល់ថាមកមែនឬយ៉ាងណា?*

### អ្នកស្រីខៀវ សំណុល

នរណា?

### អ្នកឡាំណោ

សម្តេចឪ

### សម្លេងមេក្រូ

ទាំងអស់គ្នាត្រូវចេញ។ ត្រូវតែចេញពីគ្រប់អាគារទាំងអស់។ អាគារទាំងអស់គ្មានរើសមុខ។ គ្មានរើសមុខទេ។
៣ថ្ងៃទៀតបងប្អូននឹងត្រឡប់មកវិញបាន។ ៣ថ្ងៃទៀត។ ទុកពេលនេះឲ្យកងកម្លាំងដ៏អង់អាចរបស់យើងសំអាត
ក្រុងឲ្យអស់ពួកក្បត់, ក្បត់ដល់កំពូល, ផ្តាច់ការដល់កំពូល, ពុករលួយដល់កំពូល។
ចេញពីទីក្រុងភ្លាមទៅ។
បន្ទាប់មកយើងនឹងសាងកម្ពុជាថ្មីមួយ ដូចសម្តេចព្រះប្រមុខរដ្ឋព្រះនរោត្តមសីហនុបានមានបន្ទូលដូច្នោះ។
ទៅជាមួយគ្នា, យើងទៅជាមួយគ្នា។
ទាំងអស់គ្នាចេញក្រៅ។ ចេញពីក្រុង។ ចូរធ្វើតាមការណែនាំរបស់ថ្នាក់ដឹកនាំដ៏វៀងវៃ, ដ៏ត្រឹមត្រូវនិងដ៏មាន
ជោគជ័យ។
សូមចេញទៅតាមផ្លូវជាតិលេខ១៤, ៥ និង៦។ ទៅមុខ, ដើរទៅមុខ, ទៅមុខ។

*(ស្រីទាំងពីចេញទៅជាមួយយុគន្ធរ។ ខ្មោចលោកហ៊ួ យន់ចូលមក)*

### ហ៊ួ យន់

លើផ្លូវជាតិលេខ១៦
កង់រទេះវិលព្យុងើតងឹត, អ្នកស្រែ... ខំទប់ខ្លួនមិនឲ្យយំ
ក្នុងឡាន, ស្រីៗក្រចកដៃក្រហមងាំង, យំងើាង។
អ្នកក្រុងចិត្តមិនស្ងប់ ញ័រចំប្រប់ដើរខ្លួនធេងធោងដូចខ្មោចកំបុតជើង។
កូនក្មេងវង្វេងព្រាត់ម៉ែឪស្រែកយំទ្រហឹង
ផ្លូវឡើងពណ៌ក្រហម, ជណ្តប់ដោយស្បែធូលីពណ៌ក្រហម
ម្តាយឪពុកងាកមើលគ្រប់ទិសទីរកកូនមិនឃើញ
មានតែបក្សីទេ ដែលគិតថាវារស់នៅក្នុងពិភពចាស់ដដែល

ក្មេងស្រីនឹងព្រាត់ពីម្ដាយវារហូត

ចាស់។ ខ្សោយហត់ហេវ សុខចិត្តឈប់ដេកក្នុងស្នាមភ្លោះហួតហែង

តាមមាត់ផ្លូវ អ្នកខ្លះដេកស្លាប់ គ្មានស្ដាយស្រណោះអ្វីឡើយ

ស្រីខ្លះកើតកូន ហើយប្រទិចផ្ដាសាជីវិត

អ្នកឯទៀតដើរមកដល់ឃើញទឹកក្នុងចិត្តថា៖ គួរឲ្យអនិច្ចាមែន ដែលកើតថ្ងៃ១៧ មេសា ១៩៧៥នេះ។

ទាល់តែខ្មោចដែលស្លាប់ទើបមានក្ដីករុណាហើយពោលថា សំណាងល្អណាស់ ក្មេងដែលកើតថ្ងៃនេះ, ព្រោះមិនអាចរស់បានប៉ុន្មានទៀតទេ

ពួកវាវាយបំបាក់កខ្ញុំ, សម្រួចឬស្សីចាក់ខ្ញុំធ្លាយពោះធ្លាយទ្រូង។

ប៉ុន្តែខ្ញុំស្លាប់ក្នុងសេចក្ដីខ្មាសផងក្នុងកំហឹងផង,

វាយកសពខ្ញុំទៅបោះចោលឲ្យឆ្ងាយ, តែវាមិនអាចដកយកកំហឹងខ្ញុំឲ្យទៅឆ្ងាយទេ។

ស្រីចាស់ពីរនាក់ដើរទទ្រើកទទ្រើកទប់គ្នាទៅវិញទៅមកតាមហ្វូងមនុស្សមិនខុសអ្វីពីស្លឹកឈើងាប់ពីរសន្លឹកដែលអណ្ដែតទឹកឡើយ។

ម្នាក់និយាយទៅម្នាក់ទៀតថា៖ “យុគន្ធរវារកយើងឃើញទេ?”, ម្នាក់ទៀតថា “កាលណាទៅ ទើបវារកយើងឃើញ?”

បុរសម្នាក់ដែលធំធាត់, មុខញញឹមហើយ, ជិះឡាន Mercedes ខ្មៅកាត់ហ្វូងមនុស្សដែលកំពុងក្រពុលមុខនោះ គឺជនកំណាច អៀង សារី។

នៅពីក្រោយគាត់គឺប៉ុល ពតដែលគេប្រមាណស្ទង់ចិត្តមិនត្រូវ។ ស្រីពីរនាក់អម្បាញ់មិញក្រឡេកទៅឃើញជនផ្ដាច់ការថ្មីទាំងពីរលើប្រទេសកម្ពុជា។ គាត់ចូលថា “ម៉េចក៏ពួកអានេះវាធាត់ចុកខ្លាញ់ល្អម្ល៉េះ?”

លើផ្លូវជាតិលេខ១៦

ទន្លេហូររឹម។ ហូរដូចជាខ្វាក់នេះ ជាទន្លេហ្វូងមនុស្សគ្រាន់តាប់

ទន្លេនេះមានប្រភពមកពីភ្នំពេញ,

ហូរទៅចាក់ឯណាទៅហ្ន៎!

*(គាត់ចេញទៅ)*

# ឈុតទី៤

## ឆាកទី១

*(ប៉េកាំង។ លោកដូ អេនឡាយចូលមក, មានអ្នកបម្រើមកផង)*

**ដូ អេនឡាយ**

កាលនៅអាយុ២០ឆ្នាំ ខ្ញុំទៅវាយលុកលុយយ៉ាងក្រអឺតរហូតដល់ព្រះអាទិត្យ។
ម្ដេចក៏ជីវិតខ្លីយ៉ាងនេះ? ខ្ញុំដើរអស់ពេល៥០ឆ្នាំ។
ចប់ហើយថ្ងៃនេះ, ក្បាលជង្គង់ឡើងញ័រទទ្រើក។យប់សន្ធិយាចូលមកដល់ហើយ,
តែខ្ញុំគ្មានបានធ្វើអីចប់ចុងចប់ដើមសោះ, ឈ្នះក៏មិនឈ្នះ ចាញ់ក៏មិនចាញ់, តែខ្ញុំត្រូវតែឈប់។
តែអ្នកវិញ, ឱប្រទេសចិនជាទីស្នេហា, អ្នកនៅតែតទៅទៀត។ ប្រយត្ន័ប្រយែងបន្តិច,
កុំធ្វើរបៀបយុវជនឈាមរាវ,
ធ្វើខ្លួនឲ្យចាស់ទុំមិនពុះកញ្ជ្រោលវិញទើបបានវែងឆ្ងាយ។

*(ព្រះសីហនុយាងចូលមក)*

**ព្រះសីហនុ**

មហាមិត្ត! ... លោកមិនបណ្ដោយខ្លួនឡើយ, មែនទេ? មនុស្សធម្មតាអាចស្លាប់ងាយ, តែបើមានព្រះជួយបន្តិចផងនោះ មហាបុរសដូ អេនឡាយអាចប្រយុទ្ធឈ្នះរោគាព្យាធិបាន!

**ដូ អេនឡាយ**

កុំខ្វល់នឹងទូលបង្គំ, មិត្តជាទីមេត្រីយ៍, ទូលបង្គំប្រយុទ្ធដូចតែធម្មតាដូច្នេះឯង។ ទូលបង្គំឮគេថា សម្ដេចនឹងយាងទៅកូរ៉េ។

**ព្រះសីហនុ**

ខ្ញុំអៀនខ្លួនណាស់ដែលរំខានមិត្តចិនគ្រប់ពេលវេលាយ៉ាងនេះ។

### ជូ អេនឡាយ

នៃមិត្ត, កុំទៅកូរ៉េអី។ យាងចូលស្រុកខ្មែរវិញតែម្ដងទៅ, មិនចាំបាច់វាងទៅនេះ ទៅនោះសិនទេ។ ពាក្យទូន្មាន ជាសេចក្ដីប្រាថ្នាដោយស្មោះស្ម័គ្ររបស់ទូលបង្គំ។ ប្រជាជនព្រះអង្គកំពុងត្រូវការព្រះអង្គ។

### ព្រះសីហនុ

ខ្ញុំក៏អញ្ចឹងដែរ, គឺត្រូវការប្រជាជនខ្ញុំដែលគេបានលួចយកទៅ។ តាមពិតទៅកូរ៉េនោះ មិនមែនជាបំណងប្រាថ្នាអ្វីទេ, គឺមកពីគិតថាទាល់តែធ្វើដូច្នោះ។

### ជូ អេនឡាយ

ទូលបង្គំដឹងច្បាស់ថា សម្ដេចខ្វែងគំនិតស្ដាប់គ្នាមិនបានជាមួយពួកកុម្មុយនីស្ដ៍កម្ពុជា, ប៉ុន្តែ ទូលបង្គំជឿថា មានហេតុផលនយោបាយព្រមទាំងសណ្ដានចិត្តល្អផ្សេងៗ ច្រើន ដែលនឹងធ្វើឲ្យដោះស្រាយបញ្ហានោះរួច។

### ព្រះសីហនុ

ឯកឧត្តមយល់ថា មានការខ្វែងគំនិតស្ដាប់គ្នាមិនបាន? គ្មានទេ។ នរណានិយាយអ្វីទាំងប៉ុន្មានប្រាប់ខ្ញុំ ឬលាក់នឹងខ្ញុំ, ខ្ញុំឮទាំងអស់, ព្រោះ... ត្រចៀកខ្ញុំអាចឮធ្លុងជញ្ជាំង។ ដែលមានកើតឡើងនោះ គឺការមិនឮអ្វីទាំងអស់ទៅវិញទេ។ មានតែភាពស្ងាត់ឈឹងរាប់ខែ, តែទឹកស្រក់មួយដំណក់ក៏មិនឮផង, យូរវែងអន្លាយដូចជាមហាកំពែងចិន។ នេះហើយការពិតដែលមាននៅក្នុងកិច្ចសន្ទនាសំបកក្រៅ, ភរគេ, រវាងខ្ញុំនិងរដ្ឋមន្ត្រីនានាដ៏ចម្លែកនិងដ៏រឹងរូសរបស់ខ្ញុំ។ បើឯកឧត្តមជ្រាបថា រឿងអ្វីៗខ្លះកើតឡើងប៉ុន្មានអាទិត្យជាប់ៗគ្នានេះច្បាស់ជាឯកឧត្តមមិនឲ្យសីហនុចូលទៅស្រុកមួយដែលលែងជាស្រុករបស់ខ្លួនទៀតហើយនោះទេ។ ដូចជាថ្ងៃមុន, ខ្ញុំដឹងដោយចៃដន្យ ថាកម្ពុជាលែងជាព្រះរាជាណាចក្រទៀតហើយ! មែន, គឺដឹងដោយចៃដន្យមែន។ គឺថាសព្វថ្ងៃមិនមែនរដ្ឋាភិបាលទៀតទេដែលផ្ដល់ពត៌មានទៀងទាត់មកខ្ញុំ, គឺការចៃដន្យ!

ដូច្នេះហើយបានជាទាល់តែមានពិធីជប់លៀងនៅស្ថានទូតកាលពីថ្ងៃមុន ទើបខ្ញុំឮគេនិយាយថារាជធានីភ្នំពេញធ្លាក់ក្នុងដៃខ្មែរក្រហម។ គេប្រាប់ខ្ញុំថា គេបណ្ដេញមនុស្សចេញអស់ហើយ។ ឯខ្ញុំវិញ, ពេលនោះ, ខ្ញុំឆ្លើយឆ្លងនឹងគេឯងថាម៉េច? គឺខ្ញុំមានតែប្រកែកថា ពុំមែន! ខ្ញុំប្រកែកថាដំណឹងនោះគ្រាន់តែជាពាក្យចាមអារាមយកជាការមិនបាន។

### ជូ អេនឡាយ

ទូលបង្គំពេញចិត្តដែរ ដែលពេលនោះព្រះអង្គមិនព្រមជឿ។

### ព្រះសីហនុ

ឯកឧត្តមឃើញទេ, ដល់អញ្ចឹងទៅ ខ្ញុំទៅជាមនុស្សភរភូត, ល្ងង់ខ្លៅ, មិនដឹងអី, គេបោកបានតាមចិត្ត! ខ្មាសគេណាស់, មិនដឹងយកមុខទៅទុកឯណាទេ, កាលដែលគេជប់លៀងឲ្យខ្ញុំពេលដែលខ្ញុំថ្លែងកាត់ប្រទេសអាល់បានី, គឺក្នុងពិធីជប់លៀងយ៉ាងត្រចះត្រចង់មួយ ដើម្បីអបអរសាទររដ្ឋធម្មនុញ្ញថ្មីនៃកម្ពុជា។ រដ្ឋធម្មនុញ្ញថ្មី? អីយ៉ា, ទើបនឹងឮ, ភ្ញាក់ដូចគេចោល! សីហនុអើយ, ធ្វើអ្វីកើត, បើអញ្ចឹងទៅហើយ! គឺមានតែលើកកែវឡើងអបអរនឹងមហារដ្ឋធម្មនុញ្ញថ្មីដែលខ្លួនត្រូវអនុមតិយល់ព្រម ដោយមិនដឹងអ្វីសោះពីមុនមកបន្តិចនោះ! ឯកឧត្តម, បើនិយាយឲ្យចំៗតែម្ដងគឺខ្មែរក្រហមធ្វើទុក្ខបុកម្នេញខ្ញុំគ្មានល្ហែ! ដូច្នេះខ្ញុំត្រូវតែទៅកូរ៉េ, ខ្ញុំដកខ្លួនថយ, ខ្ញុំកាត់ផ្ដាច់ចំណងខ្សែដែលគេទាញខ្ញុំឲ្យធ្វើអាយ៉ង, ខ្ញុំរំដោះសីហនុឲ្យផុតពីស្ថានភាពអាប់អោននេះ។ ខ្ញុំឈប់លេងល្បែងនេះទៀតហើយ។ ខ្ញុំនឹងងើបមុខឡើង, សូមលាលែងពីតំណែង, ដើម្បីស្ដារសុខភាពខ្ញុំដែលកំពុងតែចាប់ផ្ដើមទ្រុឌទ្រោមនេះឲ្យប្រសើរឡើងវិញផង។
បើបណ្ដោយឲ្យអាម៉ាស់មុខដូច្នេះតទៅទៀត គឺច្បាស់ជាស្លាប់។ ឯកឧត្តមយល់ទេ?

### ជូ អេនឡាយ

ទូលបង្គំយល់, ការដែលព្រះអង្គឈឺចាប់នោះ ក៏វាលដាលឲ្យទូលបង្គំចុកចាប់ដែរ, ប៉ុន្តែទូលបង្គំនៅតែទទូចថាឲ្យព្រះអង្គយាងទៅភ្នំពេញ។ វាសនាកម្ពុជាជារឿងសំខាន់បំផុត, ដែលត្រូវតែអត់ធ្មត់យករឿងនោះជាធំ។ បើព្រះអង្គលាលែងពីតំណែង, គឺមានន័យថាយកប្រជាជនព្រះអង្គប្រគល់ទៅឲ្យមនុស្សដែលទាំងព្រះអង្គទាំងទូលបង្គំមិនអាចទុកចិត្តទាំងស្រុងបាន។

### ព្រះសីហនុ

អូ, បើអញ្ចឹងឯកឧត្តមមិនចូលចិត្តពួកនោះដែរ!

### ជូ អេនឡាយ

ទូលបង្គំចូលចិត្តសីហនុ, មិនចូលចិត្តប៉ុលពតទេ។ ប៉ុន្តែមនុស្សរបៀបយើងដែលជាអ្នកយាមប្រទេសរៀងៗខ្លួននេះ យើងត្រូវតែចងឬស្រាយចំណងសម្ពន្ធភាពទៅតាមពេលវេលាដែលតម្រូវឲ្យយើងធ្វើ, ដោយគ្មានត្រាប្រណីអ្វីបន្តិចដល់បេះដូងផ្ទាល់ខ្លួនឡើយ។ ព្រះអង្គតែងតែប្រាថ្នាយ៉ាងណាឲ្យកម្ពុជានៅជាខ្មែរ។ ឯចិនវិញក៏មិនចង់ឲ្យពួករុស្ស៊ីឬកព្រហើនយកស្រមោលវាមកគ្របតណ្ដប់ដែនដីឥណ្ឌូចិនដែរ។ បើគ្មានខ្មែរក្រហម, តើនរណាអាចតទល់នឹងវៀតណាមរមិលគុណបាន? ព្រះអង្គជ្រាបស្រាប់ហើយថា ហាណូយត្រៀមខ្លួនចាំតែបើកទ្វារ

ចំហរឲ្យយក្សរុស្សីចូលមកអាស៊ីរបស់យើងតែប៉ុណ្ណោះ។ អញ្ចឹងទៅចុះ, សម្តេចជាទីស្នេហា, យើងត្រូវតែដកយកពិសពីពស់កំណាចមួយមកប្រើជាថ្នាំសម្រាប់សុខមាលភាពមនុស្សទៅវិញឲ្យបាន។ ទូលបង្គំសន្យាថា ប្រទេសចិននឹងយកទម្ងន់ទាំងប៉ុន្មានរបស់ខ្លួនទៅទប់សង្កត់កុំឲ្យជនរួមជាតិព្រះអង្គខ្លះកញ្ឆ្រោលខ្លាំងពេក។

*(លេខាធិការម្នាក់ចូលមក)*

**លេខាធិការ**

ឯកឧត្តម, លោកអៀង សារី និងអ្នកស្រីអញ្ជើញមក។

**ជូ អេនឡាយ**

មើល, លោកកូនយល់ឲ្យឪធ្វើយ៉ាងម៉េចដែរ?

**ព្រះសីហនុ**

តើសីហនុអាចនិយាយថា "ទេ" ទៅជូ អេនឡាយកើតដែរឬយ៉ាងម៉េច?

**ជូ អេនឡាយ**

សូមអរព្រះគុណ។ (*ងាកទៅលេខាធិការ*) សម្តេចនិងខ្ញុំរង់ចាំទទួលភ្ញៀវទាំងនេះ។

*(លេខាធិការចេញទៅ)*

*(លោកអៀង សារីនិងអ្នកស្រីអៀង ធីរិទ្ធចូលមក)*

សូមស្វាគមន៍ដល់មិត្តកម្មុយនីស្តជាទីស្នេហានៃកម្ពុជាដ៏ខ្លង់ខ្លស់ដែលទើបនឹងរំដោះបាន។ សម្តេចព្រះសីហនុទើបនឹងប្រាប់ខ្ញុំថា ព្រះអង្គចង់យាងចូលប្រទេសរបស់ព្រះអង្គដែលទើបនឹងរំដោះបានក្នុងជោគជ័យត្រចះត្រចង់ឲ្យបានឆាប់បំផុត ដើម្បីបម្រើប្រជាជនព្រះអង្គនៅក្នុងរង្វង់រដ្ឋាភិបាលដែលព្រះអង្គបានទទួលកិត្តិយសដឹកនាំ។ ប្រទេសចិនពេញចិត្តសោមនស្សនឹងរដ្ឋាភិបាលដ៏ប្រពៃនោះណាស់។

**អៀង សារី**

យើងខ្ញុំយល់រឿងនេះច្បាស់ណាស់, លោកនាយករដ្ឋមន្ត្រី, នេះជាកិត្តិយសមួយយ៉ាងខ្លង់ខ្លស់។

### ព្រះសីហនុ

ខ្ញុំអន្ទះសាចង់ឃើញប្រទេសឡើងវិញ, ចង់ឃើញមិត្តភក្តិ, បងប្អូន... អ្នកដែលនៅរស់។ ចង់ឃើញរដ្ឋាភិបាលជាទីខ្ពង់ខ្ពស់ទាំងមូលរបស់ខ្ញុំ, រាប់បញ្ចូលទាំងលោកសាឡុត សរ- ប៉ុល ពតផង ដែលខ្ញុំកម្រនឹងបានជួបគោរពគាត់, ព្រមទាំងលោកហ៊ូ យន់ជាជនស្អាតស្អំ ដែលខ្ញុំមិនដែលបានជួបមុខទៀតសោះ។

### អៀង សារី

ព្រះអង្គនឹងទតឃើញការផ្លាស់ប្តូរយ៉ាងធំធេងដែលទូលបង្គំយើងខ្ញុំបានធ្វើឡើងក្នុងរយៈពេលតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះឲ្យប្រទេសយើងដែលបានរងគ្រោះហិនហោចដោយសង្គ្រាម។

### ជូ អេនឡាយ

គឺត្រង់ចំណុចថា មួយប៉ប្រិចភ្នែកនេះហើយ ដែលខ្ញុំចង់ជម្រាបពីយោបល់ខ្ញុំដែលកើតឡើងក្រោយពីការពិចារណាវែងឆ្ងាយមក។ អស់លោកនៅក្មេង, អស់លោកចាប់ផ្តើមបណ្តុះកុម្មុយនីស្តនៅដីជាទីសក្ការៈរបស់អស់លោក។ នេះគឺអស់លោកមានសំណាងណាស់ ដែលយើងខ្ញុំជាចិនមិនធ្លាប់មាន, គឺថាលោកអាចមើល, អាចដកស្រង់បទពិសោធន៍មានស្រាប់ដែលកើតឡើងដោយបងៗរបស់អស់លោកបានធ្វើមុន។ ចិត្តពុះកញ្ជ្រោលគ្មានអ្វីសម្រន់បង្អង់បាននេះហើយ ដែលធ្វើឲ្យចិនជួបប្រទះនឹងបរាជ័យធ្ងន់ធ្ងរជាច្រើនលើកច្រើនសា។ បត់បែនផ្នត់គំនិតមនុស្ស ត្រូវការពេលវេលា ហើយត្រូវធ្វើដោយថ្នម, ធ្វើតាមសម្រួល។ សូមទុកប្រទេសអស់លោកដូចជាកូននៅតូចខ្ចីអញ្ចឹងដែរ, ឬក៏ដូចជាម្តាយលោកដែលចាស់ជរាខ្លាំង។ ធ្វើយ៉ាងណាចៀសវាងកុំឲ្យមានមហាលោតផ្លោះមហាអស្ចារ្យ។ ធ្វើតាមតែអ្នកថែទាំសួនទៅមិនខុសទេ, គឺដើរឲ្យប្រយ័ត្នប្រយែងកុំជាន់ដំណាំដែលទើបនឹងចាប់ពន្លក។ ប្រជាជនទាំងអស់ត្រូវដុះងើបទៅរកកុម្មុយនីស្ត ដូចដើមផ្កាដែលងើបធំខ្ពស់ឡើងទៅរកព្រះអាទិត្យដែរ។ លោកយើងនេះមានពេល, មានខែ, មានរដូវ, កុំលោតផ្លោះរំលងឲ្យផុតរដូវដែលត្រូវមកជាបន្ទាប់ឲ្យ សោះ។ នេះហើយការដែលខ្ញុំចង់ជម្រាប។

### អ្នកស្រីអៀង ធិរិទ្ធ

*(និយាយទៅលោកអៀង សារី)*

ទូន្មានមើលតែលោកសង្ឃ!

**អៀង សារី**

ឯកឧត្តម...

**ព្រះសីហនុ**

ឯកឧត្តម, រដ្ឋភិបាលយើងខ្ញុំរំភើប ហើយដឹងគុណខ្លាំងណាស់ចំពោះពាក្យដ៏ថ្លៃថ្លានេះ។ មែនទេ? អ្នកស្រីរំភើបណាស់, មិនអញ្ចឹង, អ្នកស្រីអៀង សារី?

**អ្នកស្រីអៀង ធិរិទ្ធ**

ក្រាបទូល, រំភើបខ្លាំងណាស់។

**អៀង សារី**

បទពិសោធន៍របស់ប្រទេសចិនមានប្រយោជន៍ថ្លៃថ្លាណាស់សម្រាប់សាកលលោកទាំងមូល។ យើងនឹងទាញសេចក្ដីសន្និដ្ឋានឲ្យបានត្រឹមត្រូវ។

**ជូ អេនឡាយ**

ខ្ញុំត្រូវលាអស់លោកហើយ។ ជើងខ្ញុំវាលែងស្ដាប់បង្គាប់ខ្ញុំហើយ, វាមិនព្រមទ្រទម្ងន់ខ្ញុំទៀតទេ។ ឃើញទេ, នេះហើយ មកពីកាលមុនដើរញាប់ជើងលឿនពេក។

**ព្រះសីហនុ**

មិត្តជាទីស្នេហា, ឲ្យខ្ញុំជួយជូនដំណើរផងបានទេ?

**ជូ អេនឡាយ**

ទូលបង្គំបម្រុងនឹងសូមឲ្យជួយដូច្នេះឯង។

*(ព្រះសីហនុយាងចេញទៅជាមួយលោកជូ អេនឡាយ)*

**អៀង សារី**

មើលចុះ, អតីតកាលកំពុងផ្អែកលើអតីតកាល, នាំគ្នាចេញទៅទើមៗរញ៉ែរញ៉ៃ។ បដិវត្តយើងនឹងបង្ហាញទៅពិភពលោកទាំងមូលថា គេអាចទៅដល់កម្រិតកុម្មុយនីស្ដ៍ឥតខ្ចោះតែមួយរំពប, មិនចាំបាច់វារែកក្រញ៉ឹមក្រញ៉ុមឡើយ។ មិត្តប៉ុល ពតធ្លាប់និយាយហើយថា កម្ពុជានឹងទទួលពានរង្វាន់ធំបង្អស់ក្នុងវិស័យបដិវត្តន៍។ គ្មានអ្វីដែលធ្វើមិនបាននោះទេ, ឲ្យតែប្ដេជ្ញាចិត្តថាធ្វើ។

**អ្នកស្រីអៀង ធីរិទ្ធ**

លោកសង្ឃឹមខ្លាំងពេកហើយ ក្នុងកាលណាស្អែកនេះយើងឡើងទៅដល់កំពូលភ្នំដោយខ្លួនឯង, មិនបាច់នរណាជួយ?

**អៀង សារី**

គ្មានថាអីទៀតកើតទេ, ព្រោះស្អែកនេះគាត់នឹងស្លាប់ទៅហើយ។ ហើយចិននឹងគាំទ្រយើងពេញទំហឹង ដោយគ្មានទៅសូញសាញសាំញ៉ាំទៀតទេ។

**អ្នកស្រីអៀង ធីរិទ្ធ**

ចុះសីហនុវិញ? ត្រូវតែទ្រាំចិញ្ចឹមឲ្យបាយទៀតឬយ៉ាងម៉េច?

**អៀង សារី**

ទុកឲ្យព្រះអង្គចូលទៅស្រុកចុះ។ តែចូលក្នុងទ្រុងហើយ សិង្ហនេះគ្មានអ្វីគួរឲ្យខ្លាចទៀតទេ, ដូចតែកូនចាបមួយប៉ុណ្ណោះ។

*(ទាំងអស់គ្នាចេញទៅ)*

# ឆាកទី២

*(ពេលយប់។ ដម្រុំវាលវង់។ អ្នកស្រីខៀវ សំណុល និងអ្នកឡាំណៃចូលមក)*

**អ្នកស្រីខៀវ សំណុល**

កន្លែងនេះហើយដែលខ្មោចឡើងគោកមករកមនុស្សរស់, កាលណាគេច្លងស្ទឹងផុតហើយ។ មានទៀនទេ, អ្នក?

**អ្នកឡាំណៃ**

ច្បាស់ជាអញ្ចឹងមែន, ហ្អាស់, បងសំណុល?

**អ្នកស្រីខៀវ សំណុល**

បើមិនច្បាស់ខំអស់អង្ករពាកំប៉ុងឲ្យយាយមេមត់នោះធ្វើអី? ខ្មោចនឹងមកឡើងគោកកន្លែងនេះ ពេលណាដែលផ្កាយចាប់ផ្ដើមរះ។ ប៉ុន្តែទាល់តែជឿ, បើមិនជឿខ្មោចមិនមកទេ។

**អ្នកឡាំណៃ**

ជឿហើយ, ខ្ញុំជឿហើយ, ខ្ញុំហ៊ានស្បថ។

កូនប្រុសទី២របស់អ្នកនៅជាប់នឹងយើង ស្លាប់ថ្ងៃនេះឯង, ឯនាងម្ដាយយំមិនចេញ។ គឺពេលនោះតែម្ដង ដែលឪពុកនាងស្លាប់ទៀត។

**អ្នកស្រីខៀវ សំណុល**

មួយថ្ងៃអស់មួយ! មួយថ្ងៃអស់បី! មួយថ្ងៃអស់ប្រាំ! ឲ្យតែយ៉ាងនេះគឺភ្លើងចេះកល្បហើយ!

**អ្នកឡាំណៃ**

មែន, ទាល់តែយូរទៅទើបខ្ញុំយល់។ វាបន្ថយរបបហូបយ៉ាងនេះមកពីវាចង់ឲ្យយើងងាប់ចាប់។

**អ្នកស្រីខៀវ សំណុល**

ចាំមើល, ខ្ញុំនឹងទៅសួរលោកមេកម្មាភិបាលធំឈ្មោះខៀវ សំផនថា៖ "មិត្ត, ធ្វើម៉េចឲ្យរស់បានដោយមិនចាំបាច់ហូប? ធ្វើការបានដោយមិនចាំបាច់មានកម្លាំង? សាបព្រួសដោយគ្មានគ្រាប់ពូជ? ធ្វើឲ្យប្រជាជនកើនចំនួន

ដោយគ្មានកូន? ជឿជាក់ដោយគ្មានសង្ឃឹម? អញ្ចឹងទៅឬ បដិវត្តន៍របស់មិត្ត? គឺធ្វើឲ្យ ប្រជាជនខ្មែរអកុសលទៅជាសត្វព្រលាត់ ដែលអស់អ្វីទៀតហៅថាមនុស្សបាន ក្រៅពីស្មារតីចងចាំ, មែនទេ?”

### អ្នកឡាំណោ

បងស្រីសម្លាញ់, មិនគួរណាបងមិនលើកស្លួយជីវិតខ្លួនឯងសោះ ដោយមិនទៅនៅជាមួយកូនដែលមានបុណ្យសក្ដិធំយ៉ាងនេះ។

### អ្នកស្រីខៀវ សំណុល

ឈប់និយាយយ៉ាងនេះទៀតណា, អ្នកឡាំណោ! កូនខ្ញុំ, ខ្ញុំភ្លេចវាបាត់ទៅហើយ បើនឹកឃើញម្ដងៗ គឺគ្រាន់តែដើម្បីប្រទិចផ្កាសាតែប៉ុណ្ណោះ។ ស្លាប់ទៅវិញល្អជាងដឹងថាមានកូនបែបនេះ។
កុំធ្វេសប្រហែសណា! មើលនាយមើលអាយ!

### អ្នកឡាំណោ

ចាស, ខ្ញុំមើលនាយមើលអាយ។
ចុះសម្ដេចសីហនុយើងនៅឯណា? ចាំអីទៀតមិនមកជួយយើង?

### អ្នកស្រីខៀវ សំណុល

ឮល្បៀងៗថាលោកនឹងយាងមកស្រុកវិញ ហើយកាន់អំណាចវិញនៅពេលចូលឆ្នាំ។

### អ្នកឡាំណោ

ចូលឆ្នាំ? បើអញ្ចឹងយើងមិនបានទាន់ទេ, ព្រោះឥឡូវខែតុលាទៅហើយ, ហើយតាមខ្ញុំមើលទៅ យើងមុខជាស្លាប់នៅខែវិច្ឆិកា, បើគ្មាននរណាមកជួយ។

### អ្នកស្រីខៀវ សំណុល

តុលាឯណា? ឥឡូវនេះចង់ដាច់ខែវិច្ឆិកាទៀតទៅហើយ!

### អ្នកឡាំណោ

កុំនិយាយអញ្ចឹង! បើថាអញ្ចឹង មានតែខ្ញុំបាត់ពេលវេលាអស់ទៅទៀត!

### អ្នកស្រីខៀវ សំណុល

គិតមែនទែនទៅ អញ្ចឹងក៏ល្អម្យ៉ាងដែរ, ព្រោះខែវិច្ឆិកាហើយ យើងនៅតែរស់នៅឡើយ។

### អ្នកឡាំណោ

មែន, តែគេប្រាប់ខ្ញុំថា ព្រះសីហនុចូលមករំដោះយើង ហើយគេចាប់គាត់ឃុំឃាំងក្នុងគុកទៅហើយ។

### អ្នកស្រីខៀវ សំណុល

គ្មានអញ្ចឹងទេ! លោកនឹងយាងមកវិញ, បើកវត្ត, បើកសាលាឡើងវិញ, ហើយលោកនឹងបញ្ជាខ្មែរក្រហមដើម្បីឲ្យយើងត្រឡប់ទៅផ្ទះវិញភ្លាម។ លោកមានបន្ទូលដូច្នេះឯង។ មាន៥ចំណុច។ គេប្រាប់ខ្ញុំថាដូច្នេះឯង។

### អ្នកឡាំណោ

អ្នកណាប្រាប់បង?

### អ្នកស្រីខៀវ សំណុល

ប្រធានភូមិ។ ក្រហមមែនតែកាលមុនបួសជាលោកសង្ឃ។

### អ្នកឡាំណោ

ប៉ុន្តែខ្ញុំវិញ, គាត់ប្រាប់ខ្ញុំថា៖ “មួយជីវិតនេះ អ្នកឯងគ្មានទៅណាទៀតទេ! គឺអង្គការសម្រេចយ៉ាងដូច្នេះ។”

### អ្នកស្រីខៀវ សំណុល

គាត់ថាអញ្ចឹង? ប៉ុន្តែអ្នកចំណូលថ្មីម្នាក់ប្រាប់ខ្ញុំថា លោកសក្តិ៤ គង់ ស៊ីលាស់ចូលព្រៃករទ័ពដើម្បីដេញខ្មែរក្រហមឲ្យអស់។

**អ្នកឡាំណោ**

គង់ស៊ីលាស់? លោកសក្ដិ៍៣ គង់ស៊ីលាស់? ទេ, គាត់ស្លាប់តាំងតែពី១៧មេសាម្ល៉េះ។ ខ្មែរក្រហមសម្លាប់គាត់, ព្រោះគាត់ស្រឡាញ់សម្ដេចពេក។

**អ្នកស្រីខៀវសំណុល**

បើលោកសក្ដិ៍៣ ខ្ញុំមិនហ៊ានថាទេ, តែបើលោកសក្ដិ៍៤ គឺច្បាស់ជានៅរស់។

**អ្នកឡាំណោ**

ពុគេថា! ពុគេថា! ពុគេថា! សព្វថ្ងៃលែងរស់នឹងបាយហើយ, គឺរស់នឹងពុគេថា។

**អ្នកស្រីខៀវសំណុល**

រស់សព្វថ្ងៃស្មើនឹងគោងក្បួនធ្វើពីចំបើងពុក, បណ្ដែតខ្លួនកុំឲ្យតែងាប់!

# ឆាកទី៣

*(ខេត្តសៀមរាប។ នៅតំបន់អង្គរ។ ព្រះសីហនុយាងមកជាមួយអ្នកម្នាង, សម្តេចប៉ែន នុត, លោកខៀវសំផន និងខ្មែរក្រហមមួយចំនួន)*

**ខៀវសំផន**

សូមព្រះអង្គស្តេចយាងឡើងដល់លើកំពែងដីនេះ។ ពីទីនេះគេអាចមើលឃើញការដ្ឋានជេរុងៗរហូតដាច់កន្ទុយភ្នែក។

**ព្រះសីហនុ**

ចាស, មានអី។ តាំងពីខ្ញុំមកវិញខ្ញុំសុខចិត្តធ្វើអ្វីគ្រប់បែបយ៉ាងដែលខ្ញុំមិនចូលចិត្ត។

**ខៀវសំផន**

ព្រះអង្គទតឃើញទេ, ពលកររាប់លាននាក់កំពុងជីកព្រែក, ញើសហូរលើមុខដោតជាំដោយមោទនភាព។

**ព្រះសីហនុ**

អញ្ចឹងមែនហើយ។ ដោតជាំ។

**ខៀវសំផន**

ប៉ុន្មានខែមុននេះសោះ ដែលគេបង្ខំឲ្យអ្នកទាំងនោះរស់ជាន់កគ្នានៅភ្នំពេញ ឬនៅក្រុងឯទៀត ដែលជាជម្រុំគុកអ្នកទោស។

**អ្នកម្នាង**

ជាន់កគ្នាក្នុងជម្រុំយ៉ាងម៉េច?

**ខៀវសំផន**

បងប្អូនយើងរាប់លាននាក់រស់ទាំងត្រដរអត់ឃ្លាន, ត្រូវគេធ្វើបាប។ គេបំបែកគ្រួសារឲ្យព្រាត់ប្រាសគ្នាអស់។ ស្រីៗ គេយកទៅធ្វើជាស្រីពេស្យា។ ឯក្មេងៗវិញ គឺគេចាប់យកម្តងៗរាប់ម៉ឺននាក់ទៅលក់ឲ្យពួកឈ្មួញទាសករអាមេរិកាំង។

**អ្នកម្នាង**

*(មានបន្ទូលទៅព្រះសីហនុ)*

ម៉េចគាត់និយាយផ្ដេសផ្ដាសដូច្នេះ?

**ព្រះសីហនុ**

ឱ, ព្រះម្ចាស់ថ្លៃអើយ!

**ខៀវ សំផន**

លុះមកដល់ថ្ងៃ១៧ មេសា ទើបសម័យកាលថ្មីមួយផុះឡើង, ប្រកបដោយសុភមង្គល, រុងរឿង, ថ្លៃថ្នូរ។ តែប៉ុន្មានខែក្រោយមកប៉ុណ្ណោះ ព្រះអង្គអាចទតឃើញទឹកមុខភ្លឺស្រស់ប៉ប្រិមនៃប្រជាជន។

**ព្រះសីហនុ**

*(មានបន្ទូលទៅសម្ដេចប៉ែន នុត)*

សម្ដេច, មានមើលឃើញឬអត់ ទឹកមុខភ្លឺថ្លាស្រស់ប៉ប្រិមនោះ?

**សម្ដេចប៉ែន នុត**

ឃើញ, ក្រាបទូល, ទូលបង្គំឃើញ។

**ខៀវ សំផន**

រាល់យប់, ពលករតែងនិយាយថា រាល់ថ្ងៃសុទ្ធសឹងជាថ្ងៃបុណ្យរីករាយ។ ក្នុងសង្គមចាស់, ជីវិតកំសត់លំបាកណាស់, ម្នាក់ៗធ្វើការដាច់ពីគ្នា ហើយមិនដែលជួបគ្នាទេ។ មិនស្គាល់ទេអ្វីទៅហៅថាសុភមង្គលនោះ។

**ព្រះសីហនុ**

ខ្ញុំចាំថាជ្រេងទៅវិញ។ ចុះសម្ដេចវិញយ៉ាងម៉េចដែរ?

**សម្ដេចប៉ែន នុត**

ក្រាបទូល, ការប្រឹងប្រែងឥតសំចៃកម្លាំងនៃប្រជាជនកម្ពុជាថ្មីនេះ ធ្វើឱ្យទូលបង្គំរំភើបកោតសរសើរក្រៃលែង។

*(យុគន្ធរចូលមក)*

**យុគន្ធរ**

ឱ, សម្ដេចឪ! ឪមកវិញហើយ, ហើយទូលបង្គំឃើញឪស្រស់ច្បាស់នឹងភ្នែក, ឃើញទាំងជើងនៅក្នុងស្បែកជើងរបស់ឪ, ជើងដែលឈរនៅលើដីដ៏កំសត់វេទនាជាច្រើនឆ្នាំ រហូតមកដល់៥នាទីមុននេះ។ អូ, ដៃ, នេះដៃសម្ដេចឪ, បាតដៃ, ម្រាមដៃ។ ច្បាស់ហើយ, គឺជាសម្ដេចឪមែនទែនហើយ។ បើអញ្ចឹងគឺពិតជាខ្ញុំហើយ, មិនមែននរណាផ្សេងទៀតទេ, គឺខ្ញុំ, យុគន្ធរដែលកំពុងឃើញសម្ដេចឪ។

ដោយសារសម្ដេចឪមិននៅ, រាប់ខែ, ពីមួយខែទៅមួយខែ, ពីខែមួយទៅខែមួយទៀត, កូននៅកំព្រាធ្វើការក្រោមថ្ងៃក្ដៅចាំងចែង។ ប៉ុន្តែកូនតែងស្រម័យគិតថា ពេលណាសម្ដេចឪជ្រាបរឿងនេះ? ពេលណានឹងសម្ដេចឪយាងត្រឡប់មកវិញតាមផ្លូវរទេះ, មានមែកឈើ មានបន្លាប្រជើងប្រជ៉ាង, តែឪមានមុខស្រស់ស្រទន់មូលដូចព្រះចន្ទ្រ, មកស្រោចស្រង់ពួកយើងដែលរស់!

**ព្រះសីហនុ**

កូនសម្លាញ់, ខាងឪឯណេះវិញក៏ដូចគ្នា, យើងទើបនឹងឃើញថា ការស្រម័យរបស់យើងក្លាយជាការពិត។ ដោយសារគុណអង្គការដែលមានឯកឧត្ដមនៅទីនេះជាសមាជិកមួយដ៏ខ្ពង់ខ្ពស់, ប្រទេសយើងទៅជាអ្នកជាវិញហើយ, ឯប្រជាជនបានជួបជុំគ្នាឡើងវិញ។ ឪគាំទ្រដោយពេញទំហឹងនូវនយោបាយនៃរដ្ឋាភិបាលនេះ ដែលឪខ្លួនឯងជាប្រមុខនៅទីខ្ពស់, ប្រហែលគ្នានឹងកូនទូកមួយដែលរលកធំៗ កំពុងធាក់ឡើងទៅលើយ៉ាងខ្ពស់ដែរ។ អ្នកទាំងអស់គ្នាវិញក៏មិនខុសពីឪ, គឺថាកំពុងតែរំភើបកោតសសើរអង្គការភ្នែកម្នាស់ ដែលគេធ្វើអ្វីនៅទីណាទិសណា, ក្រហែងណាឃើញទាំងអស់។

**យុគន្ធរ**

សម្ដេចឪ, ប៉ុន្តែ...

**អ្នកម្នាង**

សម្ដេចម៉ែឃើញថា កូនច្លាតមែន, កែវភ្នែកដ៏ភ្លឺថ្លារបស់កូនបង្ហាញថាកូនយល់អស់ហើយ, មែនទេ?

**យុគន្ធរ**

មែនហើយ, ខ្ញុំឃើញច្បាស់ចែស!

### ព្រះសីហនុ

អូ, ឆ្លាតណាស់កូនខ្ញុំ។ ឥឡូវនេះទៅចុះ, កូន, ត្រឡប់ទៅការដ្ឋានវិញដឹកព្រែកដ៏ល្អអស្ចារ្យនោះតទៅទៀត, ចិត្តពោរពេញដោយក្ដីសង្ឃឹម, ទឹកភ្នែកហូរដោយរំភើបសប្បាយ។

### យុគន្ធរ

បាទ, សម្ដេចឪ, កូនត្រឡប់ទៅវិញហើយ។

*(យុគន្ធរចេញទៅ)*

### ខៀវ សំផន

*(និយាយទៅអ្នកយាមម្នាក់)*

តាមឃ្លាំមើលកុមារនោះឲ្យមែនទែន។

ក្រាបទូល, បន្ទាប់ទៅនេះ យើងទៅទស្សនាអាងចិញ្ចឹមក្រពើ។

### ព្រះសីហនុ

កុំអី, ឯកឧត្ដម, កុំអី, ខ្ញុំធ្លាប់ឃើញហើយក្រពើ។

### ខៀវ សំផន

ធ្លាប់ឃើញ? ទេ, មិនដែលទេ។

### ព្រះសីហនុ

ឃើញ, ខ្ញុំធ្លាប់ឃើញហើយ។ ក្រពើនោះធំដូចត្រីបាឡែនអញ្ចឹង។

### សម្ដេចប៉ែន នុត

ទូលព្រះបង្គំសូមអង្វរឲ្យព្រះអង្គខំអត់ធ្មត់ឲ្យមែនទែន។

### ព្រះសីហនុ

ខ្ញុំពិបាកទ្រាំទៀតណាស់, តាំងពីដាក់ជើងឡើងជិះឡាន Mercedes ចង្រៃនេះ! ម្សិលមិញម្ដងទៅហើយ, ពេលជិះឡានកាត់បាត់ដំបង។ ថ្ងៃនេះសៀមរាប ធ្វើឲ្យខ្ញុំដល់កតែម្ដង។ ខ្ញុំចង់បញ្ចេញខ្យល់ចប់ស្ទះនៅក្នុងទ្រូងទាំង

ប៉ុន្មានឲ្យអស់ក្លាម ហើយទៅប៉ះកាំងវិញឲ្យរួចខ្លួន។ គិតសព្វៗទៅ, យើងមានខុសអីពីខ្មោច? សម្តេចមុខស្លេក ចម្លែកខុសធម្មតា, មិនមែនមនុស្សទេ ម្សិលមិញនេះ, ពេលដែលយើងជិះឡានតាមផ្លូវក្នុងក្រុងដែលរកមនុស្ស តែម្នាក់ក៏គ្មាន។ ពីមុនមកធ្លាប់តែអ៊ូអរច្រាត់ច្រែង។

**សម្តេចប៉ែន នុត**

អញ្ចឹងមែន, ក្រាបទូល។ គ្រាន់តែឮស្នូរជើងខ្មែរក្រហមដើរតាមផ្លូវធំស្ងាត់ជ្រងំដូចត្រូវបណ្តាសាទេវតានោះ, ទូលបង្គំ, បែកញើសស្រោកៗចង់ងងឹតមុខមួយរំពេច។ ប៉ុន្តែ...

**ព្រះសីហនុ**

វត្តទាំងឡាយរាបស្មើនឹងដី, វិហារឥស្លាមទៅជារោងជ្រូក, ឡានទៅសល់សែំបកនៅគរគ្នាកើតជាភ្នំ, មាស៊ីន ត្រជាក់ក៏ដូចគ្នា, ច្រេះស៊ីដូចដង្កូវចោះ។ គួរណាស់តែលក់ទៅស្រុកសៀមដែរ, យ៉ាំងហោចណាស់។ ប៉ុន្តែមិន ដូច្នេះទេ, មិនដូច្នេះទាល់តែសោះ! កូនចៅខ្ញុំវិញ គេប្រើឲ្យជីកដីមិនថាថ្ងៃមិនថាយប់, សមតែថាយមរាជទេ ដែលប្រើឲ្យជីកមហារណ្តៅមួយដើម្បីកប់កម្ពុជាទាំងមូលឲ្យលិចបាត់។ ឯខ្ញុំវិញកំពុងមគ្គុទេសក៍ជូនទស្សនា មហាផ្នូរនោះទៀតផង!

ខ្ញុំជាភ្ញៀវព្រះយមរាជ។ ទាំងអស់គ្នា មើលខ្ញុំស្គាល់តាំងពីចម្ងាយ។ គេកាប់ដីបណ្តើរ មើលមកសីហនុដែល កំពុងដើរកាត់បណ្តើរ, គេញញឹមមករកទៀតផង, ញញឹមពោរពេញដោយទុក្ខសោក។ ទេ! ខ្ញុំទ្រាំមើល ទស្សនីយភាពនេះមិនបានទៀតទេ! ខ្ញុំត្រូវតែលាលែងពីដំណែង, លាលែងយ៉ាងដាច់ឥឡូវនេះឯង!

**អ្នកម្នាង**

កុំទាន់ធ្វើក្លាម, ក្រាបទូល។ បើគេលែងទាញប្រយោជន៍អ្វីបានពីព្រះអង្គហើយ, គេនឹងមិនរារែកគួរសមអ្វីទៀត ឡើយ។

**សម្តេចប៉ែន នុត**

ព្រះករុណាថ្លៃវិសេស, សូមព្រះអង្គមេត្តាទប់ព្រះទ័យឲ្យនឹង។ យើងត្រូវនាំគ្នាធ្វើមុខស្ងប់, កុំឲ្យគេស្ទង់ចិត្តបាន។

## ព្រះសីហនុ

ចុះខ្ញុំមានប៉ែន នុតឯណា? ខ្ញុំមិនចេះយកថ្នាំមកលាបជាស្រទាប់ពណ៌បិតបាំងមុខកុំឲ្យគេដឹងថាយំដង្ហក់ទេ។ បើខ្ញុំមិនបង្ហាញឲ្យគេដឹងចិត្តខ្ញុំពិតប្រាកដទេ ខ្ញុំនឹងក្លាយជាស្វាក្រេះមួយតែប៉ុណ្ណោះ។ ខ្ញុំសំញ៉ែញញ្ចេញញធ្វើជាញញឹម។ ទេ! ខ្ញុំចង់ស្រែក! ខ្ញុំចង់យំ! ខ្ញុំចង់ក្លាយទៅជាមនុស្សពិតប្រាកដដូចមុនវិញ!

*(អ្នកម្នាងនិងសម្ដេចប៉ែន នុតនាំព្រះអង្គយាងចេញ)*

## ខៀវ សំផន

ប្រយត្ន័រើយ, សំណល់ក្រមរជំបៅផ្ដាច់ការ! បើឯងហ៊ានតែលាលែងពីដំណែងយ៉ាងរមិលគុណ ធ្វើឲ្យមុខមាត់ដ៏ថ្លៃថ្លារបស់យើងចុះអាប់អោន, យើងច្បាស់ជាមិនទុកឲ្យឯងបានសុខដោយសារដកខ្លួនទៅសម្ងំនៅសុខក្បែរក្បាន្តនោះទេ។ ឯងនឹងកណ្ដោចកណ្ដែងងាប់នៅក្នុងចំណោមខ្មោចក្រុមញាតិឯង, មិត្តភក្តិឯង, និងក្រុមបៃវាំងដែលស្រែកថ្ងូរមករកឯងយ៉ាងសង្វេគ។អស់លោក អុងមាង, ជា សាន, សារិន ចាក, នរោត្តមភូរិស្សរា, នរោត្តមនរទីបោ, ស៊ីសុវត្ថិមេថាវី, គោរក្បាលទាំងអស់គ្នា ហើយទៅបន់ស្រន់អង្វរករព្រះរបស់អស់លោកទៅ, ព្រោះសីហនុជាឪរបស់អស់លោក បោះបង់លោកចោលហើយ, ហើយត្រូវជាប់ទោសប្រហារជីវិត។

**ឆាកទី៤**

*(អ្នកម្នាងនិងព្រះសីហនុយាងមក)*

**ព្រះសីហនុ**

ញញឹមតែបន្តិចមកបងក៏មិនបានដែរ?

**អ្នកម្នាង**

ខ្ញុំម្ចាស់ធ្វើមិនកើត, ក្រាបទូល។ តាំងពីព្រះអង្គផ្សព្វផ្សាយពាក្យសុំលាលែងមក, ខ្ញុំម្ចាស់វិលវល់គិតអ្វីមិនចេញដែរ, ដោយសារខ្លាចអ្វីៗគ្រប់ យ៉ាង។

**ព្រះសីហនុ**

បងយល់ច្បាស់ថា ដែនដីនៅតែវិល, ហើយការលាលែងនោះគឺសមហេតុសមផល។ មួយឆ្នាំមកហើយដែលបងភូតភរគ្រប់ដង្ហើម។ ទេ, បងមិនបានដកដង្ហើមទៀតផង៖ បងភូត, បងភរ, បងកុហកទាំងស្រុង។ ពាក្យភរភូតនោះពណ៌ក្រហមឆ្អៅ, បើកមាត់និយាពេលណា, គេឃើញថាក្រហមពេញមាត់។

បើថាគួរឲ្យអាម៉ាស់មុខ ក៏មិនគ្រប់គ្រាន់ដែរ។ គឺថាដល់កុហកភូតភរយូរៗទៅ, ពាក្យភូតភរនោះទៅគរលើគ្នាកើតជាកំពែងមួយយ៉ាងខ្ពស់នៅពាត់ជុំវិញខ្លួនបង ទាល់តែងងឹតដូចនៅក្នុងនរកមិនឲ្យមើលការពិតឃើញ។ យល់ងងឹតថាភ្លឺ, យល់គុកថាសេរីភាព, យូរៗទៅភ្លេចថាអ្វីទៅជាពន្លឺ, អ្វីទៅជាការពិត។

បើតែរបៀបនេះតទៅទៀត គង់យល់រហោស្ថានស្ងាត់ជ្រងុំថាជាពិភពតន្ត្រីជាមិនខាន។

តាមពិត បើស្លាប់តែម្តងល្អជាងទ្រាំទ្ររឿងអាស្រូវទាំងប៉ុន្មាន ដោយសារមិនចង់ស្លាប់ខ្លួនឯង ហើយនឹងមិនចង់ឲ្យគេឯទៀតស្លាប់។

ចុះនាងវិញ, នាងយល់ថាបើបងមិនលាលែងទេ, អ្នកគាំទ្របងទាំងប៉ុន្មានអាចរួចខ្លួនពីខ្មែរក្រហមដែរ ឬយ៉ាងណា?

**អ្នកម្នាង**

ខ្ញុំម្ចាស់ជឿ, ក្រាបទូល។

**ព្រះសីហនុ**

ឯបងវិញលែងជឿហើយ។ ពេលណាខៀវ សំផនថា អ្នកនេះឬអ្នកនោះសុខសប្បាយជាទេ បងដឹងថាអ្នកនោះទើបនឹងស្លាប់។

*(លោកអុងមាងចូលមក)*

**អុងមាង**

*ព្រះករុណាថ្លៃវិសេស, សម្តេចប៉ែន នុត អញ្ជើញមកតែម្នាកឯងគត់!*

**ព្រះសីហនុ**

*តែម្នាក់ឯង! អញ្ជើញលោកឲ្យចូលមកភ្លាម!*

*(សម្តេចប៉ែន នុតចូលមក)*

*ឱ, សម្តេចជាត្រាណត្រើយ! សម្តេចជាទីពំនាក់! សម្តេចធ្វើម៉េចបានជាបញ្ចៀសពួកអស់នោះផុត?*

**សម្តេចប៉ែន នុត**

ទូលបង្គំមិនបានបញ្ចៀសទេ, ក្រាបទូល។ គឺគេអនុញ្ញាតិឲ្យទូលបង្គំជួបព្រះករុណាជាលើកក្រោយបង្អស់។

**អ្នកម្នាង**

*លើក ក្រោយបង្អស់ ? !*

**សម្តេចប៉ែន នុត**

ទេ, មិនមែនទេ, ទូលបង្គំចង់ទូលថា ជាការជួបក្រៅផ្លូវការ, មុននឹងអង្គការជាទីស្រឡាញ់សម្រេចចិត្តថាយ៉ាងម៉េចសិន អំពីការលាលែងពីដំណែងនោះ។

*សូមព្រះអង្គដូរព្រះទ័យវិញទៅ, ក្រាបទូល, កុំលាលែង។ អង្គការត្រូវការព្រះអង្គជាចាំបាច់ជាទីបំផុត, ព្រោះបើមិនដូច្នោះ...*

**ព្រះសីហនុ**

*សម្តេចយល់ថា បើមិនដូច្នោះនឹងមានទណ្ឌកម្ម?*

**អ្នកម្នាង**

ព្រះករុណាមានចិននៅការពារពីក្រោយ!

**សម្តេចប៉ែន នុត**

មានតែសពលោកតាដូ អេនឡាយប៉ុណ្ណោះ, ក្រាបទូល។ តែតាំងពីគាត់ទទួលអនិច្ចកម្មមក, គឺអស់ហើយ, គេនឹងចាប់ព្រះអង្គ។

**ព្រះសីហនុ**

គេប្រាប់សម្តេចឲ្យមកនិយាយបន្ទាចខ្ញុំ, មែនទេ?

**សម្តេចប៉ែន នុត**

គេសូមឲ្យទូលបង្គំធ្វើយ៉ាងណាឲ្យព្រះអង្គបោះបង់គម្រោងលាលែងនោះវិញ។ ប៉ុន្តែពេលនេះ គឺប៉ែន នុតខ្លួនឯងតែម្តងដែលអង្វរព្រះអង្គ។

**អ្នកម្នាង**

សម្តេចយល់ថា គេនឹងធ្វើតាមពាក្យគម្រាមរបស់គេ?

**សម្តេចប៉ែន នុត**

ទូលបង្គំជឿថាដូច្នោះឯង។

**ព្រះសីហនុ**

បើអញ្ចឹងខ្ញុំក៏ដូចគ្នាដែរ, ខ្ញុំនឹងធ្វើតាមពាក្យគម្រាមរបស់ខ្ញុំ។
គ្មានអ្វីបំបែកពាក្យលាលែងឲ្យបាត់ពីរូបខ្ញុំបានទេ។
ខ្ញុំក្លាហានឡើងវិញហើយ។ ខ្ញុំមិនលាក់លៀមទេ, សេចក្តីក្លាហាននេះក៏ធ្វើឲ្យខ្ញុំព្រួយបារម្ភដែរ។
ខ្ញុំខ្លាច, ព្រឺដល់ឆ្អឹងខ្នង, តែខ្ញុំត្រេកអរ។

**សម្តេចប៉េន នុត**

ព្រះករុណាថ្លៃវិសេស, ញាតិមិត្តអ្នកជិតស្និទ្ធទាំងអស់នឹងរងគ្រោះដោយសារសេចក្តីក្លាហាននោះ។

**ព្រះសីហនុ**

សម្តេច, សូមអាណិតខ្ញុំ, ជួយខ្ញុំឲ្យលាលែងផង។

**សម្តេចប៉េន នុត**

ឲ្យទូលបង្គំជួយយ៉ាងម៉េចកើត, ក្រាបទូល?

**ព្រះសីហនុ**

កុំដើរតាមផ្លូវខ្ញុំដើរ។ សូមសម្តេចនៅឲ្យស្ងៀមស្ងាត់ខាងខ្មែរក្រហមនោះទៅ។ ខ្ញុំមិនចង់ឲ្យនរណារងគ្រោះដោយសារខ្ញុំទេ។ បោះបង់ខ្ញុំចោលចុះ! ធ្វើដូច្នេះទើបសម្តេចរួចខ្លួនពីគេធ្វើបាប។

**សម្តេចប៉េន នុត**

ក្រាបទូល, ចុះប្រសិនបើ ទូលបង្គំ... ប្រសិនបើទូលបង្គំទូលព្រះអង្គថាសុខចិត្តនៅ... ជាមួយអង្គការ...ព្រះអង្គខ្វាល់នឹងទូលបង្គំទេ?

**ព្រះសីហនុ**

គ្មានខឹងសម្បារអ្វីទាំងអស់, ណាសម្តេច។ ខ្ញុំទៅវិញទេ ដែលសូមឲ្យសម្តេចធ្វើដូច្នោះទៅ។

**សម្តេចប៉េន នុត**

ក្រាបទូល, ម្សិលមិញនេះ ទូលបង្គំបានទទួលយកនាទីជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំមេបញ្ជាការខ្មែរក្រហម។ ព្រះអង្គអត់ទោសឲ្យទូលបង្គំបានទេ?

**ព្រះសីហនុ**

ម្សិលមិញ!

**អ្នកម្នាង**

ធ្វើនោះត្រូវហើយ, សម្ដេច! សម្ដេចមានករណីយកិច្ចការពារគ្រួសារព្រមទាំងអនាគតសម្ដេចក្នុងចាកនយោបាយដង។ ពីព្រោះ, បើទេព្ដាជួយយើង, គឺយើងនឹងរួចខ្លួនទាំងអស់គ្នា។ ពេលនោះព្រះករុណានឹងត្រូវការសម្ដេច, ដូចតែសព្វមួយដងដូច្នោះ។

**សម្ដេចប៉ែន នុត**

ព្រះករុណាថ្លៃវិសេស, ព្រះអង្គលើកលែងទោសទូលបង្គំទេ?

**ព្រះសីហនុ**

ម៉េចក៏និយាយតែរឿងអត់ទោស? ខ្ញុំមានតែការទុកចិត្តនិងការដឹងគុណប៉ុណ្ណោះទៅសម្ដេច។ សម្ដេចធ្វើនោះត្រូវហើយ។ បើខ្ញុំអាចធ្វើបាន, ខ្ញុំក៏ជ្រើសរើសផ្លូវដើររបៀបប្រយត្ន័ប្រយែងនោះដែរ។ ប៉ុន្តែខ្ញុំគ្មានសេចក្តីក្លាហាននឹងធ្វើ។ ប៉ុន្តែ, ទេ ខ្ញុំមាន, ខ្ញុំមានអំនួត។ ហើយអំនួតក្រអឺតនេះ ធ្វើឲ្យខ្ញុំក្លាហាន។ ឯសម្ដេចវិញ, គឺការដាក់ខ្លួនស្រគត់ស្រគំ, ដែលជាគុណសម្បត្តិដ៏ប្រពៃ។

**សម្ដេចប៉ែន នុត**

ព្រះអង្គយល់ដូចមានព្រះបន្ទូលមែនឬ?

**ព្រះសីហនុ**

ខ្ញុំហ៊ានស្បថ។ ហើយសូមកុំយំដូច្នេះ។

**សម្ដេចប៉ែន នុត**

ព្រះករុណាថ្លៃវិសេស, ទូលបង្គំត្រូវថ្វាយបង្គំលាទៅវិញហើយ។ បើនៅស្ដាប់បន្ទូលព្រះអង្គ, មុខព្រះភក្ត្រដ៏ថ្លៃថ្លារបស់ព្រះអង្គតទៅទៀត, ទូលបង្គំមិនអាចបកក្រោយវិញ, ឆ្លងទឹកត្រឡប់ទៅខាងត្រើយខ្មែរក្រហមបានទៀតទេ។

**ព្រះសីហនុ**

អញ្ជើញទៅចុះ, អញ្ជើញទៅ, សម្ដេចជាទីគោរព។

**អ្នកម្នាង**

សម្ដេច, ពេលណាទៀតទើបយើងអាចឃើញសម្ដេចទៀត?

**សម្ដេចប៉ែន នុត**

ក្រាបទូល, ទូលបង្គំលែងមានឱកាសដ៏ប្រពៃមកគាល់ទៀតហើយ។

**ព្រះសីហនុ**

យ៉ាងម៉េច, ខ្ញុំនឹងលែងបានជួបប៉ែន នុតជាទីស្រឡាញ់ទៀតហើយ?

**សម្ដេចប៉ែន នុត**

មានតែ "អ្នកមិនខ្វល់ខ្វាយ" ប៉ុណ្ណោះដែលគេនឹងអនុញ្ញាតិឲ្យមកជិតព្រះអង្គ, គឺថាពួកស្នងការខ្មែរក្រហម។

**ព្រះសីហនុ**

មានតែកម្មាភិបាលប៉ុណ្ណោះដែលជួបសីហនុ?

**អ្នកម្នាង**

ចុះក្រែងសម្ដេចជាទីប្រឹក្សាជាន់ខ្ពស់??

**សម្ដេចប៉ែន នុត**

គ្មាននរណាជឿថាទូលបង្គំជាអ្នក "មិខ្វល់ខ្វាយ" ទេ។

**ព្រះសីហនុ**

បើអញ្ចឹង, តែទូរសព្ទក៏មិនបានដែរ, មែនទេ?

**សម្ដេចប៉ែន នុត**

គ្មានការទាក់ទងគ្នាទេ, ក្រាបទូល។

**ព្រះសីហនុ**

អញ្ចឹង? បើដូច្នោះ យើងទាក់ទងគ្នាតាមមេឃតាមផ្កាយ, បើខ្ញុំអស់ជីនៅ, ក៏គង់នៅសល់មេឃដែរ។ សម្តេចនិងខ្ញុំ, យើងនឹងជួបគ្នារាល់យប់, ពេលដែលផ្កាយទីមួយចាប់រះភ្លាម។ កុំខកខានឲ្យសោះ, ណាសម្តេច! ខ្ញុំនឹងផ្ញើសាររៀបរាប់ពីចិត្តខ្ញុំតាមអាកាសមេឃា, ចេញពីគុកខ្ញុំនេះ។

**សម្តេចប៉ែន នុត**

ក្រាបទូល, ទូលបង្គំនឹងមិនខកខានយប់ណាមួយទេ។

**ព្រះសីហនុ**

បើអញ្ចឹង, សូមលាហើយ, មិត្តដ៏ស្មោះស្ម័គ្រ។ ទេពនិករទាំងឡាយជាអ្នកនាំសារយើងទៅវិញទៅមក។ អង្គការចង់ធ្វើយ៉ាងម៉េចក៏មិនអាចផ្តាច់ប៉ែន នុតពីសីហនុដែរ។

*(ទាំងអស់គ្នាយាងនិងចេញទៅ)*

# ឈុតទី៥

## ធាកទី១

*(ពេលយប់។ ជម្រុំវាលវង់។ អ្នកស្រីខៀវ សំណុល និងអ្នកឡាំណេចូលមក)*

**អ្នកឡាំណេ**

បើអញ្ចឹង, ឥឡូវនេះបងឯងសូត្រឲ្យត្រឹមត្រូវមក, ហ្នា!, ព្រោះពេលប្រជុំអប់រំនយោបាយនេះ, បងឯងមិនអាចធ្វើដូចអាទិត្យមុនបានទេ។ បើមេរៀនតែមួយក៏មិនចាំដែរ, កម្មាភិបាលមានពុកមាត់នោះនឹងបញ្ជូនបងឯងឲ្យទៅព្រៃ។ ពេលនោះខ្ញុំក៏ត្រូវតែទៅតាម, ហើយកង់ប្រវត្តិសាស្ត្រនឹងកិនយើងសំប៉ែតដូចដែនស្វាយអញ្ចឹង។, គ្មានថ្នឹងថ្នែងណាមួយដែលថាមិនខ្ទេចទេ។

នែបងស្រីសម្លាញ់, ដឹងហើយថាបងហត់ហេវអស់កម្លាំងកាយកម្លាំងចិត្ត, តែត្រូវខំឲ្យខ្លាំងជាងនេះ, ព្រោះខ្ញុំមិនស្រឡាញ់ទេរឿងស្លាប់, ស្រឡាញ់តែរឿងរស់។

ហ! ឥឡូវនេះ យើងចាប់ផ្ដើមអំពីចិន, រួចទៅសឹមតទៅយួន, ណាបង! សុខចិត្តទេ?

**អ្នកស្រីខៀវ សំណុល**

សុខ! មិនត្រឹមតែសុខចិត្តទេ, គឺសុខចិត្តយ៉ាងដាច់ណាត់, ដូចមិត្តប៉ុល ពតថា "ដាច់ខាត", មិនអញ្ចឹង?

**អ្នកឡាំណេ**

ដាច់ខាតថាអញ្ចឹង!

**អ្នកស្រីខៀវ សំណុល**

ឥឡូវចាប់ផ្ដើមមក, អ្នកឡាំណេឯងសួរខ្ញុំមក, អំពីរឿងចិន។

**អ្នកឡាំណេ**

យើងឈ្នះនរណាដាច់ថ្វាយ?

### អ្នកស្រីខៀវ សំណុល

ចិនកោតសរសើរយើងណាស់, ព្រោះយើងឈ្នះចិនដាច់ឆ្ងាយ។ ចិនទិញម៉ាស៊ីនដេរឲ្យប្រពន្ធរបស់គេ, ព្រោះគេជាប់ជំពាក់វាក់វីននឹងគ្រួសារ, នឹងការរស់នៅស្រួល, នឹងចិត្តអាឡោះអាល័យគ្មានថ្លៃថ្នូរអ្វីសោះ។
ឯយើងវិញ, យើងកំចាត់ចោលបានអស់ហើយ, ចិត្តជំពាក់នឹងគ្រួសារនោះ។ គ្រួសារយើងឥឡូវគឺអង្គការ។
ឯការរស់នៅស្រួល, គឺយើងធ្វើការដោយហត្ថាទាំងទ្វេ ដើម្បីបដិវត្តយើង។

### អ្នកឡាំណេ

ខំនិយាយឲ្យត្រូវ, ខំបន្តិចមក, ហត្ថាទាំងទ្វេដើម្បីមហាបដិវត្តដ៏ធំធេងរបស់យើង។

### អ្នកស្រីខៀវ សំណុល

មហាបដិវត្តធំធេង ព្រមទាំងអង្គការជាទីស្រឡាញ់ដែលជាម្ចាស់លើកូនយើង, ជាម្ចាស់លើស្វាបព្រាបាយយើង, ឮទេ, ដែលខ្ញុំថានេះ?

### អ្នកឡាំណេ

កូនយើងនិងស្វាបព្រាបាយយើង។
យើងឈ្នះចិនដាច់, ដាច់ណាត់, ដាច់ខាត។ ចិនខំយកតម្រាប់តាមយើង។ ធ្វើបានទេ, មើលទៅ?

### អ្នកស្រីខៀវ សំណុល

ដាច់ខាតជាមិនកើត។ អ្នកឮភ្លេងនោះទេ?

### អ្នកឡាំណេ

ភ្លេងអី? ខ្ញុំឮតែខ្លែងស្រាកស្រែកនៅលើមេឃឈើថា ប៉ុល ពត។។ ព្រោះសព្វថ្ងៃនេះ អ្វីៗសុទ្ធតែនយោបាយទាំងអស់, ញើសសំបោរក៏ជានយោបាយដែរ។ នែបងស្រី, ឥឡូវនេះបងសូត្ររឿងយួនមក។ ហ! អ្វីទៅកាតព្វកិច្ចយើង?

### អ្នកស្រីខៀវ សំណុល

កាតព្វកិច្ចយើងគឺត្រូវស្អប់ពួកយួនឈ្លានពានឲ្យអស់ពីពោះពីពុង, ហើយត្រូវពុះកញ្ជ្រោលដោយកំហឹងខ្លាំងក្លាក្លាម កាលណាឮពាក្យថាយួននោះ។ ឯខ្ញុំវិញ, ចិត្តថ្លើមខ្ញុំពិតប្រាកដវិញ, កំពុងពុះកញ្ជ្រោលច្រងេងច្រងាងដោយសារនិយាយពាក្យផ្ដេសផ្ដាសនេះ។

### អ្នកឡាំណៃ

ទាំងបងទាំងខ្ញុំ, យើងមុខជាខ្សោយបេះដូងស្លាប់ដោយសារចិត្តយើងខ្សោយនេះ។

តទៅទៀត, យើងត្រូវបញ្ចប់រឿងយួន៖ "យើងមានកាតព្វកិច្ចនឹងបង្រៀនឲ្យកូនចៅយើងស្អប់យួន។ ត្រូវតែសម្លាប់ពួកវា"។

### អ្នកស្រីខៀវ សំណុល

យើងម្នាក់ៗត្រូវតែសម្លាប់យួនឲ្យបាន១០ក្បាល, ហើយត្រូវបង្រៀនកូនចៅឲ្យធ្វើដូច្នេះតទៅទៀត។ ដាច់ខាតត្រូវតែធ្វើ។

### អ្នកឡាំណៃ

ឥឡូវនេះ រឿងគោម្ដង៖ "ឃើញគោនោះទេ?"

### អ្នកស្រីខៀវ សំណុល

ឃើញគោដែលកំពុងអូសនង្គ័លនោះទេ? វាគិតតែពីអូស, គ្មានគិតទៅញី ឬទៅកូនវាទេ។ គោមិនដែលប្រកែកមិនធ្វើការឡើយ។ ធ្វើការតាមបញ្ជាអង្គការដូចខ្ញាក់ ហើយមិនដែរត្អូញត្អែអ្វីសោះ។ គេចងវាកន្លែងណា វាស៊ីស្មៅកន្លែងនោះ។

ត្រូវយកតម្រាប់តាមគោ។ ខ្ញុំជាគោ...

រសជាតិសាច់ជ្រូក, ជួយរំលឹកខ្ញុំផងព្រោះខ្ញុំភ្លេចរសជាតិនោះហើយ។

### អ្នកឡាំណៃ

រសជាតិសាច់ជ្រូក? នែ, បងសំណុល, ឥឡូវសូត្រ *ជយោ* ទាំង៧មក ហើយយើងបញ្ចប់ត្រឹមនេះ។ គ្មានពិបាកអីទេ។

### អ្នកស្រីខៀវ សំណុល

*គ្មានពិបាកអីទេ, តែថ្ងៃនេះខ្ញុំធ្វើមិនកើត, ព្រោះបបូរមាត់ខ្ញុំវាលែងព្រមកម្រើក។ ឯក្បាលខ្ញុំវិញ ប្រៀបដូចជាខ្ទមដែលគេបោះបង់ចោលមួយ ហើយដែលក្នុងនោះមានក្មេងស្រីម្នាក់អង្គុយចោងហោងស្រែកថា, ម៉ែ, ម៉ែ, ម៉ែ។*

### អ្នកឡាំណៃ

*បើអញ្ចឹងគឺបងស្រីគ្រុនហើយ។ ឥឡូវខ្ញុំសូត្រឲ្យស្តាប់, ជយោ ទាំង៧នោះ, រួចហើយយើងចូលដេក។*

*ជយោ អង្គការដ៏ត្រឹមត្រូវនិងដ៏ភ្លឺស្វាង!*

*ជយោ មហាបដិវត្តកម្ពុជា!*

*ជយោ ប្រជាជនកម្ពុជាដ៏ធំធេង!*

*ជយោ កម្ពុជាប្រជាធិបតេយ្យដ៏រុងរឿង!*

*ជយោ កងទ័ពបដិវត្តដ៏អង់អាចខ្លាំងក្លា*

*ជយោ លទ្ធិម៉ាក-ឡេនីន*

### អ្នកស្រីខៀវ សំណុល

*តិចៗ! ឮសូរអីដូចជាភ្លេងនេះ?*

*ឱ, ម្ចាស់ថ្លៃ! សម្លេងត្រដោកគោអូនឯងសោះ! មែន, កុំប្រកាន់បង, អប់រំនយោបាយនោះ វាធ្វើឲ្យវង្វេងវង្វាន់អស់។*

### អ្នកឡាំណៃ

*បងស្រីមិនស្តាប់ខ្ញុំទេ ឬយ៉ាងម៉េច?*

### អ្នកស្រីខៀវ សំណុល

*អូ, អូនស្រី, កុំប្រកាន់បងអំពីរឿង ជយោ ទាំង៧។ ពួកខ្មោចស្លាប់កំពុងអន្ទងហៅបង, ហើយបងត្រូវតែទៅ, ទៅឥឡូវនេះឯង! កុំប្រកាន់, បងមិនបានប្រាប់ឲ្យដឹងមុន, មិនបានឲ្យអ្នកឡាំណៃដឹងផង មិនឲ្យខ្លួនឯងដឹងមុនផង, ព្រោះទើបនឹងឮគេអន្ទងហៅអម្បាញ់មិញនេះតែម្តង។*

**អ្នកឡាំណោ**

*ទេ, ទេកុំធ្វើដូច្នោះ, កុំទៅ! មិនកើតទេ! ទេ, កុំទៅណា, នៅឯណោះហើយ! ឈប់សិន, ឈប់សិន! យុគន្ធរ! កុំទៅណាចោលខ្ញុំ, ខ្ញុំសុំអង្វរ។ ចាំថ្ងៃណាផ្សេងទៀតទៅ! ចាំខ្ញុំមើលបងស្រីឲ្យជា, ខ្ញុំមើលព្យាបាលឲ្យជា! ទេ, ព្រះជាម្ចាស់!*

*(យុគន្ធរចូលមក)*

**យុគន្ធរ**

*កើតអីហ្នឹង?*

**អ្នកឡាំណោ**

*កូនអើយ, គាត់ទៅហើយ, គាត់ទៅហើយ។*

**អ្នកស្រីខៀវ សំណុល**

*ឱ, អូនស្រីបង, អូនមិនដឹងថា មានមនុស្សខ្ពង់ខ្ពស់ដែលស្លាប់ជាច្រើនដែលកំពុងចាំបង! មានព្រះករុណាហ្លួងម៉ែ, មានអ្នកស្រីមុំសាវៃទៀត។*

*យីខ្ញុំទទួលកិត្តិយសខ្ពង់ខ្ពស់ណាស់។*

*មានលោកប្រុសម្នាក់នោះ, ខ្ញុំមើលមិនស្គាល់ទេ, ក្អែកខ្ញុំ, ជួយមើលប្រាប់ខ្ញុំផង...*

**អ្នកឡាំណោ**

*លោកម្នាក់?*

**អ្នកស្រីខៀវ សំណុល**

*ឈប់សិន! អូ, លោកហ៊ូ យន់ទេតើ!*

**អ្នកឡាំណោ**

*លោកហ៊ូ យន់!! យ៉ាងម៉េច? បើអញ្ចឹង, បើលោកហ៊ូ យន់ គឺទៅជាមួយ, បើឡាំណោវិញគឺមិនឲ្យទៅជិតទេ! យី, អយុត្តិធម៌អ្វីដល់ម្ល៉េះ, ម្ចាស់ថ្លៃ!*

### អ្នកស្រីខៀវ សំណុល

អូនសម្លាញ់បង, អូនស្មានថាបងទៅចោល, មិនមែនទេ! នៅត្រើយម្ខាងនោះបងគិតមកអូនជានិច្ច, ជានិច្ច, រហូតដល់ពេលដែលបងនឹងត្រឡប់មកយកអូនទៅជាមួយ។ ពុទ្ធោអរហំ!

### អ្នកឡាំណោ

ពុទ្ធោអរហំ! ទេ, កុំទៅ, បណ្តូលចិត្តអូន, កុំឲ្យអូននៅម្នាក់ឯងកណ្តោចកណ្តែងគ្មានសង្ឃឹមអ្វីសោះយ៉ាងនេះ!

### យុគន្ធរ

ស្ងាត់បន្តិច, លោកយាយ!

### អ្នកស្រីខៀវ សំណុល

ស្ងាត់បន្តិច, អូនឡាំណោ, ប្រយ័ត្នកម្មាភិបាលពុកមាត់នោះវាឮ។ ហ្ន! ឃើញទេ, វាមកហើយ, ដើរតាមផ្លូវលំមក។ ណ្ហើយចុះអ្នកទាំងពីរ, ខ្ញុំត្រូវតែទៅឥឡូវនេះឯង។ កុំយាត់, កុំយាត់ខ្ញុំអី... កាន់ដៃបងមក, កាន់ដៃយាយមក ហើយកុំនិយាយអ្វីទាំងអស់, នៅឲ្យស្ងៀម, ខ្ញុំស្រឡាញ់អ្នកទាំងពីរគ្មានអ្វីប្រៀប។ ពុទ្ធោអរហំ! ស្ងាត់, ...

### អ្នកឡាំណោ

បងសំណុល! យកខ្ញុំទៅផង! ជួយផង! ខ្ញុំរស់នៅវេទនាក្នុងនរកប៉ុល ពតនេះមិនកើតទេ! គាត់ទៅបាត់ហើយ, បងស្រីបណ្តូលចិត្តខ្ញុំ! គាត់ត្រឡប់ទៅស្ថានសុខហើយ!

### យុគន្ធរ

កុំស្រែកខ្លាំង, លោកយាយ, កុំមាត់ឲ្យគេឮ!

*(កម្មាភិបាលចូលមក)*

### កម្មាភិបាល

ស្អីទៀតហើយ! ថ្ងង់គេថ្ងង់ឯងទាំងយប់អាធ្រាត្រ! យីមិត្តឯងហ្នឹងទៀតហើយ, មិត្តមេខ្មោច! រាល់ពេលគឺមិត្តឯងហ្នឹងតែម្តង...

**អ្នកឡាំណេ**

*ឱមិត្តជាទីគោរព! គឺបងស្រីខ្ញុំ! បងខ្ញុំទើបនឹងចាកចេញពីខ្ញុំអម្បាញ់មិញនេះ។ ទុកពេល៥នាទីឲ្យខ្ញុំយំសិន, ខ្ញុំសូមអង្វរ, ទុកឲ្យខ្ញុំយំស្តាយស្រណោះបងស្រីខ្ញុំផង!*

**កម្មាភិបាល**

*យំ! យំ! គ្មានចេះអីក្រៅពីយំទេ!*

*បានហើយ, ប៉ុណ្ណឹងហើយមិត្ត។ ស្អែកយើងយកទៅកប់។*

*ឥឡូវ, ទៅសម្រាកទៅ! តែប៉ុណ្ណោះបានជីវលេខ២ថែមទៀតហើយ។*

**អ្នកឡាំណេ**

*កុំប៉ះបងខ្ញុំ! ជួយផង, ជួយផង!*

*(លោកហ៊ូ យន់ចូលមក)*

**យុគន្ធរ**

*មិត្ត! គាត់ជាជីដូនខ្ញុំ។*

**កម្មាភិបាល**

*នែ, មកជិតអញបន្តិច។ ឯងចង់ឲ្យអញបិទមាត់យាយឯងទេ?*

**យុគន្ធរ**

*ខ្ញុំសូមអង្វរ!*

**ហ៊ូ យន់**

*មិត្ត, កុំប៉ះពាល់យាយឲ្យសោះ។*

**កម្មាភិបាល**

*ស្អី? ថាម៉េច? អ្នកណានិយាយហ្នឹង?*

**ហ៊ូ យន់**

*(ចាប់កម្មាភិបាលពីក្រោយដាប់)*

*ហ៊ូ យន់! ឧត្តមសេនីយ៍ហ៊ូ យន់!*

ចាំអីទៀត, យុគន្ធរ! លឿនឡើង, ពូចាប់វាជាប់ហើយ, លឿនឡើង, ព្រលះវាឲ្យតាយហោងទៅ!

**យុគន្ធរ**

*(ចាក់កម្មាភិបាលម្នាក់ទៅបិត)*

អើ, ងាប់ទៅមិត្ត, ងាប់ទៅ, អាងាប់!

**អ្នកទ្បាំណោ**

សម្លាប់វាទៅ! សម្លាប់វាទៅ!

**ហ៊ួ យន់**

ងាប់ទៅប៉ុល ពត! ងាប់ទៅអៀង សារី! ងាប់ទៅខៀវ សំផន!

អូ, សូមស្មាលាទោស

**អ្នកទ្បាំណោ**

ទេ, អញ្ជឹងហើយ។

**យុគន្ធរ**

វាស្លាប់ហើយ? ខ្ញុំសម្លាប់វា, មែនទេ?

**ហ៊ួ យន់**

ក្មួយឯងតែម្តងដែលសម្លាប់វា។

**យុគន្ធរ**

ខ្ញុំ? ខ្ញុំសម្លាប់ខ្មែរក្រហមម្នាក់? មែន ឬមិនមែន? ឱ, ព្រះជាម្ចាស់! គិតទៅ, ពីមុនមកខ្ញុំចង់ធ្វើម៉េចឲ្យបានសម្លាប់អាមេរិកាំងម្នាក់!

ឥឡូវខ្ញុំសម្លាប់ខ្មែរក្រហម, ដឹងទេលោកយាយ?

**អ្នកឡាំណោ**

គិតធ្វើម៉េចអញ្ចេះ, ម្ចាស់ថ្លៃ!

**ហ៊ូ យន់**

ចាំខ្ញុំយកវាទៅ, មីងឡាំណោ, កុំព្រួយ។ ខ្ញុំទុកតែខ្មោចមីងសំណុលចុះ ឲ្យនៅជាមួយមីង។ ពេលណាបន់ព្រះម្ដងៗ, សូមមីងគិតឧទ្ទិសពាក្យពេចន៍មកដល់ហ៊ូ យន់ផង។

**យុគន្ធរ**

លោកពូហ៊ូ យន់, ខ្ញុំអរគុណពូខ្លាំងណាស់អម្បាញ់មិញ។ នេះជាកិត្តិយសដែលខ្ញុំទទួលដោយរីករាយ។

**ហ៊ូ យន់**

ពូទេ ដែលត្រូវអរគុណឯង, ចំពោះជំនូនដែលឯងបានឲ្យពូនេះ។ ក្មួយដឹងទេ, អ្នកស្លាប់ដូចជាពូនេះ, មានតែចំណង់ចិត្តប៉ុណ្ណោះ, តែគ្មានកម្លាំងធ្វើអ្វីកើត។

*(គាត់ចេញទៅដោយយកសពខ្មែរក្រហមទៅជាមួយ)*

**អ្នកឡាំណោ**

ខ្ញុំអង្គុយចោងហោងម្នាក់ឯង, កណ្ដោចកណ្ដែងចិត្តរកថាមិនត្រូវ។ ខ្យល់កំណាចមួយត្រជាក់ដូចទឹកកក បក់បោកមកលើស្រុកខ្មែរ។ សូម្បីតែខ្មោចក៏រត់គេចពីធាតុអាកាសកំណាចនេះដែរ។ ខ្ញុំនិយាយអង្វរសូមឲ្យបងស្រីបណ្ដូលចិត្តខ្ញុំត្រឡប់មកវិញ, តែមិនដឹងជាគាត់ឮឬមិនឮ!
គួរអនិច្ចាណាស់, វៀតណាម, កម្ពុជា។
ឮតែរឿងស្លាប់, ឃើញតែយប់ដែលងងឹតកាន់តែយូរទៅៗ ! អណ្ដែតត្រសែតខ្ពស់ទៅៗ, សង្ឃឹមថានឹងឃើញពន្លឺថ្ងៃម្ដេចបាន?

*(អ្នកឡាំណោនិងយុគន្ធរចេញទៅ)*

# ឆាកទី២

*(ភ្នំពេញ, ព្រះរាជវាំង។ ព្រះមហាក្សត្រីយានីយាងមក)*

**ព្រះមហាក្សត្រីយានី**

បីឆ្នាំកន្លងផុតទៅ! ក្នុងពេលបីឆ្នាំនោះ គ្មានអ្វីសោះដែលកើតឡើងនៅប្រទេសកម្ពុជា ក្រៅពីរឿងស្លាប់។

កម្ពុជាស្លាប់នៅទីនេះឯង, ស្លាប់, ស្លាប់មិនចប់។

យើងដួលដេក, ដួលដេក, ក្បាលដាំដូងចុះទៅដី។

មានធ្វើអ្វីទៀតកើត, ក្រៅពីក្បាលនោះស្រែកហើយស្រែកទៀត, ស្រែកឲ្យពិភពលោកដែលយកដៃចុកត្រចៀកខ្លួនឯងនោះឮ,

ឲ្យឮកម្ពុជាស្រែកដង្ហោយហៅ។

ប៉ុន្តែគ្មាននរណាមកទេ ក្នុងគ្រាក្របែបនេះ

មិត្តធ្លាប់ជិតដិតតែម្នាក់ក៏គ្មានដែរ។

ក្នុងមួយរយៈនេះ, កូនខ្ញុំនៅឯណា?

នៅជាប់ឃុំឃាំង៣០ខែហើយជាមួយព្រះជាយា។

កូនខ្ញុំស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិក,

ស្តាប់សម្លេងប៉ុល ពត,

កូនមានសង្ឃឹម, កូនអស់សង្ឃឹម។

វិទ្យុផ្សាយប្រកាសថា សីហនុស្លាប់ហើយ, ថាសីហនុថ្លង់, សីហនុឆ្កួត, កំពុងសរសេរប្រវត្តិខ្លួនឯង។

កូនភ័យខ្លាចមិនលោះថ្ងៃឡើយ,

រាល់ល្ងាច, កូនអើតតាមបង្អួចមើលបក្សីទាំងហ្វូងដែលហើរទៅឆ្ងាយពីភ្នំពេញដោយស្រែកកោកកាកផង។

*(ព្រះអង្គយាងចេញ។ ព្រះសីហនុយាងចូលមក)*

**ព្រះសីហនុ**

នែបក្សី! នែសត្វស្លាប! Bird! Oiseau!

ហើរឲ្យលឿនជាងនេះទៅ! ឲ្យខ្ពស់ជាងនេះ! ប្រយ័ត្នពួកប៉ុល ពត! ខ្ពស់ជាងនេះទៀត! ខ្ពស់ទៀត!

ស្ងាត់! កណ្តុរ! កណ្តុរ! ឱកូនកណ្តុរខ្ញុំ! មកនេះមក ពួកអស់ឯងទាំងប៉ុន្មាន! មក, អឺ, ល្អណាស់!

*ឱព្រះគុណម្ចាស់! ព្រះទ័យល្អណាស់ដែលទុកកណ្តុរឲ្យនៅជាមួយទូលព្រះបង្គំ។*

*(អ្នកម្នាងយាងចូលមក)*

*មកនាង, មកមើលក្រុមគ្រួសារតូចច្រឡឹងនេះ, ប្រហែលនៅមានទៀត!*

**អ្នកម្នាង**

*ប្រជាជនយើងគ្មានបង្កើតកូនចៅទៀតទេ។ គ្មានទារកខ្មែរណាមួយកើតទៀតសោះ។ ម្ចាស់ថ្លៃអើយ, ព្រះអង្គដែលបង្កើតលោក, ឥឡូវនេះ សត្វលោកដែលព្រះអង្គបង្កើត ឃើញនៅសល់តែកូនកណ្តុរប៉ុណ្ណោះ!*

**ព្រះសីហនុ**

*ខ្ញុំនឹកកូនខ្ញុំណាស់, ខ្ញុំចង់ឃើញកូនខ្ញុំទាំងអស់, លោកឈន ហៃ! ឮទេ លោកឈន ហៃ!*

*(លោកឈន ហៃចូលមក)*

*មានរឿងអីកើតឡើង? បីអាទិត្យហើយដែលខ្ញុំប្រគល់សំបុត្រឲ្យលោកប្រគល់ឲ្យលោកខៀវ សំផន, លោកបានប្រគល់ទៅទេ?*

**ឈន ហៃ**

*ទូលបង្គំបានប្រគល់ព្រះចុកហ្មាយនោះទៅលោកប្រធានគណប្រធានរដ្ឋថ្ងៃនោះឯងតែម្តង, ក្រាបទូល។ ច្បាស់ជាលោកនឹងមកគាល់ព្រះអង្គពេលណាមួយហើយ។*

**ព្រះសីហនុ**

*ខ្ញុំមិនចង់ជួបលោកខៀវ សំផនទេ!*

*ខ្ញុំចង់ជួបកូនខ្ញុំ, កូនសម្លាញ់ខ្ញុំទាំងប៉ុន្មាន!*

*ពីរឆ្នាំមកហើយដែលខ្ញុំឃើញតែជីពាក់, ឃើញតែពស់, តុកកែ, មូស, កណ្តុរ!*

*យី, ជ្រុលពេកហើយ។ ក្នុងឱកាសខួបកំណើតខ្ញុំ, ហើយតែក្នុងថ្ងៃនោះប៉ុណ្ណោះឯងដែលខ្ញុំសូមអនុញ្ញាតជួបកូន, ជួបចៅ, ជួបអ្នកជិតដិត ដែលសព្វថ្ងៃនេះ គេបញ្ជូនបែកខ្ញែកទៅសហករណ៍ដ៏ធំធេងនិង ដ៏ត្រចះត្រចង់នានានៅជនបទ។ ខ្ញុំចង់ជួបកូនដូចតទៅ នេះ៖*

- *អ្នកអង្គម្ចាស់នរទីបោ*
- *អ្នកអង្គម្ចាស់ខេមានុរៈ*

- អ្នកអង្គម្ចាស់ក្សត្រី បុទុមបុប្ផា
- អ្នកអង្គម្ចាស់ក្សត្រី សូរិយារង្សី
- អ្នកអង្គម្ចាស់ក្សត្រី សុជាតិ, និងគ្រួសារនាងទាំងអស់

ខ្ញុំចង់ឃើញចៅទាំង១៤នាក់

ខ្ញុំចង់ឃើញបងប្អូនជីនដូនមួយខ្ញុំដូចជាអ្នកអង្គម្ចាស់នរោត្តមភូរិស្សរា និងអ្នកអង្គម្ចាស់ស៊ីសុវត្ថិមេថាវី ព្រមទាំងក្រុមគ្រួសារអ្នកទាំងអស់នោះ។

ខ្ញុំចង់ឃើញលោកអនុសេនីយ៍ឯកអ៊ុង មាង ជាទីស្រឡាញ់របស់ខ្ញុំ។

ខ្ញុំចង់ឃើញលោកជា សានជាមិត្ត, ខ្ញុំចង់ឃើញសម្តេចប៉ែន នុត និងលោកជំទាវ។ ខ្ញុំសូមជួបអ្នកទាំងអស់នេះម្តង ហើយខ្ញុំលែងសូមជួបទៀតហើយ។ ខ្ញុំចង់ស្លាប់។ ខ្ញុំចង់ឃើញព្រះភក្ត្រព្រះមហាក្សត្រីយានីហ្លួងម៉ែខ្ញុំ។ ខ្ញុំចង់ចេញពីទីនេះ, ខ្ញុំចង់លួចរត់ចេញ។ អរគុណ, លោកឈន ហៃ។

*(លោកឈន ហៃចេញទៅវិញ)*

### អ្នកម្នាង

កាលពីមុនច្បាស់ជាព្រះអង្គស្រឡាញ់លោកណាស់, លោកឈន ហៃ។ ឥឡូវក៏នៅតែអាចមើលឃើញថាដូច្នោះ។

### ព្រះសីហនុ

កុំមាត់! ខ្ញុំឮស្នូរតុកកែ

### តុកកែ

តុកកែ!

### ព្រះសីហនុ

រួចខ្លួន!

### តុកកែ

តុកកែ!

ព្រះសីហនុ

*កំទេចចោល។*

តុកកែ

*តុកកែ!*

ព្រះសីហនុ

*រួចខ្លួន!*

តុកកែ

*តុកកែ!*

ព្រះសីហនុ

*កំទេចចោល។*

តុកកែ

*តុកកែ!*

ព្រះសីហនុ

*រួចខ្លួន!*

តុកកែ

*តុកកែ!*

ព្រះសីហនុ

*កំទេចចោល។*

**តុកកែ**

*... តុកកែ!*

**ព្រះសីហនុ**

*ទៀត, នែ, ទៀតទៅ!*

**អ្នកម្នាង**

*តុកកែ!*

**ព្រះសីហនុ**

*រួចខ្លួន! នាងជឿថាយើងនឹងរួចខ្លួនទេ?*

**អ្នកម្នាង**

ខ្ញុំម្ចាស់ជឿលើព្រះពុទ្ធជាម្ចាស់។ ខ្ញុំម្ចាស់ជឿ...

*(លោកឈេន ហៃចូលមកវិញ)*

***ឈេន ហៃ***

ព្រះករុណាថ្លៃវិសេស, អង្គការទើបនឹងបញ្ជាឲ្យទូលបង្គំក្រាបបង្គំលាព្រះអង្គទាំងពីរហូតទៅ។ បុគ្គលិកទាំងប៉ុន្មានត្រូវចេញផុតអស់ពីកំពែងវាំងនៅមុនថ្ងៃលិច។

**អ្នកម្នាង**

ពួកគេនឹងមកយប់នេះហើយ, មែនទេ?

**ព្រះសីហនុ**

បើដូច្នោះ, លាហើយលោកឈេន ហៃ។ អញ្ជើញភ្លាមទៅ, អញ្ជើញទៅចុះ, បន្តិចទៀតយប់មកដល់ហើយ។

*(លោកឈេន ហៃចេញទៅ)*

**តុកកែ**

*តុកកែ!*

**ព្រះសីហនុ**

*កំទេចចោល! ច្លួតទេដឹង, តុកកែនេះ?*

**អ្នកម្នាង**

*យប់ហើយ, ក្រាបទូល, យប់មកដល់ហើយ!*

**ព្រះសីហនុ**

*បើបានជួប*Alfred Hitchcock *មុននឹងរឿងខ្ញុំចប់, មិនដឹងជាយ៉ាងណាទេ!*

**អ្នកម្នាង**

*ពួកវានឹងមិន... បាញ់ព្រះអង្គចោលទេ។*

**ព្រះសីហនុ**

*បើវាមិនបាញ់ខ្ញុំចោលទេ, ឱ! ព្រះពុទ្ធជាម្ចាស់, វាធ្វើទារុណកម្មវិញ, វាធ្វើបាបឲ្យទូលព្រះបង្គំស្រែកដូចសត្វ... បើវាស្ដោះទឹកមាត់លើមុខទូលព្រះបង្គំវិញ!*

*(ព្រុសម្លេងអ្វីម្យ៉ាងគួរបារម្ភ)*

*អូ, នោះ, អាជ្រាតហើយ? លឿនឡើង, ឲ្យបងបើបមួយខ្សឹតសិន, បើបមួយខ្សឹត!*

*(តុកកែ! ព្រុសម្លេងតទៅទៀត)*

*យាត់ឲ្យពួកវាចាំមួយភ្លែតសិន! ប្រាប់វាថាបងកំពុងរាគរូស! សូមឲ្យចាំបន្តិចនៅបន្ទប់សាឡុង។ បងមិនឲ្យវាចាប់បងបានទាំងរស់ទេ! លែងបង!* Zodiaque *សេះសំណាប់អើយ, មកណោះ!*

**អ្នកម្នាង**

ខ្ញុំម្ចាស់មិនលែងព្រះអង្គទេ! ទេ! ទេ! ធ្វើដូច្នេះមិនបានឡើយ! ខ្ញុំម្ចាស់សូមអង្វរ, សូមអង្វរព្រះករុណាម្ចាស់។ ព្រះអង្គមិនអាចធ្វើដូច្នេះបានឡើយ! ខ្ញុំម្ចាស់មិនព្រមឲ្យព្រះអង្គធ្វើជាដាច់ខាត!

*(ព្រះសុរាម្រិតយាងចូលមក)*

**ព្រះសុរាម្រិត**

ពុកក៏ដូចគ្នាដែរ, ពុកហាមមិនឲ្យធ្វើដូច្នេះ! យី, ម៉េចក៏ធ្វើរាក់កំផែលអញ្ចេះ, មិនខ្មាសគេទេឬអី? បានសេះមក, លោតឡើងជិះម្នាក់ឯង, ទុកប្រពន្ធចោលឲ្យនៅជាមួយពួកខាងនេះតែម្នាក់ឯងកណ្ដាលវាំងស្ងាត់ជ្រងឹដូចព្រៃស្បាត។ យី, ពូជយើងចេះធ្វើអត្តឃាត! ពុកឮខ្មោចគេខ្សឹបខ្សៀវគ្នាថា កូនឯងឡប់សតិហើយ! មែនឬមិនមែនកូនស្រី? នែ... មើលឃើញពុកឬអត់?

**អ្នកម្នាង**

អូ, ក្រាបទូលឃើញ, ព្រះករុណាថ្លៃវិសេស! ខ្ញុំម្ចាស់អរកអ្វីប្រៀបគ្មានដែលឃើញព្រះភក្ត្រព្រះអង្គ!

**ព្រះសុរាម្រិត**

តែភ្នែកកូនឯងដូចជាស្លេកបន្តិច។

**ព្រះសីហនុ**

យើងទាំងពីរភ័យខ្លាចស្លុតស្មារតីណា! លោកឪពុកជាទីស្រឡាញ់។

**ព្រះសុរាម្រិត**

ពុកក៏អញ្ចឹងដែរ, គឺញាក់ព្រឺសម្បុរមួយភ្លែត ពេលដែលឃើញថាវាំងរបស់កូនស្ងាត់ជ្រងុំគ្មានមនុស្សហើយចាក់សោរជាប់ទៀត។

និយាយអញ្ចឹង, ពុកមកដើម្បីប្រាប់រឿងអី? រឿងនោះសំខាន់ណាស់, តែឥឡូវភ្លេចទៅបាត់ ដោយសារតែកូនធ្វើផ្តេសផ្តាសអម្បាញ់មិញ, ភ្លេចទៅបាត់, យី, មកពីកូនឯងនេះ!

អូ, នឹកឃើញហើយ, គឺថាអញ្ចេះ! ប្រទេសយើងកំពុងរើដោះនឹមឲ្យផុតពីកហើយ។

ពួកកម្មាភិបាលខ្មែរក្រហមខាងបូព៌ាកំពុងបះបោ។ គេជួបគ្នាជាសម្ងាត់ដើម្បីរកវិធីកំចាត់ប៉ុល ពត។ យ៉ាងម៉េច? កូនឯងស្រងំាកចិត្ត?

## ព្រះសីហនុ

ពីមួយទៅមួយមានអ្វីខុសគ្នា, បីសាចខ្មែរក្រហមទាំងនេះ, គ្រាន់តែដូរអំណាចផ្ដាច់ការពីម្នាក់ទៅម្នាក់ ប៉ុណ្ណោះ...!

## ព្រះសុរាម្រិត

ឈប់សិន, ពុកមិនល្ងង់ណាស់ណាទេ, ទុកឲ្យពុកនិយាយចប់សិន! ពុកមានទាន់បានប្រាប់ឯណាថា យួនវាយគ្នា នៅពេញទល់ដែន ដូចខ្លាដែលរង់ចាំតែសង្គ្រប់ចំណីដូច្នោះឯង។

## ព្រះសីហនុ

យួនមែនឬលោកឪពុក? យួន? ឯណា? ប៉ុន្មាននាក់? លោកឪពុកបានឃើញពួកវា? គ្នាវាច្រើនទេ?

## ព្រះសុរាម្រិត

តាមមើលទៅ, ឥឡូវនេះឡើងដល់ ៣០កងពលហើយ។ គួរឲ្យកូនឯងសប្បាយចិត្តដែរ, ព្រោះឧត្តមសេនីយ៍ យ៉ាប, មិត្តកូនឯង, ជាមេបញ្ជាការធំ។

## ព្រះសីហនុ

យ៉ាប! បើដូច្នោះអស់លោកប៉ុល ពត, អៀង សារី, ខៀវ សំផនអើយ, អស់លោករីករាយសោមនស្សណាស់ មែនទេ, ដែលបានជម្រុញកម្ពុជារបស់ខ្ញុំឲ្យចូលក្នុងមាត់យក្សយួន, យួនដែលចាំតែលេបយើងរាប់សតវត្សមកហើយ នោះ!

យ៉ាប! តានោះច្បាស់ជានឹងកិនពួកពស់មានពិសទាំងនេះខ្ទេចម៉ត់!

ទេ! កូនមិនអាចសប្បាយចិត្តទេ! ទេ!

**ព្រះសុរាម្រិត**

តាមតែកូនឯងទៅចុះ, កុំសប្បាយចិត្តអី។ តែយ៉ាងណាក៏ដោយមិនត្រូវធ្វើអត្តឃាតដែរ។

**អ្នកម្នាង**

ព្រះករុណាថ្លៃវិសេស, តែខ្ញុំម្ចាស់វិញអរម្យ៉ាងដែរ, អរសម្រាប់ថ្ងៃនេះ, អរសម្រាប់ប្រជារាស្ត្រខ្មែរដែលញើសចេញជាឈាមនៅតាមការដ្ឋាននានា។

**ព្រះសីហនុ**

លោកឪពុក, កូនគ្មានដំណឹងអ្វីសោះពីចៅទាំងអស់របស់លោកឪពុក។

**ព្រះសុរាម្រិត**

ពុកក៏គ្មានឮដំណឹងដែរ, កូនសម្លាញ់។ ចាំពុកទៅស៊ើបសួរលមើល។ ពុកនឹងទៅរុករកគ្រប់ច្រកល្ហកក្នុងប្រទេសយើង, ច្បាស់ជានៅទីណាមួយហើយ។ ពុកទៅសិនហើយ។

*(ព្រះសុរាម្រិតយាងចេញ)*

**ព្រះសីហនុ**

ក្រាបបង្គំលាហើយ, លោកឪពុកសម្លាញ់។

ឱ! ធ្វើម៉េចឲ្យសោមនស្សពេញចិត្តពេញថ្លើមនឹងការរំលាយពួកសត្វសាហាវចង្រៃនេះទៅរួច?

ចង់ឲ្យវាសម្រេចឡើង, តែខ្លាចវាផង! សោមនស្សដោយសុទ្ធចិត្តនឹងការរំដោះរបៀបនោះម្ដេចបាន?

ថ្ងៃណាមួយទៅ ដែលយើងអាចញញឹមដោយមិនស្រក់ទឹកភ្នែក?

ជីវិតនោះនឹងផ្អែមល្ហែមម្ដេចកើត, បើវៀតណាមដែលជាអ្នកផ្ដល់នោះជាផ្លែស្លែងដូច្នេះ?

*(គេឮសម្លេងផ្ទុះយ៉ាងខ្លាំង។ ភ្លើងអគ្គិសនីដាច់អស់។ ភ្លាមនោះគេឃើញមានពន្លឺពិលតូចមួយ)*

**ខៀវសំផន**

ព្រះអង្គគង់នៅឯណា, ព្រះករុណាថ្លៃវិសេស?

**ព្រះសីហនុ**

*នរណាហ្នឹង?*

**ខៀវសំផន**

*ខៀវសំផន, ព្រះករុណាថ្លៃវិសេស។*

**ព្រះសីហនុ**

*ទៀតហើយ! យើងទាំងពីរនាក់នៅឯនេះ។ នៅក្នុងភាពងងឹតនៃប្រវត្តិសាស្ត្រ! លោកបានឲ្យគេកាត់ភ្លើងមែនទេ?*

**ខៀវសំផន**

*ទេ, ទេ។ ភ្លើងដាច់ងងឹតក្រុងទាំងមូល, យប់នេះ។ ព្រះករុណាថ្លៃវិសេស, លោកប៉ុល ពតចង់ទទួលឲ្យព្រះអង្គជួបខ្លាំងណាស់នៅទីស្នាក់ការថ្មីនៃប្រធានរដ្ឋ, នៅមាត់ទន្លេ។*

**ព្រះសីហនុ**

*ម៉ោងថ្មីណេះហើយ, យីរាប់ឆ្នាំមកហើយដែលគ្មាន... អើពើនឹងខ្ញុំសោះ!*

**ខៀវសំផន**

*ព្រះករុណាថ្លៃវិសេស, ព្រះអង្គសព្វព្រះទ័យយាងមកតាមទូលព្រះបង្គំទេ? បើព្រះអង្គមិនយល់ទាស់ទេ, យើងទៅដើរ។ នៅជាប់ស្ពានមុនីវង្ស។*

**ព្រះសីហនុ**

*ដើរ! ដើរ១គីឡូដី! ល្អណាស់, បានហាត់ប្រាណឲ្យសរសៃរដើរស្រួលក្រោយពីរស់នៅដូចអណ្តើកបីឆ្នាំមកហើយនេះ!*

*(មានបន្ទូលទៅអ្នកម្នាង)* *ម្សៀសំផន, លើកនេះ, វីករាយដូចត្រីដែលគេយកទៅបង់ខ្លាញ់ដែរ។ គេនិយាយមកបងថា "ព្រះករុណាថ្លៃវិសេស"។*

*(ទាំងអស់គ្នាចេញដំណើរទៅ)*

### ខៀវសំផន

យ៉ាងមកតាមនេះ, សូមស្វាត់...!

### អ្នកម្នាង

ព្រះហស្ត, ក្រាបទូល, ព្រះហស្ត។

*(ទាំងអស់គ្នាចេញទៅ)*

# ឆាកទី៣

*(នៅមាត់ទន្លេមេគុង។ ខៀវសំផនចូលមក ដោយមានព្រះសីហនុនិងអ្នកម្នាងយាងមកតាម)*

**ព្រះសីហនុ**

*(ហាក់ដូចជាចង់ស្ទុះទៅប្រចាច់កខៀវសំផន)*

លោកខៀវសំផន, លោកអញ្ជើញមកតែម្នាក់ឯងឬមានគ្នា?

**ខៀវសំផន**

ទេ, ទេ, ក្រាបទូល។ កងកិត្តិយសនៅចាំវន្ទាទទួលយើង។

**ព្រះសីហនុ**

ស្ដាយមែន! គួរឲ្យស្ដាយមែន!

**ខៀវសំផន**

ទូលបង្គំទៅជម្រាបឯកឧត្ដមប៉ុល ពតឲ្យជ្រាប។

*(គាត់ចេញទៅ)*

**អ្នកម្នាង**

ឱទន្លេធំ! សប្បាយចិត្តម្ល៉េះទេ ដែលបានឃើញអ្នកឡើងវិញ, នៅក្រោមមេឃដែមានផ្កាយដេសដាស! ព្រះអង្គមានធំក្លិនឈើដែលលិចនៅកប់ក្នុងទឹកទេ?

*(គេឮសម្លេងកាំភ្លើងធំ)*

**ព្រះសីហនុ**

នៅពីក្រោយភាពស្ងប់ស្ងាត់ក្រោមផ្ទៃមេឃប្រកបដោយតារានេះ, ច្បាស់ជាមានយួនបន្ទំខ្លួនជាព្រៃព្រឹក្សា, ចាំតែឱកាសមកដល់ដើម្បីវាយលុកផ្ដាច់ព្រ័ត។

**អ្នកម្នាង**

*គេនឹងធ្វើអ្វីយើង?*

**ព្រះសីហនុ**

*នរណា?*

**អ្នកម្នាង**

*ខ្ញុំម្ចាស់យល់សប្តិ៍ថា យួនវាយសម្រុកចូលវាំង, ហើយថាពស់កំណាចមួយដែលជាប៉ុល ពតយកខ្លួនមកពាត់រុំយើង។ ឯស្បែកពស់នោះគ្រាន់តែប៉ះភ្លាមគួរព្រឺខ្លាច...*

**ព្រះសីហនុ**

*នោះ, មកហើយ!*

*(សម្តេចប៉ែន នុតចូលមក)*

*ប៉ែន នុត! សម្តេចប៉ែន នុតរបស់ខ្ញុំ! មិត្តជាទីស្រឡាញ់! ឱ, ព្រះជាម្ចាស់, សប្បាយចិត្តអ្វីម្ល៉េះទេ!*

**សម្តេចប៉ែន នុត**

*ព្រះករុណាថ្លៃវិសេស... (ងាកទៅអ្នកម្នាង) ថ្វាយបង្គំ,ក្រាបទូល!*

**ព្រះសីហនុ**

*បីឆ្នាំ! សម្តេចស្ទើរតែគ្មានប្លែកអ្វីបន្តិចសោះ! មែនទេនាង, សម្តេចគ្មានដូរអីសោះ? បីឆ្នាំដ៏ចូរចត់នេះដូចជាគ្មានធ្វើឲ្យសម្តេចខុសពីមុនឡើយ!*

**សម្តេចប៉ែន នុត**

*ព្រះអង្គក៏ដូច្នោះដែរ, ក្រាបទូល!*

### ព្រះសីហនុ

យ៉ាងម៉េច? មានរឿងអី?

### សម្ដេចប៉ែន នុត

ទេ, គ្មានអីទេ, ក្រាបទូល។ គ្មានអ្វីទាំងអស់។

### អ្នកម្នាង

មាន, មានអ្វីមួយហើយ!

### សម្ដេចប៉ែន នុត

ណ្ហើយ, ទូលបង្គំសូមទូលអ្នកម្នាងថា ថ្លើមប្រម៉ាត់ទូលបង្គំមិនអាចរីកឡើងស្រស់ក្លាមមួយរំពេចទេ, ព្រោះព្រះករុណាបានទុកឲ្យស្វិតស្រពោនខ្លាំងពេក។

### ព្រះសីហនុ

ទុកឲ្យស្វិតស្រពោនយ៉ាងម៉េច? មានប្រសាសន៍ឲ្យច្បាស់មកមើល!

### សម្ដេចប៉ែន នុត

ក្នុងរយៈពេល៣០ឆ្នាំ, ទូលព្រះបង្គំស្មោះត្រង់នឹងព្រះអង្គ, ៣០ឆ្នាំនៅជាប់តាមព្រះអង្គ, ៣០ឆ្នាំផ្សងព្រេងគ្រប់បែបយ៉ាង, ឆ្លងកាត់ព្យុះសង្ឃរាជាច្រើន, ៣០ឆ្នាំនៃជីវិតទូលបង្គំ ដែលទូលបង្គំថ្វាយព្រះអង្គ។ ក្នុង៣០ឆ្នាំនោះមិនដឹងជាប៉ុន្មានសឺបដងទេ ដែលទូលបង្គំបត់បែនតាមព្រះអង្គ, ដោយបោះបង់ចោលយោបល់ខ្លួនឯងផ្ទាល់។ ទាំងអស់នេះ, គឺប្រាថ្នារង្វាន់តែមួយគត់៖ រង្វាន់នោះឈ្មោះថា ការទុកចិត្តទុកព្រះទ័យ។

### អ្នកម្នាង

ទេ, សម្ដេចជាទីគោរព, សម្ដេចមានប្រសាសន៍នេះអយុត្តិធម៌ណាស់។

## ព្រះសីហនុ

កុំ, កុំកាត់ប្រសាសន៍។ ទុកឲ្យសម្ដេចតពាក្យពោលនេះឲ្យបានចប់ស្រួលបួល។ មានប្រសាសន៍មកមើល, សម្ដេច, សម្រាប់៣០ឆ្នាំនៃដំណើរជាមួយគ្នាដ៏ប្រពៃនេះ, រង្វាន់ដែលសីហនុផ្ដល់នោះគឺអ្វី?

## សម្ដេចប៉ែន នុត

កាលណាគេសង្ស័យមិត្តដែលស្លូតត្រង់ថាមានល្បិចកល, លោភ, ប្រវ័ញ្ចនៃ, គេហៅរឿងនេះថា យ៉ាងម៉េចទៅវិញ?

ម្ដេចក៏ព្រះអង្គជឿទៅកើត ថាទូលបង្គំប្រាថ្នាធ្វើឲ្យស្ត្រីដែលធ្លាប់តែស្រឡាញ់ព្រះអង្គហើយ ដែលវង់ទុក្ខដោយសារព្រះអង្គលាលែងពីដំណែងនោះ ឲ្យងាកមកស្រឡាញ់ទូលបង្គំជំនួសព្រះអង្គវិញ? ប៉ែន នុតទៅជាអ្នកប្រកួតនឹងព្រះសីហនុ? ចោទនេះធ្ងន់ហួសហេតុពេក!

មិនតែប៉ុណ្ណោះ, ដំបូងឡើយ ទូលបង្គំមិនព្រមជឿទេថា ព្រះករុណាជាអម្ចាស់ជីវិតអាចយល់ខុសខ្លាំងដល់ម្លេះ, ម្ល៉ោះហើយចេះតែខំសូមអនុញ្ញាតគាល់។ ១០ដង ដែលទូលព្រះបង្គំដាក់ចិត្តដាក់កាយទៅអង្វរសូមគាល់ ដើម្បីពន្យល់រឿងពិត, សូម្បីតែម្ដងក៏មិនអនុញ្ញាតដែរ!

មិនអនុញ្ញាតទេ, តែឲ្យគេមកប្រាប់ថាព្រះសីហនុមិនទទួលជនក្បត់ឲ្យចូលគាល់ឡើយ។ ចុះលិខិតទាំងប៉ុន្មានដែលទូលបង្គំផ្ញើថ្វាយ, ត្រឡប់មកវិញបិទជិតដដែល, ខុសពីពេលផ្ញើត្រង់មានសរសេរពាក្យថា “ទេ” ដែលព្រះអង្គឡាយដោយព្រះហស្ដដែលខ្ញាល់ក្រេវក្រោធ!

## ព្រះសីហនុ

រីឯប៉ែន នុតជាមិត្ត៣០ឆ្នាំហើយ, ប៉ែន នុតដែលធ្លាប់តែថ្លឹងថ្លែង, គ្មានដែលឆ្ងល់ថា ដូចជាមានអ្វីដែលគួរឲ្យសង្ស័យសោះ! ប៉ែន នុត, ជនដែលគេតែងគោរព, មិនដែលគិតថា អ្នកនាំលិខិតមកនោះជានរណាទេ, មែនទេ? ប៉ែន នុតដែលធម្មតាជាមនុស្សឆ្លាតប៉ិនប្រសប់នោះ មិនដែលនឹកឃើញយកវ៉ែនតាមកពាក់មើលពាក្យ “ទេ” នោះឲ្យច្បាស់ឡើយ, ពាក្យ “ទេ” ដែលឡាយដោយដៃក្រេវក្រោធរបស់ខ្ញុំ, មែនឬមិនមែន?

ទេ! ទេ! ប៉ែន នុតសុខចិត្តជឿអ្វីដែលអាក្រក់ជួជាតិទៅវិញ។

ខ្ញុំថា “សុខចិត្ត”, បើថា “ចូលចិត្ត” ប្រហែលត្រូវជាងនេះផង! យ៉ាងម៉េច, មិត្តភាពដែលខ្ញុំមានមក៣០ឆ្នាំមកហើយ មិនអាចឲ្យថាសជញ្ជីងស្រុតទៅម្ខាងបានទេ, មែនទេ?

**សម្ដេចប៉ែន នុត**

*ព្រះករុណា...*

**ព្រះសីហនុ**

ឲ្យខ្ញុំនិយាយឲ្យចប់សិន! ក្រោយពីទុកចិត្តបាន៣០ឆ្នាំមក, ប៉ែន នុតវិកិលខ្លួនតាមជម្រាលផ្លូវមិនទុកចិត្តវិញ។ សម្ដេចបាន "ជ្រើសរើស" យកផ្លូវមិនទុកចិត្តសីហនុវិញ។

**សម្ដេចប៉ែន នុត**

ក្រាបទូល, សូមព្រះអង្គកុំមានបន្ទូលបញ្ឈឺស...

**អ្នកម្នាង**

ឱ! ម៉េចក៏សម្ដេចជឿយ៉ាងនោះកើត? ព្រះករុណាមិនដែលបានទទួលដំណឹងអ្វីពីសម្ដេចដ៏តិចតួចសោះឡើយ។

**ព្រះសីហនុ**

កុំ, កុំ, កុំពោលឲ្យបង្ខូចខ្លួន។ កុំឲ្យកស្ដុតាងអ្វីទាំងអស់ទៅដល់មិត្តដែលលែងនឹងននេះ។ ប៉ុន្តែខ្ញុំសូមសារភាពរឿងមួយទៅចុះណា, អតីតមិត្តជាទីគោរព៖ នៅក្នុងគុកខ្ញុំនោះ, មានគេប្រាប់ខ្ញុំថាសម្ដេចប៉ែន នុតមិនជាទាស់ចិត្តប៉ុន្មានទេអំពីការដែលខ្ញុំលាលែងនោះ, មានតែសម្លឹងឃើញផលប្រយោជន៍ផ្សេងៗផ្ទាល់ខ្លួនទៅវិញ។

**សម្ដេចប៉ែន នុត**

*អីយ៉ា!...*

**ព្រះសីហនុ**

ប៉ុន្តែសំណាងល្អ, គឺសំណាងល្អមែនដែលខ្ញុំមិនដែលចិត្តទន់ចង់ជឿពាក្យទាំងនោះ! ទេ! ខ្ញុំសុខចិត្ត, គាប់ចិត្តគិតតែទៅមិត្តភាពដ៏ប្រពៃ, មិនអាចធ្វើឲ្យល្អក់កករ, ដែលមាន៣០ឆ្នាំមកហើយនោះ។ ឱអនិច្ចាណាស់, សម្ដេច! គិតទៅខ្ញុំត្រូវអាណិតសម្ដេច ពីព្រោះសម្ដេចបានបាត់បង់សីហនុ, ឯខ្ញុំវិញ, ក្នុងពេល៣ឆ្នាំ, ខ្ញុំសប្បាយរីករាយដោយសារនៅសល់ប៉ែន នុត។

*(លោកប៉ុល ពតចូលមក ដោយមានលោកខៀវ សំផន, លោកអៀង សារីនិងអ្នកហែរហមមកតាម)*

**ប៉ុល ពត**

ព្រះករុណាថ្លៃវិសេស! អ្នកម្នាង! ទូលបង្គំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដែលបានផ្តល់កិត្តិយសឲ្យទូលព្រះបង្គំដោយយាងមកទីនេះ! *(និយាយទៅសម្តេចប៉ែន នុត)* លោកទីប្រឹក្សាជាន់ខ្ពស់...

សូមព្រះរាជទានទោស, ក្រាបទូល, ដែលទូលបង្គំពុំមានពេលទៅគាល់ព្រះអង្គ។ ពេលវេលាចេះតែទៅមុខ, ដោយកន្ទង់ភ្នែកយ៉ាងរហ័ស។

**ព្រះសីហនុ**

លោកប្រធាន, ខ្ញុំដឹងថាលោកមានបន្ទុកទទួលខុសត្រូវធ្ងន់ធ្ងរពន់ប្រមាណ។ ឯខ្ញុំវិញដែលលែងមានបន្ទុកអ្វីទាំងអស់ទៅតាំងពីបីឆ្នាំមកនេះ, ខ្ញុំតែងតែអើតតាមបង្អួចសម្លឹងមើលទៅដំបូលវាំងខ្ញុំ, ហើយខ្ញុំតែងឃើញពេលកន្លងទៅ, នៅលើមេឃ។

**ប៉ុល ពត**

ខ្ពស់ផុតពីដំបូលទៅ, មានមេឃផ្ទៃខៀវថ្លា, ថ្លាបរិសុទ្ធពន់ពេក។ Verlaine។

**ព្រះសីហនុ**

សូមទោស, ខ្ញុំសូមកែបន្តិច៖ ខ្ពស់ផុតពីដំបូលទៅ មានមេឃផ្ទៃខៀវថ្លា, ខៀវស្រក្សាន្តពន់ពេក។ Verlaine។ Sagesse។

**ប៉ុល ពត**

ព្រះករុណាថ្លៃវិសេស, ព្រះអង្គជ្រាបហើយថាយើងបានប្រកាសសង្គ្រាមជាមួយយួន។ កាលពីខែមុន យើងបានបើកការវាយសម្រុកយ៉ាងខ្លាំងក្លាទៅរកសត្រូវ។ ទូលបង្គំមានកិត្តិយសនឹងទូលព្រះអង្គថា យើងបានកំ-ទេ-ច ពួកវា!

**ព្រះសីហនុ**

បាន កំ-ទេ-ច ពួកវា?!

*(សម្តេចប៉ែន នុតធ្វើកាយវិការថាមិនមែនទេ)*

**ប៉ុលពត**

*សូមព្រះអង្គអនុញ្ញាតឲ្យទូលបង្គំថ្វាយសង្ខេបយ៉ាងខ្លីអំពីស្ថានភាពសមរភូមិ។ ឥឡូវនេះ យួនវានៅត្រង់ម្ដុំគគីរ។*

**ព្រះសីហនុ**

*គគីរ? បើដូច្នេះ គឺនៅជិតបង្កើយនេះឯង, ម្ដេចក៏មានប្រសាសន៍ថាយើងវាយសម្រុក?!*

**ប៉ុលពត**

*សូមព្រះអង្គជ្រាបដូចតទៅ៖ ទូលបង្គំទុកឲ្យក្រុមវាសន្ធឹកសន្ធាប់នោះចូលមកក្នុងដីយើងឲ្យបានជ្រៅមែនទែន។ វារុលមកមុខៗ ទូលបង្គំដកថយ, ថយហើយថយទៀត! ដល់ពេលមួយ ទូលបង្គំពាត់វាពីគ្រប់ទិសទី, ហ៊ុំវាជាប់, វាទៅណាមិនរួច។ ពេលនោះយើងក្រញេចវាដូចថៃ។ គឺពេលនោះហើយដែលយើងបំបែកវាឲ្យបែកខ្ញែកជាដុំតូចៗ, ហាន់វាឲ្យល្អិត, កិនឲ្យល្អិតជាកំទេចតូចទៅទៀត, ហើយទីបំផុតផ្លុងផងដូចម្សៅ, ខ្យល់បក់មកហើរអស់រលីង។ តែពីរខែទៀតទេ, ក្រាបទូល, គ្មានសល់អ្វីបន្តិចសោះឡើយ។*

*នៅចន្លោះពេលនោះ, ព្រះករុណាជាអម្ចាស់ព្រមទាំងព្រះជាយា យាងទៅរាយការណ៍ពន្យល់ស្ថានភាពនេះនៅទីផ្សេងៗឯបរទេស។*

**ព្រះសីហនុ**

*យ៉ាងម៉េច? ខ្ញុំ"ទៅ" ? ខ្ញុំចេញពីស្រុកខ្មែរ?*

**ប៉ុលពត**

*ទូលបង្គំរីករាយនឹងសូមស្នើព្រះអង្គយ៉ាងនេះ។ ព្រះអង្គនឹងយាងទៅទាក់ទាញឲ្យប្រជាជាតិផ្សេងៗចាប់អារម្មណ៍លើការឈ្លានពានពីសំណាក់ពួកយួនពង្រីកទឹកដី។ ព្រះអង្គយាងទៅចិនមុនគេដូចតាមទម្លាប់, បន្ទាប់មកយាងទៅអង្គការសហប្រជាជាតិ។ បន្ទាប់មកទើបយាងទៅអឺរ៉ុបខាងលិច។ ពីរខែទៀតទើបយាងត្រឡប់មកវិញ។*

**អ្នកម្នាង**

*ពីរខែទៀត?...*

**ព្រះសីហនុ**

*(មានបន្ទូលទៅអ្នកម្នាង)*

ពីរខែទៀត... គឺថាពេលនោះលោកប៉ុល ពតបានកំចាត់, រំលាយកិនពួកយួនម៉ត់អស់ហើយ។

ចុះសម្តេចប៉ែន នុត?

**ប៉ុល ពត**

សម្តេចប៉ែន នុតអញ្ជើញទៅជាមួយព្រះអង្គដែរ។ បេសកកម្មនេះចេញដំណើរស្អែកពេលព្រលឹមទៅប៉េកាំង។

**អ្នកម្នាង**

យើងចេញដំណើរ, ទៅប៉េកាំង?

**ព្រះសីហនុ**

*(មានបន្ទូលទៅអ្នកម្នាង)*

កន្លះម៉ោងមកហើយដែលលោកប៉ុល ពតរាយការណ៍បង្ហាញថាដំណើរស្នេហាជាតិនេះជាការប្រញ៉ាប់បន្ទាន់។

យើងចេញដំណើរបន្តិចទៀតនេះ, ហើយត្រឡប់មកវិញនៅ២ខែខាងមុខ។

*(លោកខៀវសំផនខ្សឹបទៅប៉ុលពត)*

**ប៉ុល ពត**

២ម៉ោងទៀតនឹងមានរថយន្តប្រណិតមួយមកទទួលព្រះអង្គនៅទីនេះតែម្តង។ ទូលបង្គំសូមព្រះរាជានុញ្ញាត

ថ្វាយបង្គំលាហើយ។

ជយោកម្ពុជាប្រជាធិបតេយ្យមានជ័យជំនះជានិរន្តរ៍!

*(ពួកខ្មែរក្រហមចេញទៅ)*

**ព្រះសីហនុ**

អស្ចារ្យមែន, ចេញទៅវិញ! ក្រុមគេចេញទៅយ៉ាងលឿនដូចពស់បត់បែនវារចន្លោះថ្មដែលរលំបាក់ខ្ទេចខ្ទីរមក

ដី។

**អ្នកម្នាង**

ទាំងអស់នេះមានន័យថាដូចម្ដេច?

**សម្ដេចប៉ែន នុត**

យួនមកដល់មាត់ទ្វារច្រកចូលភ្នំពេញហើយ។ ពួកមេៗខ្មែរក្រហមកំពុងគេចខ្លួនចូលព្រៃ។

**អ្នកម្នាង**

ឯណាទៅកប៉ាល់ហោះ? មានកប៉ាល់ហោះម៉ែនឬអ្វី?

**សម្ដេចប៉ែន នុត**

ក្រាបទូលអ្នកម្នាង, ស្អែកនេះយើងទៅដល់ប៉េកាំងហើយ។ ខ្មែរក្រហមនឹងធ្វើយ៉ាងណាមិនឲ្យព្រះករុណាប៉ះនឹងយួនឡើយ។

**ព្រះសីហនុ**

ម្ដេចបានជាពួកគេទៅជាមិនសម្លាប់យើង?

**សម្ដេចប៉ែន នុត**

គេធ្លាប់គិតដូច្នេះដែរ, ក្រាបទូល។ ប៉ុន្តែ មតិអន្តរជាតិ...

*(ទ័ពយួនផ្គោងគ្រាប់កាន់តែខ្លាំងឡើងចូលភ្នំពេញ)*

**ព្រះសីហនុ**

និរទេសម្ដងទៀតហើយ។ ៩ឆ្នាំ, ៩ឆ្នាំហើយដែលព្រាត់ប្រាស។ មើលទៅប្រហែល៩ឆ្នាំប៉ុន្មានដងទៀត? ព្រហ្មលិខិតគ្មានប្រណីទេ, យកអ្វីៗទៅអស់៖ កូន, ចៅ, ក្ដីសង្ឃឹម, ដំណែង, កិត្តិយស, សូម្បីតែមិត្តចុងក្រោយបង្អស់ក៏យកទៅដែរ។

**សម្ដេចប៉ែន នុត**

ក្រាបទូល, នេះមកពីទូលព្រះបង្គំស្មានថាព្រះអង្គគុំគួននឹងទូលព្រះបង្គំ។

## ព្រះសីហនុ

ខ្ញុំបានប្រាប់សម្តេចកាលពីខែមេសា ឆ្នាំ១៩៧៦ថា ខ្ញុំយល់ពីសម្តេចទាំងអស់។ ទេ, ទេ, កុំយករួចខ្លួន។ មើល, មានប្រសាសន៍មកមើល, សម្តេច, នៅពេលដែលខ្ញុំបំភ្លេចទុក្ខសោកអផ្សុកដោយរាប់កណ្តុរ, សម្តេចធ្វើអ្វីខ្លះពេលនោះ?

## សម្តេចប៉ែន នុត

មែន! ទូលបង្គំយល់មិនខុសទេ! ព្រះអង្គខ្ញាល់នឹងទូលបង្គំ!

## ព្រះសីហនុ

អត់សោះ, អត់សោះ, ប៉ុន្តែខ្ញុំចង់ដឹង, ចង់ដឹង*ណាស់*។

## អ្នកម្នាង

ប៉ុណ្ណឹងបានហើយ។ ខ្ញុំម្ចាស់ពិបាកចិត្តខ្លាំងណាស់ដែលឃើញថាពួកខ្មែរក្រហមធ្វើឲ្យមិត្តបែកបាក់ពីគ្នាបានទៅទៀត។

## ព្រះសីហនុ

មិនមែនខ្មែរក្រហមទេ ដែលបំបែកបំបាក់យើង, គឺសម្តេចប៉ែន នុតដែលដកឃ្លាចេញពីបង!

## អ្នកម្នាង

សូមព្រះអង្គពង្រឹងព្រះទ័យវិញឡើង។ ធ្វើយ៉ាងនេះគឺដូចជាទៅបំពេញចិត្តពួកនរកនោះពេញទី។ បើព្រះករុណាលែងខ្ញាល់ហើយអភ័យទោសទៅគឺជាជ័យជំនះផ្លូវចិត្តធំមួយហើយ។ យើងនឹងដល់ប៉ះកាំងជុំគ្នាដូចពីមុនមក...

## ព្រះសីហនុ

កាលជំនាន់ខ្ញុំនៅហ៊ឺកហ៊ាក់លើលោកនេះ, ខ្ញុំមិនស្គាល់ម៉េចហៅថាស្ងាត់ស្ងៀម! ខ្ញុំច្រៀងកាត់អស់ហើយ, ឈ្នះអស់, ចាញ់អស់, ខ្ញុំយល់ត្រូវ, ខ្ញុំយល់ច្រឡំ, ខ្ញុំយល់ត្រូវមុនគេពេក, ខ្ញុំមិនបានឃើញថាគេយកកាំបិតមកចាក់ខ្ញុំពីក្រោយខ្នង, ខ្ញុំគិតខុស, ខ្ញុំគិតត្រូវ, ខ្ញុំនិយាយភូតភរជាញឹកញាប់, ខ្ញុំនិយាយការពិតច្រើន, ច្រើនហួស។

ឥឡូវនេះ, នៅអាយុ៥៦ឆ្នាំ, ខ្ញុំអាយុពាពាន់ឆ្នាំហើយ។ ខ្ញុំគ្មានខ្លាចបាត់បង់អ្វីទៀតទេ។ ខ្ញុំមកដល់ចំណុចកំពូលនៃពេលហើយ។ ជាច្រើនសតវត្សហើយដែលសីហនុដើបចេញផុតពីទន្លេ។ ចប់ហើយការកាន់ច្រឡំ, ចប់ហើយចិត្តពុះពោ។ នៅពីមុខខ្ញុំសុទ្ធសឹងជារឿងដំណាលនិទានលាតសន្ធឹងលើវាលមួយវែងស្រឡះដាច់កន្ទុយភ្នែក។ ខ្ញុំអាចសន្ធឹងខ្លួនដេកលើនោះ, សម្រាកលើនោះ។ ខ្ញុំរស់នៅឡើយទេ, តែខ្ញុំទៅជាព្រឹទ្ធាចារ្យចាស់ទុំដូចអ្នកស្លាប់ដែរ។ ខ្ញុំគ្មានកម្លាំងអ្វី, សេចក្ដីក្លាហានអ្វីទៀតនឹងទៅកាន់ច្រឡំ, ទៅប្រជែងក្នុងល្បែងប្រណាំងពិភពលោកនេះទៀតទេ។ ខ្ញុំឈប់និយាយត្រឹមនេះហើយ។

**អ្នកម្នាង**

មិនបានយូរទេ, ក្រាបទូល។ មិនអាចស្ងប់ស្ងៀមយូរទេ។ ព្រះអង្គនឹងធ្វើអ្វីរបៀបជាព្រឹទ្ធាចារ្យនោះ?

**ព្រះសីហនុ**

បងនឹងសរសេរប្រវត្តិសាស្ត្រកម្ពុជា។ វគ្គទី១ ៖ Paradise Lost។ បន្ទាប់មក, តើលន់ នល់បានរៀបចំដើងព្រួលអ្វីខ្លះឲ្យប៉ុល ពត។ តមកទៀត, តើប៉ុល ពតបានរៀបដើងព្រួលអ្វីខ្លះឲ្យប្រទេសវៀតណាម។ ឯបងវិញ, យ៉ាងម៉េចដែរ? បងអស់អនាគតហើយ, តែនៅរស់, មិនទាន់ស្លាប់។ បងជាជនរងគ្រោះនឹងបដិហារប្រវត្តិសាស្ត្រមួយ។ បងទៅផ្នែកម្ខាងទៀតនៃផែនដី, ទៅត្រង់ណាដែលអាស៊ីនិងបីសាចអាស៊ីមិនតាមធ្វើបាបបង។

**អ្នកម្នាង**

គេនឹងតាមរកព្រះអង្គជានិច្ច, ព្រោះគេត្រូវការព្រះអង្គ។ ប្រវត្តិសាស្ត្រមិនទាន់ចប់ឯណា!

**ព្រះសីហនុ**

បើគេត្រូវការមែន, គេគង់តែមករកឃើញទេ។ អ្វីដែលគេត្រូវការ គេតែងតែរកឃើញ, យូរឬឆាប់។

*(ទាំងអស់គ្នាចេញទៅ។ យូនវាយលុកកាន់តែខ្លាំងឡើងៗ)*

# ឈុតចុងក្រោយ

*(កម្ពុជា។ អ្នកស្លាប់ទាំងអស់ចូលមក៖ ព្រះសុរាម្រិត, ព្រះមហាក្សត្រីយានីកុសុមៈ, អ្នកម៉ុំសាវ៉ៃនិងអ្នកស្រីខៀវ សំណុល។ បន្ទាប់មកអ្នកឡាំណៅនិងយុគន្ធរទាំងកងមកផង)*

**ព្រះសុរាម្រិត**

ឥឡូវពេលវេលាសម្រាប់មហានិរទេសមកដល់ហើយ។ ដីកម្ពុជាដ៏ស្រគត់ស្រគំលែងជាដីរបស់ខ្មែរទៀតហើយ។ យើងនាំគ្នាមកនេះដើម្បីលាអ្នកទាំងអស់, លារហូត, សូមធ្វើអ្វីឲ្យបានសមប្រកបទៅចុះ!

**អ្នកស្រីខៀវ សំណុល**

ពេលដើរតាមព្រៃតាមជ្រៃ, ប្រយត្ន័គ្រាប់មីនឲ្យមែនទែនណាកូន, មុននឹងដើរមួយជំហាន។មើលសិន។

**អ្នកឡាំណៅ**

បែកគ្នាទៀត, ឃ្លាតគ្នាទៀតហើយ! ខ្ញុំដឹងហើយថាយើងត្រូវតែចេញចាកស្រុក, ប៉ុន្តែមិនដាច់អាល័យសោះក្នុងចិត្ត! ពេលយើងចេញផុតទៅ, អស់ព្រះអង្គ, អស់លោកអ្នកនឹងទៅជាយ៉ាងណា?

**អ្នកម៉ុំសាវ៉ៃ**

យើងដឹងថា អ្នកនឹងនឹកមកយើង ព្រោះយើងជាអតីតកាលរបស់អ្នក, ដែលមានមេត្រីយ៍មកលើអ្នក។

**អ្នកស្រីខៀវ សំណុល**

ឱ, ស្តាប់សម្លេងភ្លៀងស្រក់ដោយគ្មានអ្នកនៅជាមួយ! សម្លឹងមើលទៅរដូវដែលវិលផ្លាស់ទៅមក។! យើងច្បាស់ជានឹកអ្នក! ច្បាស់ជានឹក! ទោះជាកូនឯងទៅណាក៏ត្រូវនឹកមកម៉ែផង, ទៅណាក៏ម៉ែមិនជំទាស់ដែរ, តែនឹកមកម៉ែផង។

**អ្នកឡាំណៅ**

ទោះជាខ្ញុំទៅរស់នៅឯណាក៏ដោយ, សំណុលបងសម្លាញ់, បងរះនៅក្នុងថ្ងៃមប្រម៉ាត់ខ្ញុំរាល់ព្រឹកដូចព្រះអាទិត្យ, ហើយរះឡើងពេលយប់ដូចព្រះចន្ទ្រដែរ។

**ព្រះសុរាម្រិត**

និយាយអញ្ចឹង, យុគន្ធរ, ទោះជាឯងទៅនៅឯណាក៏ដោយ, ប្រទេសទីពីរ, ប្រទេសទីបី, នៅអឺរ៉ុប, នៅអាមេរិកដ៏ឆ្ងាយ...

**អ្នកស្រីខៀវសំណុល**

អាមេរិក! ទេ, កូន! ម៉ែ...

**អ្នកឡាំណោ**

ឈប់, ទុកឲ្យខ្ញុំស្ដាប់ព្រះបន្ទូលព្រះករុណាឲ្យចប់។

**ព្រះសុរាម្រិត**

អម្បាញ់មិញខ្ញុំនិយាយថា ទោះជាទៅនៅស្រុកក្រៅឯណាក៏ដោយ, កុំភ្លេចភាសាយើង, ភាសាខ្មែរដ៏ពិរោះពិសា។ ត្រូវនិយាយភាសាខ្មែររាល់ថ្ងៃ, កុំទុកឲ្យរលាយបាត់បង់។

**ព្រះកុសុមៈ**

ព្រោះអីភាសាយើងគឺទឹកទន្លេធំមេកុង, ជាប្រភពជាតិយើង, ជាសេរីភាពយើង, ជាដីដ៏ថ្លៃថ្លារបស់យើង, ជាជីវិតដែលបន្តរស់, ជាស្មារតីចងចាំ, ធ្វើឲ្យយើងងើបមុខមិនខ្មាសគេ។ ដូច្នេះដរាបណាទឹកពីប្រភពយើងនេះហូរ, នៅទីណាលើលោកនេះក៏ដោយ, គ្មាននរណាភ្លេចយើងបានឡើយ, យើងដែលជាអ្នករស់, យើងដែលជាអ្នកស្លាប់។

**អ្នកមុំសាវៃ**

ឯប្រភពទីពីរគឺរបាំ។ របាំព្រះរាជទ្រព្យ។ ត្រូវរក្សាល្ខោនហ្លួងឲ្យបានគង់វង្ស។

**យុគន្ធរ**

ឱ! ព្រះជាម្ចាស់, របាំព្រះរាជទ្រព្យ, ត្រូវធ្វើម៉េចទៅ, ហ្ន?!!

### អ្នកមុំសារ៉ៃ

យាយមានចៅស្រីម្នាក់ឈ្មោះ ស៊ីហាមីនូ។ ឯងស្គាល់ទេ? យាយធ្លាប់បង្រៀននាងនោះរាំ។ សព្វថ្ងៃនៅក្រុង Vancover, នៅកាណាដា។

### អ្នកស្រីខៀវ សំណុល

កាណាដា! ឱ, អាណិតគ្នាណាស់!

### ព្រះសុរាម្រិត

ដល់ពេលថ្ងៃណាមួយដែលមានពន្លឺព្រាល។ ចេញពីមាតុភូមិមកទម្លុះជញ្ជាំងនិរទេសនេះ, កូនចៅយើងជំនាន់ក្រោយនឹងត្រឡប់ទៅរកប្រទេសខ្លួនវិញ, ប្រទេសកម្ពុជាដែលជាអម្រិត, កម្ពុជាដែលមិនដែលសូន្យ។ យើងខ្ញុំនឹងចាំអ្នកនៅទីនោះ។

### យុគន្ធរ

ព្រះករុណាថ្លៃវិសេស, ថ្ងៃនោះគឺដល់ពេលណាទៅ?

### ព្រះសុរាម្រិត

គាមិនដឹងអង្កាល់ទេ, ចៅ។ ថ្ងៃណាមួយនៅអនាគត។

### អ្នកស្រីខៀវ សំណុល

យ៉ាងណាក៏ដោយ ថ្ងៃមួយគឺថ្ងៃមួយ។ ដែលសំខាន់នោះគឺថា ថ្ងៃនោះនឹមកដល់ថ្ងៃណាមួយ។

### ព្រះសុរាម្រិត

នាំគ្នាទៅចុះ, ឥឡូវនេះ។ យើងនឹងមើលរក្សាអ្នកក្នុងដំណើរតាមព្រៃ, រហូតដល់ភ្នំក្រវាញ។ តែផុតពីភ្នំក្រវាញទៅរហូតដល់ដីទំនាបប្រទេសថៃឡង់ដ៍, សូមរំលឹកគុណព្រះរតនត្រ័យទៅ!

**អ្នកឡាំណោ**

ប៉ុន្តែ ចេះតែខំប្រឹងលើកជើងដើរ ពីមួយថ្ងៃទៅមួយថ្ងៃទៅ, ពេលណាមួយយើងនឹងទៅដល់ប៉ែកម្ខាងទៀតនៃជួរភ្នំ, នៅស្រុកពួកថៃ, ពេលនោះនឹងមានអ្វីកើតឡើង, ខ្ញុំភ័យណាស់នឹកឃើញរឿងនេះ!

**យុគន្ធរ**

បានដល់ទីនោះ គឺសប្បាយហើយ! ព្រោះនរណាក៏អាណិតអាសូរខ្មែរដែរ, នៅខាងនោះ, ពេលដែលពិភពលោកដឹងថាខ្មែរយើងរងទុក្ខដល់ណា។

**អ្នកឡាំណោ**

អញ្ចឹងមែន?

**យុគន្ធរ**

វាត្រូវតែអញ្ចឹងឯង, កាលណាប្រទេសមួយដែលស្លូតត្រង់រងគ្រោះខ្លាំងពេកនឹងព្រហ្មលិខិត។ ពេលនោះប្រទេសខាងលិចដែលជាអ្នកមានសម្បូណ៌ហូរហៀរដូចជាប្រទេសកាណាដា, ស្វីស, បារាំង, អាមេរិក និងអូស្ត្រាលី, គ្រាន់តែដឹងរឿងទុក្ខវេទនាយើងភ្លាម, គេនឹងមករកជួយយើងមួយរំពេច។

**អ្នកស្រីខៀវ សំណុល**

អញ្ចឹងមែនឬ, ព្រះអុំជាម្ចាស់?

**ព្រះសុរាម្រិត**

ខ្ញុំមិនដឹងទេ។ នែ, បានហើយ, ឥឡូវនេះអ្នករស់និងអ្នកស្លាប់ត្រូវបែកគ្នា។

**អ្នកឡាំណោ**

ដែលខ្ញុំបានស្គាល់បងមួយរយៈពេលរស់នោះ, គឺជាសេចក្ដីសប្បាយធំបំផុតក្នុងជីវិតខ្ញុំ។ ខ្ញុំរៀបចំខ្លួនហើយ។ លារហូតហើយ, ចាំជួបគ្នាទៀត។ លារហូតហើយចាំជួបគ្នាទៀត។

**ព្រះសុភាម្រិត**

ឥឡូវដល់ពេលយំសោកបោកខ្លួនចុងក្រោយហើយ, យើងទាំងអស់គ្នា។

*(អ្នកឡាំណោនឹងយុគន្ធរចេញទៅ)*

**អ្នកស្រីខៀវ សំណុល**

អ្នកឡាំណោ! Marie-Madeleine! អូនស្រីសម្លាញ់! ឮឬអត់, មើលទៅ? បងចង់ប្រាប់អូនថា៖ បើអូនអាចទៅដល់ប៉ារីស៍! ប៉ារីស៍ស្រុកបារាំងណា! ឮបងនិយាយឬអត់?

**អ្នកឡាំណោ**

*(សួរពីចម្ងាយមក)*

បងថាម៉េច?

**អ្នកស្រីខៀវ សំណុល**

នៅប៉ា-រីស៍! លែងឮហើយ, មើលទៅ!

*(ងាកទៅព្រះមហាក្សត្រីយានីនិងអ្នងមុំសាវ៉ៃ)*

ខ្ញុំម្ចាស់ចង់ទៅលេងប៉ារីស៍តាំងពីយូរមកហើយ, មិនដែលបាន ទៅដល់សោះ, ប៉ារីស៍ល្អមែន! ហើយខ្ញុំម្ចាស់មានបងប្អូនជីដូនមួយម្នាក់នៅប៉ារីស៍, ដែលរស់នៅBesançon។

អ្នកសាវ៉ៃ, ភ្នែកអ្នកនៅច្បាស់ជាងខ្ញុំ, មើលឃើញទៅដល់ណាហើយ?

**អ្នកមុំសាវ៉ៃ**

គ្នាយើងជិតទៅដល់ចុងស្រុកយើងហើយ, ឥឡូវនេះ។

**អ្នកស្រីខៀវ សំណុល**

ឱ! ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ, ប្រយត្ន័បន្តិច! ជិតដល់ទល់ដែនមែនទែនហើយ!

**អ្នកមុំសាវ៉ៃ**

ឥឡូវនេះខ្ញុំមើលលែងឃើញហើយ!

**អ្នកស្រីខៀវ សំណុល**

*លែងឃើញហើយ?!*

**អ្នកម៉ុំសាវៃ**

*ទៅដល់ហើយ, អ្នកសំណុល។ ទៅដល់ប្រទេសថៃឡង់ដឺ, នៅខាវអ៊ីដាង។*

**អ្នកស្រីខៀវ សំណុល**

*ថៃឡង់ដឺ, អួយ ខ្ញុំព្រួយណាស់!*

*បាននរណាថែទាំអ្នកទៀត, ខ្មែរអើយ ខ្មែរកំសត់ភៀសខ្លួន។ នរណាអាចគិតទៅអ្នករាល់ពេលដូចយើងជាខ្មោចនេះបាន?!*

*ឥឡូវក្រុមយើងឯណោះក៏កណ្តោចកណ្តែងឥតគ្នាដែរ។*

**ព្រះសុរាម្រិត**

*ឥឡូវដល់ពេលរួសរាន់ធ្វើការហើយ! ត្រូវនាំគ្នាសង្ឃឹម។*

**ព្រះកុសុមៈ**

*ធ្វើយ៉ាងណា? នាំគ្នាសង្ឃឹមដោយសង្ឃឹមរាល់ថ្ងៃ, ផុតមួយថ្ងៃទៅមួយថ្ងៃទៀតរៀងរហូត។*

**អ្នកស្រីខៀវ សំណុល**

*ជីវិតខ្លីណាស់, ស្លាប់ទើបវែង។ ខ្ញុំចង់តែសើចទេ, កាលណានឹកឃើញថាអ្នក* Marie-Madeleine *សំណាប់ចិត្តខ្ញុំប្រហែលនឹងពុទូរសព្ទដែលហោះហើរនៅក្នុងសុបិន្តគាត់។*

**អ្នកម៉ុំសាវៃ**

*ខ្ញុំនឹកទៅខ្មែរដ៏កំសត់ដែលនៅក្រៅប្រទេស, អើតតាមបង្អួចនឹកមកយើង។*

**អ្នកស្រីខៀវ សំណុល**

កើតមកជាខ្មែរលំបាកមែន, និយាយមែនទែនទៅគឺលំបាកបំផុតលើសគេលើសឯង ក្នុងពេលបច្ចុប្បន្ននេះ។ តែយ៉ាងណាក៏ខ្ញុំនៅតែចង់កើតមកជាខ្មែរទៀតដែរ។

# ចប់